ខែតុលា

២០១៨

# យុទ្ធសាស្ត្រ និងផែនការសកម្មភាពគ្រប់គ្រងសំណល់សម្រាប់រាជធានីភ្នំពេញ ឆ្នាំ២០១៨-២០៣៥

## គណៈនិពន្ធ

យុទ្ធសាស្ត្រ និងផែនការសកម្មភាពគ្រប់គ្រងសំណល់សម្រាប់រាជធានីភ្នំពេញឆ្នាំ២០១៨-២០៣៥ គឺជាលទ្ធផលនៃកិច្ចសហការរវាងទីចាត់ការគ្រប់គ្រងសំណល់នៃសាលារាជធានីភ្នំពេញ និងក្រុមទីប្រឹក្សានៃមជ្ឈមណ្ឌលសហប្រតិបត្តិការបច្ចេកវិទ្យាបរិស្ថាននៃវិទ្យាស្ថានដើម្បីយុទ្ធសាស្ត្របរិស្ថានសាកលប្រទេសជប៉ុន អង្គការ Nexus សម្រាប់ការអភិវឌ្ឍ ប្រចាំនៅប្រទេសកម្ពុជា និងអង្គការកែច្នៃសំរាម និងការសិក្សានៅកម្ពុជា (COMPED)។

មាតិកានៃយុទ្ធសាស្ត្រ និងផែនការសកម្មភាពគ្រប់គ្រងសំណល់សម្រាប់រាជធានីភ្នំពេញនេះ ត្រូវបានពង្រាងឡើងដោយផ្អែកលើកិច្ចពិគ្រោះយោបល់ជាមួយអ្នកពាក់ព័ន្ធជាច្រើនរួមមាន អង្គភាពពាក់ព័ន្ធសំខាន់ៗដែលចំណុះឱ្យក្រសួងនានា តំណាងសាលារាជធានីភ្នំពេញ អាជ្ញាធរមូលដ្ឋានខណ្ឌ-សង្កាត់ នៅក្នុងរាជធានីភ្នំពេញ មន្ទីរជំនាញពាក់ព័ន្ធ ដៃគូអភិវឌ្ឍន៍ អង្គការក្រៅរដ្ឋាភិបាល និងគ្រឹះស្ថានអប់រំជាដើម។ ការរៀបចំយុទ្ធសាស្ត្រនេះ ជាគម្រោងរួមគ្នារវាងកម្មវិធីបរិស្ថានអង្គការសហប្រជាជាតិ និងកម្មវិធីសម្ព័ន្ធភាពប្រែប្រួលអាកាសធាតុកម្ពុជា (CCCA) ដែលគ្រប់គ្រងដោយអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព (NCSD)។

## សេចក្តីបដិសេធ

ខ្លឹមសារ និងការបង្ហាញក្នុងឯកសារបោះពុម្ពផ្សាយនេះមិនមានន័យឆ្លុះបញ្ចាំងពីទស្សនៈ ឬមតិយោបល់ណាមួយរបស់រដ្ឋបាលរាជធានីភ្នំពេញ រាជរដ្ឋាភិបាលកម្ពុជា អង្គការ UN Environment កម្មវិធីសម្ព័ន្ធភាពការប្រែប្រួលអាកាសធាតុកម្ពុជា (CCCA) វិទ្យាស្ថាន IGES ឬអង្គការ Nexus ពាក់ព័ន្ធនឹងស្ថានភាពស្របច្បាប់ ដែនដី ទីក្រុង តំបន់ អាជ្ញាធរ ឬទាក់ទងនឹងការកំណត់ព្រំប្រទល់ ឬព្រំដែននៃប្រទេសណាមួយឡើយ។ លើសពីនេះ ទស្សនៈដែលបានសម្តែងនេះ គឺមិនបានតំណាងឱ្យសេចក្តីសម្រេចចិត្ត ឬគោលនយោបាយរបស់រដ្ឋបាលរាជធានីភ្នំពេញ រាជរដ្ឋាភិបាលកម្ពុជា អង្គការ UN Environment កម្មវិធីសម្ព័ន្ធភាពប្រែប្រួលអាកាសធាតុកម្ពុជា (CCCA) វិទ្យាស្ថាន IGES ឬអង្គការ Nexus នោះទេ ហើយក៏មិនលើកឡើងពីឈ្មោះផ្សាយពាណិជ្ជកម្ម ឬក្នុងគោលដៅអាជីវកម្មដោយមិនមានការយល់ព្រមជាមុនឡើយ។

## បោះពុម្ពផ្សាយដោយ រដ្ឋបាលរាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០១៨

**ការសរសេរជាឯកសារយោង៖**

PPCA, IGES, Nexus, UN Environment, CCCA. (2018). Phnom Penh Waste Management Strategy and Action Plan 2018-2035. Phnom Penh, Cambodia.

**ក្រេឌីតរូបភាព:** ©ក្រុមការងារសិក្សាគម្រោង PPCH-IGES-Nexus

**រដ្ឋបាលរាជធានីភ្នំពេញ**

អាសយដ្ឋាន: # ៦៩ មហាវិថីព្រះមុនីវង្ស សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ

គេហទំព័រ: www.phnompenh.gov.kh/

***United Nations Environment Programme International Environmental Technology Centre***

អាសយដ្ឋាន*: 2-110 Ryokuchi koen, Tsurumi-ku, Osaka 538-0036, Japan*

គេហទំព័រ: *www.unep.org*

***Cambodia Climate Change Alliance***

អាសយដ្ឋាន*: Ministry of Environment, No. 503 Road along Bassac River, Sangkat Tonle Bassac, Chamkamon, Phnom Penh*

គេហទំព័រ:*www.camclimate.org.kh/en/activities/ cambodian-climate-change-alliance.html*

***IGES Centre Collaborating with UNEP on Environmental Technologies, Institute for Global Environmental Strategies***

អាសយដ្ឋាន*: 2108-11 Kamiyamaguchi, Hayama, Kanagawa, 240-0115 Japan*

គេហទំព័រ: *www.ccet.jp*

***Nexus Carbon for Development***

អាសយដ្ឋាន*: #33 E3 Sothearos Blvd Sangkat Chey Chumneas, Daun Penh 12206, Phnom Penh*

គេហទំព័រ: *www.nexusfordevelopment.org/*

# យុទ្ធសាស្ត្រ និងផែនការសកម្មភាព
# គ្រប់គ្រងសំណល់
# សម្រាប់រាជធានីភ្នំពេញ
# ឆ្នាំ ២០១៨-២០៣៥

ខែតុលា ឆ្នាំ២០១៨

# មាតិកា


**មាតិកា** ..... v
**បញ្ជីរូបភាព** ..... vii
**បញ្ជីតារាង** ..... viii
**ពាក្យបំព្រួញ និងអក្សរកាត់** ..... ix
**អារម្ភកថា** ..... xiii
**ជំពូកទី I ៖ សេចក្តីផ្តើមនៃយុទ្ធសាស្ត្រ** ..... **៣**
១. តម្រូវការនូវយុទ្ធសាស្ត្រគ្រប់គ្រងសំណល់ ..... ៣
២. ការកំណត់ទីតាំងនៃយុទ្ធសាស្ត្រ និងផែនការសកម្មភាពគ្រប់គ្រងសំណល់ ..... ៤
២.១. ភាពស្របទៅនឹងគោលនយោបាយថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ..... ៤
២.២. ភាពស្របទៅនឹងគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព ..... ៨
២.៣. ដំណើរការនៃការរៀបចំយុទ្ធសាស្ត្រ ..... ១០
**ជំពូកទី II ៖ បញ្ហាប្រឈមនៃការគ្រប់គ្រងសំណល់ - តើយើងកំពុងឈរនៅចំណុចណា?** ..... **១៥**
១. ទិដ្ឋភាពទូទៅរាជធានីភ្នំពេញ ..... ១៥
២. ការធ្វើសារពើភណ្ឌសំណល់ ..... ១៧
២.១. សំណល់រឹងទីប្រជុំជន ..... ១៧
២.២. សំណល់សំណង់ ..... ២៥
២.៣. សំណល់វេជ្ជសាស្ត្រ ..... ២៦
២.៤. សំណល់ឧស្សាហកម្ម ..... ២៨
២.៥. សំណល់គ្រោះថ្នាក់ ..... ៣១
២.៦. សំណល់អេឡិចត្រូនិក និងបរិក្ខារអគ្គិសនី ..... ៣១
៣. ការរៀបចំស្ថាប័ន ..... ៣៤
៣.១. បទបញ្ញត្តិ និងការធ្វើចំណាត់ថ្នាក់សំរាម សំណល់រឹង ..... ៣៤
៣.២. តួនាទី និងការទទួលខុសត្រូវរបស់ភាគីពាក់ព័ន្ធ ..... ៣៥
៤. ទិដ្ឋភាពទូទៅនៃបញ្ហាប្រឈមសំខាន់ៗ ..... ៤១
**ជំពូកទី III ៖ ជំហានឆ្ពោះទៅមុខនៃយុទ្ធសាស្ត្រគ្រប់គ្រងសំណល់** ..... **៤៧**
១. ការរៀបចំយុទ្ធសាស្ត្រ និងផែនការគ្រប់គ្រងសំណល់ ..... ៤៧
២. គោលការណ៍ណែនាំ ..... ៤៧
៣. ចក្ខុវិស័យ ..... ៤៩
៤. បេសកកម្ម ..... ៤៩
៥. រយៈពេលនៃយុទ្ធសាស្ត្រ ..... ៤៩
៦. គោលដៅ (គុណភាព) និងទិសដៅ (កម្រិត) ត្រូវសម្រេច ..... ៤៩
៦.១. គោលដៅទូទៅ ..... ៤៩
៦.២. ទិសដៅ ..... ៥០
៧. សកម្មភាពចម្បង ..... ៥២
៨. រចនាសម្ព័ន្ធទូទៅនៃយុទ្ធសាស្ត្រ និងផែនការសកម្មភាព ..... ៥៨

**ជំពូកទី IV ៖ ផែនការសកម្មភាព ........ ៦១**

១. សកម្មភាពចម្បងទី១: ការពង្រឹងប្រព័ន្ធសេវាប្រមូល ការបញ្ចេញសំណល់ និងការពង្រឹងគុណភាពសេវាកម្ម ........ ៦១

២. សកម្មភាពចម្បងទី២: ការលើកកម្ពស់ការច្នៃសំណល់ឡើងវិញ តាមរយៈការញែកសំណល់ ដោយមានការចូលរួមពីក្រុមហ៊ុនឯកជនកែច្នៃសំណល់ និងការលើកកម្ពស់ការប្រើប្រាស់ផលិតផលកែច្នៃ ........ ៧៣

៣. សកម្មភាពចម្បងទី៣: ការលើកកម្ពស់ការគ្រប់គ្រងទីលានចាក់សំរាមប្រកបដោយចីរភាពបរិស្ថាន និងការកាត់បន្ថយផលប៉ះពាល់លើបរិស្ថាន និងជីវភាពរស់នៅ ........ ៨១

៤. សកម្មភាពចម្បងទី៤: ការគ្រប់គ្រងរំហូរសំណល់ពិសេស ........ ៨៨

៤.១. សំណល់សំណង់ ........ ៨៨

៤.២ សំណល់វេជ្ជសាស្ត្រ ........ ៩២

៤.៣ សំណល់ឧស្សាហកម្ម ........ ៩៤

៤.៤. សំណល់បរិក្ខារអគ្គិសនី និងអេឡិចត្រូនិក ........ ៩៥

៥. សកម្មភាពចម្បងទី៥: ការចែករំលែកចក្ខុវិស័យ និងដៃគូជាមួយភាគីពាក់ព័ន្ធលើសកម្មភាពរួម ........ ៩៦

៦. តារាងប្រតិបត្តិការ – សកម្មភាពអាទិភាព ដែនតួនាទី និងភារកិច្ច និងសូចនាករ ........ ១០១

**ជំពូកទី V ៖ ការគ្រប់គ្រងវដ្តគម្រោង ទិន្នន័យ និងហិរញ្ញវត្ថុ ........ ១១៥**

១. ការគ្រប់គ្រងវដ្តនៃគម្រោង ទិន្នន័យ និងហិរញ្ញវត្ថុ - ធានាការអនុវត្តន៍ និងគុណភាពសេវាកម្ម ........ ១១៥

២. ដំណើរការគ្រប់គ្រងដោយផ្អែកលើវដ្ត PDCA ........ ១១៥

៣. ដំណើរការបង្កើតទិន្នន័យ ដើម្បីសម្រួលដល់ការសម្រេចចិត្ត និងការគ្រប់គ្រងគម្រោងបានល្អ ........ ១១៧

៤. ការធានាធនធានមនុស្សសម្រាប់ការផ្តល់សេវាប្រកបដោយចីរភាព ........ ១១៧

**ជំពូកទី VI ៖ ឧបសម្ព័ន្ធ ........ ១២១**

ឧបសម្ព័ន្ធទី១ - ឯកសារយោង ........ ១២១

ឧបសម្ព័ន្ធទី២ - ផែនការគម្រោងសាកល្បង ........ ១២៣

ឧបសម្ព័ន្ធទី៣ - ការគ្រប់គ្រងហិរញ្ញវត្ថុ ........ ១២៦

១. ទិន្នន័យមូលដ្ឋាន - កម្រៃសេវាប្រមូលសំរាម និងហិរញ្ញវត្ថុ ........ ១២៦

២. ប្រភពមូលនិធិគ្រប់គ្រងសំណល់ប្រកបដោយសក្តានុពល ........ ១២៩

៣. ហិរញ្ញប្បទានកាបូន ........ ១៣៧

៤. ភាពជាដៃគូរវាងវិស័យឯកជន - សាធារណៈ ........ ១៣៨

ឧបសម្ព័ន្ធទី៤ - គំរូគណនាការចំណាយលើការអនុវត្តន៍ ........ ១៣៩

ឧបសម្ព័ន្ធទី៥ - ការបែងចែកតួនាទី និងភារកិច្ច ........ ១៤២

ឧបសម្ព័ន្ធទី៦ - រូបភាពអនុវត្តន៍ការគ្រប់គ្រងសំណល់ ........ ១៥៦

ឧបសម្ព័ន្ធទី៧ - ផែនទីតំបន់ទីលានចាក់សំរាមដង្កោ ........ ១៥៨

ឧបសម្ព័ន្ធទី៨ - ឧទាហរណ៍នៃបច្ចេកវិទ្យាប្រព្រឹត្តកម្មសំណល់ ........ ១៥៩

ឧបសម្ព័ន្ធទី៩ - រចនាសម្ព័ន្ធទូទៅនៃយុទ្ធសាស្ត្រ និងផែនការសកម្មភាព ........ ១៦៦

# បញ្ជីរូបភាព


រូបភាពទី១ : ទីតាំងនៃយុទ្ធសាស្ត្រ និងផែនការសកម្មភាពគ្រប់គ្រងសំណល់សម្រាប់រាជធានីភ្នំពេញ ៥
រូបភាពទី២ : ទិដ្ឋភាពយុទ្ធសាស្ត្រជាតិ និងផែនការសកម្មភាពនៃការគ្រប់គ្រងសំណល់រឹងឆ្នាំ២០១៨-២០៣០ ៧
រូបភាពទី៣ : ពិធីចុះហត្ថលេខាលើអនុសារណៈយោគយល់៣ភាគី (រូបភាពខាងលើ) និងសិក្ខាសាលារៀបចំយុទ្ធសាស្ត្រ (រូបភាពកណ្តាល និងខាងក្រោម) ១២
រូបភាពទី៤ : ផែនទីរាជធានីភ្នំពេញ ១៥
រូបភាពទី៥ : ព្យាករណ៍ចំនួនប្រជាជនដោយការសិក្សាមួយចំនួន ១៦
រូបភាពទី៦ : ការលូតលាស់នៃ GDP និងវិស័យចម្បងៗ ចាប់ពីឆ្នាំ២០១១ ដល់ ២០១៧ ១៧
រូបភាពទី៧ : ព្យាករណ៍កំណើនបរិមាណបង្កើតសំរាម សំណល់រឹងនៅក្នុងរាជធានីភ្នំពេញរហូតដល់ឆ្នាំ២០៣០ ១៨
រូបភាពទី៨ : និន្នាការនៃកំណើនសំរាម សំណល់រឹងចាក់ចោលនៅទីលានចាក់សំរាមដង្កោ រាជធានីភ្នំពេញ ១៩
រូបភាពទី៩ : ប្រភព និងភាគរយបង្កើតសំរាម សំណល់រឹង ក្នុងរាជធានីភ្នំពេញ ២០
រូបភាពទី១០ : សមាសភាពសំរាម សំណល់រឹងនៅតាមប្រភព នៃរាជធានីភ្នំពេញ ២១
រូបភាពទី១១ : បរិមាណសំណល់ដែលអាចកែច្នៃបាន នៅដេប៉ូសម្រាប់កែច្នៃ (តោន/ឆ្នាំ) ២៤
រូបភាពទី១២ : បរិមាណសំណល់កែច្នៃ នាំចេញតាមរយៈក្រសួងបរិស្ថាន (តោន/ឆ្នាំ) ២៤
រូបភាពទី១៣ : ការចាក់ចោលសំរាមគ្មានសណ្តាប់ធ្នាប់ និងការដុតសំណល់សំណង់នៅរាជធានីភ្នំពេញ ២៦
រូបភាពទី១៤ : បរិមាណសំណល់វេជ្ជសាស្ត្រដែលប្រមូលបានសម្រាប់ដុតកម្ទេច ២៧
រូបភាពទី១៥ : បរិមាណសំណល់ឧស្សាហកម្មប្រមូលបានដោយក្រុមហ៊ុន សារ៉ុ ត្រេឌីង ២៩
រូបភាពទី១៦ : សមាសភាពសំណល់ឧស្សាហកម្មនៅទីលាន សារ៉ុ ត្រេឌីង ៣០
រូបភាពទី១៧ : ការប៉ាន់ស្មានលើកំណើនសំណល់អេឡិចត្រូនិកសម្រាប់រាជធានីភ្នំពេញ (គិតជាឯកតា) ៣២
រូបភាពទី១៨ : ការព្យាករណ៍ការផលិតសំណល់អេឡិចត្រូនិកក្នុងរាជធានីភ្នំពេញគិតពីទម្ងន់ ៣២
រូបភាពទី១៩ : សង្ខាក់រំហូរផលិតកម្ម និងពាណិជ្ជកម្ម នៃសំណល់អេឡិចត្រូនិកក្នុងរាជធានីភ្នំពេញ ៣៣
រូបភាពទី២០ : ការបែងចែកសំណល់ និងបទបញ្ញត្តិគ្រប់គ្រងសំណល់ដែលពាក់ព័ន្ធនៅត្រឹមឆ្នាំ២០១៧ ៣៤
រូបភាពទី២១ : ការរៀបចំស្ថាប័នជាតិថ្នាក់ក្រោមជាតិសម្រាប់ការគ្រប់គ្រងសំណល់ ៣៦
រូបភាពទី២២ : ផែនទីបង្ហាញអ្នកពាក់ព័ន្ធការងារអភិបាលកិច្ចគ្រប់គ្រងសំរាម សំណល់រឹងនៅរាជធានីភ្នំពេញ ៣៩
រូបភាពទី២៣ : ឋានានុក្រមការគ្រប់គ្រងសំណល់ ៤៨
រូបភាពទី២៤ : ឧទាហរណ៍ការប្រើម៉ូដែលប្រមូលសំរាម សំណល់រឹងផ្សេងៗទៅតាមតំបន់ខុសៗគ្នា ៥២
រូបភាពទី២៥ : វិធីសាស្ត្រ-ដំណាក់កាលណែនាំអំពីការបែងចែកសំណល់នៅប្រភព និងលទ្ធភាពកែច្នៃ ៥៤
រូបភាពទី២៦ : កិច្ចអន្តរាគមន៍តាមសកម្មភាពចម្បងសម្រាប់ការរៀបចំប្រព័ន្ធគ្រប់គ្រងសំណល់បែបចម្រុះ ៥៧
រូបភាពទី២៧ : រចនាសម្ព័ន្ធរួមនៃយុទ្ធសាស្ត្រ និងផែនការសកម្មភាព ៥៨
រូបភាពទី២៨ : "រាជធានីភ្នំពេញស្អាត" - ឧទាហរណ៍វីឌីអូអប់រំអំពីការទុកដាក់សំណល់ឱ្យបានត្រឹមត្រូវ ៦៦
រូបភាពទី២៩ : ម៉ូដែលរំហូរសំណល់ /វត្ថុធាតុដើមតាមរយៈការញែកនៅប្រភព និងការប្រមូលសំណល់អេតចាយ ៧៩
រូបភាពទី៣០ : មធ្យោបាយនៃការអនុវត្តន៍ ១១៥
រូបភាពទី៣១ : វដ្ត PDCA ១១៦
រូបភាពទី៣២ : រំហូរថវិការដ្ឋបាលពីថ្នាក់ជាតិទៅថ្នាក់ក្រោមជាតិគិតត្រឹមឆ្នាំ២០១៣ ១២៧

# បញ្ជីតារាង


តារាងទី១ : គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព និងសកម្មភាពចម្បងពាក់ព័ន្ធក្នុងយុទ្ធសាស្ត្រនេះ ........ ៨
តារាងទី២ : ដំណើរការកិច្ចប្រជុំពិគ្រោះយោបល់សម្រាប់ការរៀបចំយុទ្ធសាស្ត្រ និងផែនការសកម្មភាព ........ ១១
តារាងទី៣ : បរិមាណសំរាម សំណល់រឹងបង្កើតឡើងក្នុងម្នាក់ៗ ផ្អែកលើទិន្នន័យឆ្នាំ២០១៦ ........ ១៩
តារាងទី៤ : បរិមាណសំរាម សំណល់រឹងទីប្រជុំជននៅតាមប្រភព និងចាក់នៅទីលានក្នុងឆ្នាំ២០១៤ - ២០១៧ ........ ២២
តារាងទី៥ : បរិមាណសំណល់កែច្នៃនាំចេញ និងទិសដៅប្រទេសនាំចេញ ក្នុងឆ្នាំ២០១៣ និង២០១៤ ........ ២៥
តារាងទី៦ : សមាសធាតុនៃសំណល់វេជ្ជសាស្ត្រដែលបានបង្កើតនៅរាជធានីភ្នំពេញ ........ ២៧
តារាងទី៧ : តំបន់សេវាគ្របដណ្តប់របស់អង្គភាពគ្រប់គ្រងសំណល់វេជ្ជសាស្ត្រនៅរាជធានីភ្នំពេញ ........ ២៨
តារាងទី៨ : អាណត្តិអភិបាលកិច្ចនៃក្រសួងពាក់ព័ន្ធលើការគ្រប់គ្រងសំណល់នៅកម្ពុជា ........ ៣៥
តារាងទី៩ : តួនាទី និងការទទួលខុសត្រូវរបស់មន្ទីរពាក់ព័ន្ធលើការគ្រប់គ្រងសំណល់នៅរាជធានីភ្នំពេញ ........ ៤០

# ពាក្យបំព្រួញ និង អក្សរកាត់

| | | |
|---|---|---|
| AA | Action Area | សកម្មភាពចម្បង |
| ADB | Asian Development Bank | ធនាគារអភិវឌ្ឍន៍អាស៊ី |
| AFD | Agence Française de Développement (French Development Agency) | ទីភ្នាក់ងារអភិវឌ្ឍន៍បារាំង |
| CCET | IGES Centre Collaborating with UNEP on Environmental Technologies | វិទ្យាស្ថាន IGES សហការជាមួយអង្គការ UNEP ស្តីពីបច្ចេកវិទ្យាបរិស្ថាន |
| C&D | Construction and Demolition | សំណល់សំណង់ |
| CCCSP | Cambodian Climate Change Strategic Plan | ផែនការយុទ្ធសាស្ត្រឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុកម្ពុជា |
| CEA | Cambodia Environmental Association | សមាគមបរិស្ថានកម្ពុជា |
| CER | Certified Emission Reductions | ការកាត់បន្ថយការបំភាយឧស្ម័ន |
| COMPED | Cambodian Education and Waste Management Organization | អង្គការកែច្នៃសំរាម និងការសិក្សានៅកម្ពុជា |
| CRC | Cambodian Red Cross | កាកបាទក្រហមកម្ពុជា |
| DANIDA | Danish International Development Agency | ភ្នាក់ងារអភិវឌ្ឍន៍អន្តរជាតិដាណឺម៉ាក |
| DoE | Department of Environment | មន្ទីរបរិស្ថាន |
| DoEYS | Department of Education, Youth and Sports | មន្ទីរអប់រំ យុវជន និងកីឡា |
| DEF | Department of Economy and Finance | មន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុ |
| DLMUPC | Department of Land Management, Urban Planning, Construction and Cadastre | មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី |
| DoH | Department of Health | មន្ទីរសុខាភិបាល |
| DoIH | Department of Industry and Handicraft | មន្ទីរឧស្សាហកម្ម និងសិប្បកម្ម |
| DPWT | Department of Public Works and Transport | មន្ទីរសាធារណការ និងដឹកជញ្ជូន |
| EEE | Electrical and Electronic Equipment | ឧបករណ៍អេឡិចត្រូនិក និងបរិក្ខារអគ្គិសនី |
| E-Waste | Waste Electrical and Electronic Equipment | សំណល់អេឡិចត្រូនិក |
| GCF | Global Climate Fund | មូលនិធិអាកាសធាតុសាកល |

| | | |
|---|---|---|
| GDP | Gross Domestic Product | ផលិតផលក្នុងស្រុកសរុប (ផ.ស.ស) |
| GHG | Green-house Gas | ឧស្ម័នផ្ទះកញ្ចក់ |
| GIZ | Deutsche Gesellschaft für Internationale Zusammenarbeit GmbH (German Corporation for International Cooperation GmbH) | ទីភ្នាក់ងារអាល្លឺម៉ង់ដើម្បីកិច្ចសហប្រតិបត្តិការអន្តរជាតិ |
| GWP | Global Warming Potential | សក្តានុពលឡើងកម្តៅផែនដី |
| HCW | Healthcare Waste | សំណល់ពីសេវាថែទាំសុខភាព |
| IGES | Institute for Global Environmental Strategies | វិទ្យាស្ថានដើម្បីយុទ្ធសាស្រ្តបរិស្ថានសាកល |
| IFAD | International Fund for Agricultural Development | មូលនិធិអន្តរជាតិដើម្បីអភិវឌ្ឍន៍កសិកម្ម |
| IFC | International Finance Cooperation | សហប្រតិបត្តិការហិរញ្ញវត្ថុអន្តរជាតិ |
| JCM | Joint Crediting Mechanism | យន្តការឥណទានកាបូនរួមគ្នា |
| JICA | Japan International Cooperation Agency | ភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិជប៉ុន |
| Kg | Kilogram | គីឡូក្រាម |
| KOICA | Korea International Cooperation Agency | ភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិកូរ៉េ |
| L | Litre | លីត្រ |
| LGCC | Local Governments and Climate Change | រដ្ឋាភិបាលក្នុងតំបន់ និងការប្រែប្រួលអាកាសធាតុ |
| MAFF | Ministry of Agriculture, Forestry and Fisheries | ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ |
| M/D | Municipality and Districts | ក្រុង ឬ ស្រុក |
| MEF | Ministry of Economy and Finance | ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ |
| MFAT | Ministry of Foreign Affairs and Trade (New Zealand) | ក្រសួងការបរទេស និងពាណិជ្ជកម្ម (នូវែលសេឡង់) |
| MLMUPC | Ministry of Land Management Urban Planning and Construction | ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ |
| MME | Ministry of Mines and Energy | ក្រសួងរ៉ែ និងថាមពល |
| MoC | Ministry of Commerce | ក្រសួងពាណិជ្ជកម្ម |
| MoE | Ministry of Environment | ក្រសួងបរិស្ថាន |
| MoEYS | Ministry of Education, Youth and Sports | ក្រសួងអប់រំ យុវជន និងកីឡា |
| MoH | Ministry of Health | ក្រសួងសុខាភិបាល |

| | | |
|---|---|---|
| MoI | Ministry of Interior | ក្រសួងមហាផ្ទៃ |
| MoIH | Ministry of Industry and Handicraft | ក្រសួងឧស្សាហកម្ម និងសិប្បកម្ម |
| MPP | Municipality of Phnom Penh | សាលាក្រុងភ្នំពេញ |
| MSW | Municipal Solid Waste | សំណល់រឹងទីក្រុង |
| MSWM | Municipal Solid Waste Management | ការគ្រប់គ្រងសំណល់រឹងទីក្រុង |
| MWMU | Medical Waste Management Unit | អង្គភាពគ្រប់គ្រងសំណល់វេជ្ជសាស្ត្រ |
| NCCC | National Climate Change Committee | គណៈកម្មាធិការជាតិគ្រប់គ្រងការប្រែប្រួលអាកាសធាតុ |
| NCGG | National Council on Green Growth | ក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍បៃតង |
| NCDD | National Committee for Sub-national Democratic Development | គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ |
| NCSD | National Council for Sustainable Development | ក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព |
| NGO | Non-government Organisation | អង្គការមិនមែនរដ្ឋាភិបាល |
| NORAD | Norwegian Agency for Development Cooperation | ទីភ្នាក់ងារន័រវែសសម្រាប់កិច្ចសហប្រតិបត្តិការអភិវឌ្ឍ |
| NSDP | National Strategic Development Plan | ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ |
| PA | Provincial Administration | រដ្ឋបាលខេត្ត |
| PFI | Private Finance Initiative | ការផ្តួចផ្តើមហិរញ្ញវត្ថុឯកជន |
| PET | Polyethylene Terephthalate | ប្លាស្ទិក PET (ដបទឹកសុទ្ធថ្លា) |
| PDCA | Plan-Do-Check-Action | ផែនការ -ធ្វើ -ត្រួតពិនិត្យ- សកម្មភាព |
| POPs | Persistent Organic Pollutants | សារធាតុបំពុលសរីរាង្គមិនងាយបំបែក |
| PPCA | Phnom Penh Capital Administration | រដ្ឋបាលរាជធានីភ្នំពេញ |
| PPCC | Phnom Penh Capital City | រាជធានីភ្នំពេញ |
| PPCH | Phnom Penh Capital Hall | សាលារាជធានីភ្នំពេញ |
| PPUTMP | Phnom Penh Urban Transport Master Plan | ផែនការមេលើការងារដឹកជញ្ជូនក្នុងរាជធានីភ្នំពេញ |
| PPP | Public-Private Partnership | ភាពជាដៃគូរវាងរដ្ឋ និងឯកជន |
| PPSEZ | Phnom Penh Special Economic Zone | តំបន់សេដ្ឋកិច្ចពិសេសភ្នំពេញ |
| PSP | Private Sector Participation | ការចូលរួមពីវិស័យឯកជន |
| RGC | Royal Government of Cambodia | រាជរដ្ឋាភិបាលកម្ពុជា |

| | | |
|---|---|---|
| SDG | Sustainable Development Goals | គោលដៅអភិវឌ្ឍន៍ដោយចីរភាព |
| SIDA | Swedish International Development Cooperation Agency | ភ្នាក់ងារសហប្រតិបត្តិការអភិវឌ្ឍន៍អន្តរជាតិស៊ុយអែត |
| SNAs | Sub-national Authorities | អាជ្ញាធរថ្នាក់ក្រោមជាតិ |
| STT | Sahmakum Teang Tnaut (NGO) | សមាគមធាងត្នោត |
| t | tonne / metric ton ($10^3$kg) | តោន |
| UNCDF | United Nations Capital Development Fund | មូលនិធិអភិវឌ្ឍន៍មូលធនសហប្រជាជាតិ |
| UNDP | United Nations Development Programme | កម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ |
| UNEP | United Nations for Environment Programme | កម្មវិធីបរិស្ថានសហប្រជាជាតិ |
| UNFCCC | United Nations Framework Convention on Climate Change | អនុសញ្ញាក្របខណ្ឌសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ |
| UNIDO | United Nations Industrial Development Organization | អង្គការអភិវឌ្ឍន៍ឧស្សាហកម្មសហប្រជាជាតិ |
| UPWD | Urban Poor Women Development | អង្គការអភិវឌ្ឍន៍ស្ត្រីក្រីក្រក្នុងទីក្រុង |
| USAID | United States Agency for International Development | ទីភ្នាក់ងារ ស.រ.អ ដើម្បីអភិវឌ្ឍន៍អន្តរជាតិ |
| USD | United States Dollar | ដុល្លារអាមេរិក |
| WEEE | Waste Electrical and Electronic Equipment | សំណល់អេឡិចត្រូនិក និងបរិក្ខារអគ្គិសនី |
| Yr | Year | ឆ្នាំ |

## អារម្ភកថានៃយុទ្ធសាស្ត្រគ្រប់គ្រងសំណល់សម្រាប់រាជធានីភ្នំពេញ

នៅក្នុងផែនការមេនៃការប្រើប្រាស់ដីធ្លីរបស់រាជធានីភ្នំពេញ ដែលមានចក្ខុវិស័យទៅដល់ឆ្នាំ២០៣៥ គឺជាឯកសារតម្រង់ទិសអភិវឌ្ឍន៍រយៈពេលមធ្យម-វែងរបស់រាជធានីភ្នំពេញ ដែលមានគោលដៅកសាងទីក្រុងនេះឱ្យក្លាយជាមជ្ឈមណ្ឌលនយោបាយ សេដ្ឋកិច្ចពាណិជ្ជកម្ម វប្បធម៌ ប្រកបដោយសក្តានុពលប្រកួតប្រជែង ជាមួយការអភិវឌ្ឍមួយប្រកបដោយវឌ្ឍនភាព សមធម៌ និងចីរភាព។ ដើម្បីសម្រេចបាននូវចក្ខុវិស័យនេះ គឺត្រូវពឹងផ្អែកសំខាន់លើការរៀបចំខ្លួនជារបស់ប្រជាពលរដ្ឋម្នាក់ៗ និងសង្គមជាតិក្នុងផ្នែកជាច្រើន ដែលវិស័យគ្រប់គ្រងសំណល់នឹងដើរតួនាទីយ៉ាងសំខាន់ ក្នុងការកសាងសង្គមមួយប្រកបដោយចីរភាព។

ស្រដៀងគ្នាទៅនឹងទីក្រុងផ្សេងៗទៀតដែរ ការគ្រប់គ្រងសំរាម សំណល់រឹងតែងតែជាបញ្ហាប្រឈមដ៏សំខាន់មួយសម្រាប់រាជធានីភ្នំពេញ។ ដូចដែលបានពន្យល់នៅក្នុងយុទ្ធសាស្ត្រនេះ បរិមាណសំរាមដែលបានចាក់ចោលនៅទីលានចាក់សំរាមប្រចាំខែ បានកើនទ្វេដងក្នុងរយៈពេលមួយទសវត្សរ៍ចុងក្រោយនេះ ដោយកត្តាជាច្រើនដូចជាៈ កំណើនប្រជាជន កំណើនសេដ្ឋកិច្ច ការផ្លាស់ប្តូររចនាសម្ព័ន្ធឧស្សាហកម្ម និងរបត់នៃការរស់នៅ។ ខណៈរដ្ឋបាលរាជធានីភ្នំពេញ បានកំពុងខិតខំប្រឹងប្រែងយ៉ាងច្រើនក្នុងការរៀបចំប្រព័ន្ធគ្រប់គ្រងសំរាម សំណល់រឹង ការដោះស្រាយលើបញ្ហាការកើនឡើងនៃសំណល់ដ៏គំហុកនេះ គឺជាកិច្ចការដ៏លំបាកមួយ។ ការប្រមូល ការដឹកជញ្ជូន និងការចាក់ចោលសំរាមត្រូវតែពង្រឹង ប៉ុន្តែគោលការណ៍ ៣R (ការកាត់បន្ថយ ការប្រើប្រាស់ឡើងវិញ និងកែច្នៃសំណល់) និងត្រូវជំរុញការទុកដាក់សំរាមឱ្យបានត្រឹមត្រូវផងដែរ តាមរយៈកិច្ចសហប្រតិបត្តិការនៃគ្រប់ភាគីពាក់ព័ន្ធដែលបង្កើតសំណល់ទាំងអស់គ្នា។

យុទ្ធសាស្ត្រ និងផែនការសកម្មភាពគ្រប់គ្រងសំណល់សម្រាប់រាជធានីភ្នំពេញឆ្នាំ២០១៨-២០៣៥ ត្រូវបានរៀបចំឡើងដើម្បីឆ្លើយតបទៅនឹងតម្រូវការទាំងនេះ តាមរយៈកម្មវិធី និងសកម្មភាពស្របទៅតាមចក្ខុវិស័យ បេសកកម្ម និងគោលដៅរួមមួយ។ ឯកសារនេះ គឺជាលទ្ធផលនៃកិច្ចខិតខំប្រឹងប្រែងរួមគ្នារបស់អ្នកពាក់ព័ន្ធទាំងអស់ ដែលចូលរួមក្នុងការគ្រប់គ្រងសំណល់ប្រចាំថ្ងៃពីអង្គភាពគ្រប់គ្រងសំណល់ មន្ទីរពាក់ព័ន្ធ រដ្ឋបាលខណ្ឌ និងសង្កាត់ វិស័យឯកជន អង្គការក្រៅរដ្ឋាភិបាល និងគ្រឹះស្ថានអប់រំ។ ជាមួយគ្នានេះដែរ វាមានគោលបំណងបញ្ជាក់អំពីតួនាទី និងការទទួលខុសត្រូវរបស់ភាគីពាក់ព័ន្ធ ដើម្បីឱ្យភាគីនីមួយៗអាចចាត់វិធានការជាក់ស្តែង ហើយបំពេញនូវទំនួលខុសត្រូវរបស់ខ្លួនចំពោះក្មេងជំនាន់ក្រោយ វាសំខាន់ណាស់ ដែលយើងម្នាក់ៗចាប់ផ្តើមធ្វើអ្វីដែលយើងអាចធ្វើបាន។

រដ្ឋបាលរាជធានីភ្នំពេញ នឹងបន្តដាក់អាទិភាពខ្ពស់ក្នុងការធ្វើឱ្យប្រសើរឡើងនូវសេវាគ្រប់គ្រងសំណល់រឹង តាមរយៈការអនុវត្តន៍សកម្មភាព ដែលត្រូវបានបញ្ចូលក្នុងវិស័យសំខាន់ៗទាំង៥នៃយុទ្ធសាស្ត្រ និងតាមរយៈការសម្របសម្រួល និងការសហការយ៉ាងជិតស្និទ្ធជាមួយភាគីពាក់ព័ន្ធ។ ជាពិសេស រដ្ឋបាលរាជធានីភ្នំពេញនឹងធ្វើការយ៉ាងជិតស្និទ្ធជាមួយរដ្ឋបាលខណ្ឌដែលបានទទួលនូវទំនួលខុសត្រូវថ្មីៗក្នុងការអនុវត្តន៍សេវាកម្មគ្រប់គ្រងសំរាម សំណល់រឹង នៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួនក្នុងបរិបទនៃការធ្វើវិមជ្ឈការក្នុងវិស័យនេះ។

ជាចុងក្រោយ តាងនាមក្រុមប្រឹក្សារាជធានីភ្នំពេញ និងអភិបាលនៃគណៈអភិបាលរាជធានីភ្នំពេញ ខ្ញុំសូមថ្លែងអំណរគុណចំពោះអង្គការបរិស្ថានសហប្រជាជាតិ (UN Environment) វិទ្យាស្ថាន IGES សហការជាមួយ អង្គការ UNEP ស្តីពីបច្ចេកវិទ្យាបរិស្ថាន (CCET) កម្មវិធីសម្ព័ន្ធភាពប្រែប្រួលអាកាសធាតុកម្ពុជា (CCCA) អង្គការ Nexus សម្រាប់ការអភិវឌ្ឍ និងភាគីទាំងអស់ដែលបានចូលរួមក្នុងដំណើរការនិងឧបត្ថម្ភលើការរៀបចំយុទ្ធសាស្ត្រនេះរហូតទទួលបានលទ្ធផលជាផ្លែផ្កានាពេលនេះ និងសូមអំពាវនាវឱ្យមានកិច្ចសហការពីគ្រប់ភាគីពាក់ព័ន្ធទាំងអស់ ដើម្បីឆ្ពោះទៅអនុវត្តយុទ្ធសាស្ត្រ ធ្វើឱ្យទីក្រុងស្អាត មានអនាម័យ និងប្រកបដោយចីរភាពបរិស្ថាន។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០១ ខែសីហា ឆ្នាំ២០១៨

Governor of Phnom Penh Capital



Khuong Sreng

ការអនុវត្តន៍ការគ្រប់គ្រងសំណល់ដ៏ល្អមួយ គឺត្រូវបញ្ចៀសនូវការជះឥទ្ធិពលអវិជ្ជមានទាំងឡាយទៅលើសុខភាពមនុស្ស សត្វ និងបរិស្ថាន ព្រមទាំងរួមចំណែកក្នុងការកែច្នៃធនធានពីសំណល់ផងដែរ។ តាមរយៈរបាយការណ៍បរិស្ថានរបស់អង្គការសហប្រជាជាតិ ស្តីពី "ដំណើរឆ្ពោះទៅរកពពិភពដែលគ្មានការបំពុល" បានថែងថា កំហាតបង់ផ្នែកសេដ្ឋកិច្ចពីការគ្រប់គ្រងសំរាមសំណល់ទូទៅដោយមិនបានត្រឹមត្រូវមានតម្លៃគិតជាទឹកប្រាក់រហូតដល់ជាង ២០០កោដិដុល្លាអាមេរិក ក្នុងមួយឆ្នាំៗ។ ចំពោះប្រទេសដែលមានប្រាក់ចូលទាប និងមធ្យម ជាទូទៅការគ្រប់គ្រងសំណល់ត្រូវបានចូលរួមចំណែកពីសំណាក់អ្នករើសសំណល់អេតចាយជាលក្ខណៈក្រៅប្រព័ន្ធ ដែលមានចំនួនប្រហែល ១៥លាននាក់ នៅទូទាំងពិភពលោក។ ខណៈពួកគេនាំគ្នាប្រមូលយកសំណល់មានតម្លៃនៅទីលានចាក់សំរាម ហើយជារឿយៗពួកគេតែរស់នៅក្នុងសភាពបរិស្ថានមិនសមរម្យ និងងាយទទួលរងគ្រោះថ្នាក់ជាច្រើន។ សភាបរិស្ថាននៃអង្គការសហប្រជាជាតិកាលពីឆ្នាំ២០១៧ នៅឯកិច្ចប្រជុំលើកទី៣របស់ខ្លួន ក៏បានស្វះស្វែងដោះស្រាយបញ្ហាគ្រប់គ្រងសំណល់ប្រកបដោយចីរភាពបរិស្ថាន ធានាបាននូវកិច្ចគាំពារសុខភាពមនុស្ស និងបរិស្ថាន។ ជាកិច្ចឆ្លើយតបមួយរបស់រដ្ឋបាលថ្នាក់ក្រុងទៅនឹងបញ្ហាទាំងនេះ ការរៀបចំនូវយុទ្ធសាស្ត្រ និងផែនការសកម្មភាពគ្រប់គ្រងសំណល់សម្រាប់រាជធានីភ្នំពេញឆ្នាំ២០១៨-២០៣៥ បានដាក់ចេញនូវគន្លងដ៏ពេញលេញមួយសម្រាប់គ្រប់ភាគីពាក់ព័ន្ធនៅក្នុងរាជធានីភ្នំពេញ ក្នុងការរួបរួមជំនះបញ្ហាប្រឈមទាំងឡាយ ដែលមាននៅក្នុងការអនុវត្តន៍ការងារគ្រប់គ្រងសំរាម សំណល់រឹងនាពេលបច្ចុប្បន្ននេះ។ តាងនាមឱ្យអង្គការបរិស្ថានសហប្រជាជាតិ សង្ឃឹម និងជឿជាក់ថា ផែនការនេះនឹងអាចធ្វើឱ្យរាជធានីភ្នំពេញសម្រេចបានជោគជ័យនៅក្នុងការគ្រប់គ្រងសំរាម សំណល់រឹងប្រកបដោយចីរភាពបរិស្ថាន ព្រមទាំងចំណេញផ្នែកសេដ្ឋកិច្ចសុខភាព និងបរិស្ថានផងដែរ។



**Keith Alverson**

នាយកនៃមជ្ឈមណ្ឌលបច្ចេកវិទ្យាបរិស្ថានអន្តរជាតិ (IETC)

នៃអង្គការបរិស្ថានសហប្រជាជាតិ (UN Environment)

ដូចគ្នាទៅនឹងបណ្តាទីក្រុងរីកលូតលាស់រហ័សដទៃទៀតនៅទ្វីបអាស៊ី រាជធានីភ្នំពេញកំពុងប្រឈមនឹងបញ្ហាយ៉ាងច្រើននៅក្នុងការគ្រប់គ្រងសំរាម សំណល់រឹងរបស់ខ្លួន។ មជ្ឈមណ្ឌលសហប្រតិបត្តិការបរិស្ថាន CCET នៃវិទ្យាស្ថាន IGES និងអង្គការ UNEP បានជ្រើសរើសរាជធានីភ្នំពេញជាទីក្រុងគោលដៅដំបូងមួយ ដើម្បីសហការរៀបចំនូវយុទ្ធសាស្ត្រ និងផែនការសកម្មភាពគ្រប់គ្រងសំណល់ ដោយផ្អែកលើវិធីសាស្ត្រគ្រប់គ្រងសំណល់តាមបែបចម្រុះ។ តាមរយៈការប្តេជ្ញាចិត្តយ៉ាងមុតមាំ និងការចូលរួមយ៉ាងសកម្មរបស់មន្ត្រី និងថ្នាក់ដឹកនាំរដ្ឋបាលរាជធានីភ្នំពេញ ធ្វើឱ្យយុទ្ធសាស្ត្រ និងផែនការសកម្មភាពគ្រប់គ្រងសំណល់ឆ្នាំ ២០១៨-២០៣៥ នេះត្រូវបានបង្កើតឡើងដោយជោគជ័យ ដោយមានការសម្របសម្រួល និងការត្រួតពិនិត្យរបស់មន្ទីរពាក់ព័ន្ធ និងតំណាងមកពីបណ្តារដ្ឋបាលខណ្ឌ វិស័យឯកជន អង្គការក្រៅរដ្ឋាភិបាល និងសាកលវិទ្យាល័យ។

យុទ្ធសាស្ត្រ និងផែនការសកម្មភាពនេះ ត្រូវបានបង្កើតឡើងតាមរយៈដំណើរការពិគ្រោះយោបល់រយៈពេល២ឆ្នាំ ដោយបានបង្ហាញនូវបញ្ហាប្រឈមនៃការគ្រប់គ្រងសំណល់សំខាន់ៗ ព្រមទាំងបង្ហាញពីចក្ខុវិស័យ បេសកកម្ម គោលដៅ និងទិសដៅសម្រាប់ប្រព័ន្ធគ្រប់គ្រងសំរាម សំណល់រឹងឱ្យបានកាន់តែប្រសើរឡើង ហើយរៀបចំជាផែនទីបង្ហាញផ្លូវសម្រាប់សកម្មភាពរួមផងដែរ ដល់គ្រប់ភាគីពាក់ព័ន្ធនានាឆ្ពោះទៅរកការសម្រេចបាននូវគ្រប់គ្រងធនធានប្រកបដោយប្រសិទ្ធភាព និងចីរភាពនៅក្នុងរាជធានីភ្នំពេញ។ កម្មវិធី និងវិធីសាស្ត្រដែលបានកំណត់នៅក្នុងយុទ្ធសាស្ត្រនេះ ឈរលើវិធីសាស្ត្រវិភាគគ្រប់ជ្រុងជ្រោយ ព្រមទាំងគ្របដណ្តប់គ្រប់ជំហាននៃខ្សែសង្វាក់គ្រប់គ្រងសំណល់តាំងពីការប្រមូលសំរាម ការផ្ទេរ ការធ្វើប្រព្រឹត្តកម្មសំណល់ និងការចាក់ចោលសំរាម ដោយបានរួមបញ្ចូលនូវពហុប្រភេទសំណល់រឹងផ្សេងៗជាច្រើនរួមមាន សំណល់រឹងទីក្រុង សំណល់ឧស្សាហកម្ម សំណល់វេជ្ជសាស្ត្រ សំណល់សំណង់ សំណល់អេឡិចត្រូនិក និងបរិក្ខារអគ្គិសនីផ្សេងៗទៀត។ វិសាលភាពនៃអភិបាលកិច្ចទូលំទូលាយត្រូវបានបញ្ជាក់ថាមានសារៈសំខាន់យ៉ាងខ្លាំងផងដែរ ក្រៅពីដំណោះស្រាយបច្ចេកទេស ដើម្បីធានាថាសេវាសំណល់មាននិរន្តរភាពក្នុងរយៈពេលវែង តាមរយៈយន្តការគាំទ្រផ្នែកហិរញ្ញវត្ថុ គោលនយោបាយល្អ ក្របខណ្ឌស្ថាប័នត្រឹមត្រូវ និងការត្រួតពិនិត្យច្បាស់លាស់។ វិទ្យាស្ថាន CCET សង្ឃឹមថា យុទ្ធសាស្ត្រ និងផែនការសកម្មភាពនេះ នឹងដើរតួនាទីជាជំហានដំបូងដ៏សំខាន់មួយសម្រាប់ប្រជាពលរដ្ឋក្នុងរាជធានីភ្នំពេញ ឆ្ពោះទៅរកការបង្កើតសង្គមមួយប្រកបដោយចីរភាព។



**Kazunobu Onogawa**

នាយក នៃមជ្ឈមណ្ឌលសហប្រតិបត្តិការបរិស្ថាន

នៃវិទ្យាស្ថាន IGES និងអង្គការ UNEP (CCET)

អង្គការ Nexus សម្រាប់ការអភិវឌ្ឍ គឺជាអង្គការមិនរកប្រាក់ចំណេញ និងជាដៃគូហិរញ្ញវត្ថុ ដែលស្វែងរកដំណោះស្រាយបញ្ហាក្នុងស្រុក ដើម្បីឆ្ពោះទៅរកគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព។ អស់រយៈពេលជាង ៨ឆ្នាំ មកហើយ អង្គការ Nexus បានផ្តល់នូវភាពជំនាញ និងធនធាន ដើម្បីគាំទ្រពង្រីកគម្រោងអភិវឌ្ឍន៍ការបំភាយឧស្ម័នកាបូនតិចនៅក្នុងតំបន់អាស៊ីអាគ្នេយ៍។ អង្គការ Nexus ដំបូងបង្អស់បានចាប់ផ្តើមនៅក្នុងព្រះរាជាណាចក្រកម្ពុជា ដោយមានគោលដៅបង្កើតឱ្យមានសមធម៌នៅក្នុងការទទួលបានឥណទានកាបូន និងលើកកម្ពស់ការយល់ដឹងអំពីការប្រែប្រួលអាកាសធាតុ។

យុទ្ធសាស្ត្រ និងផែនការសកម្មភាពគ្រប់គ្រងសំណល់សម្រាប់រាជធានីភ្នំពេញឆ្នាំ២០១៨-២០៣៥ គឺជាលទ្ធផលនៃកិច្ចសហការ ដែលមានការគាំទ្រពីកម្មវិធីសម្ព័ន្ធភាពប្រែប្រួលអាកាសធាតុកម្ពុជា (CCCA) តាមរយៈភាពជាដៃគូជាមួយនឹងរដ្ឋបាលរាជធានីភ្នំពេញ និងវិទ្យាស្ថាន IGES /វិទ្យាស្ថាន IETC នៃអង្គការ UNEP។ អង្គការ Nexus បានរួមចំណែកក្នុងការប្រមូលផ្តុំអ្នកពាក់ព័ន្ធ និងសម្របសម្រួលកិច្ចពិភាក្សាដែលចាំបាច់សម្រាប់ការរៀបចំយុទ្ធសាស្ត្រនេះ។ គោលបំណងដំបូងរបស់យើង គឺដើម្បីស្តារឡើងវិញនូវបញ្ហានៃការគ្រប់គ្រងសំណល់ទីក្រុង នៅក្នុងរបៀបវារៈនៃការអភិវឌ្ឍទីក្រុង និងដើម្បីលើកទឹកចិត្តឱ្យមានកិច្ចសហការរវាងភាគីពាក់ព័ន្ធផ្សេងៗ។ យុទ្ធសាស្ត្រនេះ មានគោលដៅផ្តល់សកម្មភាពសកម្មក្នុងរយៈពេលខ្លី មធ្យម និងយូរអង្វែង និងដើម្បីលើកកម្ពស់ការប្រើប្រាស់ធនធានប្រកបដោយប្រសិទ្ធភាព សម្រាប់ការអនុវត្តន៍ការគ្រប់គ្រងសំណល់ប្រកបដោយនិរន្តរភាពនៅរាជធានីភ្នំពេញ។

យើងខ្ញុំសង្ឃឹមថា សកម្មភាពចម្បងៗទាំង៥ដែលបានព្រមព្រៀងគ្នា នឹងត្រូវបានដោះស្រាយប្រកបដោយប្រសិទ្ធភាព បញ្ចៀសបានហេតុប៉ះពាល់បរិស្ថានពីប្រព័ន្ធគ្រប់គ្រងសំណល់ និងអាចសម្រេចបានគោលដៅមួយចំនួននៃផែនការយុទ្ធសាស្ត្រប្រែប្រួលអាកាសធាតុកម្ពុជាឆ្នាំ២០១៤-២០២៣ និងយុទ្ធសាស្ត្រអភិវឌ្ឍន៍បៃតងឆ្នាំ២០១៦-២០២០ សម្រាប់ប្រទេសកម្ពុជា។

សកម្មភាពរួមគ្នាទាំងនេះ បានឆ្លុះបញ្ចាំងពីចក្ខុវិស័យច្បាស់លាស់របស់រាជធានីភ្នំពេញ ឆ្ពោះទៅជាទីក្រុងដែលមានការអភិវឌ្ឍប្រកបដោយចីរភាព និងបៃតងជាក់ជាមិនខាន។

**Claire Dufour**

នាយកប្រតិបត្ត នៃអង្គការនីសឹសសម្រាប់ការអភិវឌ្ឍ

I

# ជំពូកទី១

# សេចក្តីផ្តើមនៃយុទ្ធសាស្ត្រ

Chapter I

# សេចក្តីផ្តើមនៃយុទ្ធសាស្ត្រ

## ១. តម្រូវការនូវយុទ្ធសាស្ត្រគ្រប់គ្រងសំណល់

ភ្នំពេញ ជារាជធានីនៃព្រះរាជាណាចក្រកម្ពុជា សម្រេចបាននូវកំណើនសេដ្ឋកិច្ចយ៉ាងឆាប់រហ័សក្នុងរយៈពេលប៉ុន្មានទសវត្សរ៍ចុងក្រោយនេះនាំមកនូវភាពរុងរឿង ហើយប្រជាពលរដ្ឋមានជីវភាពរស់នៅល្អប្រសើរឡើង។ ទោះបីជាយ៉ាងណាក៏ដោយ ការអភិវឌ្ឍសេដ្ឋកិច្ចដ៏ឆាប់រហ័ស រួមនឹងការរីកលូតលាស់វិស័យឧស្សាហកម្ម និងទីក្រុងនាំឱ្យមានការផ្លាស់ប្តូរឥរិយាបទរស់នៅរបស់ប្រជាពលរដ្ឋធ្វើឱ្យបរិមាណសំរាម សំណល់រឹងមានការកើនឡើងយ៉ាងឆាប់រហ័សដូចគ្នាផងដែរ ដែលបង្កឱ្យមានបញ្ហាដល់សុខភាពសាធារណៈ បរិស្ថាន និងគំរាមកំហែងដល់ធនធានផងដែរ។

តាមរយៈឯកសារយុទ្ធសាស្ត្រពិស្តារ បរិមាណសំណល់រឹងក្នុងរាជធានីភ្នំពេញដែលបញ្ចេញសរុបប្រចាំឆ្នាំមានប្រមាណ ១លានតោន ក្នុងមួយឆ្នាំ ហើយត្រូវបានដឹកយកទៅចាក់ចោលនៅទីលានចាក់សំរាមមានប្រមាណជាង ៧០០.០០០តោន ប៉ុណ្ណោះក្នុងឆ្នាំដូចគ្នា។ ដោយឡែក ទីលានចាក់សំរាមរាជធានីភ្នំពេញទទួលសំណល់ប្រមាណ ២.០០០តោន ពីខណ្ឌចំនួន១២ ក្នុងមួយថ្ងៃ។ តាមរយៈកិច្ចខិតខំប្រឹងប្រែងរបស់សាលារាជធានីភ្នំពេញក្នុងការកែលម្អប្រព័ន្ធប្រមូលសំណល់ ធ្វើឱ្យបរិមាណសំរាម ដែលយកទៅចាក់នៅទីលានចាក់សំរាមមានការកើនឡើងជាបន្តបន្ទាប់នៅក្នុងទសវត្សរ៍ចុងក្រោយនេះ (ក្រសួងបរិស្ថាន ឆ្នាំ២០១៥)។ ទោះជាយ៉ាងណាក៏ដោយ ការគ្របដណ្តប់លើសេវាកម្មប្រមូលសំណល់មាននៅត្រឹមតែតំបន់ទីប្រជុំជនរាជធានីភ្នំពេញ ខណៈពេលដែលការបញ្ចេញសំរាមចោល និងការប្រមូលត្រូវបានធ្វើឡើងនៅមានកម្រិតនៅឡើយ បង្កឱ្យវត្តមាននៃគំនរសំរាមអនាធិបតេយ្យមានការកើនឡើងក្នុងទីក្រុង ការធ្វើប្រព្រឹត្តកម្ម និងការទុកដាក់សំណល់ចុងក្រោយមិនបានល្អ និងសមស្របតាមលក្ខណៈបរិស្ថាននៅឡើយ។

ដោយការអនុវត្តន៍តាមគោលការណ៍ ៣អ៊ែរ (ការកាត់បន្ថយ ការប្រើឡើងវិញ និងការកែច្នៃសំណល់) នៅមានកម្រិតនៅឡើយ ជាហេតុធ្វើឱ្យទីលានចាក់សំរាមនៅខណ្ឌដង្កោ ដែលជាទីកន្លែងគេយកសំរាមពីរាជធានីភ្នំពេញមកចាក់ចោលនៅទីនោះកំពុងប្រឈមនឹងកត្តាផ្សេងៗ ដែលបណ្តាលមកពីហូរនៃសំណល់ ព្រមទាំងថយសមត្ថភាពស្តុករបស់វាយ៉ាងឆាប់រហ័ស។ ជាលទ្ធផល វិធានការទប់ស្កាត់ផលប៉ះពាល់អវិជ្ជមានដល់សុខភាពមនុស្ស សត្វ និងបរិស្ថានមួយចំនួន ត្រូវបានយកចិត្តទុកដាក់តិចតួច បើប្រៀបធៀបទៅនឹងការរក្សានិរន្តរភាពដំណើរការទីលានចាក់សំរាម។ រណ្តៅដីធំៗ ត្រូវបានសាងសង់តាមបែបសាមញ្ញសម្រាប់ចាក់សំរាម ព្រមទាំងមានការថែទាំ និងយកចិត្តទុកដាក់នៅមានកម្រិតនៅឡើយ ដូចជា មិនមានការរៀបចំចាក់ដីគ្របគ្មានប្រព័ន្ធគ្រប់គ្រងអគ្គីភ័យ គ្មានប្រព័ន្ធប្រមូលឧស្ម័នទីលាន និងគ្មានប្រព័ន្ធប្រព្រឹត្តកម្មទឹកសំអុយពីទីលានចាក់សំរាម។

ការគ្រប់គ្រងសំរាម សំណល់រឹងមិនបានត្រឹមត្រូវបាននិងកំពុងចាប់ផ្តើមបង្កផលប៉ះពាល់លើសុខភាពសាធារណៈ ប្រព័ន្ធអេកូឡូស៊ី រួមចំណែកក្នុងការបំពុលបរិយាកាស ទឹក ដី និងខ្យល់ ព្រមទាំងគំរាមកំហែងដល់និរន្តរភាពធនធានធម្មជាតិ និងការអភិវឌ្ឍសេដ្ឋកិច្ចផងដែរ។

តាមរយៈចក្ខុវិស័យជាសាកល សហគមន៍អន្តរជាតិបានព្រមព្រៀងគ្នាលើកិច្ចព្រមព្រៀងអន្តរជាតិសំខាន់ៗពីរ គឺកិច្ចព្រមព្រៀងទីក្រុងប៉ារីស ស្តីពីអាកាសធាតុ និងគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព (SDGs) ដែលផ្តល់ជាត្រីវិស័យសម្រាប់ការធ្វើសេចក្តីសម្រេចចិត្តក្នុងក្របខណ្ឌថ្នាក់មូលដ្ឋានថ្នាក់ជាតិ និងថ្នាក់សាកល។ ការរៀបចំសង្គមមួយឱ្យមានការបំភាយកាបូនតិច ការប្រើប្រាស់ធនធានប្រកបដោយប្រសិទ្ធភាព និងចីរភាព គឺជាភាពចាំបាច់សម្រាប់ប្រទេសទាំងអស់ និងទីក្រុងនានារួមទាំង

រាជធានីភ្នំពេញផងដែរ ដើម្បីទទួលបានភាពចម្រុងចម្រើនប្រកបដោយចីរភាពសម្រាប់ប្រជាពលរដ្ឋរបស់ខ្លួន ព្រមទាំងដើរតួនាទីដ៏សំខាន់ក្នុងវិស័យគ្រប់គ្រងសំណល់។

កូនចៅជំនាន់ក្រោយរបស់យើងអាចរីករាយ និងទទួលបានអត្ថប្រយោជន៍ពីបរិស្ថានធម្មជាតិអាស្រ័យលើសមត្ថភាពរបស់យើងទាំងអស់គ្នា រាប់ចាប់ពីបុគ្គលម្នាក់ៗរហូតដល់សង្គមជាតិទាំងមូលតាមរយៈការរៀបចំផ្សេងៗ ដើម្បីផ្លាស់ប្តូររបៀបរបបរស់នៅ ឥរិយាបថ និងប្រព័ន្ធសង្គមរបស់យើង ឈានទៅកាត់បន្ថយបន្ទុកលើបរិស្ថានឱ្យបានជាអតិបរមា។ ដើម្បីសម្រេចគោលដៅនេះ យើងមិនត្រឹមតែពិនិត្យឡើងវិញនូវប្រព័ន្ធគ្រប់គ្រងសំណល់បច្ចុប្បន្នប៉ុណ្ណោះទេ ប៉ុន្តែត្រូវពិនិត្យទាំងខ្សែសង្វាក់នៃតម្លៃធនធានទាំងមូលទៀតផងដែរ។ ចំណុចសំខាន់គឺថា តើប្រព័ន្ធគ្រប់គ្រងសំណល់ប្រកបដោយប្រសិទ្ធភាព និងចីរភាពអាចត្រូវបានបង្កើតឡើងយ៉ាងដូចម្តេច ហើយត្រូវមានអ្នកពាក់ព័ន្ធផ្សេងៗណាខ្លះ ដើម្បីជំរុញសកម្មភាពនានាឆ្លើយតបនឹងបញ្ហាប្រឈមផ្សេងៗ។

ទាក់ទងនឹងបញ្ហានេះ រដ្ឋបាលរាជធានីភ្នំពេញបានធ្វើការជាមួយភាគីពាក់ព័ន្ធ ដើម្បីបង្កើតយុទ្ធសាស្ត្រ និងផែនការសកម្មភាពគ្រប់គ្រងសំណល់ ដោយមានគោលបំណងកំណត់ទិសដៅគ្រប់គ្រងសំរាម សំណល់រឹង និងលើកកម្ពស់ការអភិវឌ្ឍក្របខ័ណ្ឌគោលនយោបាយប្រកបដោយប្រសិទ្ធភាព។ ការរៀបចំនូវយុទ្ធសាស្ត្រគ្រប់គ្រងសំណល់នេះ គឺផ្អែកទៅលើវិធីសាស្ត្រគ្រប់គ្រងសំណល់រួម ដែលស្វែងរកដំណោះស្រាយទៅលើសំណល់គ្រប់ទម្រង់ទាំងអស់ (សំរាម សំណល់រឹង សំណល់រាវ/ទឹកស្អុយ និងការបំភាយឧស្ម័ន) ដោយផ្តោតជាសំខាន់លើសំរាម សំណល់រឹង ប៉ុន្តែក៏គ្របដណ្តប់លើសំណល់ផ្សេងៗទៀតនៅក្នុងអាណត្តិរបស់រដ្ឋបាលរាជធានីភ្នំពេញ។

យុទ្ធសាស្ត្រ និងផែនការសកម្មភាពគ្រប់គ្រងសំណល់សម្រាប់រាជធានីភ្នំពេញឆ្នាំ២០១៨ - ២០៣៥ គឺជាលទ្ធផលដំបូងនៃគំនិតផ្តួចផ្តើមនេះ ហើយជាឯកសារចក្ខុវិស័យ និងជាមគ្គុទេសក៍យុទ្ធសាស្ត្រ ដើម្បីដោះស្រាយបញ្ហាសំខាន់ៗ តម្រូវការ និងបញ្ហាប្រឈមនានា ដែលត្រូវបានផ្សារភ្ជាប់ជាមួយនឹងការងារគ្រប់គ្រងសំណល់ ព្រមទាំងធ្វើការបង្កើនការយល់ដឹងក្នុងចំណោមភាគីពាក់ព័ន្ធសំខាន់ៗ ឆ្ពោះទៅសម្រេចឱ្យក្លាយជារាជធានីប្រកបដោយធនធាន ប្រសិទ្ធភាព និងនិរន្តរភាព។

កម្មវិធី និងវិធីសាស្ត្រនៅក្នុងយុទ្ធសាស្ត្រនេះ មិនត្រឹមតែដើម្បីធ្វើឱ្យប្រសើរឡើងដល់សេវាកម្មគ្រប់គ្រងសំណល់បច្ចុប្បន្នតាំងពីការប្រមូលសំណល់ ការកែច្នៃធ្វើប្រព្រឹត្តកម្ម និងចាក់ចោលនៅទីលានចាក់សំរាមនោះទេ ហើយថែមទាំងធានាឱ្យបាននូវចីរភាពសេវាកម្មគ្រប់គ្រងសំណល់ ដោយធានាឱ្យបាននូវហិរញ្ញវត្ថុ ភាពបង្កើតថ្មី និងបន្តភាពរីកចម្រើនតាមរយៈវដ្តគ្រប់គ្រងប្រកបដោយបរិយាប័ន្ន និងទៀងទាត់ ព្រមទាំងមានការតាមដាន និងត្រួតពិនិត្យឡើងវិញទៅតាមដំណាក់កាល។

## ២. ការកំណត់ទីតាំងនៃយុទ្ធសាស្ត្រ និងផែនការសកម្មភាពគ្រប់គ្រងសំណល់

### ២.១. ភាពស្របទៅនឹងគោលនយោបាយថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ

យុទ្ធសាស្ត្រនេះត្រូវបានរៀបចំទៅតាមតម្រូវការ និងអាទិភាពរបស់រដ្ឋបាលគ្រប់គ្រងសំណល់នៃរាជធានីភ្នំពេញ និងបំពេញទៅនឹងគោលនយោបាយគ្រឹះនៃការអភិវឌ្ឍទីក្រុង ដែលដាក់ចេញជាសាធារណៈនូវផែនការ និងយុទ្ធសាស្ត្រទៅលើវិស័យសំខាន់ៗដែលពាក់ព័ន្ធគ្នាមួយចំនួន។ កិច្ចប្រឹងប្រែងនេះ ត្រូវបានដាក់បញ្ចូលទៅក្នុងកិច្ចព្រមព្រៀងគោលនយោបាយកន្លងមករួមមាននូវ **ចក្ខុវិស័យ គោលដៅ** និង**សកម្មភាព** ដែលត្រូវបានតាក់តែងសម្រាប់គោលនយោបាយប្រព្រឹត្តទៅទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ដើម្បីធានានូវភាពស្របគ្នានៃគោលនយោបាយ និងជាមគ្គុទ្ទេសក៍សម្រាប់ភាគីពាក់ព័ន្ធក្នុងភាពស្ថិតរម្លូត។ ការកំណត់យុទ្ធសាស្ត្រ និងផែនការសកម្មភាពគ្រប់គ្រងសំណល់សម្រាប់រាជធានីភ្នំពេញ ធៀបនឹងឯកសារគោលនយោបាយទាំងនេះ ព្រមទាំងឯកសារផ្សេងៗទៀតរបស់រដ្ឋបាលរាជធានីភ្នំពេញ ត្រូវបានបង្ហាញដូចខាងក្រោម។




*រូបភាពទី១៖ ទីតាំងនៃយុទ្ធសាស្ត្រ និងផែនការសកម្មភាពគ្រប់គ្រងសំណល់សម្រាប់រាជធានីភ្នំពេញ*

## ក្របខណ្ឌគោលនយោបាយថ្នាក់ក្រោមជាតិ

### ប្លង់គោលប្រើប្រាស់ដីធ្លីរាជធានីភ្នំពេញ ឆ្នាំ២០៣៥

ប្លង់គោលអភិវឌ្ឍន៍រាជធានីភ្នំពេញត្រូវបានអនុម័តដោយទីស្តីការគណៈរដ្ឋមន្ត្រីនៅក្នុងឆ្នាំ២០១៥ ដើម្បីធ្វើការគ្រប់គ្រងការអភិវឌ្ឍនៅក្នុងរាជធានីភ្នំពេញក្នុងរយៈពេល២០ឆ្នាំ។ ប្លង់គោលឆ្នាំ២០៣៥ បានលើកឡើងនូវកំណើនប្រជាពលរដ្ឋយ៉ាងឆាប់រហ័សនៅក្នុងទីក្រុង ដែលអាចនឹងលើស ៣លាននាក់ នៅត្រឹមឆ្នាំ២០២០ ដែលមានចក្ខុវិស័យកសាងរាជធានីនេះឱ្យក្លាយជា "មជ្ឈមណ្ឌលនយោបាយ សេដ្ឋកិច្ចពាណិជ្ជកម្ម វប្បធម៌ ប្រកបដោយសក្តានុពលប្រកួតប្រជែង ជាមួយការអភិវឌ្ឍមួយប្រកបដោយវឌ្ឍនភាព សមធម៌ និងចីរភាព ត្រឹមបំណាច់ឆ្នាំ២០៣៥"។

ចក្ខុវិស័យនៃប្លង់គោលប្រើប្រាស់ដីរាជធានីភ្នំពេញឆ្នាំ២០៣៥ មានគោលដៅសំខាន់ៗចំនួន៣៖

១. តម្រង់ទិសការប្រើប្រាស់ដីធ្លី និងធានាតម្លៃសក្តានុពលដែលមានស្រាប់របស់ទីក្រុងប្រកបដោយប្រសិទ្ធភាពខ្ពស់ ចីរភាព និងសមធម៌ ដើម្បីគាំទ្រដល់ការអភិវឌ្ឍសេដ្ឋកិច្ច សង្គមកិច្ច ការធានាសន្តិសុខស្បៀង សោភ័ណភាព និងគុណភាពបរិស្ថាន

២. តម្រង់ទិសអភិវឌ្ឍដោយតុល្យភាព សមភាព និងភាពស៊ីចង្វាក់គ្នា រវាងរាជធានីភ្នំពេញ ទីក្រុងតូចបន្ទាប់ ខេត្តរបស់ប្រទេស និងទីក្រុងរបស់ប្រទេសនានា

៣. ធានាការលើកស្ទួយអត្តសញ្ញាណរាជធានីភ្នំពេញ ដើម្បីឆ្ពោះទៅសមាហរណកម្មទៅក្នុងតំបន់ និងប្រកួតប្រជែងជាមួយទីក្រុងនានានៅក្នុងតំបន់ សម្រាប់ការអភិវឌ្ឍនៅក្នុងបរិបទដែលផ្តល់នូវលទ្ធភាពធំជាងពេលមុន ទាំងលើផ្នែកបច្ចេកទេស និងផ្នែកហិរញ្ញវត្ថុ។

ប្លង់គោលនេះ ក៏បានដាក់ចេញនូវយុទ្ធសាស្ត្រតម្រង់ទិសចំនួន៥ធំៗ សម្រាប់ការងារអភិវឌ្ឍន៍ ការធ្វើឱ្យប្រសើរឡើង និងការពង្រីករាជធានីភ្នំពេញក្នុងកិច្ចឆ្លើយតបទៅនឹងតម្រូវការនៃកំណើនប្រជាពលរដ្ឋ និងបញ្ហាប្រឈមនានា៖

- រាជធានីភ្នំពេញត្រូវក្លាយជាមជ្ឈមណ្ឌលស្នូលសម្រាប់ការអភិវឌ្ឍ
- រាជធានីភ្នំពេញត្រូវក្លាយជាទីក្រុងស្តង់ដារអន្តរជាតិ
- ការបង្កើតធនបម្រុងសម្រាប់ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្តចាំបាច់
- ការរៀបចំក្រុង ដើម្បីឱ្យភ្នំពេញក្លាយជារាជធានីមេត្រូប៉ូលីតែន
- ការរៀបចំតំបន់បេតិកភណ្ឌវប្បធម៌ និងទេសភាពរាជធានី

## ផែនការយុទ្ធសាស្ត្រឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុសម្រាប់រាជធានីភ្នំពេញ

ផែនការសកម្មភាពនេះត្រូវបានរៀបចំ និងបោះពុម្ពនៅក្នុង ខែកក្កដា ឆ្នាំ២០១៧ ជាលទ្ធផលនៃកិច្ចសហការបច្ចេកទេសរវាងរាជធានីភ្នំពេញ និងទីក្រុងបងប្អូន Kitakyushu នៃប្រទេសជប៉ុនទៅលើបញ្ហាប្រឈមបរិស្ថាន ហើយត្រូវបានរំពឹងទុកថានឹងអនុវត្តនូវ "ផែនការយុទ្ធសាស្ត្រឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុនៃប្រទេសកម្ពុជាឆ្នាំ២០១៤-២០២៣" រៀបចំដោយរាជរដ្ឋាភិបាលកម្ពុជាកាលពីខែធ្នូ ឆ្នាំ២០១៣។ ខណៈគោលនយោបាយតំរង់ទិសដៅទូទៅផ្តោតលើវិស័យចំនួន ៦ គឺ សំណល់ ថាមពល ការដឹកជញ្ជូន ប្រព័ន្ធចែកចាយទឹក/ សំណល់រាវ/ ប្រព័ន្ធរំដោះទឹកភ្លៀង ការអភិរក្សបរិស្ថាន និងផលិតកម្មបៃតង ផែនការសកម្មភាពនេះក៏បានរៀបចំនូវវិធានការជាក់លាក់ទៅតាមវិស័យនីមួយៗ ដោយលើកឡើងនូវបញ្ហាបរិស្ថានដែលបណ្តាលឱ្យមានបម្រែបម្រួលអាកាសធាតុ ដែលជាភាពប្រឈមរបស់រាជធានីភ្នំពេញ។

ពាក់ព័ន្ធនឹងវិស័យសំណល់ ឯកសារនេះបានស្នើនូវសកម្មភាពចម្បងមួយចំនួនឆ្ពោះទៅរកការបង្កើតសង្គម/សេដ្ឋកិច្ចចក្រា ដែលត្រូវពង្រឹងការប្រមូលសំណល់ និងការប្រព្រឹត្តកម្មសំណល់ ដែលអាចការពារហេតុប៉ះពាល់ផ្សេងៗពីសំណល់ និងផ្តល់នូវផែនការមេស្តីពី ការគ្រប់គ្រងសំណល់ និងផ្តល់ជាមូលដ្ឋានសម្រាប់ការបង្កើតយុទ្ធសាស្ត្រ និងផែនការសកម្មភាពនេះ។

## ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ទីក្រុងបៃតងសម្រាប់រាជធានីភ្នំពេញ ឆ្នាំ២០១៧-២០២៦

ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ទីក្រុងបៃតងសម្រាប់រាជធានីភ្នំពេញ គឺជាលទ្ធផលនៃកិច្ចខិតខំប្រឹងប្រែងរួមគ្នាមួយរបស់រដ្ឋបាលរាជធានីភ្នំពេញ(PPCA) ក្រុមប្រឹក្សាជាតិសម្រាប់ការអភិវឌ្ឍប្រកបដោយនិរន្តរភាព(NCSD) និងវិទ្យាស្ថាន GGGI និងផ្តល់នូវគោលនយោបាយតម្រង់ទិសសំខាន់ៗ សម្រាប់សមាសភាគវិស័យទាំង៨នៃការរៀបចំផែនការអភិវឌ្ឍទីក្រុងបៃតង ដោយផ្តោតទៅលើការរៀបចំផែនការអភិវឌ្ឍទីក្រុង ភាពងាយរងគ្រោះរបស់ទីក្រុង វិស័យថាមពល វិស័យការដឹកជញ្ជូន វិស័យបរិស្ថាន សំណង់ វិស័យកម្មន្តសាល ការគ្រប់គ្រងសំណល់រឹង និងវិស័យទីធ្លាសាធារណៈ និងបេតិកភណ្ឌវប្បធម៌។ យុទ្ធសាស្ត្រនេះបំពេញបន្ថែមផែនការប្លង់គោលរបស់រាជធានីភ្នំពេញស្តីពីការប្រើប្រាស់ដីធ្លីឆ្នាំ២០៣៥ ដែលចាត់ទុកទីក្រុងជា "មជ្ឈមណ្ឌលនយោបាយ សេដ្ឋកិច្ច ពាណិជ្ជកម្ម វប្បធម៌ ប្រកបដោយសក្តានុពលប្រកួតប្រជែង ជាមួយការអភិវឌ្ឍមួយប្រកបដោយវឌ្ឍនភាព សមធម៌ និងចីរភាព"។

នៅក្នុងវិស័យនៃគ្រប់គ្រងសំណល់ យុទ្ធសាស្ត្រនេះបានដាក់ចេញនូវសកម្មភាពជាអាទិភាពទៅតាមគោលបំណងនៃការគ្រប់គ្រងសំណល់រឹងចំនួន៤ ដូចខាងក្រោម៖

១. ពង្រីកសេវាប្រមូល និងគ្រប់គ្រងសំណល់រឹងប្រកបដោយគុណភាព

២. កាត់បន្ថយបរិមាណសំណល់ជីវៈទៅកាន់ទីលានសំរាម ឬឡដុតសំរាម

៣. ការញែកសំណល់រឹង ដែលអាចកែច្នៃឡើងវិញនៅតាមផ្ទះគ្រួសារ ទីផ្សារ និងសហគ្រាសពាណិជ្ជកម្ម

៤. ការអនុវត្តន៍គោលការណ៍ ៤អ៊ែរ (កាត់បន្ថយ ប្រើប្រាស់ឡើងវិញ ជួសជុល និងកែច្នៃឡើងវិញ)

## ក្របខណ្ឌគោលនយោបាយថ្នាក់ជាតិ

### យុទ្ធសាស្ត្រជាតិ និងផែនការសកម្មភាពថ្នាក់ជាតិ នៃការគ្រប់គ្រងសំណល់រឹង ក្នុងព្រះរាជាណាចក្រកម្ពុជា

នៅឆ្នាំ២០១៦ ក្រសួងបរិស្ថាន (MoE) ដោយមានការឧបត្ថម្ភពីអង្គការ UN Environment និងវិទ្យាស្ថាន IGES តាមរយៈមជ្ឈមណ្ឌល CCET ជាមួយនឹងអង្គការ UNEP បានផ្តួចផ្តើមគម្រោងរៀបចំយុទ្ធសាស្ត្រជាតិ និងផែនការសកម្មភាពថ្នាក់ជាតិស្តីពីគ្រប់គ្រងសំរាមសំណល់រឹង ដែលនឹងផ្តល់នូវក្របខណ្ឌគោលនយោបាយជាតិ សម្រាប់ពន្លឿនការអនុវត្តន៍ការគ្រប់គ្រងសំណល់នៅទូទាំងប្រទេស។ ឯកសារនេះកំពុងត្រូវបានព្រាងដោយក្រសួងបរិស្ថាន (កំពុងពង្រាងចុងក្រោយកាលពី ខែឧសភា ឆ្នាំ២០១៨) ហើយត្រូវបានគេរំពឹងថានឹងចាប់ផ្តើមនៅក្នុងឆ្នាំ២០១៩ ដោយផ្តល់ការណែនាំសម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិយកទៅអនុវត្តតាម។ គោលការណ៍ស្នូលនៃយុទ្ធសាស្ត្រនេះត្រូវបានពន្យល់នៅក្នុងរូបភាពទី២។

| | |
|---|---|
| **ចក្ខុវិស័យ** | ព្រះរាជាណាចក្រកម្ពុជានឹងក្លាយទៅជាប្រទេសដែលមានទីក្រុងស្អាត និងមានសោភ័ណភាព ទន្ទឹមនឹងការរីកចម្រើននៃសុខភាពសាធារណៈ សន្តិសុខសង្គម និងគុណភាពបរិស្ថាន នៅក្នុងឆ្នាំ២០៣០ |
| **បេសកកម្ម** | • លើកកម្ពស់ការកែច្នៃធនធានពីសំណល់ តាមរយៈការញែកសំណល់តាមប្រភេទនីមួយៗ និងជំរុញបន្ថែមលើការប្រើប្រាស់ផលិតផលដែលកែច្នៃពីសំណល់<br>• ធ្វើឱ្យប្រសើរ និងពង្រីកសេវាកម្មប្រមូលសំណល់ទៅតាមប្រភេទសំណល់នីមួយៗ ដែលបានញែក<br>• រៀបចំនូវហេដ្ឋារចនាសម្ព័ន្ធផ្សេងៗក្នុងការចាក់ចោលសំណល់ និងធ្វើឱ្យទីលានចាក់ចោលសំរាមបច្ចុប្បន្នប្រសើរឡើង តាមរយៈការគ្រប់គ្រងសំរាមចាក់ចោលប្រកបដោយចីរភាពបរិស្ថាន |
| **គោលដៅថ្នាក់ជាតិ** | អភិវឌ្ឍន៍ឱ្យមានការគ្រប់គ្រងសំណល់មួយដែលគិតគូរទៅដល់បរិស្ថាន ធានាបាននូវតុល្យភាពរវាងការអភិវឌ្ឍសេដ្ឋកិច្ច និងគាំពារបរិស្ថាន |
| **គោលបំណង ក:** | ធ្វើឱ្យប្រសើរឡើងនូវការប្រមូលសំណល់គ្របដណ្តប់ទូទាំងទីប្រជុំជន និងកាត់បន្ថយបរិមាណសំណល់ចាក់ចោលនៅទីលានចាក់សំរាមឱ្យនៅកម្រិតអប្បបរមា តាមរយៈការលើកកម្ពស់ការងារញែកសំណល់នៅនឹងប្រភពនូវសំណល់ជីវៈ និងសំណល់ប្លាស្ទិក ដើម្បីអាចធ្វើការកែច្នៃបាន |
| **គោលបំណង ខ:** | ចិញ្ចឹមបីបាច់វិស័យជំនួញឯកជនពាក់ព័ន្ធនឹងការកែច្នៃ ដោយធ្វើការលើកកម្ពស់ការកែច្នៃសំណល់សម្រាប់ការគ្រប់គ្រងសំណល់ប្រកបដោយចីរភាព និងការអភិវឌ្ឍសេដ្ឋកិច្ច |
| **គោលបំណង គ:** | លើកកម្ពស់កិច្ចការពារការបំពុលទឹក និងខ្យល់ឱ្យកាន់តែប្រសើរឡើង តាមរយៈការបង្កើតឡើងនូវការគ្រប់គ្រងសំណល់ដ៏ល្អមួយ |
| **គោលបំណង ឃ:** | ធ្វើឱ្យប្រសើរឡើងនូវវិធីសាស្ត្រប្រមូល និងប៉ាន់ស្មានទិន្នន័យ នៃការគ្រប់គ្រងសំណល់សម្រាប់ការត្រួតពិនិត្យ តាមដាន និងវាយតម្លៃលើការងារគ្រប់គ្រងសំណល់ |

**រូបភាពទី២៖ ទិដ្ឋភាពយុទ្ធសាស្ត្រជាតិ និងផែនការសកម្មភាពនៃការគ្រប់គ្រងសំណល់រឹង ឆ្នាំ២០១៨-២០៣០**

ប្រភព៖ កែសម្រួលពីក្រុមការងារនៃក្រសួងបរិស្ថានឆ្នាំ២០១៨

## ផែនការយុទ្ធសាស្ត្រឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុកម្ពុជា ឆ្នាំ២០១៤-២០២៣

នៅថ្នាក់ជាតិ យុទ្ធសាស្ត្រគ្រប់គ្រងសំណល់រឹងនេះ គឺស្របតាមចក្ខុវិស័យ ដើម្បីសម្រេចឱ្យបាននូវការអភិវឌ្ឍអាកាសធាតុបៃតងឆ្លាតវៃ ដែលត្រូវបានជំរុញនៅក្នុងដោយ CCCSP ឆ្នាំ២០១៤-២០២៣។

យុទ្ធសាស្ត្រនេះ នឹងបង្ហាញពីបញ្ហាប្រឈមសំខាន់ៗ និងលើកកម្ពស់ផែនការបំភាយកាបូនតិច និងបច្ចេកវិទ្យាផ្សេងៗ ដើម្បីគាំទ្រការអភិវឌ្ឍប្រកបដោយនិរន្តរភាព ដែលនឹងជួយបំពេញគោលបំណងទី១ នៃយុទ្ធសាស្ត្រ "លើកកម្ពស់ភាពធន់ទ្រាំនឹងអាកាសធាតុតាមរយៈការកែលម្អសន្តិសុខស្បៀង និងថាមពល" របស់ CCCSP ឆ្នាំ២០១៤-២០២៣។ ការវិភាគអំពីការកាត់បន្ថយការបំភាយ និងសក្តានុពលនៃអន្តរាគមន៍ក្នុងការកាត់បន្ថយ ដែលបានដាក់បញ្ចូលនៅក្នុងយុទ្ធសាស្ត្រនេះនឹងឆ្លើយតបទៅនឹងគោលដៅយុទ្ធសាស្ត្រទី៤ "លើកកម្ពស់ការធ្វើផែនការ និងបច្ចេកវិទ្យាដោយបញ្ចេញកាបូនតិច ដើម្បីគាំទ្រការអភិវឌ្ឍប្រកបដោយនិរន្តរភាព" ដោយផ្តល់នូវការវិភាគតាមវិស័យស្តីពីជម្រើសនៃការបញ្ចេញកាបូនតិច និងប្រភពនៃការបញ្ចេញកាបូនក្នុងការគ្រប់គ្រងសំណល់ រួមចំណែកដល់គោលនយោបាយអភិវឌ្ឍន៍ដោយបញ្ចេញកាបូនតិច ក្របខណ្ឌច្បាប់ និងផែនការសកម្មភាពស្របតាមទិសដៅអាទិភាព នៃការអភិវឌ្ឍថ្នាក់ជាតិ។ លើកកម្ពស់ការផ្ទេរបច្ចេកវិទ្យាសមស្របសម្រាប់ការអភិវឌ្ឍកាបូនតិច ដែលសម្របសម្រួលការសាយភាយតាមរយៈយន្តការទីផ្សារកាបូន និងលើកកម្ពស់ផែនការអភិវឌ្ឍន៍ទីក្រុងដោយបញ្ចេញកាបូនតិច និងអភិវឌ្ឍយន្តការសម្របសម្រួលថ្នាក់ក្រោមជាតិ។

## ២.២. ភាពស្របទៅនឹងគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព

ការគ្រប់គ្រងសំណល់ ជាសេវាសាធារណៈដែលមិនអាចខ្វះបានទាក់ទងនឹងការរស់នៅ ហើយភាពធ្វើឱ្យប្រសើរឡើងត្រូវបានរំលេចនៅក្នុងយុទ្ធសាស្ត្រ និងផែនការសកម្មភាពនេះ ដែលនឹងនាំមកនូវផលប្រយោជន៍រួមជាច្រើនដល់គោលដៅ និងទិសដៅនៃការអភិវឌ្ឍប្រកបដោយចីរភាព ព្រមទាំងគោលដៅគ្រប់គ្រងសំណល់ជាសាកល។ តារាងខាងក្រោម បង្ហាញពីសារៈសំខាន់នៃយុទ្ធសាស្ត្រគ្រប់គ្រងសំណល់នេះក្នុងការសម្រេចគោលដៅសាកល និងវិធីសាស្ត្រដែលរដ្ឋបាលរាជធានីភ្នំពេញ មានបំណងចាត់វិធានការឱ្យបានល្អប្រសើរឆ្ពោះទៅរកការអភិវឌ្ឍប្រកបដោយចីរភាព តាមរយៈវិស័យគ្រប់គ្រងសំណល់។

SUSTAINABLE DEVELOPMENT GOALS

**តារាងទី១៖ គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព និងសកម្មភាពចម្បងពាក់ព័ន្ធនៅក្នុងយុទ្ធសាស្ត្រនេះ**

| គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព | | សកម្មភាពចម្បងនៃយុទ្ធសាស្ត្រ ដែលពាក់ព័ន្ធ |
|---|---|---|
| 1 NO POVERTY | **គោលដៅទី១៖** បញ្ចប់ភាពក្រីក្រគ្រប់ទម្រង់នៅគ្រប់ទីកន្លែង | ការដាក់បញ្ចូលក្រុមអ្នករើសសំណល់អេតចាយ និងទទួលស្គាល់តួនាទីរបស់ពួកគេជាផ្លូវការ នៅក្នុងប្រព័ន្ធគ្រប់គ្រងសំណល់ (សកម្មភាពចម្បងទី៣) |
| 2 ZERO HUNGER | **គោលដៅទី២៖** បញ្ចប់ភាពអត់ឃ្លាន និងសម្រេចឱ្យបានសន្តិសុខស្បៀង ធ្វើឱ្យប្រសើរឡើងស្ថានភាពអាហារូបត្ថម្ភ និងលើកកម្ពស់កសិកម្មប្រកបដោយចីរភាព | ការគ្រប់គ្រងការខាតបង់សំណល់ចំណីអាហារតាមរយៈការជំរុញការកាត់បន្ថយសំណល់នៅប្រភព (សកម្មភាពចម្បងទី១ និងទី៥) |
| 3 GOOD HEALTH AND WELL-BEING | **គោលដៅទី៣៖** ធានាឱ្យជីវភាពរស់នៅរបស់ប្រជាជនប្រកបដោយសុខភាពល្អ និងលើកកម្ពស់សុខមាលភាពរបស់មនុស្សគ្រប់រូប និងគ្រប់វ័យ | ឈានសម្រេចឱ្យបានពេញលេញ និងត្រឹមត្រូវនូវការប្រមូលសំណល់ ការដឹកជញ្ជូន ប្រព្រឹត្តកម្ម និងចាក់ចោលសំណល់គ្រប់ប្រភេទទាំងអស់ (សកម្មភាពចម្បង ទី១ ទី២ ទី៣ និងទី៤) |

| គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព | សកម្មភាពចម្បងនៃយុទ្ធសាស្ត្រ ដែលពាក់ព័ន្ធ |
|---|---|
| **គោលដៅទី៤៖** ធានាការអប់រំប្រកបដោយគុណភាព បរិយាប័ន្ន និងសមធម៌ និងលើកកម្ពស់កាលានុវត្តភាពសិក្សាពេញមួយជីវិត | ការអប់រំបរិស្ថានមានលក្ខណៈទំនើបនៅតាមសាលារៀន និងកន្លែងផ្សេងទៀត (សកម្មភាពចម្បងទី៥) |
| **គោលដៅទី៦៖** ធានាឱ្យមានទឹក និងអនាម័យ និងការគ្រប់គ្រងប្រកបដោយចីរភាព | ចាប់ផ្តើមរៀបចំប្រព័ន្ធប្រព្រឹត្តកម្មទឹកសំអុយនៅទីលានចាក់សំរាម (សកម្មភាពចម្បងទី៣)<br>ទប់ស្កាត់ការហូរចូលនៃសំណល់រឹងទីក្រុងទៅក្នុងផ្ទៃទឹក (សកម្មភាពចម្បងទី១ ទី៤ និងទី៥) |
| **គោលដៅទី៧៖** ធានាឱ្យទទួលបានថាមពល ដែលមានបច្ចេកវិទ្យាទំនើប ប្រកបដោយចីរភាព អាចជឿជាក់បាន និងមានតម្លៃសមរម្យសម្រាប់ប្រជាជនគ្រប់រូប | ជំរុញដំណោះស្រាយថាមពលកែច្នៃពីសំណល់ មានតម្លៃសមរម្យ ជាប្រភពថាមពលស្អាត/កកើតឡើងវិញ (សកម្មភាពចម្បងទី១ ទី២ និងទី៣) |
| **គោលដៅទី៨៖** ធានាកំណើនសេដ្ឋកិច្ចប្រកបដោយចីរភាព និងបរិយាប័ន្ន មានមុខរបរពេញលេញនិងផលិតភាព និងមានការងារសមរម្យសម្រាប់ប្រជាជនគ្រប់រូប | ឧស្សាហកម្មសំណល់/ កែច្នៃប្រកបដោយបច្ចេកវិទ្យាទំនើប ជាវិស័យមួយត្រូវបានផ្តោតសម្រាប់ការអភិវឌ្ឍបៃតង (សកម្មភាពចម្បងទី២)<br>ការរៀបចំបរិយាកាសការងារល្អ សម្រាប់ក្រុមកម្មករធ្វើការនៅក្នុងវិស័យសំណល់ (សកម្មភាពចម្បងទី៣) |
| **គោលដៅទី១០៖** កាត់បន្ថយវិសមភាពក្នុងប្រទេស និងក្នុងចំណោមបណ្តាប្រទេសនានា | |
| **គោលដៅទី១១៖** ធ្វើឱ្យទីក្រុង និងកន្លែងតាំងទីលំនៅថ្មីសម្រាប់ប្រជាពលរដ្ឋមានលក្ខណៈបរិយាប័ន្ន សុវត្ថិភាព ធន់នឹងបម្រែបម្រួលអាកាសធាតុ និងប្រកបដោយចីរភាព | បង្កើតឱ្យមានប្រព័ន្ធគ្រប់គ្រងសំណល់ប្រកបដោយគុណភាពបរិស្ថាន និងទាញយកផលចំណេញសេដ្ឋកិច្ចពីវដ្តនៃការកែច្នៃសំណល់-វត្ថុធាតុដើម (សកម្មភាពចម្បងទី១ ទី២ ទី៣ ទី៤ និងទី៥) |
| **គោលដៅទី១២៖** ធានាឱ្យមានចីរភាពក្នុងទម្រង់នៃការប្រើប្រាស់ និងផលិតកម្ម | ជំរុញការអនុវត្តន៍គោលការណ៍ ៣អ៊ែរ (សកម្មភាពចម្បងទី១ ទី២ ទី៤ និងទី៥) |
| **គោលដៅទី១៣៖** ចាត់វិធានការជាបន្ទាន់ ដើម្បីប្រយុទ្ធប្រឆាំងនឹងបម្រែបម្រួលអាកាសធាតុ និងផលប៉ះពាល់របស់វា | ជំរុញការអនុវត្តន៍គោលការណ៍ ៣អ៊ែរ (សកម្មភាពចម្បងទី១ ទី២ ទី៤ និងទី៥)<br>កាត់បន្ថយការចាក់ចោលសំណល់ជីវៈទៅទីលានចាក់សំរាម និងធ្វើការគ្រប់គ្រងការបំភាយឧស្ម័នផ្ទះកញ្ចក់/ ឧស្ម័នបំពុលបរិយាកាសអាយុកាលខ្លីពីទីលានចាក់សំរាម (សកម្មភាពចម្បងទី១ ទី២ និងទី៣)<br>ធ្វើការប្រយុទ្ធប្រឆាំងនឹងការចាក់ចោល និងដុត |

| គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព | | សកម្មភាពចម្បងនៃយុទ្ធសាស្ត្រ ដែលពាក់ព័ន្ធ |
|---|---|---|
| | | សំរាមដោយគ្មានសណ្តាប់ធ្នាប់ (សកម្មភាពចម្បងទី១ ទី៣ ទី៤ និងទី៥) |
| | **គោលដៅទី១៤៖** អភិរក្ស និងប្រើប្រាស់ប្រកបដោយចីរភាពនូវមហាសមុទ្រ សមុទ្រ និងធនធានសមុទ្រសម្រាប់ការអភិវឌ្ឍប្រកបដោយចីរភាព | ធ្វើការប្រយុទ្ធប្រឆាំងនឹងការបោះចោលសំរាមចូលទៅក្នុងប្រភពទឹក តាមរយៈការពង្រឹងប្រព័ន្ធគ្រប់គ្រងសំណល់លើផ្ទៃគោក (សកម្មភាពចម្បងទី១ ទី២ ទី៤ និងទី៥) |
| | **គោលដៅទី១៥៖** ការពារ ស្តារ និងជំរុញការប្រើប្រាស់ប្រកបដោយចីរភាពនូវប្រព័ន្ធអេកូឡូស៊ីនៅលើដែនគោក គ្រប់គ្រងព្រៃឈើប្រកបដោយនិរន្តរភាព ប្រយុទ្ធប្រឆាំងនឹងឱនភាពដី បញ្ឈប់ និងបង្វែរទិសនៃការសឹករេចរិលគុណភាពដី និងបញ្ឈប់កុំឱ្យបាត់បង់ជីវៈចម្រុះ | ធ្វើការប្រយុទ្ធប្រឆាំងនឹងការបំពុលដី ដោយសារការចាក់ចោលសំណល់មិនបានត្រឹមត្រូវ (សកម្មភាពចម្បងទី១ ទី៣ និងទី៤)។ |
| | **គោលដៅទី១៧៖** ពង្រឹងមធ្យោបាយអនុវត្តនានា និងបង្កើតភាពរស់រវើកនៃភាពជាដៃគូសាកលសម្រាប់ការអភិវឌ្ឍប្រកបដោយចីរភាព។ | ចែករំលែកនូវយុទ្ធសាស្ត្រ សំដៅឆ្ពោះទីរៀបចំសកម្មភាពរួមគ្នា និងធានាឱ្យបាននូវការអនុវត្តន៍ព្រមទាំងគុណភាពសេវាកម្ម (សកម្មភាពចម្បងទី៥ ជំពូកទី៥)។ |

## ២.៣. ដំណើរការនៃការរៀបចំយុទ្ធសាស្ត្រ

យុទ្ធសាស្ត្រ និងផែនការសកម្មភាពគ្រប់គ្រងសំណល់សម្រាប់រាជធានីភ្នំពេញឆ្នាំ២០១៨-២០៣៥ គឺជាសមិទ្ធផលនៃកិច្ចសហការរវាងរដ្ឋបាលរាជធានីភ្នំពេញ អង្គការ UN Environment កម្មវិធីសម្ព័ន្ធភាព CCCA វិទ្យាស្ថាន CCET និងអង្គការ Nexus ហើយត្រូវបានបង្កើតឡើងតាមរយៈដំណើរការអភិវឌ្ឍដោយការចូលរួមរយៈពេល២ឆ្នាំ។ ដំណើរការពិគ្រោះយោបល់ត្រូវបានរៀបចំឡើងរួមមាន ការរៀបចំសិក្ខាសាលារៀបចំយុទ្ធសាស្ត្រ (SFW) ធំៗចំនួន២លើក ក្នុងគោលបំណង ដើម្បីឯកភាពគ្នាកំណត់នូវគោលបំណង និងទិសដៅនៃយុទ្ធសាស្ត្រ ដែលអាចធ្វើបានដើម្បីលើកកម្ពស់នូវបរិយាប័ន្ននៃដំណើរការរៀបចំនេះ ហើយក៏មានការរៀបចំកិច្ចប្រជុំក្រុមការងារបច្ចេកទេស (TWG) ដែលបានចូលរួមដោយអ្នកជំនាញបច្ចេកទេស និងភាគីពាក់ព័ន្ធដើម្បីពិភាក្សាស៊ីជម្រៅបន្ថែមធ្វើឱ្យប្រសើរឡើងនូវភាពស្របច្បាប់ និងប្រសិទ្ធភាពនៃសមិទ្ធិផលយុទ្ធសាស្ត្រនេះ។

នៅឆ្នាំ២០១៦ សិក្ខាសាលាដំបូងត្រូវបានសហការរៀបចំដោយរដ្ឋបាលរាជធានីភ្នំពេញ វិទ្យាស្ថាន IGES និងអង្គការ Nexus ដើម្បីចាប់ផ្តើមគម្រោងរៀបចំយុទ្ធសាស្ត្រនេះ បន្ទាប់មកក៏មានចុះអនុស្សរណៈនៃការយោគយល់គ្នារវាងភាគីទាំងបីដើម្បីធ្វើកិច្ចសហប្រតិបត្តិការជាផ្លូវការ។

នៅឯសិក្ខាសាលាដំបូងនៃគម្រោង (Inception WS) មានការបង្ហាញនូវទិន្នន័យមូលដ្ឋានពីសំណល់ (ទិដ្ឋភាពរូប) និងការគ្រប់គ្រងសំណល់ជាទូទៅ (ទិដ្ឋភាពអភិបាលកិច្ច) ដែលបានចងក្រងដោយភាគីពាក់ព័ន្ធនានា ហើយត្រូវបានបង្ហាញនៅក្នុងសិក្ខាសាលា ដើម្បីទទួលបាននូវការយល់ដឹងរួមគ្នា ស្តីពីស្ថានភាពបច្ចុប្បន្ននៃបញ្ហាប្រឈមក្នុងការគ្រប់គ្រងសំរាម សំណល់រឹងក្នុងរាជធានីភ្នំពេញ។ បន្ទាប់មកទៀតក៏មានការរៀបចំនូវកិច្ចប្រជុំក្រុមការងារចំនួនពីរលើកផងដែរ ដើម្បីប្រមូលព័ត៌មានបន្ថែមស្តីពីបញ្ហាប្រឈមនៃការគ្រប់គ្រងសំណល់ ដែលភាគីពាក់ព័ន្ធបានជួបប្រទះ។

សិក្ខាសាលារៀបចំយុទ្ធសាស្ត្រ (SFW) លើកទី១ ត្រូវបានរៀបចំឡើងនៅខែមីនា ឆ្នាំ២០១៧ ដើម្បីពិភាក្សាគ្នា និងយល់ស្របលើចក្ខុវិស័យ បេសកកម្ម គោលដៅ និងសកម្មភាពចម្បងសំខាន់ៗចំនួនប្រាំ ដើម្បីសម្រេចឱ្យបាននូវចក្ខុវិស័យ បេសកកម្ម និងគោលដៅដែលបានកំណត់។ លើសពីនេះទៀត ក៏បានរៀបចំនូវកិច្ចប្រជុំក្រុមការងារបច្ចេកទេសចំនួន ៤លើក ព្រមទាំងធ្វើបទសម្ភាសន៍ប្រឹក្សាយោបល់រៀបចំឡើងនៅចន្លោះខែឧសភា និងខែវិច្ឆិកា ឆ្នាំ២០១៧ ដើម្បីពិភាក្សាពីសកម្មភាពចម្បងជាក់លាក់នៃខ្សែសង្វាក់គ្រប់គ្រងសំណល់ (ការដឹកជញ្ជូន និងការចាក់ចោលសំរាម សំណល់រឹង) និងបំភ្លឺពីឧបសគ្គនៃការអនុវត្តន៍។

## តារាងទី២៖ ដំណើរការកិច្ចប្រជុំពិគ្រោះយោបល់សម្រាប់ការរៀបចំយុទ្ធសាស្ត្រ និងផែនការសកម្មភាព

| | | |
|---|---|---|
| សិក្ខាសាលាលើកដំបូង | ខែតុលា ឆ្នាំ២០១៦ | របាយការណ៍សិក្សាមូលដ្ឋានទិន្នន័យ ការកំណត់អត្តសញ្ញាណចន្លោះប្រហោង និងកិច្ចឯកភាពទៅលើទិសដៅទូទៅ |
| កិច្ចប្រជុំក្រុមការងារលើកទី១ | ខែធ្នូ ឆ្នាំ២០១៦ | ការបញ្ចេញសំណល់ ការប្រមូលសំណល់ និងការប្រឈមទូទៅ (នៅរដ្ឋបាលរាជធានីភ្នំពេញ) |
| កិច្ចប្រជុំក្រុមការងារលើកទី២ | ខែកុម្ភៈ ឆ្នាំ២០១៧ | ដំណោះស្រាយ និងទិសដៅសម្រាប់ការបញ្ចេញសំរាម ការប្រមូល និងបញ្ហាប្រឈមទូទៅ (នៅរដ្ឋបាលរាជធានីភ្នំពេញ) |
| សិក្ខាសាលាយុទ្ធសាស្ត្រលើកទី១ | ខែមេសា ឆ្នាំ២០១៧ | កិច្ចព្រមព្រៀងទៅលើទម្រង់នៃយុទ្ធសាស្ត្រ សកម្មភាពចម្បងៗ និងពិភាក្សាស្តីពីពង្រាងយុទ្ធសាស្ត្រលើកទី១ |
| កិច្ចប្រជុំក្រុមការងារលើកទី៣ | ខែឧសភា ឆ្នាំ២០១៧ | ការប្រមូល និងដឹកជញ្ជូនសំណល់ (នៅក្រសួងបរិស្ថាន) |
| កិច្ចប្រជុំក្រុមការងារលើកទី៤ | ខែឧសភា ឆ្នាំ២០១៧ | ការគ្រប់គ្រងទីលានចាក់សំរាម (នៅរដ្ឋបាលរាជធានីភ្នំពេញ) |
| កិច្ចប្រជុំក្រុមការងារលើកទី៥ | ខែតុលា ឆ្នាំ២០១៧ | ការប្រមូល និងដឹកជញ្ជូនសំណល់ (ក្រុមហ៊ុនប្រមូលសំរាមស៊ីនទ្រី) |
| កិច្ចប្រជុំក្រុមការងារលើកទី៦ | ខែវិច្ឆិកា ឆ្នាំ២០១៧ | កិច្ចពិភាក្សាលើសេចក្តីព្រាងយុទ្ធសាស្ត្រលើកទី១ (នៅរដ្ឋបាលរាជធានីភ្នំពេញ រដ្ឋបាលខណ្ឌ) |
| សិក្ខាសាលាលើកចុងក្រោយ | ខែមករា ឆ្នាំ២០១៨ | ពិភាក្សា ពិនិត្យឡើងវិញ និងឯកភាព លើសេចក្តីព្រាងយុទ្ធសាស្ត្រ និងផែនការសកម្មភាពគ្រប់គ្រងសំណល់ |

សេចក្តីព្រាងយុទ្ធសាស្ត្រ និងផែនការសកម្មភាពនេះ ត្រូវបានកែលម្អថែមទៀត ដោយក្រុមអ្នកពង្រាងបញ្ចូលនូវធាតុចូលតាមរយៈសិក្ខាសាលារៀបចំយុទ្ធសាស្ត្រលើកចុងក្រោយ និងការពិគ្រោះយោបល់បន្ថែមជាមួយរដ្ឋបាលរាជធានីភ្នំពេញ ហើយត្រូវបានបញ្ចប់កាលពីខែមិថុនា ឆ្នាំ២០១៨។









រូបភាពទី៣៖ ពិធីចុះហត្ថលេខាលើអនុស្សរណៈយោគយល់ពភាគី (រូបភាពខាងលើ)
និងសិក្ខាសាលារៀបចំយុទ្ធសាស្ត្រ (រូបភាពកណ្តាល និងខាងក្រោម)

# ជំពូកទី២

II

# បញ្ហាប្រឈមនៃការគ្រប់គ្រងសំណល់ តើយើងកំពុងឈរនៅចំណុចណា ?

Chapter II

# បញ្ហាប្រឈមនៃការគ្រប់គ្រងសំណល់-តើយើងកំពុងឈរនៅចំណុចណា?

## ១. ទិដ្ឋភាពទូទៅរាជធានីភ្នំពេញ

រាជធានីភ្នំពេញ គឺជាទីក្រុងធំជាងគេនៃប្រទេសកម្ពុជា ដែលមានប្រជាជនរស់នៅជាអចិន្ត្រៃយ៍ចំនួន ១.៨៤៥.៩០២នាក់ ក្នុងឆ្នាំ២០១៤ ជាមួយនឹងកំណើនប្រជាជនប្រចាំឆ្នាំ ៣,៩៧% និងដង់ស៊ីតេប្រជាជនចំនួន ២.១៣៣នាក់ ក្នុងមួយគីឡូម៉ែត្រក្រឡា (នាយកដ្ឋានផែនការរាជធានីភ្នំពេញឆ្នាំ២០១៥)។

រាជធានីភ្នំពេញ មានទីតាំងភូមិសាស្ត្រស្ថិតនៅក្នុងតំបន់ភាគកណ្តាលនៃប្រទេសលើចំណុចប្រសព្វនៃទន្លេទាំងបី គឺបឹងទន្លេសាប ទន្លេមេគង្គ និងទន្លេបាសាក់។ ទីក្រុងនេះមានផ្ទៃដី ៦៩២.៦៤គីឡូម៉ែត្រក្រឡា ស្មើនឹង ០,៣៧ភាគរយ នៃផ្ទៃដីសរុបរបស់ប្រទេសកម្ពុជា។ (ប្រភព៖ សាលារាជធានីភ្នំពេញ n.d.)។

រាជធានីភ្នំពេញ ត្រូវបានពង្រីកទំហំភូមិសាស្ត្ររបស់ខ្លួនជាបន្តបន្ទាប់នៅក្នុងរយៈពេលប៉ុន្មានឆ្នាំនេះជាបួនដំណាក់កាល (ប្រភព៖ រដ្ឋបាលរាជធានីភ្នំពេញ n.d) ដែលរួមចំណែកដល់កំណើនប្រជាពលរដ្ឋក្នុងរាជធានីភ្នំពេញ។ ក្នុងឆ្នាំ២០១៤ បន្ទាប់ពីការធ្វើសមាហរណកម្មរដ្ឋបាលគ្រប់គ្រងប្រជាពលរដ្ឋក្នុងខណ្ឌទាំង១២ ត្រូវបានរៀបរាប់លម្អិតនៅក្នុងតារាងខាងក្រោម។

- ដំណាក់កាលទី ១: ការពង្រីកខណ្ឌដង្កោ
- ដំណាក់កាលទី ២: ការបង្កើតខណ្ឌឫស្សីកែវ
- ដំណាក់កាលទី ៣: សមាហរណកម្មភូមិចំនួន៤ ពីឃុំកន្ទោក
- ដំណាក់កាលទី ៤: ការធ្វើសមាហរណកម្មនៃឃុំចំនួន២០ ពីស្រុកចំនួន៥ (ស្រុកពញាឮ មុខកំពូល កៀនស្វាយ កណ្តាលស្ទឹង និងស្រុកអង្គស្នួល) នៃខេត្តកណ្តាល ទៅក្នុងដែនដីរដ្ឋបាលរាជធានីភ្នំពេញ។




**រូបភាពទី៤៖ ផែនទីរាជធានីភ្នំពេញ**

ប្រភព៖ រដ្ឋបាលរាជធានីភ្នំពេញ ឆ្នាំ២០១៤

ការអភិវឌ្ឍសេដ្ឋកិច្ចសង្គមនៅរាជធានីភ្នំពេញ បាននាំមកនូវការផ្លាស់ប្តូរយ៉ាងខ្លាំងទៅលើទេសភាពទីក្រុងកាលពីប៉ុន្មានទសវត្សរ៍កន្លងមក ដោយធ្វើឱ្យប៉ះពាល់ដល់ផ្ទៃទឹកដូចជា បឹង ប្រឡាយ និងទន្លេជាដើម ជាពិសេសទេសភាពបៃតងនៅទូទាំងរាជធានី។ ទាំងនេះ ក៏បានរួមចំណែកដល់ការកើនឡើងនូវទឹកជំនន់ ដោយសារតែការបាត់បង់មុខងារនៃប្រព័ន្ធលូបង្ហូរទឹករបស់ទីក្រុងផងដែរ (ប្រភព៖ អង្គការ Save Cambodia's Wildlife ឆ្នាំ២០១៤)។

## កំណើនប្រជាពលរដ្ឋ

គេហទំព័រផ្លូវការរបស់រដ្ឋបាលរាជធានីភ្នំពេញ[1] បានបង្ហាញនូវប្រជាជនចំនួន ១.៥០១.៧២៥នាក់។ ទោះជាយ៉ាងណាក៏ដោយការបន្ថែមខណ្ឌចំនួនបីថ្មីទៀតក្នុងឆ្នាំ២០១៣ និងការបញ្ចូលគ្នានូវឃុំមួយចំនួនធំចូលទៅក្នុងដែនដីរាជធានី បានធ្វើឱ្យចំនួនប្រជាជនកើនរហូតដល់ជាង ២លាននាក់ ចាប់តាំងពីឆ្នាំ២០១៥។ តាមការប៉ាន់ប្រមាណចំនួនប្រជាជនថ្មីៗក្នុងឆ្នាំ២០១៦ ដោយប្រើប្រាស់ទិន្នន័យជំរឿនឆ្នាំ២០០៨ ឃើញថាប្រជាពលរដ្ឋនៅរាជធានីភ្នំពេញមានចំនួន ២.១៤៧.000នាក់ ហើយកើនឡើងដល់ ២.៤០៦.000នាក់ ក្នុងឆ្នាំ២០២០ និង ២.៨៦៨.000នាក់ នៅឆ្នាំ២០៣៥ (ផែនការយុទ្ធសាស្ត្រឆ្លើយតបការប្រែប្រួលអាកាសធាតុសម្រាប់រាជធានីភ្នំពេញឆ្នាំ២០១៧)។




**រូបភាពទី៥៖ ព្យាករណ៍ចំនួនប្រជាជនដោយការសិក្សាមួយចំនួន**

ប្រភព៖ រដ្ឋបាលរាជធានីភ្នំពេញ ២០១៧

## ការលូតលាស់ផ្នែកសេដ្ឋកិច្ច

សេដ្ឋកិច្ចរបស់ប្រទេសកម្ពុជាបានបង្ហាញពីកំណើនដ៏រឹងមាំ និងយូរអង្វែងក្នុងរយៈពេលមួយទសវត្សរ៍កន្លងមកនេះ ជាមួយនឹងអត្រាកំណើន GDP ប្រហែល ៧% ដែលមានវិស័យចម្បងៗគឺ វិស័យសេវាកម្ម វិស័យផលិតកម្ម រួមទាំងវិស័យកាត់ដេរ និងវិស័យទេសចរណ៍។

ទោះជាយ៉ាងណាក៏ដោយ នាពេលថ្មីៗនេះមានសញ្ញាណនៃការធ្វើពិពិធកម្មនៅក្នុងវិស័យឧស្សាហកម្ម ជាពិសេសក្នុងផ្នែកផលិតកម្ម។ ការធ្វើបច្ចុប្បន្នភាពសេដ្ឋកិច្ចកម្ពុជា (ប្រភព៖ ធនាគារអភិវឌ្ឍន៍អាស៊ី ខែតុលា ឆ្នាំ២០១៧) បានបង្ហាញថា គេបានមើលឃើញពីលទ្ធភាពបន្ថែមតម្លៃខ្ពស់លើផលិតកម្មនៃរោងចក្រផលិត ទាំងគ្រឿងបង្គុំ សម្ភារអេឡិចត្រូនិក ព្រមទាំងគ្រឿងបន្លាស់រថយន្ត ហើយបានសន្និដ្ឋានថាប្រទេសនេះ "ជិតឈានឡើងដល់លំដាប់អាចតម្លើងខ្សែសង្វាក់ផលិតកម្មមានតម្លៃ ពោលគឺពីរោងចក្រផលិតកម្មវាយនភណ្ឌ ឈានទៅដល់ផលិតកម្មគ្រឿងអេឡិចត្រូនិក និងគ្រឿងបន្លាស់រថយន្តផ្សេងៗ"។

[1] http://phnompenh.gov.kh/en/phnom-penh-city/facts/




**រូបភាពទី៦៖ ការលូតលាស់នៃ GDP និងវិស័យចម្បងៗ ចាប់ពីឆ្នាំ២០១១ ដល់ ២០១៧**

ប្រភព៖ ធនាគារអភិវឌ្ឍន៍អាស៊ី ឆ្នាំ២០១៧

# ២. ការធ្វើសារពើភណ្ឌសំណល់

## ២.១. សំណល់រឹងទីប្រជុំជន

### ក្របខណ្ឌច្បាប់ និងគោលនយោបាយ

បទដ្ឋានច្បាប់ ប្រកាស អនុក្រឹត្យ និងសេចក្តីណែនាំផ្សេងៗ ត្រូវបានដាក់ចេញជាបន្តបន្ទាប់ទាំងថ្នាក់ជាតិ និងថ្នាក់រាជធានីអស់រយៈពេលជាច្រើនឆ្នាំទាក់ទងទៅនឹងការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន។

**បទដ្ឋានគតិយុត្តថ្នាក់ជាតិ**

- អនុក្រឹត្យស្តីពីការគ្រប់គ្រងសំណល់រឹង លេខ៣៦ (ឆ្នាំ១៩៩៩)
- សេចក្តីប្រកាសអន្តរក្រសួងនៃក្រសួងមហាផ្ទៃ និងក្រសួងបរិស្ថានស្តីពីការគ្រប់គ្រងសំរាម សំណល់រឹងនៅតាមខេត្ត/ ក្រុងនៃប្រទេសកម្ពុជា លេខ៨០ (ឆ្នាំ២០០៣)
- អនុក្រឹត្យស្តីពីការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន លេខ១១៣ (ឆ្នាំ២០១៥)
- យុទ្ធសាស្ត្រ និងផែនការសកម្មភាពគ្រប់គ្រងសំណល់នៃប្រទេសកម្ពុជា (កំពុងពង្រាង)

**បទដ្ឋានគតិយុត្តថ្នាក់ក្រោមជាតិ**

- ពង្រាងសេចក្តីណែនាំស្តីពីការកែលម្អការងារគ្រប់គ្រង ការសម្អាតសំរាម សំណល់រឹងនៅរាជធានីភ្នំពេញ
- សេចក្តីជូនដំណឹងស្តីពីការទុកដាក់ ការសម្អាត ការបញ្ចេញសំរាម និងការពិន័យចំពោះការបោះចោលសំរាមគ្មានសណ្តាប់ធ្នាប់ នៅក្នុងរាជធានីភ្នំពេញ លេខ១៣ (ឆ្នាំ២០១៣)
- ផែនការណែនាំស្តីពីការអនុវត្តន៍ការផាកពិន័យ ដើម្បីលើកកម្ពស់អនាម័យបរិស្ថាននៅរាជធានីភ្នំពេញ លេខ០៩ (ឆ្នាំ២០១០)
- សេចក្តីណែនាំស្តីពីការពិន័យលើការចោលសំរាមតាមទីសាធារណៈ លេខ១៦ (ឆ្នាំ២០១០)
- ផែនការណែនាំស្តីពីការអនុវត្តន៍ការញែកសំរាម នៅរាជធានីភ្នំពេញ លេខ០៨ (ឆ្នាំ២០១០)

# ការអនុវត្តន៍ជាក់ស្តែងលើការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន

## បរិមាណសំណល់បង្កើតឡើង

បរិមាណសរុបនៃការបង្កើតសំរាម សំណល់រឹងនៅរាជធានីភ្នំពេញនៅមិនទាន់អាចប៉ាន់ស្មានឱ្យបានជាក់លាក់នៅឡើយទេ ដោយសារការប្រែប្រួលនៃចំនួនប្រជាជននៅក្នុងរាជធានី ដូចដែលបានពន្យល់នៅក្នុងផ្នែកមុននេះ។ ទោះយ៉ាងណា និន្នាការបរិមាណបង្កើតសំណល់ត្រូវបានប៉ាន់ស្មានដោយវិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា (សូមមើលរូបភាពទី៧) បង្ហាញពីការបន្តកើនឡើងនៃបរិមាណសំរាម សំណល់រឹងទីប្រជុំជនរហូតដល់ឆ្នាំ២០៣០។ បរិមាណសំរាម ដែលចាក់នៅទីលានមានការកើនឡើងយ៉ាងគំហុកក្នុងរយៈពេល២ទសវត្សរ៍ចុងក្រោយ ដោយសារកត្តាកំណើនប្រជាជន និងការកើនឡើងនៃសំណល់នៅតាមប្រភព។ ដោយសារកិច្ចប្រឹងប្រែងរបស់សាលារាជធានី សេវាកម្មប្រមូលសំរាម និងសំរាមតាមលំនៅដ្ឋាននាំឱ្យមានការប្រមូលសំរាមកើនឡើងជារៀងរាល់ឆ្នាំ (សូមមើលរូបភាពទី៨)។ នៅក្នុងឆ្នាំ២០១៧ សំណល់ដែលយកទៅចាក់ក្នុងទីលានដង្កោជាប្រចាំថ្ងៃមានចំនួនប្រមាណ ២.៧១៥ តោន/ថ្ងៃ (ប្រភព៖ គណៈគ្រប់គ្រងទីលានចាក់សំរាមដង្កោ រដ្ឋបាលរាជធានីភ្នំពេញ ឆ្នាំ២០១៨)។




**រូបភាពទី៧៖ ព្យាករណ៍កំណើនបរិមាណបង្កើតសំរាម សំណល់រឹងនៅក្នុងរាជធានីភ្នំពេញរហូតដល់ឆ្នាំ២០៣០**

ប្រភព៖ វិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា ឆ្នាំ២០១៥




### រូបភាពទី៨៖ និន្នាការនៃកំណើនសំរាម សំណល់រឹងចាក់ចោលនៅទីលានចាក់សំរាមដង្កោ រាជធានីភ្នំពេញ

ប្រភព៖ រដ្ឋបាលរាជធានីភ្នំពេញ ឆ្នាំ២០១៧

ពាក់ព័ន្ធនឹងបរិមាណសំណល់បង្កើតឡើងក្នុងម្នាក់ៗ គេត្រូវចែកឱ្យដាច់រវាងពាក្យថា ‘សំណល់តាមគ្រួសារក្នុងម្នាក់ៗ’ និង ‘សំណល់សរុបរបស់បុគ្គលក្នុងម្នាក់ៗ’។ តួលេខគណនាថ្មីៗចុងក្រោយរបស់មូលនិធិអាស៊ីឆ្នាំ២០១៣ ស្តីពីការប្រើប្រាស់សំណល់ក្នុងម្នាក់ៗ គឺមាន ០.៤៩៨ គ.ក ក្នុងមួយថ្ងៃ ដែលមានចំនួនលើសតិចតួចពីស្ថិតិរបស់អង្គការ JICA ឆ្នាំ២០០៣ ដែលមានចំនួន ០.៤៨៧ គ.ក/ម្នាក់/ថ្ងៃ។

បរិមាណបង្កើតសំណល់ក្នុងមួយនាក់ គឺគណនាតាមរយៈបរិមាណសំណល់សរុប ចែកនឹងចំនួនប្រជាពលរដ្ឋ ដូចនេះ បរិមាណសំណល់អាចប្រែប្រួលតាមរយៈចំនួនប្រជាជន និងអត្រាប្រមូលសំរាមតាមទីប្រជុំជន។ ផ្អែកលើទិន្នន័យពីប្រភពផ្សេងៗ បរិមាណសំណល់សរុបមានការកើនឡើងពី ០.៧៤ គ.ក/ម្នាក់/ថ្ងៃ ទៅ ១.៣២ គ.ក/ម្នាក់/ថ្ងៃ ក្នុងឆ្នាំ២០១៦ (គណនាដោយក្រុមការងារផ្អែកលើទិន្នន័យឆ្នាំ២០១៦)។

### តារាងទី៣៖ បរិមាណសំរាម សំណល់រឹងបង្កើតឡើងក្នុងម្នាក់ៗ ផ្អែកលើទិន្នន័យឆ្នាំ២០១៦

| សន្ទស្សន៍វាស់វែង | | តម្លៃ |
|---|---|---|
| a | សំណល់ដឹកយកមកចាក់ក្នុងទីលាន ឆ្នាំ២០១៦ គិតជាតោន | ៧១៧.៤៣៥ |
| b | អត្រាប្រមូលសំណល់ក្នុងទីក្រុងគិតជាមធ្យម* (%) | ៧៥% |
| c | បរិមាណសំរាមសរុបលើកលែងសំណល់អេតចាយ (តោន/ឆ្នាំ) [គណនាតាមរូបមន្ត៖ a/b/១០០] | ៩៥៦.៥៨០ |
| d | អត្រាកែច្នៃឡើងវិញ នៅតាមផ្ទះ (%)** | ៥ |
| e | អត្រាកែច្នៃឡើងវិញ នៅកំឡុងពេលប្រមូល (%) | ២,៣ |
| f | ការបង្កើតសំណល់សរុប ក្នុងមួយឆ្នាំ២០១៦ (តោន/ឆ្នាំ) [គណនាតាមរូបមន្ត៖ c/(១០០-d-e)/១០០] | ១.០៣១.៩០៩,៥ |
| g | ចំនួនប្រជាជន ឆ្នាំ២០១៦ | ២.១៤៧.០០០ |
| h | បរិមាណបង្កើតសំណល់សរុប គិតជាគ.ក/ម្នាក់/ថ្ងៃ ឆ្នាំ២០១៦ [គណនាតាមរូបមន្ត៖ f x ១.០០០/g/៣៦៥] | ១,៣២ |

* យោងតាមការប៉ាន់ស្មាន ក្នុងកិច្ចពិភាក្សា ជាមួយ សាលារាជធានី ឆ្នាំ២០១៧

** អត្រាកែច្នៃឡើងវិញ ផ្អែកលើរបាយការណ៍អង្គការJICA (២០០៥) មិនអាចរកទិន្នន័យថ្មីៗបាន

តាមរបាយការណ៍ពីបណ្ដាខណ្ឌកណ្ដាលរាជធានីអត្រាប្រមូលគឺជិតដល់ ១០០% ចំណែកខណ្ឌនៅជាយរាជធានីមានអត្រា ៦០%។ ការសិក្សារបស់អង្គការលំនៅដ្ឋាននៃអង្គការសហប្រជាជាតិ (UN Habitat) ឆ្នាំ២០១៤ សិក្សាលើខណ្ឌនៅជាយរាជធានីប៉ាន់ប្រមាណថាជិត ៤០% នៃសហគមន៍ក្រីក្រជាយរាជធានីភ្នំពេញពុំមានសេវាកម្មប្រមូលសំណល់ទៅដល់នោះទេ។

យោងតាមរបាយការណ៍អង្គការ JICA ឆ្នាំ២០០៥ ប្រមាណ ៧.៣% នៃសំណល់សរុបស្មើនឹង ៧.៥០០០តោន ក្នុងមួយឆ្នាំ (ផ្អែកលើទិន្នន័យឆ្នាំ២០១៦) ត្រូវបានកែច្នៃក្រៅប្រព័ន្ធក្នុងរាជធានីភ្នំពេញ។

សំរាម សំណល់រឹងត្រូវបានប្រមូល និងនាំយកទៅចាក់នៅទីលានចាក់សំរាមពីខណ្ឌចំនួន១២ នៅទូទាំងរាជធានីភ្នំពេញភាគច្រើនគឺដាក់ក្នុងសណ្ឋានច្របល់លាយឡំគ្នា។ (រូបភាពទី៩ បង្ហាញពីសំរាម សំណល់រឹង ដែលបានមកពីប្រភពផ្សេងៗ)។ ក្នុងចំណោមប្រភពទាំងអស់នោះ សំណល់តាមផ្ទះមានចំនួនច្រើនជាងគេបំផុត (៥៥.៣%) នៃសំណល់សរុប បន្ទាប់មកគឺសណ្ឋាគារ /ផ្ទះសំណាក់ (១៦.៧%) ភោជនីយដ្ឋាន (១៣.៨%) និងទីផ្សារ (៧.៥%)។




**រូបភាពទី៩៖ ប្រភព និងភាគរយបង្កើតសំរាម សំណល់រឹង ក្នុងរាជធានីភ្នំពេញ**

ប្រភព៖ មូលនិធិអាស៊ី ឆ្នាំ២០១៣

## សមាសភាពនៃសំណល់

រូបភាពទី១០ បង្ហាញសមាសភាពសំរាម សំណល់រឹង ដែលគេប្រមូលមកពីប្រភពផ្សេងៗនៅរាជធានីភ្នំពេញ។ ជាមធ្យមទីក្រុងក្នុងប្រទេសកម្ពុជា ៥០% នៃសំណល់ទៅទីលានចោលសំរាម គឺជាសំណល់ជីវៈ បន្ទាប់មកមានប្លាស្ទិក (២០,៩% - ថង់ប្លាស្ទិក ប្រភេទប្លាស្ទិកផ្សេងៗ និងដបទឹកសុទ្ធដទៃទៀត) ក្រដាស (៩,៩%) ស្មៅ និងឈើ (២,៣%) ។ ភាគរយនៃសំណល់ជីវៈមានបរិមាណច្រើន ហើយសំណល់ដែលអាចកែច្នៃឡើងវិញនៅតាមទីលានចាក់សំរាមមានទាបជាង បើប្រៀបធៀបទៅនឹងបរិមាណរបស់វានៅឯប្រភពបង្កើតសំណល់ ដោយសារសំណល់កែច្នៃឡើងវិញមួយចំនួនដូចជា ប្លាស្ទិករឹង ដបទឹកសុទ្ធ កំប៉ុងលោហធាតុ ត្រូវបានរើសចេញនៅឯប្រភពដោយម្ចាស់សំណល់ មុនពេលប្រមូលដោយអ្នករើសសំរាម និងកំឡុងពេលប្រមូលដោយកម្មករក្រុមហ៊ុនប្រមូលសំរាម។




*រូបភាពទី១០៖ សមាសភាពសំរាម សំណល់រឹងនៅតាមប្រភព នៃរាជធានីភ្នំពេញ*

ប្រភព៖ មូលនិធិអាស៊ី ឆ្នាំ២០១៣

## ការប្រមូល និងដឹកជញ្ជូនសំរាម សំណល់រឹង

ក្រុមហ៊ុនឯកជនស៊ីនទ្រីទទួលខុសត្រូវក្នុងការប្រមូល និងដឹកជញ្ជូនសំរាម សំណល់រឹង ដែលបានបង្កើតនៅក្នុងទីក្រុង ហើយបានពង្រីកវិសាលភាពភូមិសាស្ត្រក្នុងការប្រមូលសំណល់នេះជាច្រើនឆ្នាំមកហើយ។ ទោះជាយ៉ាងណាក៏ដោយ សេវាប្រមូលសំរាមនៅជុំវិញទីក្រុងនៅតែមានកម្រិតនៅឡើយ។ លើសពីនេះទៀត សេវាកម្មនៅមិនទាន់មានស្តង់ដា បច្ចេកទេសគួរជាទីពេញចិត្តនៅឡើយទេ រួមមាន ការប្រមូលសំរាមយឺតយ៉ាវ បើទោះបីជាមានកាលវិភាគសម្រាប់ប្រមូលសំរាមក៏ដោយ និងការប្រមូលទៀតសោតនៅមានកម្រិតនៅឡើយ (ការលេចហូរទឹកស្អុយចេញពីឡានសំរាមនៅទីសាធារណៈ និងការធ្លាក់សំរាមចេញពីឡានដឹកសំរាម) គឺជាប្រភពនៃការតវ៉ាញឹកញាប់ (សាលារាជធានីឆ្នាំ២០១៧)។

ម៉្យាងទៀត ការយល់ដឹងរបស់ប្រជាពលរដ្ឋពីការគ្រប់គ្រងសំរាម អនាម័យសាធារណៈ ការទុកដាក់សំរាម នៅមានកម្រិតទាបនៅឡើយ រីឯទីតាំងប្រមូលផ្តុំសំរាមដែលបានកំណត់ (ឧទាហរណ៍ សំរាមមិនបានដាក់ក្នុងស្បោងត្រឹមត្រូវ និង/ឬ ពេលខ្លះមិនយកចេញមកតាមពេលកំណត់) កន្លែងជាច្រើនមិនមានសេវាប្រមូលសំរាម ជ្រុះរ៉ាយប៉ាយតាមដងផ្លូវ ការចាក់ចោលសំរាមតាមដីទំនេរ តាមប្រលាយទឹក ប្រព័ន្ធលូបង្ហូរទឹកស្អុយ ដែលបង្កឱ្យប៉ះពាល់ដល់អនាម័យ និងបរិស្ថានរស់នៅ។

## ការគ្រប់គ្រងទីលានចាក់សំរាម

រាជធានីភ្នំពេញពឹងផ្អែកស្ទើរតែទាំងស្រុងទៅលើទីលានចាក់សំរាមដង្កោសម្រាប់ប្រព្រឹត្តកម្ម និងចាក់ចោលសំរាមក្នុងភូមិសាស្ត្ររបស់ខ្លួន។ ទីលានចាក់សំរាមដង្កោ ដែលបង្កើតឡើងដោយមានជំនួយពីអង្គការ JICA បានចាប់ផ្តើមប្រតិបត្តិការក្នុងខែកក្កដា ឆ្នាំ២០០៩ បន្ទាប់ពីការបិទកន្លែងចាក់សំរាមនៅស្ទឹងមានជ័យ ដោយសារអស់លទ្ធភាពទទួលយកសំរាមមកចាក់ចោល។ នៅឆ្នាំ២០១៧ បរិមាណសំរាមក្នុងរាជធានីភ្នំពេញចាក់នៅទីលានចាក់សំរាមនៅខណ្ឌដង្កោរាជធានីភ្នំពេញត្រូវបានប៉ាន់ប្រមាណជាមធ្យម ២.២១៥តោន/ថ្ងៃ។ តារាងទី៤ បង្ហាញពីបរិមាណសំរាមមកពីប្រភពផ្សេងៗ។

តារាងទី៤៖ បរិមាណសំរាម សំណល់រឹងទីប្រជុំជននៅតាមប្រភព ចាក់នៅទីលានក្នុងឆ្នាំ២០១៤ និង២០១៧

| ប្រភព | ២០១៤ | | ២០១៧ | |
|---|---|---|---|---|
| | តោន/ថ្ងៃ | % | តោន/ថ្ងៃ | % |
| ក្រុមហ៊ុនស៊ីនទ្រី | ១.៦៥៣ | ៩៧% | ២.១៧២,៧៤ | ៩៨,0% |
| ផ្សារដើមគរ | ២៨ | ១,៦% | ២៧,៧១ | ១,៣% |
| ផ្សារព្រែកព្នៅ | n.a. | n.a. | ៣,២៧ | 0,១% |
| ផ្សារមានជ័យថ្មី | n.a. | n.a. | 0,0៩ | 0,១% |
| ទីសត្វឃាត្ត | ៨ | 0,៥% | ៩,៣៧ | 0,៤% |
| មន្ទីរសាធារណៈការ និងដឹកជញ្ជូន | ១0 | 0,៦% | ២,៨៥ | 0,១% |
| ផ្សេងៗ | ៦ | 0,៤% | 0,១២ | 0,១% |
| សរុប | ១.៧0៥ | | ២.២១៥.១៥ | |

ប្រភព: គណៈគ្រប់គ្រងទីលានចាក់សំរាមរាជធានីភ្នំពេញ (២០១៨)

ការអនុវត្តន៍ការគ្រប់គ្រងដែលបានផ្តល់អនុសាសន៍ដោយ JICA ដូចជា ត្រូវមានគម្របដីពីលើ ដែលត្រូវបានអនុវត្តតាមរហូតដល់ឆ្នាំ២០១០។ តែគេបានបញ្ឈប់ការគ្របដីនេះបន្តទៅទៀត ដោយសារតែការខូចខាតយ៉ាងធ្ងន់ធ្ងរនៅទីលានពីគ្រោះទឹកជំនន់ ដែលបានធ្វើឱ្យប៉ះពាល់ដល់តំបន់ភាគច្រើននៃប្រទេសកម្ពុជាផងដែរ និងបានធ្វើឱ្យគំនរសំរាមនៃតំបន់ A និងតំបន់ B ដួលរំលំផងដែរ។ ដោយគ្មានការបង្ហាប់ដីពីលើ អាយុកាលប្រើប្រាស់ទីលានចាក់សំរាមត្រូវបានកាត់បន្ថយយ៉ាងឆាប់រហ័ស ខណៈពេលដែលអនាម័យនៃការគ្រប់គ្រងទីលានបានធ្លាក់ចុះ ដែលបណ្តាលឱ្យមានក្លិនអាក្រក់ ករកើតជំងឺ និងសត្វល្អិតចង្រៃ ជាពិសេសក្នុងរដូវវស្សា។

ទឹកសំអុយពីទីលានចាក់សំរាមត្រូវបានប្រមូលផ្តុំនៅក្នុងស្រះស្តុក ប៉ុន្តែមិនមានដំណើរការនៃប្រព្រឹត្តកម្មសម្អាតទឹកនោះទេ។ លក្ខណៈភូគព្ភសាស្ត្រនៃតំបន់នេះ ត្រូវបានគេទុកឱ្យទឹកសំអុយជ្រាបចូលទៅក្នុងដី ដែលធ្វើឱ្យខូចដល់គុណភាពដីនៃតំបន់ជិតៗនោះ និងប្រព័ន្ធទឹកក្រោមដី (សូមមើលជំពូកទីVI)។

ការចោលសំរាមដោយគ្មានសណ្តាប់ធ្នាប់ និងប្រព្រឹត្តកម្មសំណល់តាមទីឯកជននៅតែបន្តកើតមានជាធម្មតា។ ទាំងនេះដោយសារតែការប្រមូលសំរាម និងសេវាកម្មដឹកជញ្ជូននៅក្នុងទីក្រុងមិនទាន់បានគ្រប់គ្រាន់ ម្យ៉ាងទៀត សំណល់ត្រូវបោះចោលនៅដីឯកជន ដីទំនេរ និងដុតបំផ្លាញជាចំហរក្នុងដីឯកជន។

ក្នុងឆ្នាំ២០១៥ សំណល់រឹងប្រមាណ ១១៧.៥៣0តោន ត្រូវគេចាក់ចោលដោយគ្មានសណ្តាប់ធ្នាប់តាមរបៀបខាងលើ ដែលស្មើនឹង ១១,៧% នៃសំណល់ដែលបានបញ្ចេញពីរាជធានីភ្នំពេញ (ទិន្នន័យសារពើភ័ណ្ឌនៃមន្ទីរបរិស្ថាន ក្រសួងបរិស្ថាន ឆ្នាំ២០១៥)។

## ការកែច្នៃ និងការនាំចេញសំណល់រឹង

ខណៈមានការខ្វះខាតទិន្នន័យបរិមាណសំណល់ ដែលបានកែច្នៃជាក់ស្តែងក្នុងប្រទេសកម្ពុជា សកម្មភាពកែច្នៃសំរាមត្រូវបានគេឃើញមានចំនួនតិចតួចក្នុងរាជធានីភ្នំពេញ។ ម្យ៉ាងទៀត អង្គការក្រៅរដ្ឋាភិបាលដូចជា អង្គការ CSARO និង អង្គការ COMPED[2] ដែលជាអ្នកកែច្នៃសំណល់ជីវៈជាជីកំប៉ុស ហើយក៏មានក្រុមហ៊ុនឯកជនមួយចំនួនបានសិក្សាពីសក្តានុពលអាជីវកម្មកែច្នៃសំណល់ជីវៈនិងអសរីរាង្គផងដែរ។ ដើម្បីឆ្លើយតប ទៅនឹងបរិមាណសំរាមដែលចាក់នៅទីលានចាក់សំរាមដង្កោ រដ្ឋបាលរាជធានីភ្នំពេញបានធ្វើការសិក្សាលើវិធានការមួយចំនួន ដើម្បីជំរុញវិស័យឯកជនក្នុងការកែច្នៃសំណល់។

សមត្ថភាពកែច្នៃសំណល់មានកម្រិត ជាឧបសគ្គចម្បងសម្រាប់រាជធានីភ្នំពេញ និងក៏ដូចជាប្រទេសកម្ពុជា ដើម្បីធ្វើការផ្លាស់ប្តូរពីសង្គមមួយដែលមានវិធីសាស្ត្រគ្រប់គ្រងសំណល់ ឬធនធានបែបខ្សែបន្ទាត់លីនេអ៊ែ (ដែលធនធានត្រូវយកមកធ្វើផលិតផលប្រើប្រាស់ និងបោះចោលទៅវិញ) ទៅជាសង្គមមួយ ដែលមានវិធីសាស្ត្រគ្រប់គ្រងសំណល់បែបវិលជុំ ដើម្បីបញ្ចៀសឱ្យមានការខាតបង់ផ្នែកសេដ្ឋកិច្ច ខ្ជះខ្ជាយធនធាន និងប៉ះពាល់ដល់បរិស្ថាន។ ទោះបីជា បរិមាណសំណល់ដែលអាចកែច្នៃបានមួយចំនួនត្រូវបានគេប្រើប្រាស់ និងប្រមូលបានទូទាំងប្រទេសក៏ដោយ តែសកម្មភាពកែច្នៃសំណល់ក្នុងស្រុកនៅមានកម្រិតដោយសារកង្វះវិស័យឧស្សាហកម្មកែច្នៃ ហេដ្ឋារចនាសម្ព័ន្ធកែច្នៃ និងទីផ្សារសម្រាប់ទទួលទិញវត្ថុធាតុដើមពីការកែច្នៃ និងផលិតផលផ្សេងៗពីការកែច្នៃ។ ដូចនេះ សំណល់ដែលអាចកែច្នៃបាន និងសំណល់ផ្សេងៗជាច្រើនទៀត ត្រូវបាននាំចេញទៅកាន់ប្រទេសជិតខាងសម្រាប់ធ្វើការកែច្នៃ។

រូបភាពទី១១ បង្ហាញពីបរិមាណសំណល់កែច្នៃឡើងវិញ ដែលបានទិញដោយទីតាំងដេប៉ូអេតចាយនៅទូទាំងប្រទេសកម្ពុជាសម្រាប់ការកែច្នៃរួមមាន៖ ក្រដាស ប្លាស្ទិក ដប ថង់ប្លាស្ទិក អាលុយមីញ៉ូម (បំណែកសម្ភារ និងកំប៉ុង) ដែក ដបកែវ ហើយរូបភាពទី១២ បង្ហាញពីនិន្នាការសំណល់ដែលអាចកែច្នៃឡើងវិញ ត្រូវបានស្នើសុំការនាំចេញស្ថិតក្រោមគម្រោងអនុញ្ញាតរបស់ក្រសួងបរិស្ថាន (ប្រភព៖ ក្រសួងបរិស្ថាន ឆ្នាំ២០១៨)។ ក្រាហ្វិកទាំង២ បានបង្ហាញពីការពង្រីកវិសាលភាពនៃការប្រើប្រាស់សម្ភារនៅកម្ពុជាក្នុងរយៈពេលប៉ុន្មានឆ្នាំកន្លងទៅនេះ។ តាមរយៈទិន្នន័យរបស់ក្រសួងបរិស្ថានសម្រាប់ឆ្នាំ២០១៣ និង ២០១៤ (តារាងទី៥) បានបង្ហាញថា សំណល់ដែលអាចកែច្នៃ ត្រូវបាននាំចេញទៅប្រទេសដទៃទៀតដូចជា៖ ប្រទេសថៃ កូរ៉េខាងត្បូង វៀតណាម ចិន សឹង្ហបុរី ម៉ាឡេស៊ី និងតៃវ៉ាន់ ដែលបណ្តាលឱ្យមានរំហូរធនធានដ៏មានសក្តានុពលចេញទៅក្រៅ ហើយពេលត្រូវការត្រូវនាំចូលវត្ថុធាតុដើមទាំងនោះមកវិញ។ លើសពីនេះទៀត ខណៈពេលដែលមានការកើនឡើងនៃការកែច្នៃពីសំណល់ គឺជាការស្វាគមន៍ចំពោះការអភិវឌ្ឍ ហើយក៏ទាមទារនូវកិច្ចខិតខំប្រឹងប្រែង ដើម្បីធានាថាសកម្មភាពកែច្នៃទាំងនោះត្រូវបានគ្រប់គ្រងដោយត្រឹមត្រូវ និងបន្ថយហានិភ័យលើសុខភាព និងបរិស្ថាន។

[2] COMPED បានផ្អាកសមកម្មភាពកែច្នៃជីកំប៉ុសនៅក្នុងរាជធានីភ្នំពេញនៅឆ្នាំ២០០៩ នៅពេលដែលទីលានចាក់សំរាមត្រូវបានផ្លាស់ប្តូរទីតាំងនៅក្នុងឆ្នាំនោះ។




**រូបភាពទី១១៖ បរិមាណសំណល់ដែលអាចកែច្នៃបាន នៅដេប៉ូសម្រាប់កែច្នៃ (តោន/ឆ្នាំ)**

ប្រភព៖ ក្រសួងបរិស្ថាន ឆ្នាំ២០១៨




**រូបភាពទី១២៖ បរិមាណសំណល់កែច្នៃ នាំចេញតាមរយៈក្រសួងបរិស្ថាន (តោន/ឆ្នាំ)**

ប្រភព៖ ក្រសួងបរិស្ថាន ឆ្នាំ២០១៨

តារាងទី៥៖ បរិមាណសំណល់កែច្នៃនាំចេញ និងទិសដៅប្រទេសនាំចេញ ក្នុងឆ្នាំ២០១៣ និង២០១៤

| ប្រភេទវត្ថុធាតុដើម | បរិមាណ (តោន/ឆ្នាំ) | | នាំចេញទៅកាន់ប្រទេស |
|---|---|---|---|
| | ២០១៣ | ២០១៤ | |
| ដែក | ៣.៣០០ | ៤.៣០០ | ថៃ |
| អាលុយមីញ៉ូម | ៤.០៧៥ | ៧.៥២៣ | កូរ៉េខាងត្បូង សឹង្ហបុរី ចិន និងកោះតៃវ៉ាន់ |
| ទង់ដែង | ១៨.០០០ | ០ | កូរ៉េខាងត្បូង |
| សំណល់អេតចាយចម្រុះ | ៦.៧០០ | ៣.២៥០ | ថៃ និងវៀតណាម |
| ក្រដាស | ១៥.៣០០ | ១២.៤០០ | ថៃ និងវៀតណាម |
| អំបែងដប | ១.៤១៧ | ៣.២៧៧ | ម៉ាឡេស៊ី |
| ប្លាស្ទិក | ១១.៩៦៦ | ១៤.៦៣៤ | វៀតណាម និងចិន |

ប្រភព៖ ក្រសួងបរិស្ថាន ឆ្នាំ២០១៥

## ២.២. សំណល់សំណង់

### ក្របខណ្ឌច្បាប់ និងគោលនយោបាយ

បច្ចុប្បន្ននៅមិនទាន់មានបទដ្ឋានច្បាប់ ឬគោលនយោបាយណាមួយត្រូវបានគេកំណត់គោលដៅជាពិសេសសម្រាប់ការគ្រប់គ្រងសំណល់សំណង់នៅឡើយទេ។

### ការអនុវត្តន៍ជាក់ស្តែងលើការគ្រប់គ្រងសំណល់សំណង់

ការគ្រប់គ្រងសំណល់សំណង់នៅក្នុងរាជធានីភ្នំពេញ គឺស្ថិតនៅក្នុងដំណាក់កាលអភិវឌ្ឍន៍ ដោយសំណល់មួយចំនួនត្រូវបានប្រមូល ទុកដាក់ និងចាក់ចោលដោយក្រុមហ៊ុនឯកជនទៅតាមកិច្ចសន្យា។ សំរាមខ្លះត្រូវបានលក់ឱ្យអ្នកទិញយកទៅប្រើប្រាស់ឡើងវិញ (ដី កំទេចថ្ម និងថ្ម) ខណៈដែលសំណល់ផ្សេងទៀតត្រូវបានចាក់ចោលនៅតាមដីទំនេរ ឬតំបន់សាធារណៈដាច់ស្រយាលជាយរាជធានី។

តាមរយៈការវាយតម្លៃរហ័ស សំណល់សំណង់នៅតាមការដ្ឋានមួយចំនួននៅក្នុងរាជធានីភ្នំពេញមានសមាសភាពប្រហែល ៦០% ជាកំទេចឥដ្ឋថ្ម កំទេចស៊ីម៉ង់ និងដី រឹង ២០% ទៀត ជាឈើ ១០% ជាលោហៈ ប្រហែល ៥% ប្លាស្ទិក និង ៥% ទៀត ជាក្រដាស និងសំណល់ផ្សេងៗទៀត។

បច្ចុប្បន្ន នៅមិនទាន់មានបទដ្ឋានច្បាប់ថ្នាក់ជាតិត្រូវបានអនុម័ត ដើម្បីដោះស្រាយទៅលើសំណល់សំណង់នៅឡើយទេ ខណៈដែលអនុក្រឹត្យលេខ១១៣ បានចែងពីការទទួលខុសត្រូវរបស់ផលិតសំណល់សំណង់លើការទុកដាក់ ប្រមូល និងដឹកជញ្ជូនឱ្យបានសមរម្យ ហើយគេចាក់ចោលសំណល់ទាំងនោះតាមរយៈអ្នកម៉ៅការ សេវាឯកជន ឬដោយខ្លួនឯង។ ខណៈពេលកំពុងរៀបចំគោលនយោបាយថ្នាក់ជាតិសំដៅជំរុញលើកកម្ពស់គោលការណ៍៣អ៊ែរ និងការគ្រប់គ្រងសំណល់សំណង់ គេរំពឹងថារដ្ឋបាលរាជធានីភ្នំពេញក៏អាចទទួលយកកិច្ចអន្តរាគមន៍ក្នុងការគ្រប់គ្រងប្រភេទសំណល់នេះ។

ទោះយ៉ាងណា នៅក្នុងការអនុវត្តន៍ជាក់ស្តែងសំណល់ការដ្ឋានសំណង់មិនត្រូវបានយកមកចាក់នៅទីលានឡើយ។ គេសង្កេតឃើញ សំណល់សំណង់មួយចំនួនត្រូវបានគេយកមកប្រើវិញ/ច្នៃឡើងវិញ (កម្ទេចកម្ទីថ្ម ឥដ្ឋ និងដី) ទៅតាមតម្រូវការ ចំណែកឯសំណល់សំណង់ដែលលាយចម្រុះគ្នាជាមួយនឹងសំរាមផ្សេងៗ និងគ្មានតម្លៃទីផ្សារ គឺត្រូវបានគេយកទៅចាក់ចោល ដោយគ្មានសណ្តាប់ធ្នាប់នៅតាមប្រឡាយទឹក ដងទន្លេ ស្ទឹង បឹងបួរ ដីកសិកម្ម ឬទីវាលទំនេរ។ សមាសធាតុមួយចំនួនរបស់វា ដែលអាចឆេះបាន ត្រូវគេដុតដោយគ្មានសណ្តាប់ធ្នាប់ តែគេក៏សង្កេតឃើញការអនុវត្តន៍បែបនេះមានការថយចុះផងដែរ។

កង្វះខាតទិន្នន័យមូលដ្ឋានបានបង្កជាបញ្ហាប្រឈមមួយផ្សេងទៀត ធ្វើឱ្យមានការលំបាកក្នុងការរៀបចំប្រព័ន្ធគ្រប់គ្រងសំណល់សំណង់នៅក្នុងរាជធានីភ្នំពេញ ហើយក៏មិនមាននូវទិន្នន័យសារពើភ័ណ្ឌថ្នាក់ជាតិផ្លូវការ ឬការសិក្សាអង្កេតទៅលើបរិមាណសំណល់បង្កើតសំណង់នេះផងដែរ។ ទោះបីយ៉ាងណា សំណល់សំណង់អាចត្រូវបានប៉ាន់ស្មានដោយផ្អែកលើប្រភេទអចលនទ្រព្យ និងទំហំសំណង់ តែទិន្នន័យបែបនេះមិនត្រូវបានបង្ហាញជាសាធារណៈ ឬត្រូវបានប្រើប្រាស់នៅក្នុងការរៀបចំផែនការគ្រប់គ្រងសំណល់នៅក្នុងទីក្រុងនាពេលនេះទេ។



**រូបភាពទី១៣៖ ការចាក់ចោលសំរាមគ្មានសណ្តាប់ធ្នាប់ និងការដុតសំណល់សំណង់នៅរាជធានីភ្នំពេញ**

ប្រភព៖ វិទ្យាស្ថាន IGES និង អង្គការ COMPED ឆ្នាំ២០១៥

## ២.៣. សំណល់វេជ្ជសាស្ត្រ

### ក្របខណ្ឌច្បាប់ និងគោលនយោបាយ

ការគ្រប់គ្រងសំណល់វេជ្ជសាស្ត្រ ត្រូវបានគ្រប់គ្រងដោយក្រសួងសុខាភិបាល និងមន្ទីរតំណាងថ្នាក់ក្រោមជាតិរបស់ខ្លួន ដោយផ្អែកលើបទបញ្ញត្តិជាតិទាំងបីដូចខាងក្រោម៖

- ប្រកាសស្តីពីការគ្រប់គ្រងសំណល់ពីសេវាថែទាំសុខភាពក្នុងព្រះរាជាណាចក្រកម្ពុជា (ឆ្នាំ២០០៨)
- សេចក្តីសម្រេចស្តីពីការបង្កើតអង្គភាពគ្រប់គ្រងសំណល់វេជ្ជសាស្ត្រលេខ៩៦ របស់កាកបាទក្រហមកម្ពុជា (ឆ្នាំ២០០៩)
- មគ្គុទ្ទេសន៍ជាតិស្តីពីការគ្រប់គ្រងសំណល់ពីសេវាថែទាំសុខភាព (ឆ្នាំ២០១២)

### ការអនុវត្តន៍ជាក់ស្តែងលើការគ្រប់គ្រងសំណល់វេជ្ជសាស្ត្រ

ការគ្រប់គ្រងសំណល់វេជ្ជសាស្ត្រនៅទីក្រុងភ្នំពេញនាពេលបច្ចុប្បន្ន ត្រូវបានគ្រប់គ្រងដោយអង្គភាពគ្រប់គ្រងសំណល់វេជ្ជសាស្ត្រ (MWMU) នៃសាខាកាកបាទក្រហមកម្ពុជារាជធានី ដែលបានបង្កើតឡើងក្នុងឆ្នាំ២០០៩ ដើម្បីផ្តល់សេវាប្រមូលសំរាម ដឹកជញ្ជូន ធ្វើប្រព្រឹត្តកម្ម និងសេវាចាក់ចោលចុងក្រោយ ពីទីតាំងថែទាំសុខភាពនៅក្នុងរាជធានីភ្នំពេញ។

បរិមាណសំណល់វេជ្ជសាស្ត្រសរុបដែលបង្កើតឡើងមានចំនួនប្រមាណ ៤០តោន ក្នុងមួយខែ នៅក្នុងរាជធានីភ្នំពេញ ដែលរួមមានសំណល់ដែលអាចឆ្លងជំងឺ សំណល់ជាតិសាស្ត្រ និងសំណល់មុតស្រួច (ឧទាហរណ៍កាំបិត និងសឺរ៉ាំង) និងសំណល់ឱសថ (លោក Choeu ឆ្នាំ២០១៦)។ បរិមាណសំណល់វេជ្ជសាស្ត្រ បាននិងកំពុងកើនឡើងស្របពេលជាមួយនឹងការរីកចំរើននៃវិស័យវេជ្ជសាស្ត្រ និងការប្រើប្រាស់សេវាថែទាំសុខភាព (សូមមើលរូបភាពទី ១៤)។




**រូបភាពទី១៤៖ បរិមាណសំណល់វេជ្ជសាស្ត្រដែលប្រមូលបានសម្រាប់ដុតកម្ទេច**

ប្រភព៖ លោក ជី ឆ្នាំ២០១៦

យោងតាមអង្គភាពគ្រប់គ្រងសំណល់វេជ្ជសាស្ត្របានឱ្យដឹងថា សំណល់វេជ្ជសាស្ត្រមានចំនួន ១,៩តោន ក្នុងមួយថ្ងៃ នៅក្នុងរាជធានីភ្នំពេញ ហើយសមាសភាពរបស់វាមានបង្ហាញលម្អិតនៅក្នុងតារាងទី៦ខាងក្រោម។

**តារាងទី៦៖ សមាសធាតុនៃសំណល់វេជ្ជសាស្ត្រដែលបានបង្កើតនៅរាជធានីភ្នំពេញ**

| សមាសភាព | សំណល់ឆ្លង | សំណល់សរីរាង្គកាយ | សំណល់សរីរាង្គ និងផ្សេងៗ |
|---|---|---|---|
| **ភាគរយ** | ប្រហែល ៧០% | ប្រហែល ២០% | ប្រហែល ១០% |

ប្រភព៖ កិច្ចសម្ភាសជាមួយនឹងតំណាងអង្គភាពគ្រប់គ្រងសំណល់វេជ្ជសាស្ត្រ នៅថ្ងៃទី៤ ខែកញ្ញា ឆ្នាំ២០១៧

សំណល់វេជ្ជសាស្ត្រត្រូវបានទុកដាក់ដាច់ដោយឡែកនៅមណ្ឌលថែទាំវេជ្ជសាស្ត្រ ហើយដែលត្រូវបានបែងចែកដាក់ក្នុងឧបករណ៍ស្តុក/វេចខ្ចប់សុវត្ថិភាពចំនួន ៣ប្រភេទ (ស្បោងប្លាស្ទិកសុវត្ថិភាព ប្រអប់ក្រដាសសម្រាប់ម្ជុលប្រើរួចហើយ និងធុងជ័រសុវត្ថិភាព)។ ទោះជាយ៉ាងណាក៏ដោយ ការអនុវត្តន៍ការញែកសំរាមនៅមណ្ឌលថែទាំវេជ្ជសាស្ត្រមួយចំនួននៅមានកម្រិតនៅឡើយ ហើយសំណល់វេជ្ជសាស្ត្រមួយចំនួនត្រូវបានដាក់លាយឡំជាមួយសំណល់ផ្ទះបាយ ឬសំណល់ធម្មតា ហើយក៏ត្រូវបានប្រមូល និងដឹកជញ្ជូនជាមួយនឹងសំរាម សំណល់រឹងទីប្រជុំជនផ្សេងទៀត។

សំណល់វេជ្ជសាស្ត្រត្រូវបានប្រមូល និងដឹកជញ្ជូន ដោយប្រើប្រាស់រថយន្តរបស់អង្គភាព MWMU ដែលមានបំពាក់ដោយប្រព័ន្ធ GPS ដឹកយកទៅដុតនៅឡដុតសំរាមរបស់សាខាកាកបាទក្រហមកម្ពុជារាជធានី ដែលមានទីតាំងស្ថិតនៅក្នុងទីលានចាក់សំរាមដង្កោ រាជធានីភ្នំពេញ។ វាមានចម្ងាយប្រមាណ១៥គីឡូម៉ែត្រ ពីរាជធានីភ្នំពេញ (លោក Choeu ឆ្នាំ២០១៦)

ហើយឡដុតកម្ទេចសំណល់វេជ្ជសាស្ត្រនេះ ត្រូវបានគេដុតនៅសីតុណ្ហភាពរហូតដល់សីតុណ្ហភាព ១២០០អង្សាសេ (លោក Choeu ឆ្នាំ២០១៦)។ ការផ្តល់សេវារបស់សាខាកាកបាទក្រហមកម្ពុជារាជធានីគ្របដណ្តប់ ១០០% នៃគ្រឹះស្ថានសុខាភិបាលទាំងស្រុង (ទាំងសេវាសាធារណៈ និងឯកជន) នៅរាជធានីភ្នំពេញ ដែលបច្ចុប្បន្នមានរហូតដល់ទៅ ២.២១៤ទីតាំង (សូមមើលតារាងទី៧) ទោះបីជាទីតាំងមួយចំនួនកំពុងដំណើរការចុះកិច្ចសន្យាសេវានៅឡើយ (លោក Choeu ឆ្នាំ២០១៦)។ ទោះជាមានសេវាគ្របដណ្តប់ល្អ ប៉ុន្តែស្ថិតិប្រមូលសំណល់វេជ្ជសាស្ត្រពិតប្រាកដនៅមិនទាន់ដឹងទេ ព្រមទាំងមិនមានរបាយការណ៍សំណល់វេជ្ជសាស្ត្រដែលមិនបានប្រមូលនោះទេនៅរាជធានីភ្នំពេញ។

**តារាងទី៧៖ តំបន់សេវាគ្របដណ្តប់របស់អង្គភាពគ្រប់គ្រងសំណល់វេជ្ជសាស្ត្រនៅរាជធានីភ្នំពេញ**

| ខណ្ឌ | ចំនួនទីតាំងសេវាថែទាំសុខភាព | | |
|---|---|---|---|
| | មានកិច្ចសន្យា | មានទាន់ចុះកិច្ចសន្យា | សរុប |
| ទួលគោក | ២២៦ | ៦១61 | ២៨៧ |
| ៧ មករា | ១៣២ | ៣១31 | ១៦៣ |
| ចំការមន | ២៣៩ | ៨៩ | ៣២៨ |
| ដូនពេញ | ១៦៤ | ១៧ | ១៨១ |
| ពោសែនជ័យ | ២២៤ | ៨១ | ៣០៥ |
| ដង្កោ | ៣៨ | ៤៣ | ៨១ |
| ព្រែកព្នៅ | ២៨ | ១ | ២៩ |
| សែនសុខ | ១៤៥ | ១២ | ១៥៧ |
| ឫស្សីកែវ | ១២២ | ៦៦ | ១៨៨ |
| ជ្រោយចង្វារ | ២០ | ១១ | ៣១ |
| ច្បារអំពៅ | ៦៥ | ៣២ | ៩៧ |
| មានជ័យ | ១៤៩ | ១០៩ | ២៥៨ |
| សរុប | ១៥៥២ | ៥៥៣ | ២១០៥ |

ប្រភព៖ លោក Choeu ឆ្នាំ២០១៦

## ២.៤. សំណល់ឧស្សាហកម្ម

## ក្របខណ្ឌច្បាប់ និងគោលនយោបាយ

ឧបសម្ព័ន្ធនៃអនុក្រឹត្យលេខ១១៣ កំណត់ និងធ្វើនិយ័តកម្មសំណល់រឹងគ្រោះថ្នាក់ដូចខាងក្រោម ដែលមានប្រភពមកពីលំនៅដ្ឋាន គ្រឹះស្ថានសាធារណៈ អគារពាណិជ្ជកម្ម និងទីតាំងទេសចរណ៍៖

## បទដ្ឋានគតិយុត្តថ្នាក់ជាតិ

- គោលការណ៍ណែនាំ ស្តីពីការគ្រប់គ្រងសំណល់រឹងនៅតាមរោងចក្រ សហគ្រាស និងក្រុមហ៊ុន លេខ១១ (២០០៣)
- គោលការណ៍ណែនាំ ស្តីពីការគ្រប់គ្រងសំណល់ភក់នៅតាមរោងចក្រ សហគ្រាស (២០០០)
- គោលការណ៍ណែនាំ ស្តីពីការគ្រប់គ្រងសំណល់គ្រោះថ្នាក់ពីរោងចក្រលេខ៨៧ (២០០០)

## បទដ្ឋានគតិយុត្តថ្នាក់ក្រោមជាតិ

- សេចក្តីប្រកាស ស្តីពីការប្រមូលសំណល់ឧស្សាហកម្ម និងដឹកជញ្ជូនក្នុងរាជធានីភ្នំពេញ និងខេត្តកណ្តាល លេខ ១៤៨ (២០០២)
- សេចក្តីប្រកាសពីការអនុញ្ញាតិឱ្យក្រុមហ៊ុន សារុំ ត្រេដឌីង ប្រមូល និងដឹកជញ្ជូនសំណល់ឧស្សាហកម្មពីរាជធានី និងខេត្តកណ្តាល លេខ១៥៦ (២០០១)

## ការអនុវត្តន៍ជាក់ស្តែងលើការគ្រប់គ្រងសំណល់ឧស្សាហកម្ម

នៅរាជធានីភ្នំពេញ ការគ្រប់គ្រងសំណល់ឧស្សាហកម្ម គឺធ្វើឡើងដោយក្រុមហ៊ុនឯកជនឈ្មោះ សារុំ ត្រេឌីង ដែលប្រមូល និងដឹកជញ្ជូនសំណល់ឧស្សាហកម្ម (រួមទាំងសំណល់ចេញពីអាងប្រព្រឹត្តកម្មទឹកសំអុយ) សំណល់ពីរោងចក្រ (ឧទាហរណ៍ សំលៀកបំពាក់ ស្បែក ប្លាស្ទិក និងក្រដាស) ទៅកាន់ទីលានចាក់សំរាមផ្ទាល់ខ្លួន ក្នុងខណ្ឌពោធិ៍សែនជ័យ (ពីមុនហៅថា ភូមិចំបក់ ខណ្ឌកំបូល ស្រុកអង្គស្នួល ខេត្តកណ្តាល) តាមលិខិតអនុញ្ញាតពីក្រសួងបរិស្ថាន។ បរិមាណសំណល់ដែលប្រមូលមកចាក់នៅទីលានរបស់ក្រុមហ៊ុននេះមានបង្ហាញក្នុងរូបភាពទី១៥។




**រូបភាពទី១៥៖ បរិមាណសំណល់ឧស្សាហកម្មដែលប្រមូលបានដោយក្រុមហ៊ុន សារុំ ត្រេឌីង**

ប្រភព៖ ក្រុមហ៊ុន Sarom Trading ឆ្នាំ២០១៦

តួលេខខាងក្រោមបង្ហាញអំពីសមាសភាពនៃសំណល់ឧស្សាហកម្ម ដែលចាក់នៅទីលានចាក់សំណល់ឧស្សាហកម្មគ្រប់គ្រងដោយក្រុមហ៊ុន សារុំ ត្រេឌីង។ សំណល់កម្ទេចក្រណាត់ពីវិស័យកាត់ដេរ គឺមានច្រើនជាងគេ ដែលឆ្លុះបញ្ចាំងអំពីការប្រមូលផ្តុំរោងចក្រកាត់ដេរ នៅក្នុងរាជធានីភ្នំពេញ។




**រូបភាពទី១៦៖ សមាសភាពសំណល់ឧស្សាហកម្ម នៅទីលានសារ៉ុ ត្រេឌីង**

ប្រភព៖ ក្រសួងបរិស្ថាន ឆ្នាំ២០១៦

សំណល់ឧស្សាហកម្មដទៃទៀត ក៏ត្រូវគេដឹកយកមកចាក់នៅទីលានចាក់សំរាមនេះផងដែរ មានដូចជា (ប្រភពពីក្រសួងបរិស្ថានប្រទេសកម្ពុជាឆ្នាំ២០០២):

- សំណល់ពាក់កណ្ដាលភក់ ដែលយកចេញពីអាងប្រព្រឹត្តកម្មទឹកសំអុយ
- ពពួកខ្សែភ្លើង និងកំទេចក្រណាត់
- សំណល់ប្លាស្ទិក ដែលមាន ប៉ូលីវីនិល ក្លរីដ
- សំណល់កៅស៊ូ និងកៅស៊ូថ្នល់ ដែលមាន ប៉ូលីម័រ ប៊ុយទីលីន
- សំណល់ថ្មពិល និងអាគុយផ្សេងៗ
- ផេះដែលសល់ពីការដុតសំណល់វេជ្ជសាស្ត្រ
- សំណល់អំពូលភ្លើង និងគ្រឿងអេឡិចត្រូនិក
- សំណល់ថ្នាំលាប និងសំណល់វេចខ្ចប់
- សំណល់មកពីថ្នាំកំចាត់សត្វល្អិតដែលប្រើក្នុងវិស័យកសិកម្ម និងក្នុងការវេចខ្ចប់ (ត្រូវតែដាក់ក្នុងធុងជ័រ មុនពេលកប់ចោល)
- សំណល់ដែលសល់ពីសកម្មភាពផលិតកម្ម និងការប្រើប្រាស់ទឹកថ្នាំព្រីន
- ទំនិញខូចគុណភាព ឬលើសកាលបរិច្ឆេទកំណត់ ដែលមិនស្របតាមស្តង់ដា
- សំណល់ពីការថតរូប
- ឱសថហួសកាលបរិច្ឆេទប្រើប្រាស់ និងសំណល់ចេញពីការផលិតឱសថ
- សំណល់ដែលមានសារធាតុអាបេស្តូស

ក្រុមហ៊ុន សារ៉ុ ត្រេឌីង ក៏មានភាពប្រឈមរបស់ខ្លួនប្រហាក់ប្រហែលគ្នាទៅនឹងក្រុមហ៊ុនស៊ីនទ្រី ដែលផ្ដល់សេវាប្រមូលសំរាម សំណល់រឹងទីប្រជុំជនផងដែរ ក្នុងការប្រមូលថ្លៃសេវាកម្មរបស់ខ្លួន នៅពេលដែលម្ចាស់រោងចក្រខ្លះគេចវេសមិនទូទាត់ប្រាក់ បណ្ដាលឱ្យប្រាក់ចំណូលរបស់ក្រុមហ៊ុនមានភាពមិនទៀងទាត់។

## ២.៥. សំណល់គ្រោះថ្នាក់

### ក្របខណ្ឌច្បាប់ និងគោលនយោបាយ

ប្រទេសកម្ពុជាបានចេញបទបញ្ញត្តិចំនួន២ សម្រាប់គ្រប់គ្រងសំណល់គ្រោះថ្នាក់ជាទូទៅ ខណៈដែលបទបញ្ញត្តិជាក់លាក់ត្រូវបានអនុម័តសម្រាប់សំណល់វេជ្ជសាស្ត្រ និងសំណល់អេឡិចត្រូនិកមានដូចជា៖

- អនុក្រឹត្យលេខ៤៤៦ ស្តីពីការរៀបចំ និងមុខងាររបស់នាយកដ្ឋានគ្រប់គ្រងសារធាតុគ្រោះថ្នាក់ (ឆ្នាំ២០១៥)
- ប្រកាសលេខ៣៨៧ ស្តីពីការដាក់ឱ្យប្រើប្រាស់នូវកម្រិតកំណត់ស្តង់ដារបរិមាណជាតិពុល ឬសារធាតុគ្រោះថ្នាក់ដែលអនុញ្ញាតឱ្យបោះបង់ចោល (ឆ្នាំ២០១៥)

ក្នុងឧបសម្ព័ន្ធនៃអនុក្រឹត្យលេខ១១៣ បានចាត់ថ្នាក់ និងចែងថា សំណល់ទាំងអស់ខាងក្រោមនេះ ជាសំណល់គ្រោះថ្នាក់ដែលមានប្រភពមកពីលំនៅដ្ឋាន និងពីគ្រឹះស្ថានសាធារណៈ អគារពាណិជ្ជកម្ម និងគ្រឹះស្ថានទេសចរណ៍ផ្សេងៗទៀត៖

- សំណល់ថ្មពិល
- សំណល់បរិក្ខារអគ្គិសនី និងអេឡិចត្រូនិក
- សំណល់ដបកែវ ឬកំប៉ុង ដែលប្រលាក់ថ្នាំគីមី និងថ្នាំកសិកម្ម
- សំបកកង់ចាស់ៗ
- ប្រេងម៉ាស៊ីន
- ថ្នាំលាប ថ្នាំជ្រលក់ និងសំបករបស់វា
- សំណល់ថ្នាំម៉ាស៊ីនព្រីន
- សំណល់សារធាតុអាបស្តូស

លើសពីនេះ ក្រសួងបរិស្ថានក៏បានចែងពីការគ្រប់គ្រងសំណល់គ្រោះ និងអណ្តូងរ៉ែ។ ទោះបីជាយ៉ាងណាក៏ដោយ ការសិក្សានេះនឹងលើកយកតែសំណល់អេឡិចត្រូនិក និងសំណល់វេជ្ជសាស្ត្រតែប៉ុណ្ណោះ ដោយសារពុំមានទិន្នន័យ និងបទដ្ឋានថ្នាក់ជាតិគ្រប់គ្រាន់ទៅតាមការបែងចែកខាងលើ ដែលជាមូលដ្ឋានគ្រឹះសម្រាប់កិច្ចអន្តរាគមន៍នៅថ្នាក់ក្រោមជាតិ។

## ២.៦. សំណល់អេឡិចត្រូនិក និងបរិក្ខារអគ្គិសនី

### ក្របខណ្ឌច្បាប់ និងគោលនយោបាយ

អនុក្រឹត្យថ្មីមួយត្រូវបានចេញដោយក្រសួងបរិស្ថាននៅឆ្នាំ២០១៦ ដើម្បីគ្រប់គ្រងក្រុមហ៊ុនដែលទិញ រុះរើបំណែក និងបោះបង់ចោលសំណល់អេឡិចត្រូនិក ក៏ដូចជាតម្រូវការស្នើសុំជាមុនសម្រាប់ការផ្តួចផ្តើមប្រតិបត្តិការអាជីវកម្ម ហើយគេក៏បានបង្ហាញពីមាត្រានៃការផាកពិន័យចំពោះភាពល្មើសតាមច្បាប់នេះចំនួន ៤០.០០០ រៀល សម្រាប់បុគ្គល និង ២.០០០.០០០ រៀល សម្រាប់អាជីវកម្មផងដែរ។

- អនុក្រឹត្យស្តីពីការគ្រប់គ្រងសំណល់បរិក្ខារអគ្គិសនី និងអេឡិចត្រូនិក (ឆ្នាំ២០១៦)

### ការអនុវត្តន៍ជាក់ស្តែងលើការគ្រប់គ្រងសំណល់អេឡិចត្រូនិក និងបរិក្ខារអគ្គិសនី

ដោយសារការរីកចម្រើនរបស់ប្រជាពលរដ្ឋទូទៅ និងរបៀបរបបរស់នៅ តម្រូវការបច្ចេកវិទ្យា និងឧបករណ៍អេឡិចត្រូនិកមានការកើនឡើងក្នុងរាជធានី គ្រឿងអេឡិចត្រូនិកដែលគេប្រើរួចហើយ មានដូចជាអេក្រង់ ម៉ាស៊ីនព្រីន ក្តារចុចកុំព្យូទ័រ ធុងកុំព្យូទ័រ ម៉ាស៊ីនបញ្ចាំង LCD ទូរស័ព្ទដៃ ខ្សែភ្លើងជាដើម ត្រូវបាននាំចូលមកក្នុងប្រទេសកម្ពុជាពីបណ្តាប្រទេសផ្សេងៗ។ ឧបករណ៍ទាំងនេះមានម៉ូដែល និងទំហំខុសៗគ្នាបានបន្សល់ជាបំណែកគ្រឿងអេឡិចត្រូនិក ហើយផ្នែកខ្លះក៏អាចត្រូវបានយកមកកែច្នៃលក់ ប្រើប្រាស់ឡើងវិញ ឬប្រែក្លាយជាសំណល់អេឡិចត្រូនិក។

តាមរយៈបញ្ជីសារពើភ័ណ្ឌ ស្តីពីបរិមាណសំណល់ប្រភេទនេះ (រូបភាពទី១៧) និងទំងន់នៅក្នុងរូបភាពទី១៨ (គិតជាតោន) សម្រាប់សំណល់អេឡិចត្រូនិក ៦ប្រភេទ ដែលត្រូវបានប៉ាន់ស្មានចាប់ពីឆ្នាំ២០០៩ រហូតដល់ឆ្នាំ២០១៩ តាមរយៈរូបភាពខាងក្រោម។ ការប្រើប្រាស់សំណល់អេឡិចត្រូនិកមានការកើនឡើងពីមួយឆ្នាំទៅមួយឆ្នាំ។ បើគិតជាទម្ងន់ ទូរទស្សន៍មានច្រើនជាងគេ បន្ទាប់មកមានម៉ាស៊ីនកុំព្យូទ័រ ទូរទឹកកក ម៉ាស៊ីនត្រជាក់ និងម៉ាស៊ីនបោកខោអាវ និងទូរស័ព្ទដៃ។ បើគិតពីចំនួនទូរស័ព្ទដៃមានបរិមាណច្រើនជាងគេ និងមានកំណើនយ៉ាងឆាប់រហ័ស (ក្រសួងបរិស្ថានកម្ពុជា ឆ្នាំ២០០៩ក)។




រូបភាពទី១៧៖ ការប៉ាន់ស្មានលើកំណើនសំណល់អេឡិចត្រូនិកសម្រាប់រាជធានីភ្នំពេញ (គិតជាឯកតា)

ប្រភព៖ ក្រសួងបរិស្ថាន កម្ពុជា ២០០៩(ក)




រូបភាពទី១៨៖ ការព្យាករណ៍ការផលិតសំណល់អេឡិចត្រូនិកក្នុងរាជធានីភ្នំពេញគិតពីទម្ងន់

ប្រភព៖ ក្រសួងបរិស្ថានកម្ពុជា ២០០៩ក

នៅរាជធានីភ្នំពេញ សំណល់អេឡិចត្រូនិកភាគច្រើននៅរាយប៉ាយតាមទីផ្សារ ជាកន្លែងដែលអ្នកប្រើប្រាស់ ពាណិជ្ជករ អ្នកលក់ ថៅកែអេតចាយ និងឈ្មួញកណ្តាលជាលក្ខណៈប្រព័ន្ធទីផ្សារពាក់កណ្តាលផ្លូវការ និងក្រៅផ្លូវការ (ក្រសួងបរិស្ថានកម្ពុជា ឆ្នាំ២០០៩ក) (សូមមើលរូបភាពទី១៩ សម្រាប់ព័ត៌មានពិស្តារ)។




**រូបភាពទី១៩៖ សង្វាក់រំហូរផលិតកម្ម និងពាណិជ្ជកម្ម នៃសំណល់អេឡិចត្រូនិកក្នុងរាជធានីភ្នំពេញ**

ប្រភព៖ ក្រសួងបរិស្ថាន និងអង្គការ UNEP-DTIE ឆ្នាំ២០០៩

អ្នករើសសំណល់អេតចាយ និងឈ្មួញកណ្តាលដើរតួយ៉ាងសំខាន់ ក្នុងការប្រមូលយកសំណល់ប្រភេទនេះ។ សំណល់ដែលពួកគេទិញពីអ្នកប្រើប្រាស់ បំបែកយកគ្រឿងបំណែកដែលនៅអាចប្រើបាន ឬអាចច្នៃបានផ្សេងៗទៀត ត្រូវបានលក់ឱ្យទៅថៅកែអេតចាយសម្រាប់ការនាំចេញ។ ឯកំទេចកំទីដែលគ្មានតម្លៃត្រូវយកទៅចាក់ចោលជាមួយនឹងសំរាមទូទៅ។ យោងទៅតាមរបាយការណ៍ឆ្នាំ២០១៥ របស់ក្រសួងបរិស្ថាន បរិមាណសំណល់អេឡិចត្រូនិកត្រូវបាននាំចេញទៅប្រទេសសឹង្ហបុរី ដែលជាប្រទេសគោលដៅដ៏ធំមួយ ដែលទទួលយកសំណល់សរុបប្រមាណ ៣.៥១៤តោន ក្នុងឆ្នាំ២០១៣ និង ១.៥៨៨តោន ក្នុងឆ្នាំ ២០១៤។

ដោយសារតែគ្មានសេវាប្រមូលសំណល់អេឡិចត្រូនិក សំណល់ប្រភេទនេះមួយចំនួនត្រូវបានគេចាក់ ឬដុតចោលតាមទីតាំងមួយចំនួន ឬនៅក្បែរទីតាំងដេប៉ូអេតចាយតែម្តង ដោយគ្មានការត្រួតពិនិត្យត្រឹមត្រូវ ដែលធ្វើឱ្យមានការសាយភាយសារធាតុពុល ប៉ះពាល់ដល់សុខភាពមនុស្ស និងបរិស្ថាន (ក្រុមការងារបច្ចេកទេសរបស់ក្រសួងបរិស្ថានកម្ពុជា ឆ្នាំ២០១៣)។

សំណល់ប្រមាណពី ៣% ពីទីតាំងកែច្នៃ ឬបំបែកគ្រឿងអេឡិចត្រូនិក ត្រូវយកមកចាក់ចោល រីឯ ៩៧% ទៀត លក់ចេញទៅដេប៉ូអេតចាយក្នុងស្រុក ឬដឹកទៅលក់ឱ្យអ្នកកែច្នៃដទៃទៀតតាមតម្រូវការ។ ទោះជាយ៉ាងណាក៏ដោយ តាមការសិក្សារបស់ក្រុមការងារ CEA ក្នុងឆ្នាំ២០០៧ បានរកឃើញថាសំណល់អេឡិចត្រូនិកប្រមាណ ៨០% ត្រូវបានគេលក់យកទៅកែច្នៃ (ក្រុមការងារបច្ចេកទេសរបស់ក្រសួងបរិស្ថានកម្ពុជា ឆ្នាំ២០១៣)។

ការយល់ដឹងរបស់អាជីវករ និងដេប៉ូអេតចាយនៅមានកម្រិតនៅឡើយស្តីពីផលប៉ះពាល់អវិជ្ជមានទៅលើបរិស្ថាន និងសុខភាពមនុស្សពីការទុកដាក់សំណល់ ឬចាក់ចោលសំណល់ប្រភេទនេះមិនបានត្រឹមត្រូវ ធ្វើឱ្យមានការសាយភាយសារធាតុពុលផ្សេងៗ។ ទន្ទឹមនឹងនោះ ការអនុវត្តន៍ជាក់ស្តែងចាំបាច់ត្រូវកែលម្អនូវប្រព័ន្ធប្រមូល និងដឹកជញ្ជូន ជំរុញការទាញយកមកវិញនូវវត្ថុធាតុដើម និងការបន្សាបជាតិពុលនៅនឹងមូលដ្ឋាន ការពង្រឹងការតាមដាន ត្រួតពិនិត្យ និងការគ្រប់គ្រងនៃការនាំចូលបរិក្ខារអគ្គិសនី និងគ្រឿងអេឡិចត្រូនិកជជុះ ក៏ដូចជាការបង្កើតគម្រោងជំរុញយន្តការយករបស់ប្រើប្រាស់ចាស់ដូរជារបស់ប្រើប្រាស់ថ្មីយកទៅវិញ ដោយផ្អែកលើ EPR ផងដែរ ដែលគួរពិចារណាមើលនៅកម្រិតថ្នាក់ជាតិ និងក្រោមជាតិក្នុងរយៈពេលវែង។

## ៣. ការរៀបចំស្ថាប័ន

### ៣.១. បទបញ្ញត្តិ និងការធ្វើចំណាត់ថ្នាក់សំរាម សំណល់រឹង

រូបភាពទី២០ បង្ហាញពីការបែងចែកប្រភេទសំណល់ ដោយផ្អែកលើបទបញ្ញត្តិស្តីពីការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជននៅកម្ពុជា។




**រូបភាពទី២០៖ ការបែងចែកសំណល់ និងបទបញ្ញត្តិគ្រប់គ្រងសំណល់ដែលពាក់ព័ន្ធ នៅត្រឹមឆ្នាំ២០១៧**

ប្រភព៖ រៀបចំដោយក្រុមការងារកិច្ចសម្ភាសន៍ជាមួយនឹងក្រសួងបរិស្ថាន

## ៣.២. តួនាទី និងការទទួលខុសត្រូវរបស់ភាគីពាក់ព័ន្ធ

## ការរៀបចំស្ថាប័នថ្នាក់ជាតិ

### ក្រសួងពាក់ព័ន្ធ

តារាងទី៨ បង្ហាញសេចក្តីសង្ខេបការរៀបចំស្ថាប័ន និងទំនួលខុសត្រូវរវាងភ្នាក់ងារជាតិសម្រាប់អភិបាលកិច្ចគ្រប់គ្រងសំណល់នៅកម្ពុជា។

**តារាងទី៨៖ អាណត្តិអភិបាលកិច្ចនៃក្រសួងពាក់ព័ន្ធលើការគ្រប់គ្រងសំណល់នៅកម្ពុជា**

| ក្រសួង | ទំនួលខុសត្រូវ |
|---|---|
| ក្រសួងបរិស្ថាន | សំណល់រឹងទីក្រុង សំណល់ឧស្សាហកម្ម និងសំណល់គ្រោះថ្នាក់រួមបញ្ចូលទាំងសំណល់សំណង់ ដែលស្ថិតនៅក្រោមអគ្គនាយកដ្ឋានគាំពារបរិស្ថាន |
| ក្រសួងសុខាភិបាល | សំណល់វេជ្ជសាស្ត្រតាមរយៈនាយកដ្ឋានមន្ទីរពេទ្យ និងមន្ទីរសុខាភិបាលខេត្ត |
| ក្រសួងឧស្សាហកម្ម និងសិប្បកម្ម | បែបបទរដ្ឋបាលជាមួយនឹងវិស័យឧស្សាហកម្មឯកជន រួមទាំងការគ្រប់គ្រងសំណល់ឧស្សាហកម្ម និងជំរុញដំណើរការផលិតកម្មស្អាត។ |
| ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | ចុះបញ្ជីថ្នាំកសិកម្ម និងជីកសិកម្មក្រោមអគ្គនាយកដ្ឋានកសិកម្ម និងគ្រប់គ្រងសំណល់ដែលបញ្ចេញចោល ក្នុងកិច្ចសហការជាមួយក្រសួងបរិស្ថាន។ |
| ក្រសួងមហាផ្ទៃ | អគ្គនាយកដ្ឋានរដ្ឋបាលសហការជាមួយនឹង NCDD គ្រប់គ្រង និងគាំទ្ររដ្ឋបាលមូលដ្ឋាន (រាជធានី-ខេត្ត និងក្រុង/ស្រុក) ដើម្បីផ្សព្វផ្សាយពីវិមជ្ឈការ និងវិសហមជ្ឈការទៅដល់រដ្ឋបាលថ្នាក់ក្រោមជាតិ រួមទាំងការធ្វើឱ្យប្រសើរឡើងនូវការគ្រប់គ្រងសំរាមសំណល់រឹងផងដែរ។ |

ប្រភព៖ ក្រុមការងារពង្រាង និងកិច្ចសម្ភាសន៍ជាមួយនឹងក្រសួងពាក់ព័ន្ធ

### កិច្ចសម្របសម្រួលអន្តរក្រសួង

យន្តការសម្របសម្រួលអន្តរក្រសួងចំពោះបរិស្ថានមានការវិវត្តនៅក្នុងទសវត្សរ៍ចុងក្រោយនេះ ជាមួយនឹងការប្តេជ្ញាចិត្តផ្នែកគោលនយោបាយដ៏រឹងមាំ។ គណៈកម្មាធិការជាតិគ្រប់គ្រងការប្រែប្រួលអាកាសធាតុត្រូវបានបង្កើតឡើងក្នុងឆ្នាំ២០០៦ តាមរយៈអនុក្រឹត្យលេខ៣៥ ក្នុងគោលបំណងសម្របសម្រួល និងត្រួតពិនិត្យក្រសួង-ស្ថាប័នពាក់ព័ន្ធ ដើម្បីរៀបចំគោលនយោបាយ រៀបចំយុទ្ធសាស្ត្រ ផែនការ បទបញ្ញា និងកម្មវិធីនានាសម្រាប់គ្រប់គ្រងការប្រែប្រួលអាកាសធាតុ។ ក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍បៃតងក៏ត្រូវបានបង្កើតឡើងក្នុងឆ្នាំ២០១២ ដោយមានអាណត្តិសម្រាប់អភិវឌ្ឍន៍បទបញ្ញត្តិច្បាប់ គោលនយោបាយ យុទ្ធសាស្ត្រ ផែនការសកម្មភាព និងកម្មវិធីអភិវឌ្ឍន៍បៃតងពាក់ព័ន្ធផ្សេងៗទៀត។

ក្រៅពីការរៀបរាប់ខាងលើ បច្ចុប្បន្នក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព (NCSD) ត្រូវបានបង្កើតឡើងថ្មីនៅខែឧសភា ឆ្នាំ២០១៥ ជាអង្គភាពមួយដែលបង្រួបបង្រួមសមាសភាពពីអង្គភាពទាំង៤ រួមបញ្ចូលគ្នា៖ គណៈកម្មាធិការជាតិគ្រប់គ្រងការប្រែប្រួលអាកាសធាតុ ក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍បៃតង លេខាធិការដ្ឋានជីវសុវត្ថិភាពជាតិ និងគណៈកម្មាធិការដឹកនាំជីវៈចម្រុះជាតិ (ក្រសួងបរិស្ថានឆ្នាំ២០១៤) ដោយមានតំណាងសមាសភាពជាន់ខ្ពស់នៃក្រសួង ស្ថាប័ន អភិបាល និងមានប្រធានកិត្តិយស

ជាថ្នាក់ដឹកនាំរាជរដ្ឋាភិបាល និងរដ្ឋមន្ត្រីនៃក្រសួងបរិស្ថានជាប្រធាន។ រចនាសម្ព័ន្ធនៃក្រុមប្រឹក្សានេះ បានបង្ហាញពីការប្តេជ្ញាចិត្តខាងគោលនយោបាយខ្ពស់ និងមានឥទ្ធិពលយ៉ាងខ្លាំងក្នុងការបង្កើតក្របខណ្ឌគោលនយោបាយជាតិ តាមរយៈកម្មវិធីគ្រប់គ្រងសំរាម សំណល់រឹង នៃព្រះរាជាណាចក្រកម្ពុជា។

ការរៀបចំស្ថាប័នថ្នាក់ក្រោមជាតិត្រូវបានពន្យល់នៅក្នុងរូបភាពទី២១ ដោយមន្ទីរថ្នាក់ខេត្តនីមួយៗមានតួនាទីសំខាន់ជាអ្នកតំណាងរបស់ក្រសួងសាមីនៅថ្នាក់ខេត្ត។ ដោយឡែក រាជធានីភ្នំពេញ និងខេត្តបាត់ដំបងមាននូវទីចាត់ការ/ ការិយាល័យគ្រប់គ្រងសំរាម សំណល់រឹងផ្ទាល់ខ្លួន ឯក្រុងដទៃទៀតមាននូវការិយាល័យនៅមន្ទីរជំនាញថ្នាក់ខេត្ត (រដ្ឋបាលថ្នាក់លើ) សម្រាប់ទទួលនូវរបាយការណ៍។




## រូបភាពទី២១៖ ការរៀបចំស្ថាប័នជាតិថ្នាក់ក្រោមជាតិសម្រាប់ការគ្រប់គ្រងសំណល់

ប្រភព៖ ក្រុមការងារពង្រាងយុទ្ធសាស្ត្រ និងកិច្ចសម្ភាសន៍ជាមួយនឹងភាគីពាក់ព័ន្ធ

ក្នុងបរិបទនេះ វិមជ្ឈការបានដំណើរការក្នុងវិស័យសំណល់ រីឯទំនាក់ទំនងសហប្រតិបត្តិការរវាងរដ្ឋាភិបាលថ្នាក់ក្រោមជាតិ និងក្រសួងពាក់ព័ន្ធ តាមរយៈមន្ទីរជំនាញ។ ការគ្រប់គ្រងសំណល់ត្រូវបានទទួលការយកចិត្តទុកដាក់កាន់តែខ្លាំងឡើងក្នុងវិស័យសុខាភិបាលនៅទូទាំងប្រទេសកម្ពុជា ដែលជាបញ្ហាអាទិភាព (លោក Min ឆ្នាំ២០១៦)។ ទោះជាយ៉ាងណា កម្រិតនៃការអនុវត្តន៍ការគ្រប់គ្រងសំរាម សំណល់រឹងមានភាពខុសគ្នាក្នុងដែនសមត្ថកិច្ចនីមួយៗ ហើយអាជ្ញាធរថ្នាក់ក្រោមជាតិជាច្រើនមានការលំបាកក្នុងការបំពេញតាមតួនាទីឱ្យមានប្រសិទ្ធភាព។ ក្នុងបរិបទនេះ អនុក្រឹត្យលេខ១១៣ ចុះខែវិច្ឆិកា ឆ្នាំ២០១៥ បានកំណត់អំពីអាណត្តិរបស់រដ្ឋបាលថ្នាក់ក្រុង/ស្រុក ស្តីពីការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន ដោយមានការគាំទ្រ និងសម្របសម្រួលដោយរដ្ឋបាលខេត្ត។

នៅក្នុងវិស័យសំណល់ មន្ទីរបរិស្ថានខេត្តធ្វើការក្នុងនាមក្រសួងបរិស្ថាន ដោយមិនទាន់បានធ្វើប្រតិភូកម្មបន្ថែមទៀតទៅការិយាល័យថ្នាក់ក្រុង/ស្រុកទេ ដោយសារតែសមត្ថភាពនៅមានកម្រិតរបស់ការិយាល័យក្រុង/ស្រុករបស់ខ្លួន។ នៅថ្នាក់ក្រុង/ស្រុកមានការិយាល័យពីរប្រភេទ គឺការិយាល័យស្ថិតក្រោមការគ្រប់គ្រងដោយផ្ទាល់របស់រដ្ឋបាលក្រុង/ស្រុក (ជាទូទៅមិនទាន់មានបុគ្គលិក និងមានធនធានគ្រប់គ្រាន់) ដូចជាការិយាល័យរដ្ឋបាល និងហិរញ្ញវត្ថុ ការិយាល័យផែនការ និងគាំទ្រឃុំ/សង្កាត់ និងការិយាល័យអន្តរវិស័យ និងអ្នកដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់មន្ទីរតាមខេត្ត ដូចជាការិយាល័យបរិស្ថាន (លោក Min ឆ្នាំ២០១៦) ។ ការិយាល័យខាងលើនេះ គឺជាសេនាធិការរបស់រដ្ឋបាលក្រុង/ស្រុក និងមន្ទីររបស់ខ្លួន ដើម្បីតាមដានដំណើរការរបស់ក្រុមហ៊ុនប្រមូលសំរាម ផ្សព្វផ្សាយឯកសារស្របច្បាប់ និងលើកកម្ពស់ការយល់ដឹងដល់សហគមន៍ ការដំឡើងស្លាកសញ្ញាអប់រំបរិស្ថាន និងការរៀបចំរបាយការណ៍ពាក់ព័ន្ធដល់សាលាខេត្ត និងមន្ទីរបរិស្ថាន (លោក Min ឆ្នាំ២០១៦)។

## ការរៀបចំស្ថាប័ននៅក្នុងរាជធានីភ្នំពេញ

នៅរាជធានីភ្នំពេញ រដ្ឋបាលរាជធានីភ្នំពេញទទួលខុសត្រូវក្នុងការធានានូវការផ្តល់សេវាគ្រប់គ្រងសំរាម សំណល់រឹង និងមានការសម្របសម្រួលជំនួយបច្ចេកទេសពីមន្ទីរនានាជាសេនាធិការ នៃក្រសួងស្ថាប័នដូចបានពិពណ៌នាពីខាងដើម។ រូបភាពទី២២ បង្ហាញពីតួនាទីរបស់រដ្ឋបាលរាជធានីភ្នំពេញក្នុងការសម្របសម្រួល អ្នកពាក់ព័ន្ធនានា ហើយក្នុងនោះតារាងទី៩ ក៏បានពន្យល់អំពីតួនាទីរបស់មន្ទីរពាក់ព័ន្ធលើការងារគ្រប់គ្រង និងអភិបាលកិច្ចផងដែរ។

ទោះបីជាយ៉ាងណាក៏ដោយអនុក្រឹត្យលេខ១១៣ (ឆ្នាំ២០១៥) បានជំរុញការយកចិត្តទុកដាក់បន្ថែមទៀតផងដែរលើការផ្តល់សេវា ដែលអនុញ្ញាតឱ្យរដ្ឋាភិបាលថ្នាក់ក្រោមជាតិអាចទទួលខុសត្រូវផ្នែកខ្លះៗនៃអភិបាលកិច្ចគ្រប់គ្រងសំណល់។ នេះជាលទ្ធផលនៃកំណែទម្រង់អភិបាលកិច្ចក្នុងវិស័យសំណល់ ដោយមានការផ្ទេរការទទួលខុសត្រូវជាច្រើនទៅរដ្ឋបាលខណ្ឌ និងសង្កាត់ ហើយត្រូវបានដកស្រង់ដូចខាងក្រោម៖

- រដ្ឋបាលខណ្ឌ ត្រូវទទួលខុសត្រូវចំពោះការអនុវត្តន៍ភារកិច្ចដែលពួកគេទទួល និងជួយគាំទ្រសម្របសម្រួលដំណើរការនៃការបោសសម្អាត ការប្រមូល និងដឹកជញ្ជូនសំរាម សំណល់រឹងទីប្រជុំជន និងសេវាផ្សេងទៀតនៅក្នុងវិស័យគ្រប់គ្រងសំណល់រឹងដូចតទៅ៖
    - គ្រប់គ្រង និងអនុវត្តភារកិច្ចដែលពួកគេទទួលបានក្នុងការគ្រប់គ្រងសំណល់នៅទីប្រជុំជន
    - ចូលរួម និងសហការក្នុងការអនុវត្តន៍កម្មវិធីគ្រប់គ្រងសំរាម សំណល់រឹងក្នុងរាជធានីភ្នំពេញ
    - ចូលរួមក្នុងការតាមដានការអនុវត្តន៍នៃការសម្អាត ការប្រមូល និងដឹកជញ្ជូនសំរាម សំណល់រឹងតាមទីប្រជុំជននៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។
- រដ្ឋបាលឃុំ-សង្កាត់ ត្រូវទទួលខុសត្រូវចំពោះការអនុវត្តន៍ភារកិច្ច ដែលបានធ្វើប្រតិភូកម្ម និងបំពេញតួនាទីគាំទ្រ និងសម្របសម្រួលនៃការសម្អាត ការប្រមូល និងសេវាដឹកជញ្ជូនសំរាម សំណល់រឹងទីប្រជុំជននៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួនដូចតទៅ:
    - គ្រប់គ្រងការអនុវត្តន៍ការគ្រប់គ្រងសំរាម សំណល់រឹងតាមទីប្រជុំជនតាមការធ្វើប្រតិភូកម្ម
    - ចូលរួមក្នុងការអប់រំ និងផ្សព្វផ្សាយការងារសម្អាត ការដឹកជញ្ជូនសំរាម សំណល់រឹងនៅតាមទីប្រជុំជននៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន
    - ចូលរួមក្នុងការផ្តល់យោបល់មតិយោបល់ទាក់ទងនឹងការរៀបចំ ការសម្អាត ការប្រមូលសំរាម និងការដឹកជញ្ជូនសំរាមទីប្រជុំជនក្នុងដែនសមត្ថកិច្ចរបស់ខ្លួន
    - ចូលរួមក្នុងការតាមដានការអនុវត្តន៍នៃការសម្អាត ការប្រមូល ការដឹកជញ្ជូន និងសេវាគ្រប់គ្រងសំរាម សំណល់រឹង

ផ្សេងៗនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន

- ចូលរួមដោះស្រាយបញ្ហាទាក់ទងនឹងការសម្អាត ការប្រមូល ការដឹកជញ្ជូន និងសេវាគ្រប់គ្រងសំរាម សំណល់រឹងផ្សេងៗនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន និង
- ចូលរួមក្នុងពង្រឹងការអនុវត្តន៍វិធានការច្បាប់ និងបទបញ្ញត្តិផ្សេងៗទាក់ទងនឹងការគ្រប់គ្រងសំរាម សំណល់រឹង។

រដ្ឋបាលខណ្ឌនីមួយៗ ត្រូវបានចុះហត្ថលេខាលើអនុស្សារណៈយោគយល់ជាមួយនឹងក្រុមហ៊ុនប្រមូលសំរាម សំណល់រឹងនៅក្រោមកិច្ចសន្យាសម្បទាន ដែលមានស្រាប់រវាងក្រុមហ៊ុន និងរដ្ឋបាលរាជធានីភ្នំពេញ ដោយធ្វើការសម្របសម្រួលប្រចាំថ្ងៃលើការអនុវត្តន៍សេវាកម្មប្រមូល និងដឹកជញ្ជូនសំរាម ដែលបានប្រព្រឹត្តទៅតាមបែបវិមជ្ឈការ។

## អភិបាលកិច្ចគ្រប់គ្រងសំណល់ - គំនូសតាងភាគីពាក់ព័ន្ធ




**រូបភាពទី២២៖ ផែនទីបង្ហាញអ្នកពាក់ព័ន្ធការងារអភិបាលកិច្ចគ្រប់គ្រងសំរាម សំណល់រឹងរាជធានីភ្នំពេញ**

## តារាងទី៩៖ តួនាទី និងការទទួលខុសត្រូវរបស់មន្ទីរពាក់ព័ន្ធ លើការគ្រប់គ្រងសំណល់នៅរាជធានីភ្នំពេញ

**១. ការិយាល័យដឹកជញ្ជូនសាធារណៈ**

- តួនាទី និងការទទួលខុសត្រូវ គឺសម្អាតតាមសួន និងទីតាំងសាធារណៈដទៃទៀត ហើយវេចខ្ចប់សំណល់ ដើម្បីឱ្យក្រុមហ៊ុនប្រមូលសំរាមអាចប្រមូលទាន់ពេល
- ធ្វើការយ៉ាងជិតស្និទ្ធជាមួយនគរបាល ឬអាជ្ញាធរមូលដ្ឋាន ត្រួតពិនិត្យតាមសួន និងអនុវត្តការផាកពិន័យអ្នកចោលសំរាមលើសួន
- រាយការណ៍ទៅកាន់សាលារាជធានីឱ្យបានទៀងទាត់

**២. មន្ទីរវិចិត្រសិល្បៈ**

- គ្រប់គ្រង និងសម្អាតឧទ្យាន ឬសួនក្នុងវត្តភ្នំ និងបញ្ចេញសំណល់ឱ្យបានត្រឹមត្រូវទៅតាមកាលវិភាគប្រមូលរបស់ស៊ីនទ្រី

**៣. មន្ទីរបរិស្ថាន**

- ដើរតួរជាសេនាធិការរបស់សាលារាជធានីភ្នំពេញក្នុងការរៀបចំផែនការសកម្មភាព ស្តីពីការប្រមូលសំរាម ការស្តុកទុកបណ្តោះអាសន្ន ការដឹកជញ្ជូន និងការចាក់ចោល
- ធ្វើការជាមួយសាលារាជធានី ជាពិសេសទីចាត់ការគ្រប់គ្រងសំណល់ និងបរិស្ថានរបស់សាលារាជធានី និងអាជ្ញាធរមូលដ្ឋាន ដូចជាខណ្ឌ និងសង្កាត់ ដើម្បីត្រួតពិនិត្យបញ្ហាសំណល់នៅតាមមូលដ្ឋាន និងវាយតម្លៃផែនការមេនៃការប្រមូលសំរាមរបស់ស៊ីនទ្រី និងក្រុមហ៊ុនប្រមូលសំរាមដទៃទៀត
- ធ្វើការជាមួយអាជ្ញាធរខណ្ឌ និងសង្កាត់ ដើម្បីលើកកម្ពស់ការយល់ដឹង លើកស្លាកសញ្ញា និងធ្វើការផាកពិន័យ
- រាយការណ៍បញ្ហាគ្រប់គ្រងសំណល់ទៅកាន់សាលារាជធានីភ្នំពេញ

**៤. មន្ទីរទេសចរណ៍**

- ត្រូវផ្តល់ការណែនាំ ឬការលើកកម្ពស់ការយល់ដឹងនៅទីរមណីយដ្ឋាន ទីកន្លែងទេសចរណ៍ ផ្ទះសំណាក់ សណ្ឋាគារ ភោជនីយដ្ឋានបរទេស អំពីការញែកសំណល់ ការបញ្ចេញចោល/ ការវេចខ្ចប់ឱ្យបានត្រឹមត្រូវស្របទៅនឹងកម្មវិធីប្រមូលសំរាម

**៥. មន្ទីរអប់រំ យុវជន និងកីឡា**

- តួនាទី និងការទទួលខុសត្រូវ ត្រូវផ្តល់ការណែនាំ ឬការលើកកម្ពស់ការយលើដឹងដល់សាលារៀនរដ្ឋ និងឯកជន អំពីការញែកសំណល់ ការបញ្ចេញ/ការវេចខ្ចប់ ឱ្យបានត្រឹមត្រូវស្របទៅនឹងកម្មវិធីប្រមូលសំរាម

**៦. មន្ទីរពាណិជ្ជកម្ម**

- ផ្តល់ការណែនាំ និងការលើកកម្ពស់ការយល់ដឹងដល់អ្នកជំនួញ អ្នកលក់ដូរ អ្នកផ្តល់សេវាកម្ម ដែលបានចុះបញ្ជីនៅក្រសួងពាណិជ្ជកម្ម ដើម្បីចូលរួមក្នុងការគ្រប់គ្រងសំណល់ក្នុងរាជធានីភ្នំពេញ។ ពួកគេត្រូវរៀបចំធុងសំរាម និងវេចខ្ចប់ឱ្យបានត្រឹមត្រូវ និងទាន់ពេលវេលាសម្រាប់អ្នកប្រមូលសំរាម។

**៧. មន្ទីរឧស្សាហកម្ម និងសិប្បកម្ម**

- ផ្តល់ការណែនាំនិងការលើកកម្ពស់ការយល់ដឹងដល់សិប្បកម្ម និងអាជីវកម្មផ្សេងៗ ដែលស្ថិតនៅក្រោមការត្រួតពិនិត្យ និងគ្រប់គ្រងដោយមន្ទីរឧស្សាហកម្ម និងសិប្បកម្មឱ្យចូលរួមក្នុងការគ្រប់គ្រងសំណល់ក្នុងរាជធានីភ្នំពេញ។ ពួកគេត្រូវរៀបចំធុងសំរាម វេចខ្ចប់ឱ្យបានត្រឹមត្រូវ និងទាន់ពេលវេលាសម្រាប់អ្នកប្រមូលសំរាម។

| |
|---|
| **៨. មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**<br>• ផ្តល់ការយល់ដឹងដល់រោងចក្រ សហគ្រាស និងកម្មករ ដើម្បីចូលរួមការអនុវត្តន៍យុទ្ធសាស្ត្រគ្រប់គ្រងសំណល់ (ការវេចខ្ចប់ ឬការបញ្ចេញសំណល់បានប្រសើរជាមុន និងការញែកសំរាម)។ |
| **៩. មន្ទីរវប្បធម៌ និងសាសនា**<br>• ផ្តល់ការយល់ដឹង ឬចែកចាយព័ត៌មានដល់ទីវត្តអារាមទាំងអស់ ឱ្យចូលរួមអនុវត្តផែនការ និងយុទ្ធសាស្ត្រដើម្បីឱ្យការអនុវត្តន៍ការងារគ្រប់គ្រងសំណល់ កម្មវិធីប្រមូលសំណល់មានភាពប្រសើរឡើង ជាពិសេសកំឡុងពេលបុណ្យទានធំៗ។ ក្នុងពេលដំណាលគ្នា វត្តអារាមនីមួយៗ ត្រូវរៀបចំធុងសំរាម និងហាមចាក់សំរាមចោលមុខក្លោងទ្វារ និងជិតជញ្ជាំងព្រោះវាប៉ះពាល់ដល់សណ្តាប់ធ្នាប់ និងសុខមាលភាព។ |
| **១០. មន្ទីរសុខាភិបាល**<br>• ត្រូវចែករំលែកព័ត៌មានដល់មន្ទីរពេទ្យ គ្លីនិកតូចធំ ក្នុងរាជធានី ឱ្យចូលរួមអនុវត្តផែនការ និងយុទ្ធសាស្ត្រដើម្បីឱ្យការអនុវត្តន៍ការងារគ្រប់គ្រងសំណល់មានភាពប្រសើរឡើង។ មន្ទីរត្រូវជំរុញឱ្យមន្ទីរពេទ្យ និងគ្លីនិកធ្វើការវេចខ្ចប់សំណល់ និងញែកសំណល់ឱ្យបានត្រឹមត្រូវ និងបញ្ចេញទាន់ពេលវេលាតាមកាលកំណត់។ |
| **១១. មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី**<br>• មន្ទីរចែកចាយព័ត៌មានពីវិធានការផាកពិន័យដល់ការដ្ឋានសំណង់ទាំងអស់ ដែលបោះចោលសំណល់មិនបានត្រឹមត្រូវ។ មន្ទីរត្រូវចែករំលែកកម្មវិធី/ពេលវេលាប្រមូលសំរាម ដល់ម្ចាស់សំណង់ទាំងអស់។ ជាការចាំបាច់ត្រូវសហការជាមួយអាជ្ញាធរមូលដ្ឋាន និងមន្ទីរជំនាញ ដើម្បីធ្វើការផាកពិន័យចំពោះការដ្ឋានសំណង់ទាំងនោះ។ |

ប្រភព៖ ក្រុមការងារពង្រាងយុទ្ធសាស្ត្រ និងកិច្ចសម្ភាសន៍ជាមួយនឹងភាគីពាក់ព័ន្ធ

## ៤. ទិដ្ឋភាពទូទៅនៃបញ្ហាប្រឈមសំខាន់ៗ

បញ្ហាប្រឈមលើការងារគ្រប់គ្រងសំរាម សំណល់រឹងសំខាន់ៗនៅរាជធានីភ្នំពេញ ដែលបានរៀបរាប់នៅក្នុងជំពូកមុនព្រមទាំងពិភាក្សាក្នុងកិច្ចប្រជុំពិគ្រោះយោបល់ ត្រូវបានសង្ខេបដូចខាងក្រោម៖

### ១: សំរាម សំណល់រឹងទីប្រជុំជន

### ការចាក់ចោលសំរាម សំណល់រឹងនៅតំបន់ក្រុងពង្រីកថ្មី

ការចាក់ចោលសំរាម សំណល់រឹងក្នុងរាជធានីភ្នំពេញ គឺពឹងផ្អែកទាំងស្រុងលើទីលានចាក់សំរាមតែមួយជាមួយនឹងការអនុវត្តន៍បទដ្ឋានអនាម័យតិចតួច។ ទីតាំងទីលានចាក់សំរាមនឹងមិនអាចឆ្លើយតបទៅនឹងកំណើនសំណល់ជារៀងរាល់ថ្ងៃបានឡើយ ដរាបណាគ្មានការកាត់បន្ថយសំណល់ បង្វែរហូរសំណល់ ឬការកែច្នៃឡើងវិញ។ ការកសាងទីលានថ្មីត្រូវការថវិកាច្រើនជាពិសេសក្នុងទីក្រុងដោយសារដីមានតម្លៃថ្លៃ ហើយពេលខ្លះប្រជាពលរដ្ឋតែងតែមិនពេញចិត្តឱ្យមានកាសាងសង់ទីលានចាក់សំរាមនៅក្បែរលំនៅដ្ឋានរបស់ពួកគាត់នោះទេ។

### សេវាប្រមូលសំរាម សំណល់រឹងមិនទៀងទាត់

បណ្តាខណ្ឌនិមួយៗនៅក្នុងរាជធានីភ្នំពេញ មានចរិកលក្ខណៈខុសប្លែកពីគ្នា ទាំងស្ថានភាពសង្គមសេដ្ឋកិច្ច ភូមិសាស្ត្រ និងហេដ្ឋារចនាសម្ព័ន្ធ។ ខណ្ឌនៅក្នុងរាជធានី ទទួលបានសេវាកម្មប្រមូលសំណល់ស្ទើរតែទាំងស្រុង ចំណែកឯខណ្ឌដែលនៅជាយរាជធានី មានផ្លូវថ្នល់តិច និងខូចខាតច្រើនជាង ដែលនាំឱ្យសេវាកម្មប្រមូលសំរាមមានកម្រិតនៅឡើយ។ ការសិក្សានៅឆ្នាំ ២០១៤ របស់អង្គការ UN Habitat បានផ្តោតលើខណ្ឌនៅជាយរាជធានី និងបានប៉ាន់ប្រមាណថា ៤០% នៃសហគមន៍ក្រីក្រ

នៅរាជធានីភ្នំពេញ មិនបានទទួលសេវាប្រមូលសំរាមឡើយ។ សហគមន៍ទាំងនោះ មានជីវភាពក្រីក្រ និងមិនសូវមានលទ្ធភាពបង់ថ្លៃសេវាប្រមូលសំរាម មានលទ្ធភាពតិចតួចក្នុងការគាំទ្រសកម្មភាពដោយខ្លួនឯង ឬស្នើសុំសេវាកម្ម/ ហេដ្ឋារចនាសម្ព័ន្ធល្អជាងមុនឡើយ។ តំបន់មួយចំនួនមិនទទួលបានសេវាឡើយ ដោយសារកន្លែងទាំងនោះមានផ្លូវតូចចង្អៀត ទោះនៅតំបន់ទីប្រជុំជនក្រុងក៏ដោយ។ លើសពីនេះ និយមន័យនៃសំរាម សំណល់រឹង ដែលត្រូវប្រមូលនៅក្រោមកិច្ចសន្យារវាងក្រុមហ៊ុនប្រមូលសំរាម និងរដ្ឋបាលរាជធានីភ្នំពេញនៅបន្សល់ទុកគម្លាតដោយសារការបកស្រាយខុសគ្នា ដែលបណ្តាលឱ្យមានវិវាទលើសេវាប្រមូលសំណល់។ ជាលទ្ធផល សំរាម សំណល់រឹងប្រភេទធំៗសំពីងសំពោង ជាញឹកញាប់មិនត្រូវបានប្រមូលដោយក្រុមហ៊ុនឡើយ ធ្វើឱ្យមានការបោះចោលមិនត្រឹមត្រូវគ្មានសណ្តាប់ធ្នាប់។

## ការអនុវត្តន៍ការប្រមូល និងបញ្ចេញសំរាម សំណល់រឹងមិនមានលក្ខណៈជាប្រព័ន្ធ

ខណៈដែលខណ្ឌនៅខាងក្នុងរាជធានីភ្នំពេញទទួលបានសេវាកម្មប្រមូលសំរាម ក៏ការសម្របសម្រួលរវាងប្រជាពលរដ្ឋអាជ្ញាធរមូលដ្ឋាន និងអ្នកប្រមូលសំរាម ស្តីពីការទុកដាក់សំរាមឱ្យបានត្រឹមត្រូវកំពុងនៅខ្វះចន្លោះនៅឡើយ៖ ទីតាំងស្តុកសំរាម និងកម្មវិធីប្រមូលសំរាម ដែលបានរៀបចំដោយក្រុមហ៊ុនប្រមូលសំរាម មិនត្រូវបានប្រជាពលរដ្ឋដឹងឮបានទូលំទូលាយឡើយ រីឯការប្រមូលសំរាមក៏នៅមានការយឺតយ៉ាវដោយសារលើកពីបញ្ហាកកស្ទះចរាចរណ៍។

សំរាម សំណល់រឹងត្រូវបានដាក់នៅពីមុខផ្ទះ និងហាងនៅតាមដងវិថីក្នុងសភាពខ្វះអនាម័យ និងកកើតនូវទីតាំងគំនរសំរាមអនាធិបតេយ្យនៅក្នុងរាជធានីភ្នំពេញ។ អ្នករើសសំរាមជាញឹកញាប់រើកកាយសំរាម ដើម្បីស្វែងរកវត្ថុដែលអាចកែច្នៃឡើងវិញយកទៅលក់។ ក្នុងរដូវវស្សាសំរាមរាយប៉ាយ ពិសេសពេលមានទឹកជំនន់ទឹកភ្លៀង សំរាមបានហូរចូលទៅក្នុងប្រព័ន្ធបង្ហូរទឹកសំអុយ ឬរាយប៉ាយនៅតាមដងផ្លូវដោយគ្មានអនាម័យ។ ប្រជាពលរដ្ឋ និងក្រុមការងាររបស់ក្រុមហ៊ុនស៊ីនទ្រីបានដឹងអំពីទីតាំងគំនរសំរាមក្រៅផ្លូវការ ដែលស្ថិតនៅតាមដងផ្លូវក្នុងរាជធានីភ្នំពេញ ទោះយ៉ាងនេះក្តី មិនមានមូលដ្ឋានទិន្នន័យជាប្រព័ន្ធ ឬការដឹងឮតាមស្ថាប័នអំពីបញ្ហាទាំងនេះ ដើម្បីផ្តោតការយកចិត្តទុកដាក់រៀបចំឱ្យត្រឹមត្រូវនៅឡើយទេ។

## ការគ្រប់គ្រងទីលានចាក់សំរាម

ទីលានចាក់សំរាមដង្កោក្នុងរាជធានីភ្នំពេញ ត្រូវបានដំណើរការដោយមានការត្រួតពិនិត្យជាអប្បបរមា ដូចជា សំរាម សំណល់រឹង ត្រូវបានថ្លឹងដោយប្រើម៉ាស៊ីនធុនធ្ងន់ ប៉ុន្តែមិនមានការគ្របដីតាមស្រទាប់ ប្រព្រឹត្តកម្មទឹកសំអុយទីលាន និងការប្រើឧបករណ៍សុវត្ថិភាពការពារផ្ទាល់ខ្លួនសម្រាប់អ្នកធ្វើការនៅទីលាននោះទេ។ ខណៈហានិភ័យលើបរិស្ថាន និងសុខភាពនៃការអនុវត្តន៍បច្ចុប្បន្ន ត្រូវបានទទួលស្គាល់ដោយរដ្ឋបាលរាជធានីភ្នំពេញ ត្បិតធនធានហិរញ្ញវត្ថុមិនមានគ្រប់គ្រាន់ ដែលជាឧបសគ្គចំពោះការបន្តរៀបចំហេដ្ឋារចនាសម្ព័ន្ធគ្រប់គ្រង និងការទិញឧបករណ៍ចាំបាច់សម្រាប់ប្រតិបត្តិការប្រចាំថ្ងៃ។ ដូច្នេះភាពប្រសើរឡើងនៃលក្ខខណ្ឌការងារ និងសុខុមាលភាពអ្នករើសសំរាមក៏គួរគិតគូរបន្ថែមទៀត។

# ២: សំណល់សំណង់

## កង្វះខាតស្ថាប័ន យន្តការផ្ទួនការលើការប្រមូល ការចាក់ចោល និងការរាយការណ៍

កំណើនសំណង់អគារនៅភ្នំពេញបានបង្ហាញយ៉ាងច្បាស់ ប៉ុន្តែមិនមានស្ថិតិជាផ្លូវការអំពីបរិមាណសំណល់ពីការដ្ឋានសំណង់ ដែលមាននៅរាជធានីភ្នំពេញទេ ហើយក៏មិនដឹងថាតើសំណល់ទាំងនោះត្រូវបានគេយកទៅធ្វើអ្វីដែរ។ នៅពេលទីក្រុងបន្តរីកចម្រើន គេឃើញថាការអភិវឌ្ឍអចលនទ្រព្យសំខាន់ៗទាំងនោះនឹងបង្កផលប៉ះពាល់ផ្នែកបរិស្ថានក៏កើនឡើងផងដែរ។ ដូច្នេះ វាទាមទារឱ្យមានការសិក្សាឱ្យបានស៊ីជម្រៅមួយ ស្តីពីការបង្កើត និងការបញ្ចេញសំណល់សំណង់ជាបន្ទាន់ ដើម្បីបង្កើតនូវប្រព័ន្ធផ្លូវការមួយឈានទៅទប់ស្កាត់ការចាក់ចោលសំណល់សំណង់ដោយគ្មានសណ្តាប់ធ្នាប់ និងបង្វែរសំណល់សំណង់ចេញពីទីលានចាក់សំរាមតាមរយៈគោលការណ៍៣អ៊ែរ។

## ៣: សំណល់វេជ្ជសាស្ត្រ

### ការបែងចែកប្រភេទសំណល់នៅឯប្រភពនៅមានកម្រិត

បច្ចុប្បន្នសំណល់វេជ្ជសាស្ត្រពីមន្ទីរពេទ្យសាធារណៈ និងឯកជននៅក្នុងរាជធានីភ្នំពេញ ត្រូវបានគ្រប់គ្រងដោយសាខាកាកបាទក្រហមកម្ពុជារាជធានី។ ថ្វីបើមានការរាយការណ៍ពីសេវាគ្របដណ្តប់ពេញលេញ និងគោលការណ៍ណែនាំជាតិលើការគ្រប់គ្រងសំណល់ពីសេវាថែទាំសុខភាពក៏ដោយ តែការញែកប្រភេទសំណល់វេជ្ជសាស្ត្រនៅមានកម្រិតនៅឡើយ ជាលទ្ធផលសំណល់វេជ្ជសាស្ត្រមួយចំនួនត្រូវបានដាក់លាយឡំចូលទៅជាមួយនឹងសំណល់លំនៅដ្ឋានទូទៅ ដែលអាចបង្កគ្រោះថ្នាក់ដល់សុខភាព និងបរិស្ថាន។

## ៤: សំណល់ឧស្សាហកម្ម

ការអនុលោមទៅនឹងបទបញ្ញត្តិនៅមានកម្រិត កង្វះទិសដៅគោលនយោបាយ កិច្ចអន្តរាគមន៍ និងការគ្រប់គ្រងទីលានចាក់សំណល់ឧស្សាហកម្មនៅមិនទាន់មានលក្ខណៈបរិស្ថានត្រឹមត្រូវ ដោយផ្អែកលើបទបញ្ញត្តិថ្នាក់ជាតិ អ្នកបង្កើតសំណល់ឧស្សាហកម្មត្រូវទទួលខុសត្រូវស្របច្បាប់ក្នុងការគ្រប់គ្រងសំណល់ដែលខ្លួនបានបង្កើត។ ខណៈពេលដែលម្ចាស់រោងចក្រជាច្រើនពឹងផ្អែកលើសេវាប្រមូល និងចាក់ចោលតាមរយៈការបង់ថ្លៃសេវាទៅក្រុមហ៊ុនគ្រប់គ្រងសំណល់ឯកជន ក៏ឃើញមាននូវការចាក់ចោលសំណល់ឧស្សាហកម្មដោយគ្មានសណ្តាប់ធ្នាប់ និងខ្លះគេចវេសមិនបង់ថ្លៃសេវាជាញឹកញាប់ផងដែរ។ ទីលានចាក់សំណល់ឧស្សាហកម្មជាទីលានចំហរ និងមានការគ្រប់គ្រងតិចបំផុត ព្រមទាំងមិនមានការគ្របដី ឬប្រព្រឹត្តកម្មទឹកសំអុយទីលាន ដើម្បីការពារផលប៉ះពាល់លើបរិស្ថាននៅឡើយទេ។

កិច្ចខិតខំប្រឹងប្រែង ដើម្បីកាត់បន្ថយសំណល់ ឬសក្តានុពលក្នុងការប្រើប្រាស់ ឬកែច្នៃឡើងវិញនៅមានកម្រិតនៅឡើយ ដែលបានរារាំងសក្តានុពលបង្វែរសំណល់ទាំងនោះចេញពីទីលានចាក់សំរាម។ គេឃើញថា នៅមានភាពខ្វះខាតទាំងទិសដៅគោលនយោបាយ ច្បាប់ និងបទបញ្ញត្តិ ក៏ដូចជាកិច្ចអន្តរាគមន៍ ដែលមានប្រសិទ្ធភាពរួមទាំងកង្វះទិន្នន័យ ហើយគុណភាពទិន្នន័យនៅមានកម្រិតក្នុងការប្រមើលឃើញពីស្ថានភាពបច្ចុប្បន្ន (ការបង្កើតសំណល់ ប្រភព និងប្រភេទ) ដើម្បីអាចរៀបចំនូវការឆ្លើយតបផ្អែកគោលនយោបាយមួយដ៏សមស្របនៅឡើយ។

## ៥: សំណល់បរិក្ខារអគ្គិសនី និងអេឡិចត្រូនិក

### កង្វះស្ថាប័ន និងយន្តការផ្លូវការសម្រាប់ការប្រមូល បោះចោលសំណល់ និងការរាយការណ៍

សំណល់អេឡិចត្រូនិកនៅភ្នំពេញ ត្រូវបានប្រមូលសម្រាប់លក់បន្ត ឬប្រព្រឹត្តកម្មនៅតាមមូលដ្ឋានទាញយកមកវិញនូវវត្ថុធាតុដើមកែច្នៃសម្រាប់ការនាំចេញ ខណៈពេលដែលសំណល់មួយចំនួនត្រូវបានគេបោះបង់ចោលដោយខុសច្បាប់ និងលាយឡំជាមួយនឹងសំរាម សំណល់រឹងទូទៅ។ ទោះយ៉ាងណា ការដោះបំបែកទាញយកវត្ថុធាតុដើមកែច្នៃ និងការបោះចោលសំណល់ទាំងនោះ កំពុងប៉ះពាល់ដល់បរិស្ថាន និងបង្កគ្រោះថ្នាក់ដល់សុខភាព ហើយដូច្នេះជាចាំបាច់គេត្រូវអនុវត្តវាឱ្យបានត្រឹមត្រូវតាមលក្ខណៈបរិស្ថាន។ លើសពីនេះទៀតដោយសារការប្រមូលសំណល់ ការកែច្នៃ និងការធ្វើពាណិជ្ជកម្មសំណល់អេឡិចត្រូនិកត្រូវបានគេរកឃើញថា វាមានលក្ខណៈគ្រប់គ្រងដោយវិស័យក្រៅប្រព័ន្ធ (ឧទាហរណ៍ដោយដេប៉ូអាជីវកម្មក្រៅប្រព័ន្ធ) ដែលមិនត្រូវបានត្រួតពិនិត្យលើគុណភាពសំណល់ និងធនធានវត្ថុធាតុដើមឡើយ។ វាពិតជាមានការលំបាកក្នុងការមើលឃើញពីស្ថានភាពពិតប្រាកដ និងរៀបចំនូវការឆ្លើយតបជាគោលនយោបាយសមស្រប។

## ៦: អភិបាលកិច្ចគ្រប់គ្រងសំណល់

### កង្វះយុទ្ធសាស្ត្រគ្រប់ជ្រុងជ្រោយ និងផែនការសកម្មភាព ដើម្បីដោះស្រាយបញ្ហាសំណល់

ការកែលម្អសេវាគ្រប់គ្រងសំរាម សំណល់រឹង នៅតែបន្តជាបញ្ហាប្រឈមសាធារណៈដ៏ធំសម្រាប់រាជធានីភ្នំពេញ ដូចដែលបានទទួលស្គាល់នៅក្នុងឯកសារគោលនយោបាយពីខាងដើមរបស់រាជធានីភ្នំពេញ និងបានលើកយកមកបង្ហាញនៅក្នុងជំពូកសេចក្តីផ្តើម។ ទោះជាយ៉ាងណា យុទ្ធសាស្ត្រនេះបានកំណត់នូវបញ្ហាប្រឈម និងទិសដៅគោលនយោបាយ រដ្ឋបាលរាជធានីភ្នំពេញអាចក្តោបក្តាប់បាននៅក្នុងវិស័យនេះ ខណៈមិនទាន់មានឯកសារគោលនយោបាយជាក់លាក់ជាពិសេស ដើម្បីកែលម្អអភិបាលកិច្ចគ្រប់គ្រងសំណល់អាចដោះស្រាយបញ្ហាប្រឈមទាំងស្រុងឱ្យបានទូលំទូលាយ និងស៊ីជម្រៅនៅឡើយទេ។

### យុទ្ធសាស្ត្រអភិបាលកិច្ចគ្រប់គ្រងសណល់ដោយមានការចូលរួម

ការចូលរួមរបស់សាធារណជន គឺជាផ្នែកមួយដែលមិនអាចខ្វះបាន សម្រាប់ភាពជោគជ័យក្នុងការគ្រប់គ្រងសំណល់ ហើយកិច្ចប្រឹងប្រែងក្នុងការផ្សព្វផ្សាយនូវមានកម្រិតនូវឡើយ។ ដើម្បីនាំមកនូវការផ្លាស់ប្តូរឥរិយាបទរបស់មនុស្សម្នាក់ៗត្រូវតែដឹងពីបញ្ហាប្រឈម ដែលរដ្ឋបាលរាជធានីភ្នំពេញកំពុងប្រឈម និងតួនាទីរបស់អ្នកពាក់ព័ន្ធនីមួយៗនៅក្នុងវិស័យនេះ។ វាមានសារប្រយោជន៍ដូចគ្នា ដែលថាប្រជាពលរដ្ឋ និងអ្នកពាក់ព័ន្ធទាំងអស់មានឱកាសចូលរួមរៀបចំនូវផែនការទៅតាមដំណាក់កាលផងដែរ។ វាទាមទារឱ្យមានបណ្តាញមួយចំនួន និងកិច្ចប្រឹងប្រែងក្នុងកិច្ចសហប្រតិបត្តិការពីភាគីពាក់ព័ន្ធទាំងអស់។

### ភាពទន់ខ្សោយនៃហិរញ្ញវត្ថុសាធារណៈ និងធនធានមនុស្សសម្រាប់ការគ្រប់គ្រងសំណល់

ដើម្បីកែលម្អ និងថែរក្សាបាននូវប្រសិទ្ធភាពប្រព័ន្ធគ្រប់គ្រងសំណល់ គេមិនអាចខ្វះបាននូវមូលដ្ឋានគ្រឹះហិរញ្ញវត្ថុដ៏រឹងមាំ ជំនាញបច្ចេកទេស និងការគ្រប់គ្រងជាចាំបាច់។ ទោះជាយ៉ាងណា បច្ចុប្បន្នរដ្ឋបាលរាជធានីភ្នំពេញខ្វះខាតហិរញ្ញវត្ថុសាធារណៈចាំបាច់ ដើម្បីរៀបចំ និងប្រតិបត្តិការបង្កើតក្រុមអ្នកជំនាញ និងបំពេញតួនាទីរបស់ខ្លួនជាអ្នកសម្របសម្រួលនៃអភិបាលកិច្ចគ្រប់គ្រងសំណល់។ បញ្ហានេះ ក៏ជាភាពប្រឈមដ៏ធំមួយសម្រាប់ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធគ្រប់គ្រងសំណល់ ដោយហេតុថាបើទោះជាគម្រោងអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធជាច្រើន បានគាំទ្រហិរញ្ញវត្ថុដោយដៃគូខាងក្រៅក៏ដោយ ប្រតិបត្តិការប្រកបដោយចីរភាពរបស់ពួកគេក្លាយជាការពិបាក ដោយសារកង្វះហិរញ្ញវត្ថុសាធារណៈគ្រប់គ្រាន់សម្រាប់ប្រតិបត្តិការប្រចាំថ្ងៃ និងគ្រប់គ្រងដែលមានចំនួនច្រើនលើសពីការវិនិយោគមូលធនដើមគ្រាទៅទៀត។

### កង្វះខាតសេវាគ្រប់គ្រងសំរាម សំណល់រឹង

ការផ្តល់ហិរញ្ញប្បទាន គឺជាបញ្ហាប្រឈមដ៏ធំមួយសម្រាប់វិស័យឯកជន ដែលរាជធានីភ្នំពេញពឹងផ្អែកលើការផ្តល់នូវប្រតិបត្តិការគ្រប់គ្រងសំណល់យ៉ាងច្រើន។ប្រាក់ចំណេញមានការថយចុះ ដោយសារតែការប្រមូលប្រាក់ចំណូលពីអ្នកប្រើប្រាស់សេវាប្រមូលសំរាម សំណល់រឹងមិនពេញលេញ គឺជាឧបសគ្គដ៏ធ្ងន់ធ្ងររបស់វិស័យឯកជនសម្រាប់ការវិនិយោគចាំបាច់នានា ដើម្បីកែលម្អសេវាកម្មគ្រប់គ្រងសំណល់នេះ ដែលកំពុងនៅមានកម្រិតនៅឡើយ ហើយវាក៏ជាមូលហេតុដែលអ្នកប្រើសេវាបដិសេធមិនបង់ថ្លៃសេវា និងបង្កឱ្យមានជាវដ្តអវិជ្ជមាននេះឡើង។

III

# ជំពូកទី៣

# ជំហានឆ្ពោះទៅមុខ
# នៃយុទ្ធសាស្ត្រគ្រប់គ្រងសំណល់

Chapter III

# ជំហានឆ្ពោះទៅមុខ នៃយុទ្ធសាស្ត្រគ្រប់គ្រងសំណល់

## ១. ការរៀបចំយុទ្ធសាស្ត្រ និងផែនការគ្រប់គ្រងសំណល់

ក្នុងគោលបំណងដោះស្រាយបញ្ហាប្រឈមខាងលើ សាលារាជធានីភ្នំពេញបានរៀបចំយុទ្ធសាស្ត្រគ្រប់គ្រងសំណល់រួមជាមួយនឹងផែនការសកម្មភាពដែលពាក់ព័ន្ធ ដើម្បីដឹកនាំសកម្មភាពរបស់ខ្លួន ចែករំលែកចក្ខុវិស័យ និងបំណងនៃសកម្មភាពលើសេវាគ្រប់គ្រងសំណល់របស់ទីក្រុងជាមួយសង្គមទាំងមូល ដើម្បីលើកកម្ពស់កិច្ចសហការជាមួយអ្នកពាក់ព័ន្ធនានា និងឆ្ពោះទៅរៀបចំធ្វើឱ្យប្រសើរនូវប្រព័ន្ធគ្រប់គ្រងសំណល់ប្រកបដោយប្រសិទ្ធភាពសម្រាប់ផលប្រយោជន៍ប្រជាពលរដ្ឋរាជធានីភ្នំពេញ។

## ២. គោលការណ៍ណែនាំ

គោលការណ៍ណែនាំខាងក្រោម ត្រូវបានគេប្រើជាមូលដ្ឋានគ្រឹះក្នុងការអភិវឌ្ឍសកម្មភាពយុទ្ធសាស្ត្រ ដើម្បីធ្វើឱ្យប្រសើរឡើងនូវការអនុវត្តន៍ការគ្រប់គ្រងសំណល់បច្ចុប្បន្ន ប្រកបដោយអនាម័យ បរិស្ថាន និងនិរន្តរភាព។

- ឋានានុក្រមនៃការគ្រប់គ្រង់សំណល់៖ គឺជាឧបករណ៍យុទ្ធសាស្ត្រដែលជាសកម្មភាពអាទិភាពសម្រាប់ការស្ថាបនាប្រពន្ធ័គ្រប់គ្រងសំរាម សំណល់រឹង ដោយផ្អែកទៅលើគោលការណ៍ ៣អ៊ែរ ដែលរួមមាន៖

a. **ការកាត់បន្ថយ៖** កាត់បន្ថយការបង្កើតបរិមាណសំរាម សំណល់រឹងតាមរយៈការផ្លាស់ប្តូរបែបបទនៃការប្រើប្រាស់ផលិតផល និង/ឬ សេវាកម្ម

b. **ការប្រើប្រាស់ឡើងវិញ៖** ជួសជុលទំនិញដែលអាចជួសជុលបានឬស្វែងរកជម្រើសប្រើប្រាស់ឡើងវិញ

c. **ការកែច្នៃឡើងវិញ៖** ធ្វើការកែច្នៃសំណល់ឱ្យវាមានតម្លៃជាធនធាន/វត្ថុធាតុដើម សម្រាប់ការផលិតឡើងវិញ

d. **ការទាញយកនូវថាមពល៖** ជាការបម្លែងសំណល់ឱ្យទៅជាប្រភពថាមពល (ឥន្ធនៈ កម្តៅ និងថាមពល) ដោយបង្កើតឱ្យមានជីវៈឧស្ម័នតាមរយៈការបំបែកសំណល់ជីវៈក្នុងលក្ខខណ្ឌគ្មានខ្យល់ ការដុតសំណល់យកថាមពល និងថាមពលពីចំហេះជីវម៉ាសជាដើម

e. **ការចាក់ចោលសំណល់ទៅទីលានចាក់សំរាម ដោយមានការត្រួតពិនិត្យ ឬដុតកម្ទេចចោលដោយមិនមានការទាញយកថាមពល**

f. **ការចាក់ចោលសំណល់ទៅទីលានចាក់សំរាម ដោយមិនមានការត្រួតពិនិត្យ**




**រូបភាពទី២៣៖ ឋានានុក្រមការគ្រប់គ្រងសំណល់**

- **ការអភិរក្សធនធាន៖** សំដៅជំរុញការប្រើប្រាស់ធនធានឱ្យមានប្រសិទ្ធភាព ទាំងការទាញយកធនធានពីសំណល់មកប្រើប្រាស់ឡើងវិញ ការបញ្ចៀសការទាញយកធនធានវត្ថុធាតុដើមផ្សេងៗ និងបញ្ចៀសការបង្កើតសំណល់
- **គោលការណ៍បង់ប្រាក់សម្រាប់អ្នកបង្កើតការបំពុល៖** ជាគោលការណ៍ ដែលអ្នកបង្កើតភាពបំពុលត្រូវទទួលខុសត្រូវ ឬការបង្កើតសំរាមត្រូវតែបង់ប្រាក់ចំពោះការបំពុល ឬការគ្រប់គ្រងសំរាម (ការប្រមូល ដឹកជញ្ជូន និងចាក់ចោល) ដើម្បីរក្សាបាននូវសុខភាព បរិស្ថាន និងប្រព័ន្ធជីវសាស្ត្រចម្រុះ
- **គោលការណ៍ប្រុងប្រយត្ន័ជាមុន៖** គោលការណ៍កំណត់ពីកង្វះទិន្នន័យ/ឯកសារផ្នែកវិទ្យាសាស្ត្រ ដែលមិនគួរប្រើប្រាស់ធ្វើជាហេតុផលសម្រាប់ភាពអសកម្មដើម្បីការពារការបំផ្លាញ ឬការរិចរិលបរិស្ថាន
- **គោលការណ៍ទីតាំងផលិត៖** ជាគោលការណ៍ដែលសំរាមត្រូវដោះស្រាយទៅតាមទីតាំងផលិត កាន់តែជិត កាន់តែប្រសើរ។ មធ្យោបាយនេះ ជួយកាត់បន្ថយចំណាយថ្លៃដឹក និងកាត់បន្ថយការបំពុលបរិស្ថានកំឡុងពេលដឹកជញ្ជូន
- **គោលការណ៍នៃការផ្ដល់ប្រឹក្សា៖** គឺជាគោលការណ៍ដែលឱ្យសារៈសំខាន់ទៅលើថ្នាក់ដឹកនាំគ្រប់កម្រិតរបស់រដ្ឋបាលរាជធានីភ្នំពេញ តាមរយៈការពិគ្រោះយោបល់ និងការធ្វើការជាមួយប្រជាពលរដ្ឋ និងអង្គការនានា តាមការអភិវឌ្ឍ និងអនុវត្តផែនការសកម្មភាព និងយុទ្ធសាស្ត្រគ្រប់គ្រងសំណល់
- **ការចែករំលែកទំនួលខុសត្រូវ៖** នៅក្នុងបរិបទនេះ សំណល់សូន្យ ( Zero waste) គឺជាការទទួលខុសត្រូវរួម និងទាមទារភាពជាដៃគូ និងសហការលើគ្រប់វិស័យរបស់រដ្ឋាភិបាល ឧស្សាហកម្ម ស្ថាប័នស្រាវជ្រាវ អង្គការក្រៅរដ្ឋាភិបាល និងសហគមន៍ទូទៅ។

**រាជធានីភ្នំពេញ ជាទីក្រុងដែលមានការអភិវឌ្ឍប្រកបដោយនិរន្តរភាព មានពណ៌បៃតង និងមានបរិស្ថានល្អ ជាទីក្រុងមានការប្រើប្រាស់ធនធានប្រកបដោយចីរភាព**

## ៣. ចក្ខុវិស័យ

ផែនការប្លង់គោលអភិវឌ្ឍន៍ទីក្រុងរបស់រាជធានីភ្នំពេញ (ឆ្នាំ២០១៥) ដែលផ្ដល់នូវក្របខណ្ឌសម្រាប់ការអភិវឌ្ឍរយៈពេលមធ្យម និងរយៈពេលវែងរបស់រាជធានីបានចែងថាៈ រាជធានីភ្នំពេញនឹងក្លាយជាមជ្ឈមណ្ឌលនយោបាយ សេដ្ឋកិច្ច ពាណិជ្ជកម្ម វប្បធម៌ ប្រកបដោយសក្ដានុពលប្រកួតប្រជែង ជាមួយការអភិវឌ្ឍមួយប្រកបដោយវឌ្ឍនភាព សមធម៌ និងចីរភាព។ យុទ្ធសាស្ត្រ និងផែនការសកម្មភាពគ្រប់គ្រងសំណល់សម្រាប់រាជធានីភ្នំពេញក៏ដើរស្របតាមចក្ខុវិស័យនេះ ដែលការគ្រប់គ្រងសំណល់ និងធនធានបានរួមចំណែកឆ្ពោះទៅរកការសម្រេចបាននូវសង្គមចក្ខុវិស័យផងដែរ។ ដោយសារតែគោលនយោបាយសាកល និងនិន្នាការគោលនយោបាយសេដ្ឋកិច្ច ការសម្រេចឱ្យបាននូវសមិទ្ធផលសង្គមប្រកបដោយប្រសិទ្ធភាព គឺជាការចាំបាច់ក្នុងការទទួលបានផលប្រយោជន៍ជាយុទ្ធសាស្ត្ររបស់រាជធានីភ្នំពេញ និងលើកកម្ពស់ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ។

## ៤. បេសកកម្ម

រដ្ឋបាលរាជធានីភ្នំពេញ បានកំណត់ចេញនូវបេសកកម្មចំនួន៤ ជាមគ្គុទ្ទេសក៍គោលនយោបាយក្នុងការគ្រប់គ្រងសំរាមសំណល់រឹងរបស់ខ្លួន ដើម្បីសម្រេចបាននូវចក្ខុវិស័យខាងលើ មានដូចជាៈ

១) ការពារបរិស្ថាន និងលើកកម្ពស់សុខមាលភាពប្រជាពលរដ្ឋ
២) ការបង្កើតសង្គមមួយដែលសំណល់ ត្រូវបានកាត់បន្ថយ ប្រើប្រាស់ឡើងវិញ និងកែច្នៃឡើងវិញ ដូច្នេះសំណល់ត្រូវបានទប់ស្កាត់ដល់កម្រិតអប្បបរមា
៣) ការចូលរួមកែលំអរសង្គមឲ្យមានការបំភាយកាបូនតិច តាមរយៈការគ្រប់គ្រងសំណល់
៤) លើកកម្ពស់ការចូលរួម / កិច្ចសហការរវាងរដ្ឋាភិបាល ប្រជាពលរដ្ឋ និងអាជីវកម្មសម្រាប់ការគ្រប់គ្រងសំណល់ឱ្យមានប្រសិទ្ធភាព

## ៥. រយៈពេលនៃយុទ្ធសាស្ត្រ

ផែនការយុទ្ធសាស្ត្រនេះ នឹងក្លាយជាមគ្គុទេសក៍សកម្មភាពនៅរាជធានីភ្នំពេញ និងភាគីពាក់ពន្ធ័ចាប់ពីឆ្នាំ២០១៨ ដល់ ២០៣៥ (១៧ ឆ្នាំ)។ ទោះបីយ៉ាងណា យុទ្ធសាស្ត្រនេះក៏នឹងត្រូវធ្វើការត្រួតពិនិត្យឡើងវិញទៅតាមពេលវេលាណាមួយ ហើយត្រូវធ្វើការកែសម្រួលដោយរដ្ឋបាលរាជធានីភ្នំពេញ ដើម្បីសម្របខ្លួនទៅតាមការវិវត្តន៍នៃបរិយាកាសនយោបាយផងដែរ។

## ៦. គោលដៅ (គុណភាព) និងទិសដៅ (កម្រិត) ត្រូវសម្រេច

### ៦.១. គោលដៅទូទៅ

**ការរៀបចំបង្កើតឱ្យមានប្រព័ន្ធគ្រប់គ្រងសំណល់ប្រកបដោយលក្ខណៈបរិស្ថាន**

គោលបំណងចុងក្រោយនៃយុទ្ធសាស្ត្រ និងផែនការសកម្មភាពនេះ គឺបង្កើតប្រព័ន្ធគ្រប់គ្រងសំណល់ប្រកបដោយប្រសិទ្ធភាព កាត់បន្ថយសំណល់ និងការប្រើប្រាស់ធនធានតាមរយៈការសហការគ្នារវាងអ្នកពាក់ព័ន្ធនានាក្នុងសង្គម ដើម្បីកាត់បន្ថយហេតុប៉ះពាល់លើបរិស្ថាន និងសុខភាពជាអវិជ្ជមាន។

## ៦.២. ទិសដៅ

| ទិសដៅចម្បង | សូចនាករ | កិច្ចស្រាវជ្រាវមូលដ្ឋាន (ឆ្នាំទិន្នន័យ) *e: តួលេខប៉ាន់ស្មាន | គោលដៅរយៈពេលខ្លី (ត្រឹមឆ្នាំ ២០២៣) | គោលដៅមធ្យម ដល់រយៈពេលវែង (ត្រឹមឆ្នាំ ២០៣៥) |
|---|---|---|---|---|
| **សកម្មភាពចម្បងទី១៖ ការប្រមូលសំណល់រឹង** | | | | |
| ១-១ | ការបញ្ចេញសំណល់ក្នុងម្នាក់ (គ.ក/ម្នាក់/ថ្ងៃ) | 0.៩៨គ.ក e (2015)[1] | ១.0 គ.ក/ម្នាក់/ថ្ងៃ[2] | ១.0 គ.ក/ម្នាក់/ថ្ងៃ[1] |
| ១-២ | អត្រាប្រមូលសំណល់ទីក្រុងជាមធ្យម | ៧៥%e (2016) | ៩0%[3] | ១00%[3] |
| **សកម្មភាពចម្បងទី២៖ ការកែច្នៃសំណល់ឡើងវិញ** | | | | |
| ២-១ | អត្រាកែច្នៃឡើងវិញ[3] (សំណល់កែច្នៃអសរីរាង្គ) | n/a[5] | ៥0% ឬ ច្រើនជាង[3] | ៩៥% ឬ ច្រើនជាង[3] |
| ២-២ | អត្រាកែច្នៃឡើងវិញ[3] (សំណល់ជីវៈ) | n/a[6] | ៥% ឬ ច្រើនជាង[2] | ២0% ឬ ច្រើនជាង[2] |
| **សកម្មភាពចម្បងទី៣៖ ការធ្វើឱ្យប្រសើរឡើងនូវការគ្រប់គ្រងទីលានចាក់សំរាម សំណល់រឹង** | | | | |
| ៣-១ | ការគ្រប់គ្រងទឹកសំអុយពីទីលានចាក់សំរាម | បច្ចុប្បន្ននៅមិនទាន់មាន | សាងសង់ | ទីលានចាក់សំរាមថ្មីដំណើរការ និង អនុវត្តការគ្រប់គ្រងបែបទីលានអនាម័យ |
| ៣-២ | ការគ្រប់គ្រងឧស្ម័នពីទីលានចាក់សំរាម | បច្ចុប្បន្ននៅមិនទាន់មាន | បំពាក់ប្រព័ន្ធផ្លុំខ្យល់ចេញចូល នៅពេលដែលប្រឈមនឹងការដួលរលំ។ ប្រសិនបើមានប្រព័ន្ធឧស្ម័នទីលាន ត្រូវធ្វើការប្រមូលឧស្ម័នផលិតជាថាមពល ឬដុតកម្ទេចចោល | |
| ៣-៣ | លក្ខខណ្ឌការងារ | បច្ចុប្បន្ននៅមិនទាន់មាន | ឧបករណ៍ការពារផ្ទាល់ខ្លួនត្រូវបានណែនាំឱ្យប្រើ | |
| ៣-៤ | ការស្តារឡើងវិញធនធាននៅទីលាន | ពឹងផ្អែកលើអ្នករើសសំរាមនាពេលបច្ចុប្បន្ន | សហការជាមួយអ្នករើសសំរាម និងចាប់ផ្តើមទទួលស្គាល់តួនាទីរបស់ពួកគាត់ជាផ្លូវការ | |
| **សកម្មភាពចម្បងទី៤៖ ការគ្រប់គ្រងសំណល់ពិសេស** | | | | |
| *សំណល់សំណង់* | | | | |
| ៤-១ | ការគ្រប់គ្រងទិន្នន័យ | គ្មានទិន្នន័យនាពេលបច្ចុប្បន្ន | ទិន្នន័យសិក្សាត្រូវបានធ្វើឡើង និងរៀបចំយន្តការរបាយការណ៍មូលដ្ឋាន | ទិន្នន័យសំណល់ត្រូវប្រមូលជាប្រចាំ និងបង្ហាញជូនជាសាធារណៈផងដែរ |
| ៤-២ | អត្រាប្រមូលសំណល់ | n/a[5] | ៩0% ឬ ច្រើនជាង[2] | ១00%[2] |
| ៤-៣ | អត្រាកែច្នៃឡើងវិញ[3] | n/a[5] | ៨៥% ឬ ច្រើនជាង[2] | ១00%[2] |
| *សំណល់វេជ្ជសាស្ត្រ* | | | | |
| ៤-៤ | អត្រាប្រមូលសំណល់ | n/a[5] | ៩៥% ឬ ច្រើនជាង | ១00% |
| *សំណល់ឧស្សាហកម្ម* | | | | |
| ៤-៥ | អត្រាប្រមូលសំណល់ | n/a[5] | ៨៥% ឬ ច្រើនជាង[2] | ១00%[2] |
| ៤-៦ | អត្រាកែច្នៃឡើងវិញ[3] (សំណល់កែច្នៃអសរីរាង្គ) | n/a[5] | ៨៥% ឬ ច្រើនជាង[2] | ៩៥% ឬ ច្រើនជាង[2] |
| ៤-៧ | អត្រាកែច្នៃឡើងវិញ[3] (សំណល់ជីវៈ) | n/a[5] | ៥% ឬ ច្រើនជាង[1] | ២0% ឬ ច្រើនជាង[1] |

| ទិសដៅចម្បង | សូចនាករ | កិច្ចស្រាវជ្រាវមូលដ្ឋាន (ឆ្នាំវិភាគ) *e: តួលេខប៉ាន់ស្មាន | គោលដៅរយៈពេលខ្លី (ត្រឹមឆ្នាំ ២០២៣) | គោលដៅមធ្យម ដល់រយៈពេលវែង (ត្រឹមឆ្នាំ ២០៣៥) |
|---|---|---|---|---|
| *សំណល់អេឡិចត្រូនិក* | | | | |
| ៤-៨ | ការគ្រប់គ្រងទិន្នន័យ | គ្មានទិន្នន័យនាពេលបច្ចុប្បន្ន | ទិន្នន័យស្ថាបស្ទង់ត្រូវបានធ្វើឡើង យន្តការរបាយការណ៍មូលដ្ឋានត្រូវបានផ្តួចផ្តើម | ទិន្នន័យសំណល់ដែលធ្វើឡើងបន្តបន្ទាប់ ដែលប្រមូលបាន និងផ្តល់ជូនដល់សាធារណជនផងដែរ |
| ៤-៩ | វិធីសាស្ត្រប្រព្រឹត្តកម្ម | ផ្តល់ហានិភ័យខ្ពស់ចំពោះបរិស្ថាន និងសុខភាព | ២០% ឬច្រើនជាងនេះត្រូវបានធ្វើប្រព្រឹត្តកម្មតាមរយៈវិធីសាស្ត្រល្អប្រសើរសម្រាប់បរិស្ថាន | ៥០% ឬច្រើនជាងនេះត្រូវបានធ្វើប្រព្រឹត្តកម្ម តាមរយៈវិធីសាស្ត្រល្អប្រសើរសម្រាប់បរិស្ថាន |
| **សកម្មភាពចម្បងទី៥៖ ការចូលរួមរបស់ភាគីពាក់ព័ន្ធ** | | | | |
| ៥-១ | យន្តការផ្តល់យោបល់ | ចំនួនកំណត់ | វេទនាសម្ព័ន្ធបញ្ចេញយោបល់ត្រូវបានបង្កើតឡើង និងអាចប្រើបាន | វេទនាសម្ព័ន្ធបញ្ចេញយោបល់ត្រូវបានបង្កើតឡើង និងអាចប្រើបាន |
| ៥-២ | កម្មវិធីសិក្សាសម្រាប់ការអប់រំបរិស្ថាន | n/a[5] | ការអប់រំបរិស្ថានដែលមានទាំងការបង្រៀន និងការអនុវត្តន៍ត្រូវបានអនុវត្តនៅសាលារៀនជាង ២០% នៅក្នុងរាជធានីភ្នំពេញ | ការអប់រំបរិស្ថានដែលមានទាំងការបង្រៀននិងការអនុវត្តន៍ត្រូវបានអនុវត្តនៅក្នុងសាលារៀនទាំងអស់នៅក្នុងរាជធានីភ្នំពេញ |
| ៥-៣ | ការអនុវត្តន៍គោលការណ៍ ៣អ៊ែរ | n/a[5] | • ការស្ទង់មតិជាលើកដំបូងបានធ្វើឡើង<br>• អ្នកឆ្លើយសំណួរច្រើនជាង ៥% បានអះអាងថាការអនុវត្តន៍ ៣អ៊ែរ ជាប្រចាំថ្ងៃ | • ការស្ទង់ជាបន្តបន្ទាប់បានធ្វើឡើង<br>• អ្នកឆ្លើយសំណួរជាង ២០% បានអះអាងថាការអនុវត្តន៍ ៣អ៊ែរ ជាប្រចាំថ្ងៃ |

**កំណត់សំគាល់៖**

1. ទិន្នន័យសារពើភ័ណ្ឌពីក្រសួងបរិស្ថាន (ឆ្នាំ២០១៥)
2. ផ្អែកលើយុទ្ធសាស្ត្រគ្រប់គ្រងសំណល់ថ្នាក់ជាតិរបស់ប្រទេសកម្ពុជា
3. ផែនការយុទ្ធសាស្ត្រឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ សម្រាប់រាជធានីភ្នំពេញ
4. កំណត់ថាជា "សមាមាត្រនៃសម្ភារដែលអាចកែច្នៃឡើងវិញបាន ដែលត្រូវបានបង្វែរចេញពីការចោលទៅកាន់ទីលានចាក់សំរាម ហើយដូច្នេះមិនត្រូវចូលសំរាម = (អត្រាបង្វែរសំរាម សំណល់រឹង)" ។ សូមមើលទំព័រ ៧១-៧២ នៃឯកសារ គណៈកម្មការពង្រាងស្តីពីស្ថានភាពគោលការណ៍ ៣អ៊ែរ នៅអាស៊ី និងប៉ាស៊ីហ្វិក (ឆ្នាំ២០១៨) ។ ស្ថានភាពនៃ ៣R នៅអាស៊ី និងប៉ាស៊ីហ្វិក សម្រាប់ព័ត៌មានលម្អិត។
5. បច្ចុប្បន្នមិនមានទិន្នន័យ។ ការស្ទង់មតិ ទិន្នន័យនឹងត្រូវបានធ្វើឡើងដើម្បីកំណត់មូលដ្ឋាន និងតាមដានវឌ្ឍនភាព។
6. តួលេខដែលបានមកពីសមីការខាងក្រោម ត្រូវបានប្រើប្រាស់ជាតម្លៃប្រហាក់ប្រហែលសម្រាប់ជាទិន្នន័យគោល៖ បរិមាណសំណល់ជីវៈដែលបានបង្វែរសម្រាប់ជីកំប៉ុសនៅខណ្ឌដង្កោ (តោន/ ឆ្នាំ២០១៧)/ បរិមាណសំណល់ចាក់ចោលទៅក្នុងទីលានចាក់សំរាមដង្កោ (តោន/ ថ្ងៃ ឆ្នាំ២០១៧) ។ ) x សមាមាត្រសំណល់ជីវៈផ្អែកលើការស្ទង់មតិស្តីពីសមាសធាតុសំណល់ (ឆ្នាំ២០១៣)
   = ៥០ ត / ១.៩៦៦ត x ៥១,៩% = ៤,៩%
   យ៉ាងណាក៏ដោយ ដោយសារតែការរើសយកសំណល់អេតចាយចេញមុនពេលសំរាមចាក់ចោលនៅទីលាន អត្រាសំណល់ជីវៈនៅទីលានចាក់សំរាមត្រូវគេគិតថាខ្ពស់ជាងអត្រាដែលបានប្រើខាងលើ ដែលគេបានមកដោយការវិភាគសំណាកនៅប្រភព។ លទ្ធផលនេះមានសក្តានុពលលើសពីការប៉ាន់ប្រមាណតួលេខខាងលើ។ (ផ្អែកលើការពិភាក្សានៅកិច្ចប្រជុំចុងក្រោយនៅ រដ្ឋបាលរាជធានីភ្នំពេញ ថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០១៨)។

## ៧. សកម្មភាពចម្បង

យុទ្ធសាស្ត្រ និងផែនការសកម្មភាពគ្រប់គ្រងសំណល់សម្រាប់រាជធានីភ្នំពេញ មានគោលបំណងកំណត់សកម្មភាពចម្បងចំនួន៥ ដើម្បីសម្រេចបានគោលបំណង និងទិសដៅខាងលើ៖

### សកម្មភាពចម្បងទី១៖ ការពង្រឹងប្រព័ន្ធសេវាប្រមូល និងបញ្ចេញសំណល់ជាប្រព័ន្ធ និងការពង្រឹងគុណភាពសេវាកម្ម

វិស័យដែលទាមទារឱ្យចាត់វិធានការជាបន្ទាន់ គឺការវេចខ្ចប់សំណល់ ការបោះចោល និងការប្រមូល។ សាលារាជធានីភ្នំពេញនឹងធ្វើការជាមួយប្រជាពលរដ្ឋ គ្រឹះស្ថានពាណិជ្ជកម្ម និងអ្នកផលិតសំណល់ដទៃទៀត ក្រុមហ៊ុនប្រមូលសំរាម រួមទាំងរដ្ឋបាលខណ្ឌ និងសង្កាត់ ដើម្បីបង្កើនការយល់ដឹងសាធារណៈ ស្តីពីការគ្រប់គ្រងសំណល់រឹង ជំរុញលទ្ធភាពទទួលយកសេវាកម្មរបស់ក្រុមហ៊ុន និងការបញ្ចេញសំរាមរបស់ប្រជាពលរដ្ឋ។ សាលារាជធានីភ្នំពេញនឹងប្រឹងប្រែងធ្វើឱ្យសាធារណជនមានការយល់ដឹងពីផលប៉ះពាល់អវិជ្ជមានពីការគ្រប់គ្រងសំណល់មិនបានត្រឹមត្រូវ ការផ្លាស់ប្តូរឥរិយាបទក្នុងការបោះចោលសំរាមឱ្យប្រសើរឡើង និងការទទួលខុសត្រូវរបស់ពួកគេក្នុងការបង់ប្រាក់សម្រាប់សេវាកម្មប្រមូលសំរាមល្អប្រសើរជាងមុន។ កិច្ចការនេះអាចធ្វើទៅបានតាមរយៈកិច្ចព្រមព្រៀងរវាងភាគីពាក់ព័ន្ធ ស្តីពីការវេចខ្ចប់ត្រឹមត្រូវ ការបោះចោល ការរៀបចំធុង ឬទីតាំងស្តុកទុកបណ្តោះអាសន្ន មធ្យោបាយប្រមូល និងកម្មវិធីប្រមូល និងតំបន់ផ្តល់សេវាកម្ម។

តាមរយៈការសិក្សាទៅលើដំណើរការវិមជ្ឈការនៃការគ្រប់គ្រងសំរាម សំណល់រឹង សាលារាជធានីនឹងផ្តល់ជំនួយចាំបាច់ដល់រដ្ឋបាលខណ្ឌ និងសង្កាត់ ដើម្បីធានាប្រសិទ្ធភាពការងារក្នុងការត្រួតពិនិត្យ និងវាយតម្លៃចំពោះក្រុមហ៊ុនប្រមូលសំរាម និងអ្នកផលិតសំរាមនៅក្នុងដែនសមត្ថកិច្ចរៀងៗខ្លួន។




រូបភាពទី២៤៖ ឧទាហរណ៍នៃការប្រើម៉ូដែលប្រមូលសំរាម សំណល់រឹងផ្សេងៗ ទៅតាមតំបន់ខុសៗគ្នា

## សកម្មភាពចម្បងទី២៖ លើកកម្ពស់ការកែច្នៃឡើងវិញតាមរយៈការញែកសំណល់ ជំរុញវិស័យឯកជនកែច្នៃសំណល់ និងលើកកម្ពស់ការប្រើប្រាស់ផលិតផលកែច្នៃឡើងវិញ

ការរៀបចំ និងប្រព្រឹត្តកម្មសំរាម សំណល់រឹងជាបឋមតាមបែបចម្រុះ ជម្រើសកែច្នៃសំណល់ផ្សេងៗ គឺជាវិស័យមួយដ៏មានសារៈសំខាន់ក្នុងការកាត់បន្ថយសំណល់ទៅចាក់នៅទីលានចាក់សំរាម និងជួយសម្រួលចលនារំហូរនៃប្រភពធនធានផងដែរ។ ជំហាននេះអាចប្រព្រឹត្តទៅបាន ដរាបណាមានការបង្កើនប្រសិទ្ធភាពប្រព័ន្ធការបោះចោល/ប្រមូលសំណល់ (សកម្មភាពចម្បងទី១) ដែលគេបានរំពឹងថានឹងមានបរិមាណសំរាមប្រមូលបាន និងយកមកចាក់នៅទីលានចាក់សំរាមកាន់តែកើនឡើង។ ជាងនេះទៅទៀត កំណើននៃការប្រើប្រាស់ធនធានវត្ថុធាតុដើមពីការកែច្នៃឡើងវិញ បង្ហាញនូវភាពពឹងផ្អែកកាន់តែតិចឡើងៗលើការនាំចូលសម្ភារពីខាងក្រៅ។ ដោយសារតម្លៃទំនិញគ្រប់សារពើកាន់តែថ្លៃនៅលើទីផ្សារជាសាកល ការបង្កើនប្រសិទ្ធភាពប្រើប្រាស់ធនធានវត្ថុធាតុដើមនឹងអាចនាំជួយកាត់បន្ថយផលប៉ះពាល់អវិជ្ជមានលើសេដ្ឋកិច្ច ពីអស្ថេរភាពនៃថ្លៃទំនិញ និងអាចរួមចំណែកដល់ភាពសន្សំនៃសេដ្ឋកិច្ចនៅក្នុងរាជធានីភ្នំពេញ។

សមត្ថភាពកែច្នៃសំណល់ ក៏អាចប្រសើរឡើងតាមរយៈចម្រុញឱ្យមានវិស័យកែច្នៃឯកជនច្រើនជាងមុន និងសកម្មភាពស្ម័គ្រចិត្តក្នុងការចូលរួមរបស់អ្នកផលិតសំណល់។ ដើម្បីទាក់ទាញវិស័យកែច្នៃឯកជន ការធានាឱ្យសំណល់ (ធនធានសម្រាប់កែច្នៃ) ដែលត្រូវតែមានបរិមាណថេរ បែងចែកសណ្ឋានភាពសំណល់ច្បាស់លាស់ និងមិនមានផ្ទុកនូវសារធាតុបំពុលផ្សេងៗ គឺជាបញ្ហាប្រឈមយ៉ាងខ្លាំងសម្រាប់ចំណាប់អារម្មណ៍របស់អ្នកវិនិយោគ។ យ៉ាងណាក៏ដោយ ការសម្រេចបាននូវប្រសិទ្ធភាពញែកសំណល់នៅតាមប្រភព ទាមទារនូវកិច្ចប្រឹងប្រែងយ៉ាងខ្លាំងក្លា និងយូរអង្វែង តាមរយៈការលើកកម្ពស់ការអប់រំ និងដំណោះស្រាយផ្នែកសេដ្ឋកិច្ច/ តាមផ្លូវច្បាប់ ដែលជាធាតុមួយមិនអាចខ្វះបានក្នុងយុទ្ធសាស្ត្រនេះ។

អាស្រ័យហេតុនេះ សាលារាជធានីភ្នំពេញនឹងអញ្ជើញឱ្យវិស័យឯកជនបានចូលរួមកែច្នៃសំណល់ ស្របតាមគុណភាពសំណល់ចង់បាន ជាពិសេសមានប្រភពចេញពីអ្នកបង្កើតសំរាម សំណល់រឹងធំៗដូចជា៖ សាលារៀន សណ្ឋាគារ ភោជនីយដ្ឋាន ការិយាល័យ និងរោងចក្រ។ ការពង្រីកជម្រើសកែច្នៃ ទំហំ ព្រមទាំងការពង្រីកការប្រមូលសំណល់ញែកតាមលំនៅដ្ឋានសម្រាប់គោលបំណងកែច្នៃសំណល់ នឹងត្រូវបានរៀបចំ និងអនុវត្តជាជំហានៗទៅតាមដំណាក់កាល។ សកម្មភាពទាំងអស់នេះ នឹងជួយបំពេញដោយគម្រោងផ្សេងៗក្នុងការជំរុញ និងគាំទ្រដោយស្ម័គ្រចិត្តរបស់អ្នកបង្កើតសំណល់ ជាពិសេសនៅតាមលំនៅដ្ឋាន។ លទ្ធភាពកែច្នៃនៅក្នុងរាជធានីភ្នំពេញ អាចមានភាពប្រសើរឡើងទៅតាមដំណាក់កាល អមដោយការត្រួតពិនិត្យ និងការពង្រឹងនីតិវិធីញែកសំណល់នៅប្រភពឱ្យបានសមស្រប។




## រូបភាពទី២៥៖ វិធីសាស្ត្រ-ដំណាក់កាល ណែនាំអំពីការបែងចែកសំណល់នៅប្រភព និងលទ្ធភាពកែច្នៃ

ការជំរុញឱ្យមានការញែកសំណល់ប្រភេទណាមួយនៅប្រភព ដរាបណាសមត្ថភាពក្នុងការកែច្នៃ/ប្រព្រឹត្តកម្មរបស់វាត្រូវបានធានានៅដំណាក់កាលបន្តបន្ទាប់ទៀត។

## សកម្មភាពចម្បងទី៣៖ លើកកម្ពស់បរិស្ថានតាមរយៈការគ្រប់គ្រងការបោះចោលសំណល់ និងកាត់បន្ថយហេតុប៉ះពាល់លើបរិស្ថាន និងសុខមាលភាព

ខណៈពេលដែលមានការព្យាយាមប្រមូលសំរាមឱ្យបានពេញលេញ និងការលើកកម្ពស់ការអនុវត្តន៍គោលការណ៍ ៣អ៊ែរ (កាត់បន្ថយ ការប្រើប្រាស់ឡើងវិញ និងកែច្នៃឡើងវិញ) ត្រូវបានកំណត់អាទិភាព ដើម្បីកាត់បន្ថយផលប៉ះពាល់អវិជ្ជមានលើបរិស្ថាន និងមនុស្ស តាមរយៈការពង្រឹងការគ្រប់គ្រងទីលានចាក់សំរាម សំណល់រឹងប្រកបដោយចីរភាពផងដែរ។ នៅក្នុងសកម្មភាពចម្បងទី៣ ហេដ្ឋារចនាសម្ព័ន្ធ និងសារៈសំខាន់ក្នុងការថែទាំ និងប្រតិបត្តិការទីលាននឹងត្រូវបានពង្រឹងជាបន្តបន្ទាប់ ដើម្បីសម្រេចបាននូវទីលានសំរាមបែបអនាម័យ។ សេចក្តីណែនាំអំពីវិធានការស្តារឡើងវិញនូវធនធានដូចជា ការប្រមូលឧស្ម័ននៅទីលានចាក់សំរាម និងប្រព័ន្ធញែកសំណល់នៅប្រភពក៏នឹងត្រូវបានគេចាត់ទុកថាជាជម្រើសមួយដ៏មានសក្តានុពល និងអាចធ្វើទៅបានផងដែរ។

ការកែលម្អបច្ចេកទេស ត្រូវអមដោយកិច្ចខិតខំប្រឹងប្រែង ដើម្បីធានានូវធនធានហិរញ្ញវត្ថុសមស្រប។ រដ្ឋបាលរាជធានីភ្នំពេញ នឹងស្វែងរកជម្រើសផ្សេងៗនៃការផ្តល់ហិរញ្ញប្បទានដូចជា ការបង្កើនថ្លៃសេវាសំណល់ និងការដាក់បញ្ចូលទៅក្នុងថវិកាប្រចាំឆ្នាំរបស់រាជធានី ដោយផ្អែកលើការប៉ាន់ប្រមាណនៃចំណាយ ដែលត្រូវការសម្រាប់ការគ្រប់គ្រងប្រកបដោយសុវត្ថិភាពនៅទីលានចាក់សំរាម។ ទិដ្ឋភាពសង្គមនៃការគ្រប់គ្រងសំណល់ដូចជា ការការពារសុខភាពរបស់កម្មករនៅទីលាន និងការប្រែក្លាយជាផ្លូវការនៃវិស័យសំណល់ក្រៅប្រព័ន្ធ (ឧទាហរណ៍ៈ អ្នករើសសំរាម និងអាជីវករលក់ដូរនៅលើទីលាន) ក៏នឹងត្រូវបានដោះស្រាយផងដែរ។

## ការបង្កើតប្រព័ន្ធគ្រប់គ្រងសំណល់សំណង់

ក្នុងបណ្តាប្រភេទសំណល់ជាច្រើន នៃសំណល់រឹងទីប្រជុំជន សំណល់សំណង់ ត្រូវបានគេមើលឃើញថាជាបន្ទុកមួយដ៏ធ្ងន់ធ្ងរសម្រាប់ប្រព័ន្ធគ្រប់គ្រងសំណល់ ដោយសារបរិមាណរបស់វា និងការទាមទារការទុកដាក់ជាពិសេស។ ដើម្បីដោះស្រាយបញ្ហា ដែលកំពុងកើនឡើងនៃសំណល់ប្រភេទនេះរួមមានបន្ទុកទៅលើទីលាន គេត្រូវរៀបចំឡើងនូវពហុអន្តរាគមន៍។

ដំបូងគេត្រូវរៀបចំបទដ្ឋានគតិយុត្តិ ហើយត្រូវអនុវត្តនៅថ្នាក់រាជធានី ដើម្បីចែងឱ្យច្បាស់ពីតួនាទី និងការទទួលខុសត្រូវ និងណែនាំពីសកម្មភាពផ្សេងៗរបស់ភាគីពាក់ព័ន្ធ។ រដ្ឋបាលរាជធានីភ្នំពេញនឹងខិតខំប្រឹងប្រែងពង្រឹងក្នុងការប្រមូល និងការគ្រប់គ្រងទិន្នន័យ ស្តីពីសំណល់សំណង់ ដើម្បីធានាថាការបង្កើតគោលនយោបាយសមស្របផ្អែកលើស្ថានភាពជាក់ស្តែង (ការបង្កើតសំណល់ ការប្រមូល ប្រព្រឹត្តកម្ម និងការចាក់ចោល)។ រដ្ឋបាលរាជធានីភ្នំពេញ ក៏នឹងលើកកម្ពស់ការអនុវត្តន៍៣អ៊ែរ លើប្រភេទសំណល់សំណង់តាមរយៈការចូលរួម និងសហការជាមួយទីតាំងឧស្សាហកម្មដែលពាក់ព័ន្ធ និងការពង្រឹងវិធានការប្រឆាំងនឹងការចោលសំណល់សំណង់ដោយគ្មានសណ្តាប់ធ្នាប់។

## សំណល់វេជ្ជសាស្ត្រ

សាខាកាកបាទក្រហមកម្ពុជារាជធានី ជាអ្នកគ្រប់គ្រងសំណល់វេជ្ជសាស្ត្រក្នុងរាជធានីភ្នំពេញ ផ្តេកលើកិច្ចសន្យាសេវារបស់ខ្លួនជាមួយនឹងទីតាំងផ្តល់សេវាថែទាំសុខភាពនីមួយៗ និងធ្វើការដុតកម្ទេចក្នុងឡមុននឹងធ្វើការចាក់ចោលក្នុងរណ្តៅដាច់ដោយឡែកនៅទីលានដង្កោ។ រីឯសាលារាជធានីភ្នំពេញ ក្នុងនាមជាស្ថាប័នគ្រប់គ្រងនឹងជួយដល់ស្ថាប័ន និងក្រសួងផ្សេងៗទទួលខុសត្រូវក្នុងសកម្មភាពលើកកម្ពស់ការយល់ដឹង និងអាចឆ្លៀតពេលចុះត្រួតពិនិត្យម្តងម្កាលនៅតាមទីតាំងផ្តល់សេវាថែទាំសុខភាពទាំងនោះ ដើម្បីធានាភាពត្រឹមត្រូវក្នុងការញែក រហូតដល់ការចាក់ចោលសំណល់វេជ្ជសាស្ត្រឱ្យស្របទៅតាមគោលនយោបាយ និងគោលការណ៍ណែនាំពីថ្នាក់ជាតិ។

## សំណល់ឧស្សាហកម្ម

តាមរយៈការអភិវឌ្ឍខ្លាំងក្លាក្នុងវិស័យកាត់ដេរ សំណង់ ទេសចរណ៍ និងកសិកម្ម ក្នុងរបាយការណ៍ឆ្នាំ២០១៧ របស់ធនាគារពិភពលោកបានប៉ាន់ស្មានថា អត្រាកំណើនផ្នែកសេដ្ឋកិច្ចរបស់កម្ពុជា គឺមានប្រមាណ ៦,៩% ដែលជាអត្រាខ្ពស់ជាងគេមួយខាងផ្នែកសេដ្ឋកិច្ចនៅក្នុងពិភពលោក (ធនាគារពិភពលោក ឆ្នាំ២០១៧)។ ដោយសារការអភិវឌ្ឍវិស័យឧស្សាហកម្មឥតឈប់ឈរ តម្រូវការក្នុងការគ្រប់គ្រងសំណល់មកពីដំណើរការឧស្សាហកម្មក៏កើនឡើង បង្កឱ្យមានផលប៉ះពាល់អវិជ្ជមានដល់បរិស្ថាន និងជីវិតមនុស្ស។ ក្របខណ្ឌច្បាប់ថ្នាក់ជាតិ បានដាក់បន្ទុកលើអ្នកបង្កើតសំណល់ ជាអង្គភាពទទួលខុសត្រូវដោយខ្លួនឯង ឬតាមរយៈសេវាកម្មផ្តល់ដោយក្រុមហ៊ុនគ្រប់គ្រងសំណល់ឧស្សាហកម្មឯកជន។ សាលារាជធានីភ្នំពេញនឹងពង្រឹងការត្រួតពិនិត្យ ដើម្បីធានាការអនុវត្តន៍នៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។

ជំហានដំបូង ត្រូវធានាថាអ្នកបង្កើតសំណល់ទាំងអស់ត្រូវធ្វើប្រព្រឹត្តកម្មប្រកបដោយសុវត្ថិភាពបរិស្ថានត្រឹមត្រូវ និងធ្វើការទុកដាក់សំណល់ដែលខ្លួនបានបង្កើតដោយខ្លួនឯង ឬតាមរយៈសេវារបស់ក្រុមហ៊ុនគ្រប់គ្រងសំណល់ឧស្សាហកម្មឯកជន។ តាមរយៈការគិតគូរទៅលើសមត្ថភាពនៅខ្វះខាតច្រើនរបស់អ្នកបង្កើតសំណល់ ក្នុងការងារដោះស្រាយបញ្ហាសំណល់ដោយខ្លួនឯង សាលារាជធានីភ្នំពេញនឹងផ្តល់ការយកចិត្តជាអាទិភាពចំពោះពួកគេ និងធានាថាពួកគេស្ថិតនៅក្រោមកិច្ចសន្យាជាមួយក្រុមហ៊ុនគ្រប់គ្រងសំរាម ព្រមទាំងពង្រឹងការត្រួតពិនិត្យលើការបោះចោល ឬប្រព្រឹត្តកម្មដោយគ្មានសណ្តាប់ធ្នាប់។

សាលារាជធានីភ្នំពេញ នឹងសហការជាមួយមន្ទីរពាក់ព័ន្ធស្របទៅតាមសកម្មភាពចម្បងទី២ ក្នុងការជំរុញការកែច្នៃ

សំណល់ឧស្សាហកម្មដែលមានតម្លៃ តាមរយៈការទាក់ទាញការវិនិយោគក្នុងវិស័យនេះ ដោយសម្របសម្រួល ផ្គូផ្គងអាជីវកម្ម រវាងក្រុមហ៊ុនផលិតសំណល់ឧស្សាហកម្ម និងក្រុមហ៊ុនកែច្នៃ។

## សំណល់បរិក្ខារអគ្គិសនី និងអេឡិចត្រូនិក

ការប្រើប្រាស់ឧបករណ៍បច្ចេកវិទ្យាព័ត៌មានទំនាក់ទំនង រួមទាំងឧបករណ៍អេឡិចត្រូនិក និងឧបករណ៍អគ្គិសនីកំពុងមានសន្ទុះកើនឡើងយ៉ាងឆាប់រហ័ស ស្របនឹងការអភិវឌ្ឍសេដ្ឋកិច្ចបណ្តាលឱ្យសំណល់អេឡិចត្រូនិកក្នុងទីក្រុងមានការកើនឡើង។ សាលារាជធានីភ្នំពេញ មានគោលបំណងទប់ស្កាត់កុំឱ្យសំណល់ប្រភេទនេះទៅលាយឡំជាមួយសំណល់រឹងទូទៅ តាមរយៈកិច្ចប្រឹងប្រែងបង្វែរសំណល់អេឡិចត្រូនិកយកទៅឱ្យអាជីវកម្មកែច្នៃឡើងវិញ។ ដើម្បីសម្រេចបានគោលដៅនេះ បទដ្ឋានស្តង់ដានៃការបំភាយឧស្ម័ន និងគោលការណ៍ណែនាំប្រតិបត្តិការ ស្តីពីការគ្រប់គ្រងសំណល់អេឡិចត្រូនិកត្រូវតែរៀបចំ និងផ្សព្វផ្សាយដល់អាជីវកម្មកែច្នៃ ដើម្បីត្រួតពិនិត្យការអនុវត្តន៍ការគ្រប់គ្រងសំណល់អេឡិចត្រូនិក ខណៈពេលដែលទិន្នន័យរបស់អាជីវកម្មកែច្នៃ និងបរិមាណសំណល់ប្រភេទនេះត្រូវបានចងក្រងទុក ហើយបញ្ជីឈ្មោះអាជីវកម្មកែច្នៃ ដែលមានស្នាដៃល្អត្រូវរៀបចំឡើយ និងធ្វើការចែករំលែក។ យុទ្ធនាការប្រមូលសំណល់អេឡិចត្រូនិក ដែលផ្តោតលើអ្នកប្រើប្រាស់ អាចរៀបចំដោយមានការសហការគ្នាជាមួយសហគ្រាសឯកជន (ផ្សារទំនើប និង/ឬហាងលក់គ្រឿងអេឡិចត្រូនិក) ដោយមានគោលដៅបង្កើនប្រសិទ្ធភាពប្រមូលជំនួសការទិញវិញ។

## សកម្មភាពចម្បងទី៥៖ ការចែករំលែកចក្ខុវិស័យ និងជំរុញឱ្យមានការចូលរួមពីភាគីពាក់ព័ន្ធសម្រាប់សកម្មភាពរួម

ចក្ខុវិស័យ និងការចូលរួមពីភាគីពាក់ពន្ធ័នូវសកម្មភាពរួម ការអញ្ជើញប្រជាពលរដ្ឋ អាជីវករ និងអង្គការក្រៅរដ្ឋាភិបាល ដើម្បីធ្វើផែនការ និងអនុវត្ត គឺជាផ្នែកដែលមិនអាចខ្វះបានក្នុងអភិបាលកិច្ចគ្រប់គ្រងសំណល់រាជធានីភ្នំពេញ។ ដោយសារគ្រប់សកម្មភាពរស់នៅប្រចាំថ្ងៃរបស់យើង សំណល់ត្រូវបានបង្កើតឡើង ហើយវាត្រូវការចាំបាច់នូវការចាប់ផ្តើមផ្លាស់ប្តូរឥរិយាបទពីបុគ្គលម្នាក់ៗ ដើម្បីឱ្យមានដំណោះស្រាយដ៏មានប្រសិទ្ធភាព។ ការចែករំលែកទស្សនវិស័យ បេសកកម្ម និងសកម្មភាពដែលចង់បានក្នុងសង្គមតាមរយៈការចូលរួមរបស់សាធារណជន គឺជាជំហានដ៏មានប្រសិទ្ធភាពមួយ ដើម្បីទាក់ទាញសកម្មភាពបុគ្គលម្នាក់ៗ។ លើសពីនេះ ផែនការ និងគោលនយោបាយរបស់រដ្ឋបាលរាជធានីភ្នំពេញអាចឱ្យសាធារណជនទទួលយកបានកាន់តែច្រើន ខណៈពេលភាពត្រឹមត្រូវសមរម្យត្រូវបានលើកស្ទួយកាន់តែខ្លាំង តាមរយៈការផ្តល់ឱកាសសម្រាប់ការសិក្សាស្វែងយល់ភាពតំណាង កិច្ចពិភាក្សារួមគ្នា ព្រមទាំងការចែកចាយ និងឆ្លុះបញ្ចាំងពីគំនិតក្នុងប្រធានបទគ្រប់គ្រងសំណល់ផ្សេងៗ។

ការអប់រំបរិស្ថានចាំបាច់ត្រូវធ្វើការគិតគូរពិចារណា ជាពិសេសផ្អែកលើសមត្ថភាពរបស់ខ្លួនក្នុងការផ្តល់ឱ្យមនុស្សជំនាន់ក្រោយ (អ្នកប្រើប្រាស់បន្ទាប់ និងអ្នកបង្កើតសំរាម) ឱ្យមានការយល់ដឹងអំពីការទទួលខុសត្រូវរបស់ពួកគេក្នុងកិច្ចគាំពារបរិស្ថាន និងធម្មជាតិ ដែលជាមូលដ្ឋានគ្រឹះនៃជីវភាពរស់នៅរបស់យើងទាំងអស់គ្នា និងការផ្លាស់ប្តូរឥរិយាបថ ឆ្ពោះទៅរកការរស់នៅប្រកបដោយនិរន្តរភាព។ ថ្វីបើវិធានការបែបនេះអាចនឹងប្រើប្រាស់ពេលវេលាយូរក្នុងការទទួលបាននូវផល ឬមើលឃើញនូវផ្លែផ្ការបស់វាក៏ដោយ ក៏វាជាសកម្មភាពមិនអាចខ្វះបានសម្រាប់ការធ្វើឱ្យប្រសើរឡើងបន្តិចម្តងៗ ឆ្ពោះទៅរកសង្គមមួយដែលមានការប្រើប្រាស់ធនធានវត្ថុធាតុដើមតិចជាងមុនក្នុងរយៈពេលវែងបាន។

សម្រាប់ការផ្សព្វផ្សាយជាសាធារណៈ គេគួររៀបចំយុទ្ធសាស្ត្រផ្សព្វផ្សាយសម្រាប់សាធារណៈ និងធ្វើបច្ចុប្បន្នភាពទៅតាមពេលវេលា និងអាស្រ័យទៅតាមភាគីពាក់ព័ន្ធ ដែលជាគោលដៅអប់រំផ្សព្វផ្សាយ។ វិធីសាស្ត្រផ្តល់ព័ត៌មានផ្សព្វផ្សាយបែបចម្រុះទៅតាមប្រព័ន្ធផ្សព្វផ្សាយ (ការបោះពុម្ព ឌីជីថល ទូរទស្សន៍ វិទ្យុ ជាដើម) និងក្លាយជាឱកាស (ព្រឹត្តការណ៍ និងការអប់រំផ្លូវការ។ល។) ក្នុងការគិតគូរ ដើម្បីធានាបាននូវប្រសិទ្ធភាពទំនាក់ទំនងទៅកាន់ភាគីពាក់ព័ន្ធក្នុងសង្គមជាអតិបរមា។




រូបភាពទី២៦៖ កិច្ចអន្តរាគមន៍តាមសកម្មភាពចម្បងៗសម្រាប់ការរៀបចំប្រព័ន្ធគ្រប់គ្រងសំណល់បែបចម្រុះ

## ៨. រចនាសម្ព័ន្ធទូទៅនៃយុទ្ធសាស្ត្រ និងផែនការសកម្មភាព

គំនូសតាងខាងក្រោមបង្ហាញនូវរចនាសម្ព័ន្ធទូទៅនៃយុទ្ធសាស្ត្រនេះ។




រូបភាពទី២៧៖ រចនាសម្ព័ន្ធរួមនៃយុទ្ធសាស្ត្រ និងផែនការសកម្មភាព

IV

# ជំពូកទី៤

# ផែនការសកម្មភាព

Chapter IV

# ផែនការសកម្មភាព

## ១. សកម្មភាពចម្បងទី១៖ ការពង្រឹងប្រព័ន្ធសេវាប្រមូល ការបញ្ចេញសំណល់ និងការពង្រឹងគុណភាពសេវាកម្ម

### សកម្មភាពទី១.១. ធ្វើឱ្យប្រសើរឡើងនូវទម្លាប់នៃការបញ្ចេញសំណល់ និងកំណត់ទីតាំងស្តុកសំណល់បណ្តោះអាសន្ន

#### គោលបំណង

ដើម្បីធ្វើឱ្យប្រសើរឡើងនូវការវេចខ្ចប់សំរាម និងការបញ្ចេញសំរាមរបស់ប្រជាពលរដ្ឋ (អ្នកបង្កើតសំណល់) និងដើម្បីឱ្យការបញ្ចេញសំរាមមកទាន់ពេលវេលា និងមានប្រសិទ្ធភាពក្នុងការប្រមូលដោយក្រុមហ៊ុនប្រមូលសំរាម។

#### ស្ថានភាពបច្ចុប្បន្ន

នៅរាជធានីភ្នំពេញ ការវេចខ្ចប់សំណល់ និងការបញ្ចេញសំរាមចោល ត្រូវបានគេអនុវត្តដោយមិនត្រឹមត្រូវទាំងនៅតាមផ្ទះ និងតាមទីតាំងសាធារណៈផងដែរ។

- អ្នករស់នៅក្នុងរាជធានីភ្នំពេញ ជាទូទៅពួកគេដាក់បញ្ចូលសំណល់ផ្សេងគ្នាទៅក្នុងថង់ប្លាស្ទិក/ធុងតែមួយ។ គេដាក់លាយឡំគ្នានូវសំណល់សើម សំណល់ស្ងួត សំណល់អេឡិចត្រូនិក និងសំណល់គ្រោះថ្នាក់តាមលំនៅដ្ឋាន។ ករណីខ្លះ សំណល់ធំៗ ត្រូវបានបញ្ចេញចោលជាមួយសំណល់ទូទៅដោយមិនបានចងឱ្យបានត្រឹមត្រូវ។
- ប្រជាពលរដ្ឋត្រូវបានអនុញ្ញាត/ណែនាំឱ្យដាក់សំរាមនៅមុខផ្ទះ។ សម្រាប់អ្នករស់នៅជាន់ទី២ ឬខ្ពស់ជាងនេះអាចដាក់ក្បែរជណ្តើរប្រើរួមគ្នា។ ទោះជាយ៉ាងណាក៏ដោយ សំណល់ទាំងនេះត្រូវបានគេនាំយកមកដាក់តាមដងផ្លូវ តាមមាត់លូ ឬកន្លែងទំនេរ ដើម្បីជៀសវាងកខ្វក់ផ្ទះរបស់ខ្លួន និងពិបាកឡើងជណ្តើរ។
- សំណល់ត្រូវដាក់ក្នុងស្បោងប្លាស្ទិក (ជាធម្មតាស្បោងចាស់ៗ) ឬក្នុងធុងដោយមិនបានចងថង់។ សំណល់រប៉ាត់រប៉ាយតាមធុងសំរាម ដោយសារដាក់ច្រើនពេកបណ្តាលឱ្យខូចអនាម័យ ខូចសោភ័ណភាព និងពិបាកក្នុងការប្រមូល ដែលករណីនេះ កើតឡើងភាគច្រើននៅពេលល្ងាច។
- ប្រជាពលរដ្ឋភាគច្រើននៅមិនទាន់យល់ដឹងពីទីតាំង និងពេលវេលាត្រូវបញ្ចេញសំរាមនៅឡើយ។
- ការអនុវត្តន៍តាមគោលការណ៍បញ្ចេញចោលសំរាម សំណល់រឹង គឺមានតិចតួចណាស់នៅរាជធានីភ្នំពេញ ហើយមានប្រជាជនតែប្រមាណ ៣៦% ដែលត្រូវបានបណ្តុះបណ្តាល និងផ្តល់ព័ត៌មានអំពីការគ្រប់គ្រងសំណល់។ ជាលទ្ធផលសំណល់ត្រូវបានបញ្ចេញយឺតពេល ដាក់រាយប៉ាយតាមផ្លូវ និងសំណល់ខ្លះត្រូវបានរាយប៉ាយដោយសារសត្វ និងអ្នករើសអេតចាយ។
- នៅតំបន់ទីធ្លាសាធារណៈខ្លះ ដែលក្រុមហ៊ុនប្រមូលសំរាមមិនអាចទៅប្រមូលដល់ទេ សំរាមត្រូវបានបញ្ចេញចោលនៅតាមសង្កាត់ ដោយដាក់ជាគំនរសំរាមតាមដងផ្លូវជាដើម ដែលរំខានដល់ការធ្វើចរាចរណ៍នៅក្នុងតំបន់នោះផងដែរ។

ឧទាហរណ៍ សំរាមដែលមិនបានប្រមូលបង្កឱ្យមានផលប៉ះពាល់យ៉ាងសម្បើមដល់អនាម័យ និងបរិស្ថាននៅក្នុងតំបន់នោះ។ បន្ថែមពីនេះទៀត ទម្លាប់ចាក់សំរាមដោយគ្មានសណ្តាប់ធ្នាប់ និងការទុកដាក់សំរាមមិនត្រឹមត្រូវ ឬរាយប៉ាយ គឺត្រូវបានចាក់ឬសគល់យ៉ាងជ្រៅក្នុងផ្នត់គំនិតប្រជាជន ដែលពួកគាត់អាចបោះសំរាមចោលនៅលើផ្លូវ ឬមិនថានៅទីតាំងសាធារណៈក្តី ហើយក្នុងករណីខ្លះ ក៏មានការដាក់សំរាមនៅខាងក្រៅធុងសំរាមជាដើម។

- ការចោលសំរាមគ្មានសណ្តាប់ធ្នាប់នៅរាជធានីភ្នំពេញ កើតឡើងរហូតក្លាយជាទម្លាប់មិនល្អមួយ និងជាសកម្មភាពតៗគ្នាទៅហើយ កាលណាសកម្មភាពទាំងនេះកើតមានជាញឹកញាប់ វានឹងជះឥទ្ធិពលដោយប្រយោល ហើយទម្លាប់អាក្រក់នេះក៏រាលដាលទៅកាន់អ្នកដទៃផ្សេងៗទៀតផងដែរ ក្នុងការទទួលយកទម្លាប់បោះចោលសំរាមដូចគ្នាដែរ។ យុទ្ធនាការការអប់រំ ឬការផ្សព្វផ្សាយនៅមានតិចតួចណាស់ ដើម្បីអប់រំដល់សាធារណជនឱ្យទទួលខុសត្រូវលើផ្នែកបរិស្ថាន និងរបៀបរបបក្នុងការបញ្ចេញសំរាមចោលឱ្យបានត្រឹមត្រូវនោះ។
- ធុងដាក់សំរាមប្រភេទធំៗមួយចំនួន ត្រូវបានដាក់នៅតាមទីតាំងសមស្រប ជាធុងធំដាក់សំរាមបណ្តោះអាសន្នបានយ៉ាងច្រើន។ ប៉ុន្តែជាទូទៅ វាមានសភាពកខ្វក់ដោយសារសំរាមជ្រុះរាយប៉ាយជុំវិញធុង ហើយជាលទ្ធផលមានការតវ៉ាច្រើនពាក់ព័ន្ធទៅនឹងអនាម័យ ហើយធុងធំៗទាំងនោះ ត្រូវបានចល័តយកទៅដាក់តាមទីតាំងផ្សេងៗទៀត ដោយគ្មានការត្រួតពិនិត្យត្រឹមត្រូវ។

## សកម្មភាព

**a. សម្រេចចិត្តលើវិធានការបែងចែកសំណល់ ដោយផ្អែកលើសមត្ថភាពប្រព្រឹត្តកម្មដូចខាងក្រោម:**

- រដ្ឋបាលរាជធានីភ្នំពេញ នឹងរៀបចំនូវប្រព័ន្ធញែកសំណល់នៅទូទាំងរាជធានី ដោយផ្អែកលើវិធីសាស្ត្រ និងសមត្ថភាពជាក់ស្តែង។ វិធីសាស្ត្រប្រព្រឹត្តកម្មសំណល់អាចមានដូចជា ការផលិតជីកំប៉ុស ប្រព័ន្ធជីវឧស្ម័នពីសំណល់ជីវៈ ក៏ដូចជាវិធីសាស្ត្រកែច្នៃឡើងវិញជាច្រើនសម្រាប់សំណល់ដែលមិនមែនជាសំណល់ជីវៈ (កំប៉ុង កញ្ចក់ លោហៈ ប្លាស្ទិកជាដើម)
- សេចក្តីកង្វល់របស់ក្រុមហ៊ុន/ ស្ថាប័នប្រព្រឹត្តកម្មសំណល់នានានឹងត្រូវពិចារណាក្នុងការរៀបចំវិធានញែកសំណល់នៅប្រភព រួមទាំងលក្ខខណ្ឌបញ្ចេញសំណល់។ ឧទា. ផលិតកម្មជីវឧស្ម័នតម្រូវឱ្យប្រជាពលរដ្ឋកាត់បន្ថយការលាយឡំជាមួយនឹងសំណល់អសរីរាង្គ ដើម្បីរក្សាគុណភាពនៃផលិតកម្ម និងទិន្នផល ដើម្បីទ្រទ្រង់ប្រតិបត្តិការរបស់ខ្លួន
- ជាយុទ្ធសាស្ត្រសំខាន់នោះ ប្រភេទសំណល់អាចត្រូវញែកបន្ថែមជាបន្តទៅតាមវិធីសាស្ត្រប្រព្រឹត្តកម្មសំណល់ដែលមានជាក់ស្តែង។

**សូមមើល៖**

+ រូបភាពទី២៥៖ វិធីសាស្ត្រក្នុងការជំរុញកិច្ចការងារកែច្នៃ តាមរយៈការញែកសំណល់នៅប្រភព អាស្រ័យនឹងសមត្ថភាពក្នុងការកែច្នៃ
+ សកម្មភាពចម្បងទី២៖ ជំរុញការកែច្នៃសំណល់តាមរយៈការញែកសំណល់ ការចូលរួមរបស់វិស័យកែច្នៃឯកជន និងជំរុញការប្រើប្រាស់ផលិតផលពីការកែច្នៃទាំងនេះ

**b. ការរៀបចំគោលការណ៍បច្ចេកទេស (សៀវភៅណែនាំ) ស្តីពីការវេចខ្ចប់សំណល់ និងការបញ្ចេញសំណល់**

- ដោយផ្អែកលើវិធានការញែកសំរាម សំណល់រឹងខាងលើ រដ្ឋបាលរាជធានីភ្នំពេញនឹងរៀបចំនូវសៀវភៅណែនាំ ស្តីពីការវេចខ្ចប់ ការទុកដាក់ ការដឹកជញ្ជូន និងការបញ្ចេញចោលសំរាម សំណល់រឹងនៅតាមលំនៅដ្ឋាន និងទីតាំងពាណិជ្ជកម្ម ដោយផ្តោតសំខាន់ទៅលើប្រជាពលរដ្ឋ និងអនុលោមទៅតាមគោលការណ៍គ្រប់គ្រងសំរាម សំណល់រឹងថ្នាក់ជាតិ។

- សៀវភៅនេះនឹងគ្របដណ្តប់លើប្រធានបទផ្សេងៗ ដោយគ្មានដែនកំណត់ដូចជា៖
    + តួនាទី និងការទទួលខុសត្រូវរវាងអ្នកផលិតសំណល់ ក្រុមហ៊ុនប្រមូល រដ្ឋបាលខណ្ឌ សង្កាត់ និងរាជធានីភ្នំពេញ
    + ប្រភេទសំណល់ និយមន័យច្បាស់លាស់ និងមានរូបភាពជាឧទាហរណ៍
    + ការណែនាំច្បាស់លាស់អំពីរបៀបវេចខ្ចប់ និងការបញ្ចេញសំណល់ទៅតាមប្រភេទរបស់វា
    + ចំណុចទីតាំងប្រមូលសំរាម ដែលបានកំណត់ (ត្រូវតែពិភាក្សាជាមួយនឹងប្រជាពលរដ្ឋ រដ្ឋបាលសង្កាត់ និងក្រុមហ៊ុនប្រមូលសំរាម)
    + វិធីសាស្រ្ត និងកាលវិភាគប្រមូលសំណល់ច្បាស់លាស់ ទៅតាមប្រភេទរបស់វា
    + ការកំណត់ចំណាត់ថ្នាក់អ្នកផលិតសំណល់/ប្រភពសំណល់នូវអត្តសញ្ញាណ ដូចជា ប្រភេទលំនៅដ្ឋាន (សំណល់តាមផ្ទះ) ទីផ្សារ ចំណតឡានក្រុង ភោជនីយដ្ឋាន ផ្ទះសំណាក់ សណ្ឋាគារ រមណីយដ្ឋាន សួនឧទ្យានសាធារណៈ បុរី អគារខ្ពស់ៗ និងផ្សារតាមចិញ្ចើមថ្នល់ ។

## ឧទាហរណ៍៖ ការអនុវត្តន៍ការញែកសំណល់នៅប្រភពនៅក្នុងទីក្រុងនៃប្រទេសជប៉ុន









### c. ការកំណត់ និងរៀបចំទីតាំងប្រមូលសំណល់/ ទុកដាក់សំណល់បណ្តោះអាសន្នជាមួយសម្ភារចាំបាច់

- រដ្ឋបាលខណ្ឌ/ សង្កាត់ នឹងបង្កើតផែនការប្រមូលសំរាម រួមទាំងរបៀបនៃការប្រមូលសំរាមផងដែរៈ ពីផ្ទះមួយទៅផ្ទះមួយ រឺការប្រមូលតាមទីតាំងប្រមូលផ្តុំ (ដោយប្រើប្រាស់ទីតាំងណាជាកន្លែងស្តុក និងប្រមូល)។

**សូមមើលៈ** សកម្មភាពទី១.២. ការធ្វើឱ្យប្រសើរឡើងដល់សេវាប្រមូល បោសសម្អាតផ្លូវ និងទីកន្លែងសាធារណៈ

- ក្នុងតំបន់ទីប្រជុំជនក្រុង ការប្រមូលសំរាមពីផ្ទះមួយទៅមួយអាចរក្សាទុកឱ្យនៅដដែល ដោយគ្រាន់តែធ្វើការវេចខ្ចប់ឱ្យបានត្រឹមត្រូវ និងធ្វើការកំណត់ទីតាំងបណ្តោះអាសន្នណាមួយតូចល្មមសម្រាប់ការបញ្ចេញសំណល់
- ខណៈពេលគេប្រមូលសំរាមពីផ្ទះមួយទៅផ្ទះមួយ (ដាក់លើចិញ្ចើមផ្លូវ) និងគរជាគំនរ ត្រូវបានអនុវត្តជាទូទៅនៅក្នុងតំបន់ទីប្រជុំក្រុង គេក៏សង្កេតឃើញមាននូវការប្រើធុងកុងតឺន័រ/ គរជាគំនរ/ បោះចោលដោយគ្មានសណ្តាប់ធ្នាប់ នៅតែបន្តមានជាធម្មតានៅក្នុងតំបន់ជាយរាជធានី

- រដ្ឋបាលខណ្ឌ និងសង្កាត់ នឹងជួយសម្របសម្រួលការចាត់ចែងកំណត់ទីតាំងប្រមូលផ្តុំសំរាម ដោយស្វែងរកកិច្ចសហការ និងការយល់ព្រមពីអ្នករស់នៅក្បែរនោះ (អ្នកបង្កើតសំណល់) ព្រមទាំងជំនួយពីក្រុមហ៊ុនប្រមូលសំរាម និងរដ្ឋបាលរាជធានីភ្នំពេញ
  - ទីតាំងប្រមូលសំរាម គួរត្រូវបានរៀបចំឱ្យត្រូវទៅតាមកម្មវិធីប្រមូល
  - ទីតាំងទាំងនេះអាចជាទីសាធារណៈ និងមានទីតាំងនៅក្បែរលំនៅដ្ឋានប្រជាពលរដ្ឋ (ដែលរស់នៅក្នុងរង្វង់ ១០០ ទៅ ១៥០ ម៉ែត្រ) អាចយកសំណល់មកចាក់បាន មុនពេលឡានមកប្រមូល
  - បន្ថែមទៅលើទីតាំងបណ្តោះអាសន្ន រដ្ឋបាលរាជធានី នឹងធ្វើការជាមួយរដ្ឋបាលខណ្ឌ/ សង្កាត់ ស្វែងរកទីតាំងដាក់លាក់សម្រាប់ធុងស្តុកធំៗ ដែលប្រជាពលរដ្ឋ ឬអ្នកលក់ដូរចល័តអាចយកសំណល់មកចាក់ក្រៅពីពេលវេលាប្រមូលធម្មតា ទៅតាមលទ្ធភាពជាក់ស្តែង
- នៅជាយរាជធានី ប្រជាពលរដ្ឋអាចប្រើធុង/ កេសសំរាម ដើម្បីចំណេញពេលវេលាប្រមូល និងមានភាពងាយស្រួល។ ប្រជាពលរដ្ឋម្នាក់ៗអាចយកសំរាមមកបញ្ចេញដាក់ទៅក្នុងធុងស្តុក ឬរទេះដឹកសំរាមតូចៗប្រមូលពីផ្ទះមួយទៅផ្ទះមួយទៀត បន្ទាប់មកគេផ្ទេរវាដាក់ធុងកុងធីន័រ។ សាលារាជធានីនឹងធ្វើការជាមួយរដ្ឋបាលខណ្ឌ/សង្កាត់ ដើម្បីធានាទីតាំងប្រមូលសំរាម និងការរៀបចំឱ្យបានសមរម្យ ដើម្បីឱ្យប្រជាពលរដ្ឋ និងរទេះដឹកសំរាមមានភាពងាយស្រួលក្នុងការចូលមកដឹកសំណល់
- រដ្ឋបាលរាជធានីភ្នំពេញ ត្រូវធ្វើការយ៉ាងស្អិតរមួតជាមួយរដ្ឋបាលខណ្ឌ/ សង្កាត់ និងក្រុមហ៊ុននឹងកែសម្រួលកម្មវិធីប្រមូលសំរាមសម្រាប់ទីតាំងទាំងអស់ក្នុងរាជធានីភ្នំពេញ (សូមមើល ផែនការនៃសកម្មភាពចម្បងទី១)។ នាពេលបច្ចុប្បន្ន ការប្រមូលប្រចាំថ្ងៃ ត្រូវគេប្រមូលនៅក្នុងទីប្រជុំជន ឯតំបន់ជាយរាជធានីគេប្រមូលប្រហែល ៣ដង ក្នុងមួយសប្តាហ៍។ កម្មវិធីប្រមូលសំរាមត្រូវធ្វើបច្ចុប្បន្នភាព និងផ្សព្វផ្សាយតាមរយៈរដ្ឋបាលខណ្ឌ/សង្កាត់ និងប្រឹក្សាជាមួយនឹងក្រុមហ៊ុនប្រមូលសំរាម និងរដ្ឋបាលរាជធានីភ្នំពេញ ដើម្បីសំរេចបាននូវភាពស៊ីសង្វាក់ និងល្អប្រសើរនៅទូទាំងរាជធានីភ្នំពេញ
- រដ្ឋបាលរាជធានីភ្នំពេញ ក៏នឹងបង្កើតកាលវិភាគប្រមូលសំណល់កែច្នៃពីតាមលំនៅដ្ឋាន សំណល់សំពីងសំពោង និងសំណល់គ្រោះថ្នាក់ ដែលត្រូវការនូវវេចខ្ចប់ និងពេលវេលាបញ្ចេញ។

**d. ការចែកចាយព័ត៌មាន ស្តីពីកម្មវិធីគ្រប់គ្រងសំណល់ (ថ្មី) និងការបញ្ចេញសំណល់៖**

- គេត្រូវធ្វើការចែកចាយសៀវភៅណែនាំថ្មីមួយដល់សាធារណជន ដើម្បីផ្តួចផ្តើមប្រតិបត្តិការគ្រប់គ្រងសំណល់ដោយផ្អែកលើការរៀបចំថ្មី ហើយវាជាជំហានដ៏សំខាន់សម្រាប់ការអនុវត្តន៍
- អនុវត្តកម្មវិធីបង្កើនការយល់ដឹង ដោយប្រើប្រាស់បណ្តាញផ្សព្វផ្សាយសម្បូរណ៍បែប
  - កម្មវិធីលើកកម្ពស់ការយល់ដឹងគួរតែត្រូវផ្តល់អាទិភាព ដោយបង្កប់នូវគោលបំណងផ្លាស់ប្តូរឥរិយាបថក្នុងការបញ្ចេញ ឬបោះសំរាមចោលរបស់ប្រជាពលរដ្ឋ ដើម្បីអាចជំរុញឱ្យពួកគេអនុវត្ត និងប្រព្រឹត្តនូវឥរិយាបថល្អប្រសើរ
  - ដើម្បីមានភាពទាក់ទាញដល់ប្រជាពលរដ្ឋ ខ្លឹមសារផ្សព្វផ្សាយចេញជាខ្សែវីឌីអូអប់រំខ្លីៗ ឬពាក្យស្លោក ដែលមានអត្ថន័យចាក់ផ្សាយតាមទូរទស្សន៍ វិទ្យុ និងស្លាកសញ្ញាបង្ហាញធំៗ
  - ព័ត៌មានមិនត្រឹមតែណែនាំប្រជាពលរដ្ឋឱ្យដឹងពីរបៀប ពេលវេលា និងទីកន្លែងសម្រាប់បញ្ចេញសំរាមប៉ុណ្ណោះទេ ប៉ុន្តែវាជួយបង្រៀនឱ្យប្រជាពលរដ្ឋចេះវេចខ្ចប់សំរាមឱ្យបានត្រឹមត្រូវ និងគិតដល់បរិស្ថានជាមុន។




**រូបភាពទី២៨៖ "រាជធានីភ្នំពេញស្អាត" ឧទាហរណ៍វីឌីអូអប់រំអំពីការទុកដាក់សំណល់ឱ្យបានត្រឹមត្រូវ**

ប្រភព៖ JCI កម្ពុជា ឆ្នាំ២០១៧

- យុទ្ធនាការទីផ្សារតាមប្រព័ន្ធផ្សព្វផ្សាយសង្គមអាចត្រូវបានប្រើប្រាស់ ដើម្បីបង្កើនការយល់ដឹងជាសាធារណៈ។

ឧទាហរណ៍ ហ្វេសប៊ុក អាចត្រូវបានប្រើជាមធ្យោបាយមួយឱ្យប្រជាពលរដ្ឋដឹងពីកម្មវិធីប្រមូលសំរាម និងទីតាំងប្រមូលព័ត៌មានគ្រប់គ្រងសំរាម សំណល់រឹងផ្សេងៗ វីឌីអូអប់រំ និងព្រឹត្តិការណ៍គ្រប់គ្រងសំណល់ ដើម្បីប្រជាពលរដ្ឋអាចចូលរួមយ៉ាងសកម្មនៅក្នុងវិស័យនេះ។

**e. ការអនុវត្តន៍/ ការដាក់ឱ្យប្រើកម្មវិធីថ្មី សម្រាប់ការគ្រប់គ្រងសំណល់ និងការបញ្ចេញសំណល់**

- ការអនុវត្តន៍កម្មវិធីគ្រប់គ្រងសំណល់ថ្មី ផ្អែកលើគោលការណ៍ណែនាំបច្ចេកទេសដែលបានបង្កើតឡើង និងអាចធ្វើឡើងជាជំហានៗ ដើម្បីផ្តល់ពេលវេលាសម្រាប់អ្នកប្រើប្រាស់ក៏ដូចជាបុគ្គលិកប្រតិបត្តិរបស់សាលារាជធានី និងមន្ទីរផ្សេងទៀតយល់ដឹងពីប្រព័ន្ធថ្មី

- ដើម្បីអនុវត្តប្រកបដោយប្រសិទ្ធភាព និងប្រសិទ្ធពលនូវកម្មវិធីគ្រប់គ្រងសំណល់ថ្មី/គោលការណ៍ណែនាំបច្ចេកទេស គួរតែមានការអន្តរាគមន៍យ៉ាងខ្លាំងក្លាពីអាជ្ញាធរមូលដ្ឋាន ជាពិសេសនៅថ្នាក់ខណ្ឌ សង្កាត់ និងភូមិ។ គោលបំណង គឺដើម្បីធានាថាគ្រប់ភាគីពាក់ព័ន្ធទាំងអស់គោរពតាមគោលនយោបាយ/ គោលការណ៍ណែនាំ កាលវិភាគដែលបានគ្រោងទុក និងរបៀបប្រមូល
- ខណ្ឌ និងសង្កាត់ គួរតែជូនដំណឹងដល់គ្រួសារទាំងអស់ ដែលស្ថិតនៅក្រោមយុត្តាធិការរបស់ពួកគេទាក់ទងនឹងការវេចខ្ចប់សំណល់ និងគោលនយោបាយប្រមូលសំណល់ និងផ្តល់ឱ្យពួកគេនូវខិត្តប័ណ្ណព័ត៌មានទាក់ទងនឹងទីតាំងប្រមូល និងកាលវិភាគប្រមូល។ ព័ត៌មានពិស្តារ មន្ត្រីក៏ត្រូវណែនាំប្រជាពលរដ្ឋអំពីរបៀបវេចខ្ចប់ និងបញ្ចេញសំណល់ឱ្យបានត្រឹមត្រូវ និងទីតាំងដែលនៅជិតបំផុតដែលពួកគេអាចបញ្ចេញសំណល់បាន។

**f. ពង្រឹងវិធានការប្រឆាំងនឹងការបោះចោលសំណល់គ្មានសណ្តាប់ធ្នាប់**

- ចែកចាយធុងដាក់សំរាម និងផ្ទាំងសញ្ញា ឬផ្ទាំងបដាដាក់នៅទីសាធារណៈ ស្តីពីការចោលសំរាមគ្មានសណ្តាប់ធ្នាប់ ឬមិនត្រឹមត្រូវតាមរយៈកិច្ចសហការស្និតរមួតជាមួយវិស័យឯកជន (សូមមើលអត្ថបទក្នុងប្រអប់ខាងក្រោម)។ ស្លាកសញ្ញាគួរធ្វើឱ្យគេមើលឃើញ និងធំល្មម ដើម្បីភាពទាក់ទាញចំណាប់អារម្មណ៍របស់ប្រជាពលរដ្ឋទូទៅ
- ធានានូវការអនុវត្តន៍ និងការពង្រឹងច្បាប់ ក៏ដូចជាការកែតម្រូវនៅពេលដែលចាំបាច់លើបទបញ្ញត្តិដែលមានស្រាប់ និងសេចក្តីណែនាំស្តីពីការបោះចោលសំរាម និងការផាកពិន័យជាប្រាក់ផ្សេងៗ ដូចជា៖
  - សេចក្តីជូនដំណឹង ស្តីពីការទុកដាក់ ការសម្អាត ការបញ្ចេញសំរាម និងការពិន័យលើការចោលសំរាមគ្មានសណ្តាប់ធ្នាប់នៅក្នុងរាជធានីភ្នំពេញ លេខ១៣ សជណ.គកស (ចុះថ្ងៃទី២ ខែកក្កដា ឆ្នាំ២០១៣)
  - ផែនការណែនាំ ស្តីពីការអនុវត្តន៍ការផាកពិន័យ ដើម្បីផ្សព្វផ្សាយបញ្ហាអនាម័យបរិស្ថានក្នុងរាជធានីភ្នំពេញ លេខ០៩ ផកណន.ស (ចុះថ្ងៃទី២ ខែមេសា ឆ្នាំ២០១០)
  - សេចក្តីណែនាំ ស្តីពីការផាកពិន័យលើការបោះចោលសំណល់ក្នុងទីធ្លាសាធារណៈ លេខ១៦សជណ.ស (ចុះថ្ងៃទី២៥ ខែមិនា ឆ្នាំ២០១០)
  - ប្រាក់ពិន័យដែលបានប្រមូល ត្រូវប្រើសម្រាប់ប្រយោជន៍គាំទ្រការអនុវត្តន៍ការងារគ្រប់គ្រងសំរាម សំណល់រឹង និងការសិក្សាស្រាវជ្រាវ។ ដើម្បីធានានូវអនុលោមភាព វាទាមទារឱ្យមានកិច្ចសហការក្នុងចំណោមភាគីពាក់ព័ន្ធ ដូចជានគរបាល ប្រធានភូមិ សង្កាត់ និងខណ្ឌជាដើម
  - ប្រសិនបើអាចធ្វើបាន រដ្ឋបាលរាជធានីភ្នំពេញអាចតំឡើងកាមេរ៉ានៅតាមទីសាធារណៈ ដើម្បីអាចត្រួតពិនិត្យការបោះចោលសំរាម ឬសកម្មភាពចាក់សំរាមដោយគ្មានសណ្តាប់ធ្នាប់។

"ការបរិភោគ និងសំណល់-ទម្លាប់មិនល្អ របស់ប្រជាពលរដ្ឋរស់នៅ រាជធានីភ្នំពេញ?"
"វាគឺជាពេលដែលត្រូវគិតគូរពីសំរាម ព្រោះវាប៉ះពាល់ដល់សុខភាព អនាម័យ និងសូម្បីតែរូបភាពអ្នកក្នុងនាមជាពលរដ្ឋមួយរូប នៃប្រទេសកម្ពុជា!"
(អនុសាសន៍សង្ខេប ដែលកែសម្រួលពី ប្លុកមួយឈ្មោះ សម្លេងទីក្រុងកម្ពុជា ក្នុងខែមីនា ឆ្នាំ២០១៧)

ទោះបីជាមនុស្សជាច្រើនរស់នៅរាជធានីភ្នំពេញត្អូញត្អែរអំពីសំរាមក៏ដោយ ពួកគេក៏មិនបានបោះចោលសំរាមឱ្យបានត្រឹមត្រូវដែរ ទាំងក្នុងភោជនីយដ្ឋាន និងតាមហាង ចិញ្ចើមថ្នល់តូចៗ ធ្វើឱ្យខូចសោភ័ណភាពទីក្រុង។ តើធ្វើដូចម្តេចដើម្បីបញ្ឈប់ទម្លាប់អាក្រក់មួយនេះ?

**ដំណោះស្រាយទី១៖** ក្នុងនាមជាអ្នកប្រើប្រាស់មួយរូប ត្រូវហ៊ានធ្វើឱ្យខុសពីគេ ធ្វើជាគំរូសម្រាប់ខ្លួនអ្នក គ្រួសារ និងមិត្តភក្តិរបស់អ្នក។ ត្រូវចោលក្រដាសជូតមាត់ឱ្យបានត្រឹមត្រូវ និងហ៊ានកែប្រែអាកប្បកិរិយារបស់អ្នកដទៃដែលធ្វើខុស។ ធ្វើឱ្យមនុស្សគ្រប់គ្នា យកចិត្តទុកដាក់ពីអាកប្បកិរិយាខុសឆ្គងក្នុងទីសាធារណៈ។

**ដំណោះស្រាយទី២៖** ម្ចាស់ភោជនីយដ្ឋានគួរតែដាក់កន្ត្រកធំល្មម និងអាចមើលឃើញសម្រាប់អតិថិជនប្រើប្រាស់។

**ដំណោះស្រាយទី៣៖** ម្ចាស់ភោជនីយដ្ឋានគួរតែមានបិទនូវសេចក្តីណែនាំ 'ហាមចោលសំរាម' ក្នុងទ្រង់ទ្រាយមួយគួរឱ្យចាប់អារម្មណ៍ និងងាយស្រួលមើល ហើយដាក់វាឱ្យចំកន្លែង ដែលអតិថិជនអាចអាន និងធ្វើតាម។

**ដំណោះស្រាយទី៤៖** សម្រាប់ចក្ខុវិស័យវែងឆ្ងាយ គឺលើកកម្ពស់ការអប់រំបរិស្ថាន ធ្វើឱ្យប្រជាពលរដ្ឋយល់ដឹងអំពីផលប៉ះពាល់នៃសំរាម និងសារៈសំខាន់នៃការកាត់បន្ថយសំរាម ការប្រើប្រាស់ឡើងវិញ និងការកែច្នៃ ក៏ដូចជាការចោលសំរាមឱ្យបានត្រឹមត្រូវ គឺមានឥទ្ធិពល និងប្រសិទ្ធភាពច្រើនជាងច្បាប់ និងបទបញ្ជាពីព្រោះវាជាសកម្មភាពដែលចម្រុញប្រជាពលរដ្ឋឱ្យគោរពខ្លួនឯង។

## សកម្មភាពទី១.២. ធ្វើឱ្យប្រសើរឡើងនូវសេវាប្រមូលសំណល់ ការសម្អាតផ្លូវ និងទីសាធារណៈ

### គោលបំណង

ធ្វើឱ្យសេវាប្រមូលសំរាមមានភាពប្រសើរឡើងដោយធានាឱ្យបានថា សំរាម សំណល់រឹងទាំងអស់ត្រូវបានប្រមូលយកទាំងស្រុង។ សេវាប្រមូលគួរគ្របដណ្តប់ ១០០% នៃទីតាំងលំនៅដ្ឋាននៅក្នុងដែនរដ្ឋបាលរាជធានីភ្នំពេញ។ លើសពីនេះទៀត ផ្លូវ និងទីសាធារណៈគួរតែត្រូវបានសម្អាតឱ្យបានទៀងទាត់ និងអាចទទួលយកបានជាសាធារណៈ។

### ស្ថានភាពបច្ចុប្បន្ន

នៅក្នុងរាជធានីភ្នំពេញ សេវាការប្រមូលសំណល់បច្ចុប្បន្ន និងសេវាសម្អាតតាមផ្លូវ គឺស្ថិតនៅក្រោមការគ្រប់គ្រងរបស់ក្រុមហ៊ុនសំរាមធំមួយ គឺក្រុមហ៊ុនស៊ីនទ្រី។ ចំណែកឯទីតាំងសាធារណៈ និងសួនស្ថិតនៅក្រោមមន្ទីរសាធារណការ និងដឹកជញ្ជូន និងមន្ទីរវប្បធម៌ និងវិចិត្រសិល្បៈរាជធានីភ្នំពេញ ហើយអ្នកម៉ៅការឯកជនមួយចំនួនទៀត ត្រូវបានប្រគល់ភារកិច្ចក្នុងការផ្តល់សេវាប្រមូលសំរាម ដែលមានទ្រង់ទ្រាយតូចៗពីទីតាំងជាក់លាក់ណាមួយ (ឧទាៈ ក្នុងផ្សាររបស់រដ្ឋ ឬឯកជន) រីឯការដឹកជញ្ជូន និងចាក់ចោលសំរាមចុងក្រោយទៅកាន់ទីលានចាក់សំរាម ដែលកំណត់ដោយរដ្ឋបាលរាជធានីភ្នំពេញ។ ក្រុមហ៊ុនស៊ីនទ្រី មានបុគ្គលិកប្រមាណ ១.៦៥២នាក់ និងមានឡានដឹកសំរាមសំនួន ៣៥៩គ្រឿង ឡានសម្អាតថ្នល់ ចំនួន ៩គ្រឿង រទេះរុញចំនួន ២៦២ធុង កុងធីន័រដាក់សំរាមចំនួន ៧៤គ្រឿង និងរទេះសំរាមចល័តចំនួន ៣៦២ សម្រាប់សេវាកម្មប្រមូលសំរាម

ទាំងមូលក្នុងរាជធានីភ្នំពេញ។

ការអនុវត្តន៍បច្ចុប្បន្ន សំរាមគ្រប់ប្រភេទ ត្រូវបានដាក់ជាមួយគ្នា វេចខ្ចប់ និងបញ្ចេញទៅឱ្យក្រុមហ៊ុនប្រមូល តែទោះយ៉ាងណាក៏នៅមានបញ្ហាប្រឈមមួយចំនួន ដែលកើតមានពីសេវាកម្មប្រមូលសំរាមនាពេលបច្ចុប្បន្នៈ

- ក្រុមហ៊ុនស៊ីនទ្រីមានឡានដឹកសំរាមច្រើន ប៉ុន្តែភាគច្រើនចាស់ៗ និងមានបញ្ហាច្រើន។ ឡានខូចញឹកញាប់ ដែលរាំងស្ទះដល់ការប្រមូលឱ្យបានទៀងទាត់
- សំណល់ដែលបោះចោលក្នុងរាជធានី ភាគច្រើនសើមមានជាតិទឹកលើសពី ៦០%។ ដោយមានអាងស្តុកទឹកសំអុយតូចមួយនៅពីក្រោមផ្នែកខាងក្រោយនៃរថយន្ត ទឹកសំអុយទាំងនេះស្រក់តាមផ្លូវពេលដឹក នាំឱ្យមានមតិរិះគន់ពីសាធារណជនអំពីបញ្ហាអនាម័យ
- ក្រុមហ៊ុនស៊ីនទ្រីបានផ្តល់កាលវិភាគប្រមូលសំរាមនៅទូទាំងរាជធានី ប៉ុន្តែប្រឈមជាមួយបញ្ហាមួយចំនួន ដូចជា ការស្ទះចរាចរណ៍ ផ្លូវតូចចង្អៀត ពិបាកចូលប្រមូល ខ្វះកម្លាំងពលកម្ម ឆ្ងាយពីទីលានជាដើម
- ក្រុមហ៊ុនស៊ីនទ្រីប្រើកម្លាំងកម្មករច្រើនក្នុងប្រតិបត្តិការប្រមូលសំណល់ ដោយសារតែការវេចខ្ចប់ និងការទុកដាក់សំណល់ក្នុងរាជធានីមិនបានត្រឹមត្រូវ។ កម្មករជាច្រើនត្រូវចូកសម្អាតសំណល់នៅលើថ្នល់ទៅក្នុងឡានដឹក ឬដើររើសសំណល់ដែលដាក់រាយប៉ាយដោយដៃទទេ
- កម្មកររបស់ក្រុមហ៊ុនស៊ីនទ្រី ដែលត្រូវទទួលខុសត្រូវក្នុងការប្រមូលសំណល់ដាក់ក្នុងឡានដឹក ជាទូទៅឈរពីក្រោយឡានរើសសំណល់ដែលអាចកែច្នៃបាន។ សកម្មភាពនេះ ធ្វើឱ្យប្រតិបត្តិការប្រមូលមិនសូវមានប្រសិទ្ធភាព និងមិនសូវល្អចំពោះសេវាកម្មប្រមូលសំរាមក្នុងរាជធានី។
- អ្នកលក់ដូរចល័តជាពិសេសនៅតាមសួនចសាធារណៈ តែងទុកដាក់សំណល់ពួកគេចោលពាសវាលគ្មានសណ្តាប់ធ្នាប់តម្រូវឱ្យមានកម្លាំងបន្ថែមមកជួយសម្អាត។

## សកម្មភាព

a. ណែនាំ វាយតម្លៃលើប្រសិទ្ធភាព និងសមត្ថភាពក្រុមហ៊ុនប្រមូលសំរាម សំណល់រឹង៖ រដ្ឋបាលរាជធានីភ្នំពេញ និងរដ្ឋបាលខណ្ឌគួររៀបចំក្របខណ្ឌវាយតម្លៃសមត្ថភាពក្រុមហ៊ុនឯកជន ក្នុងការផ្តល់សេវាកម្មក្នុងរាជធានី។ កិច្ចការនេះ គឺដើម្បីធានាថាក្រុមហ៊ុនមានសមត្ថភាពគ្រប់គ្រាន់ក្នុងការរៀបចំផែនការប្រមូល ឆ្លើយតបទៅនឹងលក្ខខណ្ឌ ដែលបានកំណត់ក្នុងកាលវិភាគប្រមូល និងគោលការណ៍បច្ចេកទេស។ សូចនាករនៃការវាយតម្លៃអាចរួមបញ្ចូល (១) បុគ្គលិកបច្ចេកទេស និងបទពិសោធន៍ក្នុងការគ្រប់គ្រងសំរាម សំណល់រឹង (២) សម្ភារប្រើប្រាស់ផ្សេងៗ (៣) ការអនុវត្តន៍សេវារបស់ក្រុមហ៊ុនប្រមូល និងរដ្ឋបាលខណ្ឌ។

b. ណែនាំក្នុងការកែលម្អឱ្យផែនការប្រតិបត្តិការ និងប្រមូលដែលមានស្រាប់កាន់តែប្រសើរឡើង សម្រាប់ខណ្ឌនីមួយៗរួមមានការរៀបចំកាលវិភាគប្រមូលសំណល់ កំណត់ទីតាំងប្រមូលរួមគ្នា (ទីតាំងសមរម្យអាចធ្វើទៅបាន) និងប្រព័ន្ធផ្លូវប្រមូលសំរាមដោយមានការសហការគ្នារវាងក្រុមហ៊ុនប្រមូលសំរាម និងរដ្ឋបាលខណ្ឌ

- រៀបចំកាលវិភាគប្រមូលសំរាម៖ រដ្ឋបាលរាជធានីភ្នំពេញសហការជាមួយរដ្ឋបាលខណ្ឌ/ សង្កាត់ និងក្រុមហ៊ុន នឹងបង្កើតផែនការប្រមូលសំរាម ដោយមានកាលវិភាគច្បាស់លាស់ និងគោលការណ៍ណែនាំ ស្តីអំពីការវេចខ្ចប់ និងការទុកដាក់សំរាម សំណល់រឹង។ ឧទាហរណ៍ រដ្ឋបាលរាជធានីភ្នំពេញនឹងឱ្យរដ្ឋបាលខណ្ឌ/ សង្កាត់ធ្វើការជាមួយក្រុមហ៊ុនប្រមូលសំរាមក្នុងការបង្កើតផែនការប្រមូលសំរាម សំណល់រឹង ដោយយកចិត្តទុកដាក់លើចំណុចដូចតទៅ៖ (១) មាន

មធ្យោបាយ/ ឧបករណ៍ប្រមូលផ្សេងៗ (២) ការរៀបចំផ្លូវដឹកជញ្ជូន (៣) ប្រតិបត្តិការ/ ការអនុវត្តន៍ប្រមូលសំណល់អាស្រ័យលើប្រភពបញ្ចេញសំណល់ (៤) ការសម្អាតនៅទីតាំងទុកដាក់សំណល់ឱ្យបានស្អាត (៥) ការទុកដាក់ឧបករណ៍ប្រមូល (៦) ការបណ្តុះបណ្តាល ឬគ្រប់គ្រងកម្មករឱ្យបានត្រឹមត្រូវ (៧) ឧបករណ៍ការពារសុវត្ថិភាព និងអនាម័យសម្រាប់កម្មករ និង(៨) បទដ្ឋានសុវត្ថិភាព/ ការពារ

- សម្រាប់តំបន់ដែលយូរៗត្រូវប្រមូលម្តង (គម្លាតរវាងរយៈពេលចាក់សំរាម និងរយៈពេលទៅប្រមូល) ក្រុមហ៊ុនប្រមូលសំរាម និងរដ្ឋបាលខណ្ឌគួរណែនាំពីវិធានការសន្សំសំចៃ ដើម្បីទុកដាក់សំណល់ដែលមិនប៉ះពាល់ដល់សោភ័ណភាពសាធារណៈ។ ជូនដំណឹងដល់សាធារណជនឱ្យបានដឹងនូវកាលវិភាគប្រមូល តាមរយៈការបិទផ្សាយតាមគេហទំព័ររបស់រដ្ឋបាលរាជធានីភ្នំពេញ និងក្រុមហ៊ុនផ្ទាល់ ហើយផ្សាយតាមកម្មវិធីទូរស័ព្ទដៃ និងផ្សព្វផ្សាយតាមបណ្តាញសង្គម និងខិត្តប័ណ្ណផ្សេងៗទៀត។
- រៀបចំផែនការ/ កាលវិភាគបោសសម្អាតតាមដងផ្លូវ និងតាមទីសាធារណៈ៖ រដ្ឋបាលរាជធានីភ្នំពេញនឹងកំណត់ឱ្យបានច្បាស់លាស់នូវតួនាទី និងការទទួលខុសត្រូវរបស់ក្រុមហ៊ុន និងមន្ទីរពាក់ព័ន្ធ (មន្ទីរសាធារណការ និងដឹកជញ្ជូន មន្ទីរវប្បធម៌ និងវិចិត្រសិល្បៈ)។ រដ្ឋបាលរាជធានីភ្នំពេញធ្វើការជិតស្និទ្ធជាមួយរដ្ឋបាលខណ្ឌ/ សង្កាត់ និងអង្គភាពពាក់ព័ន្ធខាងលើរៀបចំផែនការ និងការសម្អាតតាមដងផ្លូវ និងសួនសាធារណៈឱ្យបានប្រសើរឡើង។ កាលវិភាគ និងផែនការខាងលើត្រូវដើរស្របនឹងកាលវិភាគប្រមូលសំរាម និងសៀវភៅគោលការណ៍ណែនាំពីការវេចខ្ចប់ និងទុកដាក់សំរាម សំណល់រឹង។
- ករណីសម្អាតថ្នល់ រដ្ឋបាលរាជធានីភ្នំពេញនឹងធានាថា ក្រុមហ៊ុនមានសមត្ថភាព និងអាចចាត់ចែងធនធានគ្រប់គ្រាន់ដើម្បីអនុវត្តការងារ។ ក្នុងលក្ខខណ្ឌនេះ រដ្ឋបាលរាជធានីភ្នំពេញត្រូវសិក្សាលម្អិត និងវាយតម្លៃសំណើគម្រោងសម្អាតថ្នល់ឡើងវិញតាមរយៈការយកចិត្តទុកដាក់លើ៖ (១) សេវាគ្របដណ្តប់ (២) មានមធ្យោបាយ/ ឧបករណ៍ប្រមូលផ្សេងៗ (៣) ការបណ្តុះបណ្តាល ឬគ្រប់គ្រងកម្មករឱ្យបានត្រឹមត្រូវ (៤) ឧបករណ៍ការពារសុវត្ថិភាពកម្មករ និងអនាម័យ និង(៥) បទដ្ឋានសុវត្ថិភាព/ការពារ។
- សម្រាប់ផ្លូវដែលត្រូវសម្អាត គឺអាស្រ័យលើសារៈសំខាន់នៃផ្លូវចំពោះសាធារណៈ ឬសោភ័ណភាពទីក្រុង។ រដ្ឋបាលរាជធានីភ្នំពេញនឹងរៀបចំផែនទីបង្ហាញផ្លូវមួយ ដែលចង្អុលបង្ហាញពីថ្នល់ដែលត្រូវសម្អាត ដើម្បីឱ្យក្រុមហ៊ុនដឹងថាត្រូវសម្អាតថ្នល់មួយណា។
- ការគាំទ្រពីអាជ្ញាធរមូលដ្ឋាន/រាជធានីត្រូវធានាឱ្យបាន ដើម្បីកំណត់ទីតាំងសម្រាប់រទេះសំរាម និងដឹកជញ្ជូនទៅផ្ទេរដាក់ឡាន។
- រដ្ឋបាលខណ្ឌ/សង្កាត់ ត្រូវកំណត់ទីតាំង និងថែទាំទីតាំងស្តុកសំរាមបណ្តោះអាសន្ន។
- ត្រួតពិនិត្យតម្លាភាពសេវាកម្មរបស់ក្រុមហ៊ុនប្រមូលសំរាម មានន័យថា រដ្ឋបាលរាជធានីភ្នំពេញគួរត្រួតពិនិត្យ ថាតើក្រុមហ៊ុនផ្តល់សេវាកម្មត្រឹមត្រូវដល់ម្ចាស់លំនៅដ្ឋានទាំងអស់ឬទេ ហើយថា ភាពអសកម្មណាខ្លះដែលអាចការពារបាន និងហាមឃាត់ ឬធានាឱ្យមានការផ្តល់សេវាបានស្មើៗគ្នាក្នុងរាជធានីភ្នំពេញ។ ឧទាហរណ៍ ធានាថាបុគ្គលិកប្រមូលលុយរបស់ក្រុមហ៊ុនប្រមូលសំរាមគ្មានស៊ីសំណូកពីម្ចាស់លំនៅដ្ឋាន ដោយមិនផ្តល់សេវាកម្មល្អតែនៅទីតាំងដែលឱ្យលុយថែមក្រៅ។

c. ណែនាំ និងជំរុញការអនុវត្តន៍សកម្មភាពប្រមូលសំណល់តាមបែបសហគមន៍ ចំពោះតំបន់ទាំងឡាយណា ដែលក្រុមហ៊ុនប្រមូលសំរាមពិបាកក្នុងការចូលដឹកសំរាម ដើម្បីជៀសវាងការបោះចោលសំរាមគ្មានសណ្តាប់ធ្នាប់ និងការមិនបង់ប្រាក់ថ្លៃ

ប្រមូលសំរាម។

គេឃើញមានអង្គការក្រៅរដ្ឋាភិបាលជាច្រើននៅក្នុងរាជធានីភ្នំពេញ បាននិងកំពុងអនុវត្តគម្រោងគ្រប់គ្រងសំរាម សំណល់រឹងតាមមូលដ្ឋាន។ វាជាសកម្មភាពកាត់បន្ថយចំណាយ ដែលអាចសម្រេចបានតាមរយៈចលនាបែបសហគមន៍ លទ្ធកម្មនៃឧបករណ៍ និងរទេះដឹកសំរាម និងការបង្កើតគណៈកម្មការគ្រប់គ្រងសំណល់តាមបែបសហគមន៍។

- សេវាកម្មឯកជនក្រៅផ្លូវការមួយចំនួនអាចចូលរួមប្រមូលសំណល់តាមផ្ទះ។ បុគ្គលទាំងអស់នេះ គួរតែមានភារកិច្ចដើរប្រមូល ដោយប្រើរទេះរុញ រួចយកទៅចាក់តាមទីតាំងប្រមូល/ធុងសំរាម ដែលអាជ្ញាធរមូលដ្ឋានជាអ្នកដាក់ (ខណ្ឌ/សង្កាត់) តាមផ្លូវប្រមូលរបស់ក្រុមហ៊ុនប្រមូលសំរាម។ សំណល់អាចប្រមូលបានដោយឡានរបស់ក្រុមហ៊ុនប្រមូលសំរាមទៅតាមកាលវិភាគ។

d. បង្កើនប្រសិទ្ធភាពផ្តល់ព័ត៌មានរវាងរដ្ឋបាលរាជធានីភ្នំពេញ និងក្រុមហ៊ុនប្រមូលសំរាម ដើម្បីត្រួតពិនិត្យប្រតិបត្តិការប្រមូលសំណល់៖ ក្រុមហ៊ុនប្រមូលសំរាម គួរប្រើប្រព័ន្ធបច្ចេកទេសគ្រប់គ្រងទិន្នន័យ ដើម្បីឱ្យគេអាចតាមដាន រៀបចំផែនការ ដាក់ពេលវេលាប្រមូល វិភាគ និងត្រួតពិនិត្យលើដំណើរការទាំងមូល។

- របាយការណ៍វិភាគត្រូវចែករំលែកជាមួយភាគីពាក់ព័ន្ធនៅក្នុងរាជធានីឱ្យបានទៀងទាត់
- យន្តការទទួលយោបល់ត្រឡប់៖ យន្តការនេះ គឺដើម្បីទទួលការឆ្លើយតបដែលគួរតែរៀបចំឱ្យមាន និងផ្តល់ឱកាសដល់ប្រជាពលរដ្ឋក្នុងការដាក់ពាក្យបណ្តឹង ឬមានយោបល់កែលម្អទៅលើបទពិសោធន៍នៃការប្រមូលសំរាមនៅក្នុងតំបន់របស់ពួកគេ ដែលអាចឱ្យក្រុមហ៊ុនប្រមូលសំរាម វិភាគនូវមតិយោបល់ទាំងនោះ និងអាចផ្តល់ដំណោះស្រាយឱ្យបានត្រឹមត្រូវ។ ក្រុមហ៊ុនប្រមូលសំរាមគួរសហការជាមួយអាជ្ញាធរមូលដ្ឋាន ណែនាំដល់ម្ចាស់លំនៅដ្ឋានឱ្យត្រួតពិនិត្យឥរិយាបទចោលសំរាមរបស់ខ្លួន និងចាប់អ្នកបោះសំរាមចោលគ្មានសណ្តាប់ធ្នាប់ និងបង្កើនចំនួនអ្នកចូលរួម។

e. ការពិនិត្យឡើងវិញនូវថ្លៃសេវាកម្ម ដើម្បីឱ្យការប្រមូលសំរាមមានប្រសិទ្ធភាពខ្ពស់

ការវិភាគសេដ្ឋកិច្ចទៅលើប្រព័ន្ធថ្លៃសេវាកម្មអាចធ្វើបាន ដើម្បីកំណត់ថ្លៃឈ្នួលសេវាកម្មដែលមានភាពជាក់លាក់មួយក្នុងការធានាឱ្យបាននូវនិរន្តរភាព និងភាពពេញលេញនៃការប្រមូលសំរាមដែលផ្តល់ឱ្យអតិថិជន។ ក្រុមហ៊ុនប្រមូលសំរាមអាចចូលរួមបានតាមរយៈការបង្ហាញរបាយការណ៍ប្រតិបត្តិការរបស់ខ្លួន ដើម្បីតម្លាភាព និងជួយដល់ការដាក់ថ្លៃសេវាឱ្យបានប្រសើរ។ វិធីសាស្ត្រពីរយ៉ាង ដែលត្រូវបានគេអនុវត្តបានជោគជ័យលើប្រព័ន្ធកំណត់តម្លៃសេវាប្រមូល គឺការកំណត់តម្លៃដែលផ្តោតទៅលើបរិមាណ និងការកំណត់តម្លៃដែលគិតលើទម្ងន់។

- សម្រាប់ការកំណត់តម្លៃដោយគិតលើបរិមាណ គឺជាថ្លៃប្រមូលសំរាមគ្រួសារនីមួយៗដែលអាស្រ័យលើចំនួនស្បោងសំរាមដែលបានបញ្ចេញចោល និងទំហំរបស់ថង់នីមួយៗ។ ថង់សំរាមកាន់តែតូច ហើយសំរាមកាន់តែតិច នោះអ្នកប្រើប្រាស់នឹងបង់ថ្លៃប្រមូលសំរាមកាន់តែតិច។
- សម្រាប់ការកំណត់តម្លៃដោយគិតទៅតាមទម្ងន់ គឺជាការគិតថ្លៃប្រមូលសំរាមតាមរយៈទម្ងន់សំរាម ដែលបានបញ្ចេញចោល។ ចំពោះកម្រិតនៃការប្រើប្រាស់ ប្រជាពលរដ្ឋត្រូវបានលើកទឹកចិត្តក្នុងការបញ្ចេញសំរាមចោលកាន់តែតិចបំផុតតាមដែលអាចធ្វើទៅបាន តាមរយៈការកែច្នៃប្រើប្រាស់សំណល់ឡើងវិញ។
- ការប្រែប្រួលតម្លៃសេវាកម្ម៖ ការវាយតម្លៃអាស្រ័យលើប្រភេទអាជីវកម្ម និងទំហំអាជីវកម្ម ដើម្បីកំណត់ថ្លៃសេវា ដែលត្រូវបង់ជំនួសឱ្យការដាក់តម្លៃមួយសម្រាប់គ្រប់អាជីវកម្ម។
- នៅពេលច្បាប់នៃការញែកសំរាមត្រូវបានគេដាក់ឱ្យអនុវត្ត អត្រាតម្លៃអាចត្រូវកំណត់ខុសៗគ្នាចំពោះអ្នកបង្កើតសំរាម

ណាដែលញែកសំរាម (អត្រាទាប) និងអ្នកដែលមិនបានញែក (អត្រាខ្ពស់) ដែលនឹងជំរុញឱ្យបង្កើនការញែកសំណល់កាន់តែល្អប្រសើរនៅតាមផ្ទះ។

f. កំណត់ឡើងវិញលើភាពជាដៃគូជាមួយក្រុមហ៊ុនប្រមូលសំរាម ដើម្បីឆ្ពោះទៅរកទីផ្សារប្រកួតប្រជែង

ដំណើការនេះអាចទទួលបានជោគជ័យតាមរយៈការបង្កើតគុណតម្លៃសំណល់ ការបែងចែកទីផ្សារទៅតាមតំបន់ឱ្យក្រុមហ៊ុនប្រមូលសំរាមនានា ឬបង្កើតឱ្យមានការដាក់ដេញថ្លៃជំរុញការប្រកួតប្រជែង។

- ការដាក់ដេញថ្លៃ៖ រដ្ឋបាលរាជធានីភ្នំពេញ នឹងវាយតម្លៃនូវលទ្ធភាពនៃការដាក់ឱ្យមានការដេញថ្លៃប្រកបដោយការប្រកួតប្រជែងទៅលើក្រុមហ៊ុនសេវាប្រមូលសំរាម។ ទោះជាយ៉ាងណាក៏ដោយ កិច្ចសន្យាជាមួយក្រុមហ៊ុនស៊ីនទ្រីនឹងមិនត្រូវបញ្ចប់ឆាប់ៗនេះឡើយ ដូចនេះយុទ្ធសាស្ត្រនេះអាចមានប្រសិទ្ធភាពនៅក្នុងរយៈពេលវែងមួយ។ យុទ្ធសាស្ត្រនេះរដ្ឋបាលរាជធានីភ្នំពេញអាចបែងចែកទីតាំងក្នុងរាជធានីភ្នំពេញជាច្រើនតំបន់ (ខណ្ឌ/សង្កាត់) ហើយប្រកាសឱ្យក្រុមហ៊ុននានាដាក់ពាក្យដេញថ្លៃសម្រាប់តំបន់នីមួយៗ។ ដំណើការនេះ នឹងធ្វើឱ្យរដ្ឋបាលរាជធានីភ្នំពេញពិនិត្យមើលគ្រប់ក្រុមហ៊ុនទាំងអស់ និងជ្រើសរើសយកក្រុមហ៊ុនដែលល្អជាងគេ។ បន្ថែមពីនេះ ការអនុញ្ញាតឱ្យក្រុមហ៊ុនតែមួយទទួលខុសត្រូវសម្រាប់តំបន់ណាមួយជាក់លាក់នោះ នឹងជំរុញឱ្យក្រុមហ៊ុនទាំងអស់អនុវត្តសេវាកម្មប្រមូលសំរាមមានប្រសិទ្ធភាពល្អ។ កាជំរុញវិនិយោគក្នុងវិស័យនេះ ក៏អាចកសាង និងបង្កើនគុណតម្លៃសំណល់ក្នុងទីផ្សារបានផងដែរ។
- ស្វែងរកលទ្ធភាពផ្តួចផ្តើមកិច្ចសន្យាជាមួយក្រុមហ៊ុនប្រមូលសំរាមថ្មីមួយ សម្រាប់ប្រភេទសំណល់ ដែលមិនត្រូវបានប្រមូលដោយក្រុមហ៊ុនប្រមូលសំរាមបច្ចុប្បន្ន ដូចជាប្រភេទសំណល់សំពីងសំពោង។

## សកម្មភាពទី១.៣. គាំទ្ររដ្ឋបាលខណ្ឌ/សង្កាត់ ដើម្បីពង្រឹងការត្រួតពិនិត្យ និងការអនុវត្តន៍

### គោលបំណង

ដើម្បីជួយដល់មន្ត្រីខណ្ឌ/សង្កាត់ក្នុងការអនុវត្តន៍កម្មវិធីការគ្រប់គ្រងសំរាម សំណល់រឹង និងត្រួតពិនិត្យតាមដានការផ្តល់សេវាកម្មរបស់ក្រុមហ៊ុនប្រមូលសំរាម។

### ស្ថានភាពបច្ចុប្បន្ន

តាមរយៈខ្លឹមសារនៃអនុក្រឹត្យលេខ១១៣ រដ្ឋបាលខណ្ឌ/សង្កាត់ត្រូវរំពឹងថានឹងដើរតួនាទីយ៉ាងសំខាន់ក្នុងការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន ជាពិសេសផ្តល់ការគាំទ្រ និងសម្របសម្រួលការសម្អាត ការប្រមូល និងដឹកជញ្ជូននៅក្នុងដែនរដ្ឋបាលរបស់ខ្លួន។

តាមរយៈអនុក្រឹត្យលេខ១១៣ ជំនួសឱ្យការរៀបចំធ្វើកិច្ចសន្យា រដ្ឋបាលខណ្ឌស្ថិតនៅក្រោមការគ្រប់គ្រងរបស់រដ្ឋបាលរាជធានីភ្នំពេញបានចុះអនុស្សរណៈយោគយល់ ជាមួយអ្នកផ្តល់សេវាប្រមូលសំរាមក្នុងការផ្តល់សេវាកម្មក្រោមដែនសមត្ថកិច្ចរបស់ពួកគេ។ ភ្នាក់ងារអនាម័យ ២រូប ក្នុងមួយសង្កាត់ ដើម្បីចុះណែនាំប្រជាពលរដ្ឋលើការវេចខ្ចប់សំណល់ឱ្យបានត្រឹមត្រូវ និងការបញ្ចេញសំរាម ហើយម្យ៉ាងទៀតក៏ដើម្បីចាប់អ្នកដែលបោះបង់ចោលសំរាមគ្មានសណ្តាប់ធ្នាប់ផងដែរ។ ភ្នាក់ងារអនាម័យទាំងពីររូបអាចធ្វើការសម្របសម្រួលបានល្អជាមួយក្រុមហ៊ុន ស៊ីនទ្រី និងប្រជាពលរដ្ឋនៅមូលដ្ឋាន ប៉ុន្តែពួកគេពុំមានការណែនាំត្រឹមត្រូវលើស្តង់ដាការងារ ដែលអាចឱ្យគាត់មានសមត្ថភាពត្រួតពិនិត្យរាល់ការងាររបស់អ្នកផ្តល់សេវានោះទេ។ មធ្យោបាយទំនាក់ទំនង និងរាយការណ៍មិនទាន់បានកំណត់ និងរៀបចំឱ្យបានត្រឹមត្រូវផងដែរ។

## សកម្មភាព

a. រដ្ឋបាលរាជធានីភ្នំពេញ នឹងរៀបចំនូវគោលការណ៍ណែនាំដែលបង្ហាញពីសូចនាករការងារសម្រាប់ខណ្ឌនីមួយៗអនុវត្ត។ សូចនាកររួមបញ្ចូលទាំងៈ (១) ទីតាំងផ្តល់សេវាកម្ម (២) អត្រា/តម្លៃប្រមូលសំរាម (៣) ភាពញឹកញាប់នៃការប្រមូលសំរាម (៤) សម្ភារដែលអាចកែច្នៃ (៥) សំណល់រាយប៉ាយ (៦) បណ្តឹងពីសាធារណៈ (៧) សោភ័ណភាព និងអនាម័យទីតាំង។

b. ក្រុមការងារ ឬគណៈកម្មាធិការនៅថ្នាក់ខណ្ឌគួរតែបង្កើតឡើង ដើម្បីធ្វើការសម្របសម្រួលការងាររវាងក្រុមហ៊ុនផ្តល់សេវាឯកជន និងប្រជាពលរដ្ឋ ហើយតាមដានរាល់ការអនុវត្តន៍របស់ក្រុមហ៊ុនផ្តល់សេវាកម្ម ព្រមទាំងរៀបចំផែនការសម្រាប់ការគ្រប់គ្រងសំណល់រឹងនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។ ក្រុមការងារទាំងនេះគួរតែមានជំនួយផ្នែកបច្ចេកទេស និងហិរញ្ញវត្ថុពីសាលារាជធានីភ្នំពេញ ឬរដ្ឋបាលខណ្ឌខ្លួនឯងផ្ទាល់ ដើម្បីធានាដល់ការបំពេញការងារបាន។

c. រដ្ឋបាលរាជធានីភ្នំពេញ នឹងអនុវត្តកម្មវិធីការអភិវឌ្ឍសមត្ថភាព សម្រាប់បុគ្គលិកសាលាខណ្ឌ ជាពិសេសសម្រាប់ក្រុមការងារ ឬគណៈកម្មាធិការ ដើម្បីឱ្យពួកគេអាចរៀបចំផែនការគ្រប់គ្រងសំរាម សំណល់រឹង និងតាមដានការអនុវត្តន៍របស់ក្រុមហ៊ុនផ្តល់សេវាកម្ម។

d. វិធីសាស្ត្រដែលមានភ្នាក់ងារអនាម័យពីរនាក់ក្នុងមួយសង្កាត់សម្រាប់ការត្រួតពិនិត្យប្រចាំថ្ងៃ និងណែនាំប្រជាពលរដ្ឋ ស្តីពីការវេចខ្ចប់ និងការបញ្ចេញសំរាមឱ្យបានត្រឹមត្រូវ ត្រូវតែអនុវត្ត។ ភ្នាក់ងារអនាម័យទាំងនេះ អាចត្រូវបានដាក់បញ្ចូលនៅក្នុងក្រុមការងារខណ្ឌ ហើយពួកគេនឹងត្រូវបានបណ្តុះបណ្តាលបន្ថែមទៀត។

e. ការរៀបចំក្របខណ្ឌគ្រប់គ្រងដោយបណ្តុះបណ្តាលអាជ្ញាធរមូលដ្ឋាន លើទិដ្ឋភាពបច្ចេកទេសនៃការចោលសំរាម រួមទាំងការគូសផែនទី ការតាមដាន និងត្រួតពិនិត្យការប្រមូលសំរាម។ ធ្វើការបែងចែកភារកិច្ចការងារ និងបណ្តុះបណ្តាលមន្ត្រីរដ្ឋបាលខណ្ឌលើរបៀបតាមដានដោយប្រើប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន ដូចជា Facebook WhatsApp និងកម្មវិធីបណ្តាញសង្គមផ្សេងៗទៀត។

## ២. សកម្មភាពចម្បងទី២៖ ការលើកកម្ពស់ការច្នៃសំណល់ឡើងវិញ តាមរយៈការញែកសំណល់ ដោយមានការចូលរួមរបស់ក្រុមហ៊ុនឯកជនកែច្នៃសំណល់ និងការលើកកម្ពស់ការប្រើប្រាស់ផលិតផលកែច្នៃ

### សកម្មភាពទី២.១. បង្កើនសកម្មភាពកែច្នៃឡើងវិញ តាមរយៈការលើកកម្ពស់សកម្មភាពនានាតាមមូលដ្ឋាន និងសម្របសម្រួលបង្កើតឧស្សាហកម្មកែច្នៃនៅក្នុងស្រុក

## គោលបំណង

លើកកម្ពស់សមត្ថភាពកែច្នៃទីក្រុងតាមរយៈ៖ ១) លើកកម្ពស់សកម្មភាពមូលដ្ឋាន និង ២) សម្របសម្រួលការបង្កើតឧស្សាហកម្មកែច្នៃក្នុងស្រុក តាមរយៈការវាយតម្លៃលទ្ធភាពបង្កើតប្រព័ន្ធកែច្នៃ ដោយប្រើប្រាស់បច្ចេកវិទ្យាសមស្រប និងឱ្យមានការចូលរួមជាលក្ខណៈគ្រួសារ និងវិស័យឯកជន។

## ស្ថានភាពបច្ចុប្បន្ន

- នៅរាជធានីភ្នំពេញ ការកែច្នៃសំណល់រឹង ឬកម្មវិធីកែច្នៃសំណល់នៅមានកម្រិតនៅឡើយ។ វត្ថុធាតុដើមកែច្នៃមួយចំនួនត្រូវបានប្រមូលដោយវិស័យក្រៅប្រព័ន្ធ (អ្នកដើររើសសំណល់អេតចាយ ដេប៉ូអេតចាយ) ហើយធ្វើដំណើរការដោះ

បំបែកតាមបែបសាមញ្ញ ហើយភាគច្រើនត្រូវបានគេនាំចេញទៅប្រទេសជិតខាង ដោយសារប្រទេសកម្ពុជានៅមិនទាន់មានហេដ្ឋារចនាសម្ព័ន្ធគ្រប់គ្រាន់សម្រាប់ការកែច្នៃ។ មិនតែប៉ុណ្ណោះ គេត្រូវធ្វើការបង់ថ្លៃបន្ថែមសម្រាប់ដឹកជញ្ជូនទៅកាន់ព្រំដែនផងដែរ។

- ក្រៅពីអង្គការក្នុងស្រុកដូចជា អង្គការ CSARO ដែលទទួលយកសំណល់ជីវៈពីផ្សារដើមគរ ដើម្បីធ្វើជីកំប៉ុស ក្រុមហ៊ុនឯកជនជាច្រើនកំពុងសិក្សាពីសក្តានុពលអាជីវកម្ម ដែលផ្តោតសំខាន់លើសំណល់ជីវៈ និងសំណល់អេតចាយ។ ដើម្បីឆ្លើយតបទៅនឹងការកើនឡើងនៃសំណល់ ដែលដឹកយកទៅចាក់ចោលនៅទីលានចាក់សំរាម រដ្ឋបាលរាជធានីភ្នំពេញក៏កំពុងស្វែងរកវិធានការដ៏មានសក្តានុពលសម្រាប់ការចូលរួមជាមួយក្រុមហ៊ុនកែច្នៃឡើងវិញ។

## សកម្មភាព

a. ធ្វើការវិភាគផ្នែកសេដ្ឋកិច្ច ដើម្បីឆ្ពោះទៅរកការបង្កើតឧស្សាហកម្មកែច្នៃសំណល់ក្នុងស្រុក

- ជំហានដំបូង គេត្រូវស្វែងយល់អំពីប្រព័ន្ធកែច្នៃសំរាមនៅក្នុងស្រុក និងគួរតែចងក្រងនូវលទ្ធផលសិក្សា និងសម្រេចចិត្តថា តើការកែច្នៃអាចបង្កើតនៅក្នុងរាជធានីភ្នំពេញបានដែរឬទេ។ អាជ្ញាធរនិងស្ថាប័នពាក់ព័ន្ធនានាគួរតែចូលរួមជួយជ្រោមជ្រែងក្នុងការកំណត់អត្តសញ្ញាណ ឬការបង្កើតទីផ្សារលក់ផលិតផលពីការកែច្នៃ។
- ការបោះជំហានក្នុងការវិភាគផ្នែកសេដ្ឋកិច្ច គួរតែរួមបញ្ចូលទាំងការវាយតម្លៃលើ ការចំណាយនៃខ្សែសង្វាក់ប្រតិបត្តិការកែច្នៃទាំងមូល រួមមាន ការប្រមូលសំណល់កែច្នៃ ការរៀបចំ ក៏ដូចជាការចំណាយដើមគ្រា និងចំណាយសម្រាប់ប្រតិបត្តិការកែច្នៃឡើងវិញជាក់ស្តែង។
- ការសិក្សានេះនឹងធ្វើឡើងដោយរដ្ឋបាលរាជធានីភ្នំពេញលើជម្រើសបច្ចេកវិទ្យាកែច្នៃផ្សេងៗ ដោយមានកិច្ចសហការជាមួយភាគីពាក់ព័ន្ធ។

b. ការវាយតម្លៃលើដំណោះស្រាយបច្ចេកវិទ្យាសមស្របសម្រាប់ការកែច្នៃសំណល់ឡើងវិញ

ដោយផ្អែកលើការបកស្រាយខាងលើ រាជធានីភ្នំពេញនឹងត្រូវតែធ្វើការសិក្សាវាយតម្លៃផ្នែកបច្ចេកទេស សង្គមសេដ្ឋកិច្ច និងនយោបាយ។ ឧ. សម្រាប់សំណល់ជីវៈ សក្តានុពលកែច្នៃវាមានដូចជា ការធ្វើជីកំប៉ុស ឡជីវឧស្ម័ន ចំណីសត្វ ចំហេះសំណល់ជីវម៉ាស (អំពៅ ដើម្បីធ្វើក្រដាស គ្រឡោកដូងធ្វើជាធ្យូងអនាម័យជាដើម) និងដំណើរការធ្វើជីកំប៉ុសដោយប្រភេទសត្វដង្កូវ-រុយក្បាលខ្មៅ (Black Solider Fly Larvae)។

## ប្រព័ន្ធពហុរំហូរសំណល់កែច្នៃដោយញែកនៅប្រភព និងប្រព័ន្ធរំហូរតែមួយ ញែកសំណល់កែច្នៃដោយម៉ាស៊ីនស្វ័យប្រវត្តិ

ប្រព័ន្ធរំហូរសំណល់កែច្នៃតែមួយ គឺបែងចែកសំណល់ដោយម៉ាស៊ីនស្វ័យប្រវត្តិ ប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាចម្រុះរួមផ្សំគ្នាក្នុងការញែកសំណល់ទៅតាមប្រភេទសម្រាប់ការកែច្នៃ រួមមាន សំណល់ដប PET អាលុយមីញ៉ូម កំប៉ុងដែក ក្រដាសកាតុង និងក្រដាស។ ការប្រើវិធីញែកសំណល់ដោយម៉ាស៊ីនអាចត្រូវបានគេចាត់ទុកថា ជាដំណោះស្រាយសម្រាប់ការរៀបចំសំណល់ដែលអាចកែច្នៃឡើងវិញ ដែលមិនមានវត្តមានសំណល់សរីរាង្គ។

ប្រព័ន្ធពហុរំហូរសំណល់កែច្នៃ គឺត្រូវញែកនៅប្រភពដោយអ្នកបង្កើតសំណល់ទៅតាមប្រភេទ/ លក្ខណៈនៃសំណល់ ហើយត្រូវបានប្រមូលសម្រាប់/ ដឹកទៅទីតាំងកែច្នៃចុងក្រោយ។







ទោះបីយ៉ាងណាប្រព័ន្ធទាំងពីរ មាននូវគុណសម្បត្តិ និងគុណវិបត្តិរៀងៗខ្លួន ហើយត្រូវបានរៀបរាប់ដូចខាងក្រោម៖

**ឥទ្ធិពលចិត្តសាស្ត្រនៃប្រព័ន្ធរំហូរសំណល់តែមួយ និងញែកដោយម៉ាស៊ីនអាចប៉ះពាល់លើការជម្រុញការអនុវត្តន៍ ៣អ៊ែរ**

ការអនុវត្តន៍ប្រព័ន្ធញែកសំណល់ដោយម៉ាស៊ីនចម្រុះ អាចជួយកាត់បន្ថយបន្ទុកម្ចាស់ផលិតសំណល់ចេញពីភារកិច្ចនៃការបែងចែកសំណល់ពីប្រភព ដែលអនុញ្ញាតឱ្យសំណល់ដែលអាចកែច្នៃទាំងអស់ត្រូវបានប្រមូល ដឹកជញ្ជូន និងញែក ដើម្បីដំណើរការកែច្នៃបន្ត។ ដោយសារមូលហេតុនេះ វិធីសាស្ត្រនេះមានសក្តានុពលក្នុងការទទួលបានការចូលរួមច្រើនពីអ្នកបង្កើតសំណល់ ដូច្នេះគេអាចប្រមូលបានបរិមាណសំណល់កាន់តែច្រើន។ ទោះជាយ៉ាងណា ការបោះចោលសំណល់ដោយលាយឡំគ្នា អាចធ្វើឱ្យកិច្ចខិតខំប្រឹងប្រែង ដើម្បីលើកកម្ពស់ការអនុវត្តន៍ ៣Rs របស់អ្នកបង្កើតសំណល់ លែងសូវទទួលចំណាប់អារម្មណ៍ពីសារៈសំខាន់នៃការកាត់បន្ថយសំណល់ និងការប្រើប្រាស់ឡើងវិញ ដែលចាំបាច់សម្រាប់បង្កើតនូវសង្គមមួយប្រកបដោយប្រសិទ្ធភាពធនធាន។

**តម្រូវការផ្នែកហិរញ្ញវត្ថុ និងធនធានមនុស្ស**

ដោយសារមានបច្ចេកទេសច្រើនពាក់ព័ន្ធនឹងប្រព័ន្ធស្វ័យប្រវត្តិនេះ អាចនឹងត្រូវការមូលដ្ឋានធនធានដ៏រឹងមាំទាំងផ្នែកហិរញ្ញវត្ថុ និងធនធានមនុស្ស។ ក្រៅពីចំណាយមូលធនគ្រាដើម សម្រាប់ទីតាំងកែច្នៃ ការចំណាយសម្រាប់ប្រតិបត្តិការ និងការថែទាំប្រចាំថ្ងៃ អ្នកជំនាញបច្ចេកទេសគ្រប់គ្រាន់សម្រាប់ការងារនេះ គឺមានសារៈសំខាន់ក្នុងការទ្រទ្រង់ប្រព័ន្ធយ៉ាងខ្លាំង។

ម្យ៉ាងទៀត ប្រព័ន្ធកែច្នៃដោយមានការញែកសំណល់នៅប្រភពរួចជាស្រេច ត្រូវការចំណាយដើមទុនតិចជាង និងអ្នកជំនាញបច្ចេកទេសសម្រាប់ប្រតិបត្តិការញែកសំណល់ ខណៈពេលដែលវាអាចត្រូវការធនធានច្រើនសម្រាប់ប្រតិបត្តិការប្រមូលសំណល់ពីប្រភព តែក៏វាអាស្រ័យលើរបៀបនៃការប្រមូលពីប្រភពផងដែរ៖ ការប្រមូលសំណល់នៅប្រភពទៅតាមប្រភេទដាច់ដោយឡែកពីគ្នា អាចចំណាយអស់ច្រើនជាងការដឹកលាយឡំគ្នា ដោយសារវាត្រូវប្រើរថយន្តច្រើនជាង និងថែមទៀតចំណាយលើឥន្ធនៈ និងបុគ្គលិក/កម្មករប្រមូលផងដែរ។

**ការត្រួតពិនិត្យគុណភាពលើវត្ថុធាតុដើមពីការកែច្នៃឡើងវិញ**

ចំពោះប្រព័ន្ធកែច្នៃឡើងវិញ កិច្ចការពារកុំឱ្យសំណល់ចូលឡាយឡំគ្នា (សំណល់ត្រូវកែច្នៃឡើងវិញ) ខូចគុណភាព គឺជាគន្លឹះក្នុងការកែលម្អគុណភាព នៃធនធានផលិតកម្ម (វត្ថុធាតុដើម)។ តាមទស្សនៈនេះ ប្រព័ន្ធកែច្នៃដោយម៉ាស៊ីនស្វ័យប្រវត្តិ អាចបណ្តាលឱ្យខូចតម្លៃនៃធនធានយកមកកែច្នៃ ហេតុនេះធ្វើឱ្យខាតបង់នូវប្រាក់ចំណេញរបស់អ្នកកែច្នៃ ដែលជាធាតុផ្សំដ៏សំខាន់សម្រាប់និរន្តរភាពនៃប្រព័ន្ធគ្រប់គ្រងសំណល់-ធនធានទាំងមូល។ ប្រសិនបើការអនុវត្តន៍វាបានត្រឹមត្រូវ ប្រព័ន្ធកែច្នៃសំណល់ដោយការញែកសំណល់នៅឯប្រភព អាចមានសក្តានុពលច្រើនជាងក្នុងការកាត់បន្ថយការខូចខាងគុណភាពនៃសំណល់ ប៉ុន្តែវាទាមទារឱ្យមានកិច្ចសហប្រតិបត្តិការជាមួយអ្នកបង្កើតសំណល់ និងកិច្ចខិតខំប្រឹងប្រែងដ៏រឹងមាំរបស់អាជ្ញាធរ។

**ធានាវំហូរវត្ថុធាតុដើម - សារៈសំខាន់នៃអ្នកកែច្នៃ ទីផ្សារ និងអតិថិជនប្រើប្រាស់**

ប្រព័ន្ធពហុវំហូរសំណល់កែច្នៃ និងប្រព័ន្ធវំហូរសំណល់កែច្នៃតែមួយ ទាមទារឱ្យមានវិស័យកែច្នៃឡើងវិញ (សាធារណៈ ឬឯកជន) ដែលមានសមត្ថភាពកែច្នៃសំណល់ឡើងវិញបាន ទៅជាធនធានវត្ថុធាតុដើមប្រើប្រាស់ឡើងវិញ។ លើសពីនេះទៅទៀត ធនធានវត្ថុធាតុដើមកែច្នៃបឋម និងផលិតផលពីការកែច្នៃ ភាគច្រើនត្រូវបានគេជួញដូរនៅលើទីផ្សារ ហើយត្រូវបានកែច្នៃទៅជាវត្ថុធាតុដើមសម្រាប់ដំណើរការផលិតកម្មម្តងទៀត ហើយត្រូវបានចាត់ទុកថាជាផលិតផល។ ការរក្សាវំហូរនៃសំណល់-វត្ថុធាតុដើមនេះ (ឧ. ជាផលិតផល) ជាគ្រឹះអន្តរាគមន៍ផ្នែកគោលនយោបាយសម្រាប់ការលើកកម្ពស់ការកែច្នៃឡើងវិញ ហើយគួរតែរៀបចំឱ្យមានបរិយាកាសអំណោយផលសម្រាប់ខ្សែសង្វាក់នេះ រួមទាំងវិធានការសម្រាប់ការលើកកម្ពស់ការប្រើប្រាស់ផលិតផលកែច្នៃឡើងវិញ (សូមមើលសកម្មភាពចម្បងទី២.៣)។ បណ្តុំនៃគោលនយោបាយគាំទ្រ ដែលត្រូវបានដាក់បញ្ចូលក្នុងយុទ្ធសាស្ត្រនេះចាំបាច់ត្រូវធ្វើបច្ចុប្បន្នភាពជាបន្តបន្ទាប់ ដើម្បីបង្ការភាពប្រឈម ដែលអាចនឹងកើតមាននាពេលអនាគត៕

## c. ផ្តល់ការគាំទ្រដល់ក្រុមហ៊ុនកែច្នៃសំណល់

ដោយទីផ្សារកែច្នៃឡើងវិញនៅកម្ពុជាមានភាពក្មេងខ្ចី និងកំពុងអភិវឌ្ឍនៅឡើយ រដ្ឋបាលរាជធានីនឹងព្យាយាមទាក់ទាញ និងគាំទ្រដល់ក្រុមហ៊ុនកែច្នៃឯកជនដែលចាប់អារម្មណ៍ ដើម្បីចាប់ផ្តើម និងពង្រីកអាជីវកម្មរបស់ពួកគេ។ ដើម្បីសម្រេចគោលដៅនេះ គេត្រូវការរៀបចំបរិយាកាសធុរកិច្ចនៅក្នុងអាជីវកម្ម ដោយសហការជាមួយមន្ទីរដទៃទៀត ការបំភ្លឺ ឬកែលម្អនីតិវិធីរដ្ឋបាល ការឧបត្ថម្ភធន (ប្រសិនបើប្រភពថវិកាត្រូវបានធានា)។

d. ការទាក់ទាញការវិនិយោគនៅក្នុងវិស័យនេះ ដោយលើកទឹកចិត្ត និងបង្កើតឱ្យមានអ្នកកែច្នៃឯកជនក្នុងស្រុក

- រៀបចំឱ្យមានកិច្ចប្រជុំពិគ្រោះយោបល់ ដើម្បីបង្កើតទំនាក់ទំនងរវាងសមាគមអាជីវកម្ម និងអ្នកកែច្នៃសំណល់ឯកជន ឆ្ពោះទៅសម្របសម្រួលលើលទ្ធកម្មផ្គត់ផ្គង់វត្ថុធាតុដើមកែច្នៃឡើងវិញពីទីតាំងពាណិជ្ជកម្ម អាជីវកម្មនៅក្នុងរាជធានីភ្នំពេញ (សណ្ឋាគារ ភោជនីយដ្ឋាន ផ្សារទំនើប ជាដើម)។
- បង្កើតមូលដ្ឋានទិន្នន័យគ្រប់គ្រងលើអ្នកកែច្នៃសំរាមឯកជន ឈ្មួញកណ្តាល និងព្រមទាំងអាជីវកម្ម ដែលមានបំណងចង់ចូលរួមចុះបញ្ជីក្នុងកាប្រមូលសំណល់កែច្នៃ ព្រមទាំងប្រមូលផ្តុំព័ត៌មានស្តីពីបរិមាណសំណល់ជីវៈ និងសំណល់អសរីរាង្គ ដែលបង្កើតនៅទីតាំងពាណិជ្ជកម្មអាជីវកម្មផ្សេងៗនៅក្នុងរាជធានីភ្នំពេញ។ យ៉ាងហោចណាស់ គំនិតផ្តួចផ្តើមនេះនឹងលើកទឹកចិត្ត និងផ្តល់ជាគំរូក្នុងការអនុវត្តន៍ការញែកសំណល់មុនគេសម្រាប់ទីតាំងអាជីវកម្ម ហើយមកអនុវត្តនៅតាមលំនៅដ្ឋាន។
- អ្នកពាក់ព័ន្ធកែច្នៃសំណល់អេតចាយក្នុងស្រុក (ទាំងផ្លូវការ និងមិនផ្លូវការ) បាន និងកំពុងដំណើរការរួចហើយនៅក្នុងប្រទេសកម្ពុជា ហើយជាពិសេសនៅរាជធានីភ្នំពេញ៖ ១) គម្រោងរបស់អង្គការក្រៅរដ្ឋាភិបាល ដូចជា អង្គការ

CSARO និង អង្គការ COMPED បានសហការជាមួយផ្សារមួយចំនួននៅភ្នំពេញ ដើម្បីប្រមូលប្រភេទសំណល់ជីវៈសម្រាប់កែច្នៃជាជីកំប៉ុស ២) មានហាងជាច្រើនដែលអាចកែច្នៃគ្រឿងម៉ាស៊ីនអេឡិចត្រូនិក និងបរិក្ខារអគ្គិសនីចាស់ៗ (ជាទូទៅមានលក្ខណៈជាផ្លូវការ) ៣) កសិករនៅតំបន់ជាយរាជធានីប្រមូលសំណល់ជីវៈ (សំណល់អាហារ) ពីភោជនីយដ្ឋាន កែច្នៃធ្វើជាចំណីសត្វ ៤) បុគ្គលជាច្រើន និងអ្នកប្រមូលសំណល់ក្រៅប្រព័ន្ធធ្វើអាជីវកម្មរបស់ខ្លួន ដើម្បីប្រមូលសំណល់ប្លាស្ទិក ដបប្លាស្ទិក (ភាគច្រើនប្រភេទដបជ័រ PET) កំប៉ុងអាលុយមីញ៉ូម និងក្រដាសកាតុង។

- រដ្ឋបាលរាជធានីភ្នំពេញ គួរតែជួយគាំទ្រដល់ការរីកចម្រើននៃអាជីវកម្មកែច្នៃក្នុងស្រុក តាមរយៈការបើកកន្លែងកែច្នៃសាកល្បង សម្រាប់ខ្សែចង្វាក់សំណល់កែច្នៃ ដែលទាន់មានគេគិតគូរនៅឡើយនៅក្នុងរាជធានីភ្នំពេញមកទល់សព្វថ្ងៃនេះ (ថង់ប្លាស្ទិក កៅស៊ូ និងទុយោបឺតជាដើម)។
- ដើម្បីឆ្ពោះទៅរកការកែច្នៃសំណល់ជីវៈ និងសំណល់សំណង់ សកម្មភាពចម្បងៗដូចខាងក្រោមនេះអាចចាត់ទុកជាថាមានអាទិភាពសម្រាប់ទាក់ទាញការវិនិយោគពីវិស័យឯកជន។

ការប្រមូល និងកែច្នៃប្រភេទសំណល់៖

១) សំណល់ជីវៈពីទីផ្សារ (ផ្សារដើមគរ និងច្បារអំពៅជាដើម)

២) សំណល់អាហារពីភោជនីយដ្ឋាន និងសណ្ឋាគារ

៣) សំណល់ទីសត្តឃាត

៤) សំណល់សំណង់

- វិធានផ្លូវច្បាប់ គួរតែត្រូវបានអនុវត្ត ដើម្បីបង្កើនការកែច្នៃឡើងវិញ
- សំណល់ជីវៈ (ចំណុចទី១-៣) ត្រូវបានបែងចែកសម្រាប់ការធ្វើជីកំប៉ុស និងសម្រាប់ការបម្លែងទៅជាជីវឧស្ម័នតាមរយៈបច្ចេកវិទ្យាឡជីវឧស្ម័ន
- កិច្ចសហប្រតិបត្តិការរវាងក្រុមហ៊ុនកែច្នៃ និងអ្នកផលិតសំណល់ មានសារៈសំខាន់ណាស់។
- វិញ្ញាបនប័ត្រ (ហាងទំនិញដែលមានទំនួលខុសត្រូវសង្គម) អាចត្រូវបានចេញសម្រាប់អ្នកផលិតសំណល់ ជាការលើកទឹកចិត្ត និងជាមធ្យោបាយដើម្បីបង្កើនការយល់ដឹង
- សម្រាប់ចំណុចទី៣ ធុងសំណល់ធម្មតា ឬធុងស្តុកសំរាមធំៗ នឹងត្រូវបានរៀបចំដាក់តាមរយៈការពិភាក្សារវាងភាគីពាក់ព័ន្ធ ដើម្បីត្រួតពិនិត្យនូវការចោលសំណល់ចូលក្នុងធុងត្រឹមត្រូវ រហូតដល់ប្រព័ន្ធប្រព្រឹត្តកម្មសំណល់សត្តឃាត។

e. លើកកម្ពស់សកម្មភាពស្ម័គ្រចិត្តតាមសហគមន៍ សម្រាប់ការកែច្នៃឡើងវិញ

- ជំរុញការកែច្នៃជីកំប៉ុសតាមបែបវិមជ្ឈការនៅតាមលំនៅដ្ឋាន/សហគមន៍ ដោយ៖
  - លើកទឹកចិត្តក្នុងការញែកសំណល់ជីវៈ
  - ការចែកនូវខិត្តប័ណ្ណផ្សព្វផ្សាយស្តីពី វិធីសាស្ត្រក្នុងការកែច្នៃជីកំប៉ុសដល់អ្នកបង្កើតសំណល់

### ប្រព័ន្ធកែច្នៃកំប៉ុសតាមបែបមជ្ឈការ និងវិមជ្ឈការ

ប្រព័ន្ធកែច្នៃជីកំប៉ុសបែបមជ្ឈការ ត្រូវបានគេអនុវត្តកែច្នៃសំណល់សរីរាង្គដែលមានបរិមាណច្រើន ហើយជីកំប៉ុសអាចត្រូវបានគេលក់ ឬចែកចាយដោយឥតគិតថ្លៃសម្រាប់ការប្រើប្រាស់លើវិស័យកសិកម្ម និងសាកវប្បកម្ម។ ប្រព័ន្ធនេះទាមទារទុនសម្រាប់ការវិនិយោគដើមគ្រា ប្រតិបត្តិការ ការថែទាំ ក៏ដូចជាអ្នកជំនាញបច្ចេកទេស និងការគ្រប់គ្រង។

ម៉្យាងទៀតប្រព័ន្ធវិមជ្ឈការ ដូចជា ការកែច្នៃជីកំប៉ុសខ្នាតតូច ឬខ្នាតសហគមន៍ ជាទូទៅមិនសូវមានលក្ខណៈបច្ចេកទេស ប្រើប្រាស់ដើមទុនតិច និងសម្ភារៈដែលមានតំលៃថោក និងអាចរកបាននៅក្នុងស្រុក ហើយផលិតផលជីកំប៉ុសជារឿយៗត្រូវបានគេប្រើជាលក្ខណៈឯកជន។

ចំពោះប្រព័ន្ធទាំងពីរ កិច្ចការពារគុណភាពសំណល់សរីរាង្គសម្រាប់ការកែច្នៃជាជីកំប៉ុស និងមានដីកសិកម្មសម្រាប់ប្រើប្រាស់ជីកំប៉ុស គឺជាគន្លឹះសម្រាប់និរន្តរភាពនៃប្រតិបត្តិការកែច្នៃ។ (សូមមើលឧបសម្ព័ន្ធទី ៦)

- ជំរុញការកែច្នៃសំណល់ចំណីអាហារ (ធ្វើជីកំប៉ុស និងប្រព័ន្ធជីវឧស្ម័ន) ដោយផ្តោតទៅទៅវិស័យឯកជន ជាពិសេសឧស្សាហកម្មសេវាកម្មចំណីអាហារ វិស័យឧស្សាហកម្មបដិសណ្ឋារកិច្ច និងព្រមទាំងផ្តល់កម្មវិធីបណ្តុះបណ្តាលសម្រាប់ការអភិវឌ្ឍជំនាញ ក្នុងការលើកកម្ពស់ការកែច្នៃសំណល់អាហារសម្រាប់ភោជនីយដ្ឋាន។

## សកម្មភាពទី២.២. លើកកម្ពស់ការញែកសំណល់នៅប្រភព

### គោលបំណង

ដើម្បីលើកកម្ពស់ការចូលរួមសកម្មពីសារធារណជន នៅក្នុងការញែកសំណល់ តាមរយៈបង្កើតការផ្សព្វផ្សាយពីការយល់ដឹងជាសារធារណៈអំពីអត្ថប្រយោជន៍នៃសំណល់ បង្កើតគោលការណ៍ដែលមានប្រសិទ្ធភាពក្នុងការចាត់ថ្នាក់ប្រភេទសំណល់ និងការរួមបញ្ចូលប្រជាពលរដ្ឋទៅក្នុងប្រព័ន្ធគ្រប់គ្រងសំណល់។

### ស្ថានភាពបច្ចុប្បន្ន

សកម្មភាពនៃការញែកសំណល់មានតិចតួចណាស់ សម្រាប់ប្រជាពលរដ្ឋរស់នៅរាជធានីភ្នំពេញ។ នៅតាមលំនៅដ្ឋាននីមួយៗ ប្រជាពលរដ្ឋញែកសំណល់មួយចំនួន ដែលអាចលក់របស់របរទាំងនោះទៅឱ្យអ្នកទិញសំណល់អេតចាយដែលដើរទិញតាមផ្ទះ។ សំណល់ទាំងនោះ នឹងត្រូវលក់បន្តពីឈ្មួញមួយទៅមួយទៀតរហូតដល់ទីតាំងកែច្នៃចុងក្រោយ ដែលភាគច្រើនស្ថិតនៅក្រៅប្រទេស។ សរុបមក ដំណើការនេះ មិនមានលក្ខណៈជាប្រព័ន្ធ និងគ្មានប្រសិទ្ធភាព។

- នៅរាជធានីភ្នំពេញមិនសូវមានអ្នកយកចិត្តលើការញែកសំណល់នោះទេ។ ទោះបីជា មានធុងដាក់ប្រភេទសំរាមញែកខុសៗគ្នានៅតាមទីសាធារណៈ ប្រជាពលរដ្ឋមិនដឹងពីរបៀបប្រើប្រាស់ធុងសំរាម ធ្វើឱ្យការប្រើប្រាស់មិនបានត្រឹមត្រូវ។ ជាការពិត ពេលខ្លះវាអត់មានសញ្ញាបង្ហាញឱ្យដឹងថា ធុងមួយនេះសម្រាប់សំរាមប្រភេទណាឡើយ។

### សកម្មភាព

ការញែកសំណល់ គឺជាដំណោះស្រាយដ៏យូរអង្វែងមួយ វាមានន័យថាត្រូវការពេលវេលាយូរក្នុងការខិតខំប្រឹងប្រែងយ៉ាងខ្លាំងពីភាគគីពាក់ព័ន្ធទាំងអស់ មុនពេលដែលយើងអាចឃើញនូវលទ្ធផលជាទីគាប់ចិត្ត។ ខាងក្រោមនេះ គឺជាសកម្មភាពតូចៗដែលអាចអនុវត្ត ដើម្បីលើកកម្ពស់ទម្លាប់នៃការញែកសំណល់របស់អ្នករស់នៅក្នុងរាជធានីភ្នំពេញ។

a. កែសម្រួលឧបករណ៍ច្បាប់ដែលមានស្រាប់ ឱ្យក្លាយទៅជាគោលការណ៍/វិន័យក្នុងការញែកសំរាម ប្រើជាផ្លូវការ

ការញែកសំណល់មានពីរប្រភេទ (សំរាមសើម/សំណល់ជីវៈ និងសំរាមស្ងួត/សំណល់អសរីរាង្គ) ដោយធ្វើឡើងជាជំហានដំបូង ដោយមូលហេតុថា ប្រជាជននៅក្នុងទីក្រុងមិនបានទទួលបានការណែនាំអំពីការញែកសំណល់នៅហ្នឹងកន្លែងនាពេលកន្លងមក។ នៅតាមផ្ទះ ភោជនីយដ្ឋាន និងទីតាំងពាណិជ្ជកម្មផ្សេងៗទៀត គួរតែមានការបណ្តុះបណ្តាល ស្តីពីរបៀបរបបក្នុងការបែងចែកសំណល់ជាពីរប្រភេទ ការវេចខ្ចប់សំណល់ផ្សេងគ្នា និងបញ្ចេញទៅក្នុងធុងសំរាមទៅតាមពេលវេលាដែលបានកំណត់រួចហើយ។

b. ការបង្កើតកម្មវិធីផ្សព្វផ្សាយការយល់ដឹង និងយុទ្ធនាការអប់រំ ឬក៏ជាមូលដ្ឋានគ្រឹះ ដើម្បីឱ្យមានការបែងចែកសំរាម គឺត្រូវតែលើកកម្ពស់ការយល់ដឹងរបស់សាធារណជន និងការចូលរួមរបស់ពួកគេនៅក្នុងដំណើការគ្រប់គ្រងសំណល់នេះ។
   - មគ្គុទ្ទេសក៍ណែនាំញែកសំណល់គួររៀបចំឡើង ក្នុងទម្រង់ទំនាក់ទំនងសកម្ម ដូចជាតាមរយៈការផ្សព្វផ្សាយជាខ្សែវីដេអូខ្លីៗ តុក្កតា សៀវភៅរឿងនិទាន ល្បែងកំសាន្ត និងគួរតែត្រូវបានគេចែកចាយឱ្យបានទូលំទូលាយតាមទូរទស្សន៍ បណ្តាញផ្សព្វផ្សាយសង្គម និងការធ្វើផ្ទាំងបដាដើម
   - សិក្ខាសាលា និងវគ្គបណ្តុះបណ្តាលនានា ស្តីពីវិធីសាស្រ្តនៃញែកសំណល់ និងអត្ថប្រយោជន៍ទៅកាន់សាធារណជនគួរតែត្រូវគេបានរៀបចំឱ្យបានទៀងទាត់។ គោលបំណងសំខាន់ គឺដើម្បីមានការចូលរួមជាសកម្មនៅក្នុងយុទ្ធនាការបរិស្ថាន ជាពិសេសយុទ្ធនាការពាក់ព័ន្ធនឹងការគ្រប់គ្រងសំណល់។

c. ជំរុញការអនុវត្តន៍ ៣អ៊ែរ តាមរយៈការញែកសំណល់នៅប្រភពនៅទីសាធារណៈដូចជា នៅតាមសួនសាធារណៈ តំបន់ទេសចរណ៍ មានធុងញែកសំរាម សំណល់រឹងឱ្យបានគ្រប់គ្រាន់សម្រាប់សាធារណជន។ រដ្ឋបាលរាជធានីភ្នំពេញគួរបន្តការតំឡើងធុងសំរាមញែកតាមទីតាំងសាធារណៈនៅក្នុងរាជធានីភ្នំពេញ។ ក្នុងករណីមិនមានធុងសំរាមទេ រដ្ឋបាលរាជធានីភ្នំពេញ គួរតែជូនដំណឹងដល់ប្រជាពលរដ្ឋអំពីវិធីផ្សេងៗ ដែលពួកគេអាចញែកសំណល់របស់ពួកគេបាន។ ឧទាហរណ៍ មនុស្សអាចប្រើថង់ពណ៌ផ្សេងៗ សម្រាប់ដាក់សំណល់ផ្សេងៗគ្នាឱ្យគេប្រមូល។ រដ្ឋបាលរាជធានីភ្នំពេញក៏នឹងផ្តួចផ្តើមលើកទឹកចិត្តឱ្យស្ថាប័នសាធារណៈដូចជា សាលារៀន ទីផ្សារ ផ្សារទំនើប ឱ្យអនុវត្តការញែកសំណល់ និងចាប់ផ្តើមចេញពីទឹកចិត្តចូលរួមរបស់ពួកគេដោយផ្ទាល់។

d. លើកកម្ពស់ការញែកសំណល់នៅប្រភព នៅតាមលំនៅដ្ឋាន ដោយមានកិច្ចសហការជាមួយសិប្បកម្មកែច្នៃសំណល់ ដើម្បីធានាឱ្យមានការប្រមូលសំណល់អេតចាយយកទៅកែច្នៃឡើងវិញនៅទូទាំងរាជធានី ដោយមានកិច្ចសម្របសម្រួលពីរដ្ឋបាលរាជធានីភ្នំពេញ។




រូបភាពទី២៩៖ ម៉ូដែលរំហូរសំណល់ / វត្ថុធាតុដើម ដោយញែកនៅប្រភព និងការប្រមូលសំណល់អេតចាយ

## សកម្មភាពទី២.៣. ការលើកកម្ពស់ការប្រើប្រាស់ផលិតផលកែច្នៃ

### គោលបំណង

លើកកម្ពស់ការប្រើប្រាស់ផលិតផលកែច្នៃ ដោយលើកទឹកចិត្តដល់ការអភិវឌ្ឍប្រព័ន្ធស្លាកឈ្មោះសម្រាប់ផលិតផលកែច្នៃឡើងវិញ។

### ស្ថានភាពបច្ចុប្បន្ន

យោងតាមរបាយការណ៍ ស្តីអំពីការគ្រប់គ្រងសំណល់រឹងនៅក្នុងប្រទេសកម្ពុជា មានសំណល់ប្រមាណ៨៦តោន ត្រូវបានកែច្នៃរៀងរាល់ថ្ងៃនៅរាជធានីភ្នំពេញតាមរយៈចរន្តកែច្នៃក្រៅផ្លូវការ។ ក្នុងចំណោមសំណល់ដែលបានប្រមូលមានតែ ៣៩.៧ តោនប៉ុណ្ណោះ ត្រូវបានគេកែច្នៃជារៀងរាល់ថ្ងៃដែលស្មើនឹង ៤,៣% នៃសំណល់ទាំងអស់ដែលបានបញ្ចេញចោល។ (លោក Sethy ឆ្នាំ២០១៧)

- សកម្មភាពកែច្នៃភាគច្រើនកើតឡើងតាមបែបប្រព័ន្ធមិនផ្លូវការ ពីព្រោះការកែច្នៃឡើងវិញតាមបែបផ្លូវការនោះតិចតួចណាស់នៅក្នុងប្រទេសកម្ពុជា (មានតែក្រុមហ៊ុនផលិតក្រដាសប៉ុណ្ណោះ)
  - នៅតាមគ្រួសារ សំណល់ត្រូវបានលក់ទៅឱ្យអ្នកដើរទិញសំណល់អេតចាយ ដែលដើរពីផ្ទះមួយទៅផ្ទះមួយទៀតក្នុងតម្លៃទាបបំផុត
  - សំណល់ដែលប្រមូល បន្ទាប់មកត្រូវបានលក់សម្រាប់ប្រាក់ចំណេញតិចតួចទៅកាន់ឈ្មួញកណ្តាល បន្ទាប់មកគេក៏លក់សំណល់ជាទ្រង់ទ្រាយធំៗទៅកន្លែងកែច្នៃនៅក្នុងប្រទេសជិតខាង ដូចជាប្រទេសវៀតណាម ថៃ ឬប្រទេសម៉ាឡេស៊ីជាដើម។ សម្រាប់អ្នករើសអេតចាយ មួយគីឡូក្រាមកំប៉ុងអាលុយមីញ៉ូមអាចលក់បាន ០,៣៥ដុល្លារ ចំណែកទង់ដែងមួយគីឡូអាចលក់បាន ៣,២ដុល្លារ
- នៅតាមគ្រួសារ មិនត្រូវបានលើកទឹកចិត្តគ្រប់គ្រាន់ដើម្បីចំណាយពេលវេលាក្នុងការញែកសំណល់ឡើយ ពីព្រោះមានការលើកទឹកចិត្តតិចតួច។

### សកម្មភាព

a. កិច្ចសហការជាមួយនឹងស្ថាប័នជាតិ ក្នុងការរៀបចំគម្រោងស្លាកសញ្ញា

បង្កើតគម្រោងស្លាកសញ្ញាសម្រាប់ផលិតផលកែច្នៃដោយចាត់ថ្នាក់ និងដាក់ស្លាកផលិតផលខុសគ្នាទៅនឹងផលិតផលដែលមិនបានពីការកែច្នៃ។ រាល់កញ្ចប់ផលិផលកែច្នៃ គួរតែបោះត្រាដោយស្លាកសញ្ញាពណ៌បៃតង ដើម្បីឱ្យប្លែកខុសពីគេ និងជូនដំណឹងដល់អតិថិជន ចំពោះព័ត៌មានដែលពាក់ព័ន្ធនឹងផលិតផល ដូចជា ជួយទិញរបស់កែច្នៃយកមកប្រើប្រាស់ជាដើម។

b. លើកកម្ពស់ការប្រើប្រាស់ផលិតផលកែច្នៃពីអ្នកប្រើប្រាស់

- ការកំណត់អត្តសញ្ញាណ/ ណែនាំ/ ការលើកកម្ពស់លើផលិតផលក្នុងស្រុក ដែលបង្កើតពីរបស់កែច្នៃឡើងវិញ
- ការលើកកម្ពស់ការទិញផលិតផលបៃតងតាមរយៈការធ្វើយុទ្ធនាការផ្សព្វផ្សាយ និងជំរុញអ្នកប្រើប្រាស់ឱ្យគាំទ្រការប្រើប្រាស់ផលិតផលកែច្នៃឡើងវិញ
- គាំទ្រផ្សារតាមផ្លូវ ឬហាងលក់របស់មួយទឹក ដើម្បីជំរុញដល់សកម្មភាពប្រើប្រាស់របស់កែច្នៃនៅតាមទីផ្សារ

c. សេចក្តីណែនាំអំពីច្បាប់លទ្ធកម្មសាធារណៈផលិតផលបៃតង

ការដឹកនាំឱ្យមានការផ្លាស់ប្តូរទម្លាប់ក្នុងការប្រើប្រាស់ផលិតផល តាមរយៈរដ្ឋបាលរាជធានីភ្នំពេញក្នុងកិច្ចគាំទ្រការ

ប្រើប្រាស់ផលិតផលកែច្នៃឡើងវិញ និងផ្សព្វផ្សាយការប្រើប្រាស់ផលិតផលបៃតង (ឧទាហរណ៍៖ ការប្រើប្រាស់ក្រដាសកែច្នៃ) គឺជាការអន្តរាគមន៍មានប្រសិទ្ធភាពក្នុងការបង្កើនល្បឿនលើការប្រើប្រាស់ផលិតផលកែច្នៃ។ ច្បាប់/ បទបញ្ញត្តិលទ្ធកម្មសាធារណៈ អាចកំណត់នូវលក្ខខណ្ឌ/ តម្រូវការច្បាស់លាស់ និងបទដ្ឋានបរិស្ថាន។

ឃ. វិធានការណ៍ផ្លាស់ប្តូរឥរិយាបទបុគ្គលរបស់ភាគីពាក់ព័ន្ធ

- យុទ្ធនាការអប់រំផ្សព្វផ្សាយ ស្តីពីការជំនួសលើការប្រើប្រាស់របស់ដែលមិនអាចប្រើប្រាស់ឡើងវិញ (ឧទាហរណ៍៖ ថង់ប្លាស្ទិក) ជាមួយនឹងរបស់ដែលអាចប្រើឡើងវិញ (ឧទាហរណ៍៖ ថង់ក្រដាស ឬក្រណាត់)។ លើសពីនេះ រដ្ឋបាលរាជធានីភ្នំពេញគួរតែលើកកម្ពស់របៀបរស់នៅដ៏ត្រឹមត្រូវ និងសន្សំសំចៃ ដែលប្រជាជនប្រើប្រាស់ធនធានឱ្យបានត្រឹមត្រូវ និងការប្រើប្រាស់ឡើងវិញតាមមធ្យោបាយដែលអាចធ្វើទៅបាន។
- ផ្តល់ភាពងាយស្រួលក្នុងជម្រើសកែច្នៃឡើងវិញ៖ ដើម្បីជ្រៀតចូលទីផ្សារផ្គត់ផ្គង់ផលិតផលកែច្នៃគួរតែមានក្នុងចរន្ត ឬទម្រង់ផ្សេងៗគ្នា។ ដូចលើកឡើងខាងលើ រដ្ឋបាលរាជធានីភ្នំពេញគួរតែលើកទឹកចិត្តឱ្យមានដំណោះស្រាយការកែច្នៃដែលមានគំនិតច្នៃប្រឌិត។ ដោយមានការលើកទឹកចិត្តពីរដ្ឋបាលរាជធានីភ្នំពេញ ប្រជាជននឹងអាចទទួលបាននូវសេវាកែច្នៃឡើងវិញដែលមានលក្ខណៈទូលំទូលាយ ដែលពួកគេអាចជ្រើសរើសបាន
- បង្កើនសមត្ថភាពការកែច្នៃ៖ បណ្តុះបណ្តាលមន្ត្រីរដ្ឋាភិបាល ប្រជាពលរដ្ឋ និងអ្នកពាក់ព័ន្ធ ស្តីពីបច្ចេកវិទ្យាកែច្នៃសំណល់ និងការអនុវត្តន៍។
- ប្រព័ន្ធសម្រាប់ត្រួតពិនិត្យ និងការវាស់វែងការរីកចម្រើន (មើលជំពូកទី៥)។

## ៣. សកម្មភាពចម្បងទី៣៖ ការលើកកម្ពស់ការគ្រប់គ្រងទីលានចាក់សំរាមប្រកបដោយចីរភាពបរិស្ថាន និងការកាត់បន្ថយផលប៉ះពាល់លើបរិស្ថាន និងជីវភាពរស់នៅ

### សកម្មភាពទី៣.១. ការធ្វើឱ្យការគ្រប់គ្រងទីលានចាក់សំរាមមានភាពប្រសើរឡើង

#### គោលបំណង

ធ្វើឱ្យការគ្រប់គ្រងទីលានចាក់សំរាមបច្ចុប្បន្នប្រសើរឡើងដល់កម្រិតមួយ ដែលសាធារណជនទូទៅអាចទទួលយកបាន ដើម្បីធានានូវសុវត្ថិភាពកម្មករ និងការរួមបញ្ចូលអ្នករើសសំរាមក្រៅផ្លូវការចូលទៅក្នុងប្រព័ន្ធគ្រប់គ្រងទីលានចាក់សំណល់។

#### ស្ថានភាពបច្ចុប្បន្ន

បច្ចុប្បន្ន ទីលានសំរាមដង្កោកំពុងប្រតិបត្តិការដោយមានវិធានការគ្រប់គ្រងនៅមានកម្រិតនៅឡើយ។ ក្នុងកំឡុងពេលឆ្នាំ២០០៩-២០១២ ទីលានចាក់សំរាមត្រូវបានដំណើរការជាទីលានចាក់សំរាមពាក់កណ្តាលអ៊ែរ៉ូប៊ិក ដោយមានការណែនាំត្រឹមត្រូវពីអង្គការ JICA ។ ទោះបីជាយ៉ាងណាក៏ដោយ បន្តិចម្តងវាបានក្លាយជាទីលានចាក់សំរាមចំហរមួយ ដែលគេចាក់សំរាមចោលទៅក្នុងរណ្តៅដោយមិនត្រូវបានបែងចែកទៅតាមប្រភេទសំណល់ និងមិនមានគ្របដីប្រចាំថ្ងៃ/តាមកាលកំណត់ និងមិនមានប្រព័ន្ធប្រព្រឹត្តកម្មទឹកស្អុយ ដែលបង្កឱ្យមានផលប៉ះពាល់ដល់ទឹកក្រោមដី។ ស្ថានភាពសុខភាពអ្នករើសសំណល់អេតចាយរាប់រយនាក់ ដែលជីវភាពរបស់ពួកគេអាស្រ័យនឹងទីលានចាក់សំរាមស្ថិតក្រោមហានិភ័យ ដោយសារតែគ្មានគ្រឿងការពារផ្ទាល់ខ្លួន ឬមានតិចតួច ហើយសកម្មភាពរុករកអេតចាយរបស់ពួកគេមិនត្រឹមត្រូវតាមច្បាប់/គ្មានការគ្រប់គ្រង។

ជាធម្មតា សំណល់រឹងដែលបានបង្កើតនៅរាជធានីភ្នំពេញប្រមាណជាង ៥១,៩% គឺជាសំណល់ជីវៈដែលជាប្រភពនៃ

ការបំពុលដោយក្លិន ទឹកសំអុយ និងឧស្ម័នមេតាន ($CH_4$) ។ ជាលទ្ធផល ប្រជាពលរដ្ឋជុំវិញទីលានចាក់សំរាមតែងសំដែងការមិនពេញចិត្តផងដែរ ខណៈមានការបំពុលទឹកក្រោមដីតាមរយៈទឹកសំអុយ និងទៅលើវាលស្រែនៅជុំវិញ និងការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ទៅក្នុងបរិយាកាស។ បន្ថែមលើផលប៉ះពាល់បរិស្ថាន ក៏មានការជះឥទ្ធិពលលើបញ្ហាសុខភាពអ្នករើសសំរាមដែលជៀសមិនផុតឡើយ។

គិតមកដល់ត្រឹមឆ្នាំ២០១៨នេះ យើងអាចកត់សម្គាល់ឃើញថា មានសំណើមួយចំនួន ស្តីពីការកែលម្អទីលានចាក់សំរាមពីអ្នកអភិវឌ្ឍន៍គម្រោងអន្តរជាតិមួយចំនួនត្រូវបានដាក់ស្នើទៅរដ្ឋបាលរាជធានី ដើម្បីធ្វើការពិចារណា។ ភាគច្រើននៃពួកគេបានស្នើឱ្យមានរោងចក្រផលិតថាមពលពីសំណល់(WtE) ជាជម្រើសដែលអាចសម្រេចបានសម្រាប់ការកាត់បន្ថយបរិមាណសំរាម សំណល់រឹងពីទីក្រុងទៅទីលានចាក់សំរាម (តម្លៃបរិស្ថាន) និងព្រមទាំងផលិតថាមពលក្នុងពេលតែមួយ។

## សកម្មភាព

ការកែលម្អទីលានចាក់សំរាម គឺជាសកម្មភាពចាំបាច់ក្នុងការបង្កើនស្តង់ដានៃការគ្រប់គ្រងសំណល់ក្នុងរាជធានីភ្នំពេញ។ ទីលានចាក់សំរាមនឹងត្រូវកែលម្អជាបន្តបន្ទាប់ ពីប្រតិបត្តិការនាពេលបច្ចុប្បន្នដែលស្រដៀងនឹងទីលានចាក់សំរាមចំហរ ទៅជាទីលានចាក់សំរាមពាក់កណ្តាលសុវត្ថិភាព (សម្រាប់ទីលានចាក់សំរាមដែលមានស្រាប់) ហើយទីបំផុតរៀបចំជាទីលានចាក់សំរាមប្រកបដោយសុវត្ថិភាព និងអនាម័យពេញលេញ (សម្រាប់ទីលានចាក់សំរាមនាពេលអនាគត)។ អនុសាសន៍ដែលបានរៀបរាប់ខាងក្រោម គឺជាវិធានការបន្ទាន់សម្រាប់ទីលានចាក់សំរាមបច្ចុប្បន្នសម្រាប់ធ្វើការពិចារណា និងការអនុវត្តន៍ដែលអាចយកមកប្រើប្រាស់សម្រាប់ទីលានចាក់សំរាមនាពេលអនាគត (បច្ចុប្បន្នស្ថិតនៅក្រោមការសម្រេចចិត្តរបស់រដ្ឋបាលរាជធានី)។ ដោយហេតុថា ទីលានចាក់សំរាមបច្ចុប្បន្ន នឹងត្រូវអស់សមត្ថភាពស្តុកសំរាមរបស់ខ្លួន ដូច្នេះគេត្រូវរៀបចំ និងធ្វើផែនការសម្រាប់កំណត់នូវទីលានថ្មីមួយផ្សេងទៀត (ទីលានបែបអនាម័យ)។

a. ការចាប់ផ្តើមឡើងវិញនូវការថែទាំ និងប្រតិបត្តិការទីលានចាក់សំរាមឱ្យបានត្រឹមត្រូវ

ការកែលម្អអាចចាប់ផ្តើមពីវិធានការចំណាយអស់តិច តែមានគុណភាពខ្ពស់ ជាជាងប្រើប្រាស់បច្ចេកវិទ្យាដែលត្រូវការធនធានច្រើន។ ស្តង់ដាប្រតិបត្តិការ (SOP) ស្តីពីការងារប្រតិបត្តិ និងថែទាំទីលានចាក់សំរាម គួរតែត្រូវបានរៀបចំ និងអនុវត្តឱ្យបានល្អ។

- តាមដានត្រួតពិនិត្យកម្ពស់ទីលានចាក់សំរាម ជៀសវាងកុំឱ្យដួលរលំគំនរសំរាម (សូមមើលឧបសម្ព័ន្ធទីVI)
- ការចាក់ដីគ្របសំរាម៖ ទំហំ និងការរៀបចំរណ្តៅចាក់សំរាម ភាពញឹកញាប់ និងបរិមាណដីដែលត្រូវយកមកគ្របសំរាមអាចសម្រេចបានដោយការវាយតម្លៃត្រឹមត្រូវអំពីបរិមាណ/ ប្រភេទនៃសំណល់ និងកម្រិតទឹកក្រោមដីជាដើម។ បទពិសោធន៍នៃប្រទេសដទៃទៀត ដែលមានស្ថានភាពស្រដៀងគ្នា អាចយកមករៀនសូត្រ និងអនុវត្តបាន
- ត្រួតពិនិត្យ និងបន្តធ្វើឱ្យប្រសើរឡើង ការអនុវត្តន៍ការងារចាក់សំរាម និងបញ្ចេញទឹកស្អុយចេញពីរថយន្តប្រមូលសំរាមសំណល់រឹង៖ រថយន្តប្រមូលសំរាមចូលទីលានចាក់សំរាម ត្រូវមានស្ថានភាពល្អ ដូចជា៖ ១) មានគំរបដែកគ្របមិនឱ្យសំរាមធ្លាក់រាយប៉ាយ ២) ធុងស្តុកទឹកស្អុយ (នៅខាងក្រោមរថយន្ត) មិនត្រូវលេចធ្លាយ។ ការហូរទឹកស្អុយ និងធ្លាក់សំរាមរាយប៉ាយ គួរតែបង្ការកុំឱ្យកើតមាននៅតាមផ្លូវចូល និងចេញនៅទីលានចាក់សំរាម។ ប្រសិនបើរថយន្តប្រមូលត្រូវបង្ហូរទឹកស្អុយចេញ ទីតាំងពិសេសសម្រាប់បញ្ចេញគួរតែត្រូវបានគេកំណត់ទុក ដើម្បីចាក់ទឹកស្អុយចូលទៅក្នុងអាងទឹកស្អុយដោយផ្ទាល់
- លើកកម្ពស់ឱ្យមានសម្ភារការពារខ្លួនសម្រាប់កម្មករ (PPE) និងអ្នករើសសំរាមដែលនៅទីលានចាក់សំរាម៖ បន្តផ្តល់

ជូន ស្បែកជើង ស្រោមដៃ ម៉ាស់ និងសម្ភារការពារផ្សេងៗទៀត ដោយឥតគិតថ្លៃសម្រាប់បុគ្គលិកទីលានសំរាម និងអ្នករើសសំរាមប្រើជាបណ្តោះអាសន្ន។ លើកកម្ពស់សារៈសំខាន់ និងលើកទឹកចិត្តការប្រើប្រាស់ឧបករណ៍ការពារខ្លួនឱ្យបានត្រឹមត្រូវគ្រប់ពេលវេលា

- អនុវត្តសាកល្បងវិធីប្រមូលឧស្ម័នពីទីលានចាក់សំរាម៖ ដោយសារសំរាមមានសមាសធាតុសំណល់ជីវៈប្រហែលជាង ៥០% ឧស្ម័នកាបូនិច ($CO_2$) និងមេតាន ($CH_4$) នឹងបំភាយចេញពីទីលានចាក់សំរាមដង្កោក្នុងកំរិតមួយដែលខ្ពស់ និងគួរឱ្យព្រួយបារម្ភ។ ចំពោះប្រព័ន្ធប្រមូលឧស្ម័ន ទោះបីជាប្រភេទបញ្ចេញដោយធម្មតា ឬតាមការបូមត្រូវមានអណ្តូងប្រមូលឧស្ម័នរាយប៉ាយនៅពេញទីលាន។ វាជាការធម្មតាក្នុងការបំភាយឧស្ម័នដោយផ្ទាល់ទៅបរិយាកាសដោយមិនចាំបាច់ឆ្លងកាត់ការធ្វើប្រព្រឹត្តកម្មអ្វីទាំងអស់ បច្ចេកទេសផ្សេងៗទៀតរួមមាន ការដុតឧស្ម័ន (បច្ចេកទេសចំហេះ) និងការបម្លែងជាថាមពល (បច្ចេកទេសគ្មានចំហេះ)។

**ប្រព័ន្ធប្រមូលឧស្ម័នអកម្ម៖** ប្រើអណ្តូងប្រមូលឧស្ម័ន ដែលត្រូវបានគេស្គាល់ផងដែរថា ជាអណ្តូងទាញយកឧស្ម័ន។ អណ្តូងប្រមូលយកឧស្ម័ន ជាធម្មតាត្រូវបានដំឡើងដោយទុយោជ័រ មានរន្ធជុំវិញ ហើយត្រូវបានតំឡើងបញ្ឈរនៅទីលានចាក់សំរាមរហូតដល់ជម្រៅចាប់ពី ៥០% ទៅ ៩០% នៃកម្រាស់សំណល់។ ជាធម្មតាអណ្តូងបញ្ឈរត្រូវបានដំឡើងបន្ទាប់ពី ឬផ្នែកខ្លះនៃទីលានចាក់សំរាម ត្រូវបានគេបិទដំណើរការ។




ទឹកសំអុយទីលានហូរឆ្លងកាត់សំរាម សំណល់រឹងទាំងអស់ ទាំងសំណល់រលាយ ឬសំណល់មានសារធាតុកម្ទេចកម្ទី ហើយជាញឹកញាប់គេឃើញវាមានសមាសធាតុពុល។
បច្ចុប្បន្នទឹកសំអុយទីលានបានប្រមូលផ្តុំមកពីតាមតំបន់ទំនាបនានានៃទីលានចាក់សំរាម ហើយជួនកាលត្រូវបានបង្វែរចូលក្នុងស្រះទឹកសម្រាប់ទុកឱ្យហួត។ ដោយសារតែអវត្តមាននៃស្រទាប់កៅស៊ូក្រាល អាចធ្វើឱ្យទឹកសំអុយទីលានមួយចំនួនអាចជ្រាបចូលទៅក្នុងប្រព័ន្ធទឹកក្រោមដីបាន។

b. ការរៀបចំហេដ្ឋារចនាសម្ព័ន្ធទីលានចាក់សំរាម

- បង្កើតប្រពន្ធ័ប្រមូល និងប្រព័ន្ធប្រព្រឹត្តកម្មទឹកស្អុយ៖ ទឹកដែលចេញពីសំណល់ត្រូវបានគេហៅថា "ទឹកស្អុយ" ។ ទឹកស្អុយ នៅពេលឆ្លងកាត់សមាសធាតុសំណល់ វាទាញយកសារធាតុរឹងរលាយក្នុងទឹក ឬអណ្តែត បង្កជាសារធាតុខាប់ដែលមានសមាសធាតុពុលច្រើន។ បច្ចុប្បន្នទឹកស្អុយប្រមូលផ្តុំនៅតាមទីតាំងដីទាបក្នុងរណ្តៅទីលាន ហើយជួនកាលត្រូវបានបង្វែរចូលក្នុងអាងស្តុកទឹកស្អុយទុកឱ្យហួតរឹង។ ដោយសារតែអវត្តមានស្រទាប់ការពារជម្រាប ទឹកស្អុយនេះអាចជ្រាបចូលក្នុងដីដែលមានធ្វើឱ្យប៉ះពាល់ដល់ប្រភពទឹកក្រោមដី។ ការកែលម្អប្រព័ន្ធនេះ ត្រូវតែចាត់ទុកជាចំណុចអាទិភាពបំផុត។
    - ចាប់ផ្តើមសិក្សាវិធីសាស្ត្រ ការអនុវត្តន៍ជាដំណាក់កាលៗ ដើម្បីនាំមកនូវបច្ចេកទេសសមស្របនៅតាមមូលដ្ឋានប្រមូល និងធ្វើប្រព្រឹត្តកម្មទឹកស្អុយពីទីលានចាក់សំរាមដង្កោ និងទីលានចាក់សំរាមផ្សេងៗទៀតនាពេលអនាគតដែលអាចការពារផលប៉ះពាល់អវិជ្ជមានទៅលើដី ទឹកក្រោមដី និងផ្លូវទឹកផ្សេងៗទៀត

- រៀបចំហេដ្ឋារចនាសម្ព័ន្ធសម្រាប់បង្ហូរទឹកសំអុយពីឡានប្រមូលសំរាម
- សាងសង់ប្រព័ន្ធប្រឡាយជុំវិញទីលានចាក់សំរាម ដើម្បីប្រមូលទឹកសំអុយពីទីលាន ហើយស្តុកវានៅក្នុងអាងទឹកសំអុយ ជៀសវាងបង្ហូរវាទៅក្នុងប្រឡាយ ឬប្រព័ន្ធផ្លូវទឹកដែលទៀត

▪ រៀបចំនូវទីតាំងផ្តល់ថ្នាំសង្កូវនៅទីលានចាក់សំរាម

▪ ពង្រីកផ្ទៃដីពីសចាក់សំរាម ដើម្បីលើកកម្ពស់សុវត្ថិភាពបុគ្គលិក និងអ្នករើសសំណល់អេតចាយកាន់តែប្រសើរឡើង

▪ ផ្លាស់ប្តូរគ្រឿងចក្រចុនធូន់ (ម៉ាស៊ីនដឹកកកាយ និងម៉ាស៊ីនរុញសំរាម) ដើម្បីប្រសិទ្ធភាពប្រតិបត្តិការនៅទីលានចាក់សំរាម

c. រៀបចំការផ្លាស់ប្តូរឆ្ពោះទៅរកការញែកសំណល់៖

នៅទីលានចាក់សំរាមដង្កោ មានកន្លែងសាកល្បងមួយសម្រាប់ញែកសំណល់ជីវៈ និងយកធ្វើជីកំប៉ុស។ បច្ចុប្បន្នទីតាំងនេះមិនមានសកម្មភាពទេ ឬមានសកម្មភាពម្តងម្កាល។ ការរៀបចំបង្កើតស្ថានីយកែច្នៃសំណល់មួយពេញលេញ (Material Recovery Facility) គឺជាអ្វីដែលគេចង់បាននាពេលខាងមុខ ប៉ុន្តែជាបន្ទាន់ គេគួររៀបចំឱ្យមានទីតាំងសាមញ្ញមួយសម្រាប់អ្នករើសសំរាម ដើម្បីញែកសំណល់អេតចាយ។ អ្នករើសសំរាមអាចបែងចែកទៅជាច្រើនក្រុមសម្រាប់ធ្វើការផ្លាស់ប្តូរវេនគ្នា។ (សូមមើលសកម្មភាពទី៣.៣ ការសហការជាមួយវិស័យក្រៅប្រព័ន្ធ)

d. ទាក់ទាញអ្នកឯកទេស និងពង្រឹងធនធានមនុស្សសម្រាប់ការគ្រប់គ្រងទីលាន

កសាងសមត្ថភាពក្នុងការគ្រប់គ្រងទីលានដល់គ្រប់បុគ្គលិកទីលានចាក់សំរាមទាំងអស់ ដោយប្រើប្រាស់នូវធនធានជំនួយឧបត្ថម្ភពីក្នុងស្រុក និងអន្តរជាតិ ដែលរួមមានដូចជា៖

▪ កំណត់សមត្ថភាពបច្ចេកទេសបច្ចុប្បន្នរបស់បុគ្គលិកធ្វើការនៅកន្លែងចាក់សំរាម និងកំណត់ចំណុចដែលត្រូវកែលម្អ និងសមត្ថភាពខ្លះទៀតដែលត្រូវការ (បែបពិពណ៌នា និងកម្រិត)

▪ ដឹកនាំបុគ្គលិកចូលរួម វគ្គបណ្តុះបណ្តាល និងការធ្វើទស្សនកិច្ចសិក្សានៅមូលដ្ឋានទាំងក្នុងតំបន់ និងអន្តរជាតិ ដោយមានផែនការបេសកកម្មច្បាស់លាស់ លទ្ធផល និងការទទួលខុសត្រូវ សម្រាប់ការអនុវត្តន៍ចេញពីការសិក្សារៀនសូត្រ

▪ ស្វែងរក និងស្នើសុំជំនួយបច្ចេកទេស ពីម្ចាស់ជំនួយអន្តរជាតិ (អង្គការ JICA ធនាគារអភិវឌ្ឍន៍អាស៊ី និងស្ថាប័នដទៃទៀត) ក្នុងការផ្លាស់ប្តូរឯកទេស ដើម្បីជួយសម្រួលដល់ការផ្ទេរចំណេះដឹងស្តីពីទិដ្ឋភាពជាក់ស្តែងនៃការគ្រប់គ្រងទីលាន

▪ រៀបចំកម្មវិធីកម្មសិក្សានៅសាកលវិទ្យាល័យបច្ចេកទេសនានារបស់កម្ពុជា (ITC, RUPP ជាដើម) ដើម្បីទាក់ទាញទេពកោសល្យវ័យក្មេង ធ្វើការងារទាក់ទងទៅនឹងការច្នៃប្រឌិតដែលពាក់ព័ន្ធនឹងទីលានចាក់សំរាម/ បញ្ហាប្រឈមផ្នែករចនាសម្ព័ន្ធ/ បរិស្ថាន

e. កែលម្អឧបករណ៍ និងវិធីសាស្ត្រកត់ត្រាបរិមាណសំណល់

▪ ការកត់ត្រាបរិមាណសំណល់នៅទីលានចាក់សំរាមនៅរាជធានីភ្នំពេញ ត្រូវបានអនុវត្តតាំងពីឆ្នាំ២០០៣ ដែលនាំឱ្យមានភាពជឿជាក់ខ្លាំងលើបរិមាណសំរាមយកមកចាក់ចោល។ ការប្រើប្រាស់ និងការវិភាគទិន្នន័យដែលបានកត់ត្រាទុកស្ថិតនៅក្នុងកម្រិតអប្បរមា ដោយសារទិន្នន័យត្រូវកត់ដោយដៃ ហើយត្រូវបានរក្សាទុកនៅនឹងកន្លែងដោយប្រើ Microsoft Access ។ បច្ចុប្បន្នការិយាល័យគ្រប់គ្រងទីលានរបស់សាលារាជធានីភ្នំពេញកំពុងអនុវត្តកម្មវិធីផ្ទុកទិន្នន័យ ដែលគ្មានដែនកំណត់ ឬ cloud based system សម្រាប់កត់ត្រា និងរក្សាទិន្នន័យពីបរិមាណសំណល់ចូល។ ប្រព័ន្ធថ្មីនេះ គេអាចតាមដានបរិមាណសំណល់ទៅតាមពេលវេលាជាក់ស្តែង និងបង្ហាញទិន្នន័យសំណល់ត្រឹមត្រូវតាមថ្នាក់ខណ្ឌ/សង្កាត់

f. ការតាមដានត្រួតពិនិត្យហេតុប៉ះពាល់បរិស្ថាន និងសុខភាព

- ធ្វើការសិក្សាលើការបំពុលទឹក និងដី
- ធ្វើការសិក្សា លើផលប៉ះពាល់លើសុខភាពនៃប្រតិបត្តិការចាក់សំរាមទៅលើអ្នកជិតខាង កម្មករចាក់សំរាម និងអ្នករើសសំណល់អេតចាយ។

**ការប៉ាន់ស្មានការបំភាយឧស្ម័នផ្ទះកញ្ចក់ និងការបំពុលបរិយាកាសរយៈពេលខ្លី (SLCP) នៅទីលានចាក់សំរាមដង្កោ រាជធានីភ្នំពេញ**

ទីលានចាក់សំរាមនៅទូទាំងពិភពលោក បាននិងកំពុងរួមចំណែកបំភាយឧស្ម័នផ្ទះកញ្ចក់យ៉ាងច្រើនក្នុងចំណោមផលប៉ះពាល់អវិជ្ជមានផ្សេងៗទៀតលើបរិស្ថាន តាមរយៈការបង្កើតសំណល់រឹងទីប្រជុំជន (MSW) ក្នុងកម្រិតធំបំផុតទី៣ តាមរយៈការបំភាយឧស្ម័នមេតានដែលកើតចេញពីសកម្មភាពមនុស្ស។

ដោយផ្អែកលើស្ថាប័នទំនាក់ទំនងជាតិដំបូងរបស់កម្ពុជាប្រចាំនៅអង្គការសហប្រជាជាតិ ទៅនឹងអនុសញ្ញាក្របខណ្ឌសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ (UNFCCC) នៅឆ្នាំ២០០០ វិស័យសំណល់បានរួមចំណែកប្រមាណ ១% ចំពោះការបំភាយឧស្ម័នផ្ទះកញ្ចក់សរុបរបស់ប្រទេស ដែលរួមចំណែកជាង ២២៩.០០០តោន $CO_2$eq ក្នុងមួយឆ្នាំ។ វាជាការប៉ាន់ប្រមាណដំបូងមួយ ដែលត្រូវបានគេចាត់ទុកថាជាការសន្មត់នៅក្រោមបរិមាណជាក់ស្តែងដោយសារបញ្ហា "ការប្រមូលទិន្នន័យមិនទៀងទាត់ និងការខ្វះទិន្នន័យ" គឺជាឧបសគ្គសម្រាប់ការប៉ាន់ស្មានការបំភាយនេះឲ្យបានត្រឹមត្រូវ។

ការសិក្សាមួយរបស់អ្នកស្រាវជ្រាវ Hoklis និងក្រុមហ៊ុន Sharp (ឆ្នាំ ២០១៤) បានគណនាការបំភាយឧស្ម័នផ្ទះកញ្ចក់ពីទីលានចាក់សំរាមនៅរាជធានីភ្នំពេញ ថាមានចំនួន ៣៣១.៤០០ តោន $CO_2$eq ក្នុងមួយឆ្នាំ។ ការប៉ាន់ស្មានឯករាជ្យដទៃទៀតពីវិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា បានបង្ហាញថាការបំភាយឧស្ម័នផ្ទះកញ្ចក់សរុប ដែលទាក់ទងទៅនឹងការចាក់ចោលសំណល់រឹងនៅទីលានដង្កោ រាជធានីភ្នំពេញមានចំនួនប្រហែល ២៨៣.៥៨៤ តោន $CO_2$eq ក្នុងមួយឆ្នាំ។ ខណៈពេលដែលវាពិបាកក្នុងការនិយាយយ៉ាងច្បាស់ថាតើតួលេខមួយណា ដែលត្រឹមត្រូវបំផុតនោះណាស់ តែអ្នកអាចកត់សម្គាល់បានថា ការប៉ាន់ប្រមាណនេះ គឺមានតួលេខប្រហាក់ប្រហែលគ្នា។

ឧស្ម័នម្យ៉ាងដែលចូលរួមនៅក្នុងបំភាយឧស្ម័នផ្ទះកញ្ចក់នៅទីលានចាក់សំរាមគឺ ឧស្ម័នមេតាន ($CH_4$) ដែលត្រូវបានបង្កើតឡើងពីសំណល់សរីរាង្គដែលពុកផុយ។ មេតាន គឺជាឧស្ម័នផ្ទះកញ្ចក់ ដែលមានអនុភាពខ្លាំងជាងឧស្ម័នកាបូនិក ២៥ដង។ ប្រភពឧស្ម័នផ្ទះកញ្ចក់ ពីវិស័យគ្រប់គ្រងសំណល់ រួមបញ្ចូលការបំភាយឧស្ម័នកាបូនិក ($CO_2$) ដែលបានបញ្ចេញតាមរយៈសំណល់ ក៏ដូចជាការដឹកជញ្ជូនសំណល់ជាដើម។ ការបំភាយផ្សេងទៀត រួមមានកាបូនខ្មៅ (BC) ដែលបានមកពីការដុតនៅទីចំហរ។ កាបូនខ្មៅ (BC) ត្រូវបានគេចុះបញ្ជីជាសារធាតុពុលបរិយាកាសខ្លី SCLP ហើយក៏ស្រូបយកពន្លឺព្រះអាទិត្យដែលរួមចំណែកដល់ឥទ្ធិពលផ្ទះកញ្ចក់ផងដែរ។

ក្លិនអាក្រក់នៅទីលានចាក់សំរាម គឺបណ្តាលមកពីធាតុផ្សំនៃឧស្ម័ន ដូចជា មេតាន អាម៉ូញាក់ និងអ៊ីដ្រូសែនស៊ុលហ្វាត។ មេតាន គឺមានភាពងាយឆាបឆេះ និងកំហាប់ខ្ពស់អាចផ្ទុះបាន ដែលអាចបង្កគ្រោះថ្នាក់ដល់បុគ្គលិកនៅទីលានចាក់សំរាម និងសហគមន៍ដែលរស់នៅជិតៗនោះ។ ការបំភាយឧស្ម័នមេតានពីទីលានចាក់សំរាម គឺជាការបាត់បង់ឱកាសក្នុងការប្រមូល និងប្រើប្រាស់ធនធានថាមពលដ៏សំខាន់មួយនេះ។ វិធីប្រមូលមេតានអកម្ម និងសកម្មត្រូវបានប្រើ ដើម្បីគ្រប់គ្រងផលប៉ះពាល់នៃឧស្ម័នផ្ទះកញ្ចក់ពីទីលានចាក់សំរាម។ នៅក្នុងប្រព័ន្ធប្រមូលឧស្ម័នអកម្ម អណ្តូងប្រមូលយកឧស្ម័នជួយបន្ថយសម្ពាធឧស្ម័ន និងបញ្ចេញឧស្ម័នមេតានចេញពីរណ្តៅចាក់សំរាម។

នៅបណ្តាប្រទេសអភិវឌ្ឍន៍ បច្ចេកវិទ្យាគ្រប់គ្រងសំណល់ ដោយប្រែក្លាយឧស្ម័នទៅថាមពល (ថាមពលពីសំណល់) ដោយគេទាញឧស្ម័នមេតានពីកន្លែងចាក់សំរាមហើយប្រើវា ដើម្បីបង្កើតអគ្គិសនីស្អាត។

- ប្រព័ន្ធប្រមូលឧស្ម័នបែបសកម្ម ត្រូវបានគេចាត់ទុកថាជាមធ្យោបាយមានប្រសិទ្ធភាពបំផុតក្នុងការប្រមូលឧស្ម័នទីលានចាក់សំរាម។ ប្រព័ន្ធប្រមូលផ្តុំឧស្ម័នសកម្ម ធ្វើឡើងដោយម៉ាស៊ីនបឺត ឬបូមឧស្ម័នពីរណ្តៅប្រមូលឧស្ម័ន។ ការធ្វើបែបនេះនឹងតម្រូវឱ្យមានការវិនិយោគយ៉ាងច្រើនទៅលើប្រព័ន្ធទុយោ រ៉ានបិទបើក និងត្រូវរៀបចំតំឡើងនៅដំណាក់កាលដំបូងនៃផែនការអភិវឌ្ឍទីលានចាក់សំរាម។




## សកម្មភាពទី៣.២. ការរៀបចំធនធានហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងទីលានឱ្យមានចីរភាព

### គោលបំណង

ដើម្បីធ្វើឱ្យប្រសើរឡើងនូវធនធានហិរញ្ញវត្ថុ សម្រាប់ប្រព័ន្ធគ្រប់គ្រងសំណល់នៅទីលានប្រកបដោយនិរន្តរភាព។

### ស្ថានភាពបច្ចុប្បន្ន

បច្ចុប្បន្ន ទីលានតម្រូវឱ្យបង់ថ្លៃសំណល់ចំនួន ០,៧៥ដុល្លារអាមេរិក សម្រាប់សំណល់មួយតោនដែលយកមកចាក់។ ទោះជាយ៉ាងណាក៏ដោយ ការសិក្សាបានលើកឡើងថាការគ្រប់គ្រងទីលានចាក់សំរាមប្រកបដោយចីរភាពបរិស្ថាននឹងតម្រូវឱ្យមានការបង្កើនថ្លៃដែលត្រូវបង់។ ម្យ៉ាងទៀត ក្រុមហ៊ុនស៊ីនទ្រីបានពន្យារពេលបង់ថ្លៃចាក់សំណល់ចាប់តាំងពីខែមករា ឆ្នាំ២០១៨ មកដោយសារមិនមានមូលនិធិគ្រប់គ្រាន់។ ការមិនទូទាត់នេះនៅតែបន្តរហូតដល់ខែកក្កដា ឆ្នាំ២០១៨ បើទោះបីជាមានការស្នើសុំម្តងហើយម្តងទៀតពីរដ្ឋបាលរាជធានីភ្នំពេញ សម្រាប់ការទូទាត់ក៏ដោយ។

### សកម្មភាព

a. ជំហានទីមួយ គឺរៀបចំការប៉ាន់ស្មានលើចំណាយទូទៅមួយ សម្រាប់ការគ្រប់គ្រងប្រកបដោយនិរន្តរភាពបរិស្ថានរបស់ទីលានក្នុងវដ្តជីវិតទាំងមូលរបស់វា ដោយរាប់បញ្ចូលទាំងតម្លៃសម្រាប់ការបិទទីលាន ការថែរក្សា និងការត្រួតពិនិត្យក្រោយការបិទ ការសាងសង់កន្លែងចាក់សំរាមថ្មី បន្ទាប់ពីការបិទទីលានចាស់។

b. បង្កើនថ្លៃសេវាទីលាន ដើម្បីឆ្លើយតបនឹងតម្រូវការហិរញ្ញវត្ថុ ដែលបានបញ្ជាក់ដោយសកម្មភាពខាងលើ។ អត្រាសមស្របអាចត្រូវបានកំណត់ដោយផ្អែកលើការចំណាយសរុបដែលបានប៉ាន់ស្មាន និងកត្តាពាក់ព័ន្ធផ្សេងទៀតដូចជា សមត្ថភាពហិរញ្ញវត្ថុរបស់អ្នកដែលនាំយកសំណល់មកចាក់។ ការពិគ្រោះយោបល់ជាមួយអ្នកបង់ថ្លៃសេវា (ក្រុមហ៊ុនប្រមូលសំណល់) នឹងត្រូវបានធ្វើឡើងនៅក្នុងការកំណត់អត្រាមួយ តាមការយល់ដឹង និងកិច្ចសហការរបស់ពួកគេ។ ទាក់ទងនឹងយុទ្ធសាស្ត្រញែកសំណល់ (សូមមើលផ្នែកសកម្មភាពទី២) អត្រាខុសគ្នាអាចត្រូវបានអនុវត្តចំពោះសំណល់ចម្រុះ (អត្រាខ្ពស់ជាង) និងសំណល់ដែលបានញែក) អត្រាទាប (ដើម្បីជំរុញការញែក និង/ ឬអាស្រ័យលើប្រភព/ ប្រភេទសំណល់ (លំនៅដ្ឋាន និងពាណិជ្ជកម្ម) ឧស្សាហកម្ម សំណល់តាមស្ថាប័ន) ។

c. ការបែងចែកថវិកាប្រចាំឆ្នាំរបស់ក្រុង គួរត្រូវបានពិចារណាសម្រាប់ការគ្រប់គ្រងទីលាន និងការបង្កើនប្រសិទ្ធភាពទីលានបន្ថែមទៅលើតួនាទីជាទីតាំងចាក់សំរាម។ សម្រាប់ជម្រើសហិរញ្ញប្បទានសាធារណៈផ្សេងទៀតដូចជាមូលបត្រសាធារណៈ មូលនិធិសហគមន៍ និង/ ឬគំនិតផ្តួចផ្តើមផ្តល់ហិរញ្ញប្បទានឯកជន (PFI) និង/ ឬភាពជាដៃគូសាធារណៈ និងឯកជន (PPP) ក៏អាចយកមកប្រើផងដែរ។

d. ការរក្សាកំណត់ត្រាសំណល់ចូលឱ្យបានត្រឹមត្រូវ គឺមានសារៈសំខាន់ផងដែរក្នុងការផ្តល់នូវព័ត៌មានប្រភពសំខាន់សម្រាប់ការធ្វើសេចក្តីសម្រេចចិត្តផ្នែកហិរញ្ញវត្ថុដូចជា ការគណនាអាយុកាលរបស់ទីលានចាក់សំរាមដែលនៅសល់។ (សូមមើលសកម្មភាពផ្នែកទី៣.១. - d និងផ្នែកទី៥ ស្តីពីការគ្រប់គ្រងទិន្នន័យ។)

## សកម្មភាពទី៣.៣. សហការជាមួយអ្នកពាក់ព័ន្ធ

### គោលបំណង

សហការ និងដាក់បញ្ជ្រាបនូវវិស័យសំណល់ក្រៅផ្លូវការទៅក្នុងប្រព័ន្ធគ្រប់គ្រងសំណល់មួយឱ្យបានត្រឹមត្រូវ។

### ស្ថានភាពបច្ចុប្បន្ន

បច្ចុប្បន្ន អ្នកពាក់ព័ន្ធសំខាន់ៗក្នុងរំហូរសំណល់ ទិន្នន័យសំណល់ និងទំហំនៃសេដ្ឋកិច្ចទាក់ទងនឹងវិស័យកែច្នៃសំណល់ក្រៅផ្លូវការ (អ្នកប្រមូលសំរាម អ្នកប្រមូលទិញអេតចាយក្នុងទ្រង់ទ្រាយតូចៗ អ្នកលក់សំណល់/ អ្នកនាំចេញ) មិនត្រូវបានគេយល់ច្បាស់ទេ។ អ្នករើសសំណល់អេតចាយបានចូលរួមចំណែកយ៉ាងធំធេងចំពោះប្រព័ន្ធគ្រប់គ្រងសំណល់នៅក្នុងទីក្រុង តាមរយៈសកម្មភាពកែច្នៃធនធានឡើងវិញ ដែលគេមិនសូវឱ្យតម្លៃ និងមើលរំលងពីសក្តានុពលរបស់ពួកនោះទេ។ កិច្ចការពារសុខភាពរបស់កម្មករក៏ជាកង្វល់មួយផ្សេងទៀតផងដែរ។ (សូមមើលឧបសម្ព័ន្ធទី VI)

### សកម្មភាព

a. រៀបចំក្នុងខណៈអន្តរកាល ដើម្បីឆ្ពោះទៅរកការញែកសំណល់។ សូមមើលសកម្មភាពទី៣.១. c

b. សម្រាប់ផែនការរយៈពេលមធ្យម និងរយៈពេលវែងសម្រាប់ការសហការ ឬការធ្វើសមាហរណកម្មវិស័យក្រៅផ្លូវការអាចចាប់ផ្តើមរៀបចំឯកសារ និងទទួលស្គាល់ការចូលរួមចំណែករបស់វិស័យកែច្នៃសំណល់ក្រៅប្រព័ន្ធនេះនៅក្នុងការគ្រប់គ្រងសំរាមសំណល់រឹងរបស់ទីក្រុង។ ការសិក្សា និងបទពិសោធន៍ពីបណ្តាប្រទេសដទៃទៀតបានបង្ហាញថា ការចូលរួមចំណែកនៃវិស័យក្រៅផ្លូវការក្នុងការកាត់បន្ថយចំណាយគ្រប់គ្រងសំណល់រឹងទីប្រជុំជន ការចំណាយលើបរិស្ថាន ការកាត់បន្ថយភាពក្រីក្រ ការបង្កើតការងារ និងការចំណាយលើសុខភាពត្រូវតែគិតគូរសម្រាប់សមាហរណកម្មមួយនេះ។ ដើម្បីឱ្យមាននិរន្តរភាពម៉ូដែលនៃការធ្វើសមាហរណកម្មត្រូវតែបង្កើតដោយមានតួលេខច្បាស់លាស់ ដើម្បីឱ្យដឹងថា ការចំណាយ និងអត្ថប្រយោជន៍ដែលទទួលបានស្ថិតនៅយូរអង្វែង

c. ការអនុវត្តន៍យុទ្ធនាការលើកកម្ពស់ការយល់ដឹង ស្តីពីវិស័យកែច្នៃសំណល់ក្រៅប្រព័ន្ធ ឱ្យគេបានដឹងថាវិស័យនេះមានសារៈសំខាន់ ដើម្បីឱ្យឥរិយាបថសាធារណជនចំពោះសកម្មភាពនានានៃវិស័យក្រៅផ្លូវការនេះកាន់តែល្អប្រសើរឡើង

d. រៀបចំវិស័យកែច្នៃសំណល់ក្រៅផ្លូវការ ឱ្យក្លាយជាវិស័យផ្លូវការ
រដ្ឋបាលរាជធានីភ្នំពេញអាចជំរុញការធ្វើសមាហរណកម្មវិស័យក្រៅផ្លូវការតាមរបៀបផ្សេងៗគ្នាមានដូចជា៖ ទទួលស្គាល់អ្នករើសសំណល់អេតចាយជាអ្នកដើរតួនាទីយ៉ាងសំខាន់នៅក្នុងខ្សែចង្វាក់កែច្នៃឡើងវិញ អភិវឌ្ឍន៍កម្មវិធីញែកសំរាមនៅ

ប្រភព ទទួលស្គាល់ និងផ្តល់ការលើកទឹកចិត្តដល់វិស័យកែច្នៃសំណល់ក្រៅប្រព័ន្ធតាមរយៈការអនុគ្រោះពន្ធ និងសម្បទានផ្សេងៗ។ ការបង្កើតក្រុមប្រឹក្សា ឬវេទិកាដែលមានតំណាងស្មើគ្នានៃអ្នករើសអេតចាយ ឈ្មួញ និងរដ្ឋបាលរាជធានីភ្នំពេញ។ ចុះបញ្ជីអ្នកដើររើស និងអ្នកទិញសំណល់អេតចាយចល័តទាំងអស់ ហើយស្វែងរកវិធីដើម្បីផ្តល់នូវរបបសន្តិសុខសង្គម។ បង្កើតក្របខណ្ឌច្បាប់ និងគោលនយោបាយច្បាស់លាស់សម្រាប់សមាហរណកម្មវិស័យសំណល់ក្រៅប្រព័ន្ធ។ លើកកម្ពស់ស្ថាប័នវិស័យក្រៅប្រព័ន្ធក្នុងដំណើរការចុះកិច្ចសន្យាតាមរយៈការសម្រួលលក្ខខណ្ឌកិច្ចសន្យា។ ផ្តល់ប្រាក់កម្ចី ដែលមានអត្រាការប្រាក់ទាបដល់ស្ថាប័នក្រៅប្រព័ន្ធ ដែលស្វែងរកការដេញថ្លៃ និងកិច្ចសន្យា។ ផ្ទេរ/ផ្តល់សេវាប្រមូលសំណល់ និងការកែច្នៃសំណល់សម្រាប់សហគ្រាសក្រៅផ្លូវការ ខ្នាតតូច និងមធ្យម។ រក្សាដីបម្រុងទុកសម្រាប់ផែនការអភិវឌ្ឍន៍តាមបែបរិមជ្ឈការសំណល់ជីវៈ រក្សាទីតាំងបម្រុងសម្រាប់ទីតាំងការកែច្នៃសំណល់ ទីតាំងញែកសំរាម ទីតាំងស្តុកអេតចាយ និងទីតាំងផលិតកម្មពាក់កណ្តាលសម្រេច។ ផ្តល់ឥណទានដើម្បីជួយក្នុងការកសាងរោងដែលមានសុវត្ថិភាព និងរឹងមាំ និងផ្តល់លទ្ធភាពដឹកជញ្ជូនទៅកាន់ទីផ្សារ (ផ្លូវថ្នល់)។ ធានាមិនឱ្យទទួលរងពីការពិន័យ និងយកចរិកាខុសប្រក្រតី។ ផ្តល់សេវាគាំទ្រផ្នែកបច្ចេកទេសក្នុងការអភិវឌ្ឍបច្ចេកវិទ្យា និងដំណើរការឧស្សាហកម្ម។

e. ការបញ្ចូលអ្នកកែច្នៃសំណល់ក្រៅប្រព័ន្ធទៅក្នុងប្រព័ន្ធប្រមូលសំរាមនៃរដ្ឋបាលរាជធានីភ្នំពេញ។ វិធានការនានាអាចរួមបញ្ចូលប្រព័ន្ធចុះបញ្ជី និងការអនុញ្ញាត ដើម្បីអាចតាមដាន ឬដាក់កំហិតទៅលើលទ្ធភាពចេញ-ចូលរើសសំណល់អេតចាយ ក្នុងនាមជាបុគ្គលិកនៃមណ្ឌលកែច្នៃសំណល់ ដែលអាចបង្កើតឡើងនៅទីលានចាក់សំរាម ដោយផ្តល់គ្រឿងបរិក្ខារសុវត្ថិភាពផ្ទាល់ខ្លួន និងវិធានការអនុវត្តន៍ផ្សេងៗផងដែរ។

## ៤. សកម្មភាពចម្បងទី៤៖ ការគ្រប់គ្រងវិបារសំណល់ពិសេស

### សំណល់ពិសេសទី១៖ សំណល់សំណង់

### សកម្មភាពទី៤.១. ការបង្កើតប្រព័ន្ធគ្រប់គ្រងទិន្នន័យ

#### គោលបំណង

ដើម្បីលើកកម្ពស់ការប្រមូលទិន្នន័យតាមរយៈសង្វាក់គុណតម្លៃសំណល់ពីការបង្កើត ការប្រមូល ការធ្វើប្រព្រឹត្តកម្ម និងការទុកដាក់ចុងក្រោយ ដើម្បីគ្រប់គ្រងសំណល់សំណង់ឱ្យបានកាន់តែល្អប្រសើរ។

#### ស្ថានភាពបច្ចុប្បន្ន

វិស័យសំណង់នៅក្នុងរាជធានីភ្នំពេញមានការរីកដុះដាលយ៉ាងខ្លាំង ប៉ុន្តែនៅពុំទាន់មានស្ថិតិផ្លូវការបង្ហាញ អំពីបរិមាណសំណល់សំណង់ដែលបានបង្កើតនៅក្នុងរាជធានីភ្នំពេញ ក៏ដូចគ្នាប្រព័ន្ធទិន្នន័យបញ្ជាក់ថាកន្លែងណាសំណល់ទាំងនេះត្រូវបានគេបោះចោលដែរ។ ខណៈដែលទីក្រុងបន្តរីកចម្រើន និងមានបទពិសោធន៍លើវិស័យអចលនទ្រព្យធំៗកាន់តែច្រើន វាជាការចាំបាច់ត្រូវមានប្រព័ន្ធផ្លូវការមួយ ដែលមានចែកតួនាទី បទបញ្ញត្តិច្បាស់លាស់ និងប្រព័ន្ធប្រមូលទិន្នន័យសម្រាប់សំណល់សំណង់។

#### សកម្មភាព

a. ការដាក់ឱ្យប្រើប្រាស់នូវការប្រមូលទិន្នន័យសំណល់តាមប្រភេទនៅការដ្ឋានសំណង់ ទីតាំងទុកដាក់សំណល់ចុងក្រោយ និង/ ឬហេដ្ឋារចនាសម្ព័ន្ធកែច្នៃសំណល់។

គ្រប់គម្រោងសាងសង់ទាំងអស់ អង្គភាពគ្រប់គ្រងទីលានចាក់សំរាម ព្រមទាំងក្រុមហ៊ុនកែច្នៃសំណល់ទាំងអស់គួរមានកំណត់ត្រាសំណល់សំណង់តាមប្រភេទ និងទម្ងន់ ព្រមទាំងដំណើរការជាកាតព្វកិច្ចផងដែរ។ ក្រុមហ៊ុនទាំងអស់នោះ មិនគួរទទួលបានលិខិតអនុញ្ញាតសម្រាប់ប្រតិបត្តិការរបស់ខ្លួនឡើយ ប្រសិនបើមិនទាន់បានចុះហត្ថលេខាលើឯកសារផ្លូវច្បាប់សន្យាថានឹងរក្សាកំណត់ត្រាអំពីទិន្នន័យសំណល់សំណង់ ដែលអាចជួយយើងក្នុងការតាមដានបរិមាណ និងលំហូរសំណល់សំណង់។

អាជ្ញាធរមូលដ្ឋាន (ខណ្ឌ និងសង្កាត់) នឹងពិនិត្យមើលកំណត់ត្រាទិន្នន័យរាល់ ៦ខែ ម្តង និងប្រមូលរាល់ទិន្នន័យពីភាគីពាក់ព័ន្ធទាំងនេះ ហើយក៏នឹងផ្តល់ទៅឱ្យខណ្ឌ និងសាលារាជធានីភ្នំពេញ។ ជាមួយគ្នានេះដែរ អ្នកដែលមិនបានរក្សាកំណត់ត្រានឹងត្រូវបង់ប្រាក់ពិន័យ និងលុបចោលលិខិតអនុញ្ញាតដំណើរការការងារ/អាជីវកម្មរបស់ខ្លួន។

b. លើកកម្ពស់លទ្ធភាពទទួលបាន និងការប្រើប្រាស់ដោយបើកចំហានូវព័ត៌មានសាធារណៈពាក់ព័ន្ធនឹងប្រភេទអចលនទ្រព្យផ្សេងៗ (លំនៅដ្ឋានគ្រួសារទោល លំនៅដ្ឋានគ្រួសារចម្រុះ អគារពាណិជ្ជកម្ម និងអគារមិនមែនលំនៅដ្ឋាន។ល។) និងចំនួនម៉ែត្រការ៉េ ដើម្បីអាចធ្វើការប៉ាន់ស្មានបរិមាណសំណល់សំណង់ និងដាក់បញ្ចូលទិន្នន័យទាំងនោះទៅក្នុងការរៀបចំផែនការ និងការគ្រប់គ្រង។

សាលារាជធានីភ្នំពេញ នឹងប្រមូលព័ត៌មានអចលនទ្រព្យមុនពេលសាងសង់ពីក្រុមហ៊ុនសំណង់ ព្រមទាំងផ្តល់លទ្ធភាពទទួលបានដោយសេរីនូវព័ត៌មានទាំងនោះតាមបណ្តាញអ៊ីនធឺណិត។ ការអនុវត្តន៍បែបនេះ អាចផ្តល់ការប៉ាន់ស្មានអំពីបរិមាណសំណល់សំណង់នៅអំឡុងពេលសាងសង់ ហើយក៏អាចធ្វើការប្រៀបធៀបបរិមាណដែលបង្កើតឡើងជាក់ស្តែងក្រោយពេលសាងសង់ ដើម្បីបង្កើនប្រសិទ្ធភាពក្នុងការរៀបចំផែនការ និងការគ្រប់គ្រងសំណល់សំណង់នេះ។ ជាងនេះទៅទៀតវិទ្យាស្ថានបរិស្ថាន និងភាគីពាក់ព័ន្ធផ្សេងទៀត ដែលធ្វើការស្រាវជ្រាវអំពីសំណល់សំណង់ អាចទទួលបានទិន្នន័យកាន់តែងាយស្រួល និងស្រាវជ្រាវបន្ថែមពាក់ព័ន្ធនឹងការគ្រប់គ្រងសំណល់សំណង់ ។

## សកម្មភាពទី៤.២. លើកកម្ពស់ការកាត់បន្ថយសំណល់សំណង់

### គោលបំណង

ដើម្បីកាត់បន្ថយសំណល់សំណង់ ដែលចូលចាក់នៅក្នុងទីលានចាក់សំរាម ព្រមទាំងកាត់បន្ថយការបោះចោលសំណល់សំណង់ដោយគ្មានសណ្តាប់ធ្នាប់។

### ស្ថានភាពបច្ចុប្បន្ន

កិច្ចខិតខំប្រឹងប្រែងនៅមានកម្រិតនៅឡើយ ក្នុងការកាត់បន្ថយការបង្កើតសំណល់សំណង់នៅក្នុងដំណាក់កាលរៀបចំគម្រោង លទ្ធកម្ម និងសាងសង់។ ជាងនេះទៅទៀត ពុំមានកម្មវិធីយុទ្ធនាការលើកកម្ពស់ការយល់ដឹង ដើម្បីអប់រំដល់គ្រប់ភាគីពាក់ព័ន្ធពីសារៈសំខាន់ និងអត្ថប្រយោជន៍នៃការកាត់បន្ថយការបង្កើតសំណល់នៅឡើយទេ។

### សកម្មភាព

a. លើកកម្ពស់ការយល់ដឹងរបស់ភាគីពាក់ព័ន្ធទាំងអស់នៅក្នុងការបង្កើតសំណល់សំណង់ និងចូលរួមក្នុងការគ្រប់គ្រងសំណល់។

- រៀបចំកិច្ចពិភាក្សាពិគ្រោះយោបល់ជាមួយភាគីពាក់ព័ន្ធ (វិស័យឧស្សាហកម្ម) ដើម្បីលើកកម្ពស់ការយល់ដឹងអំពីសារៈសំខាន់ និងអត្ថប្រយោជន៍នៃតួនាទី និងភារកិច្ចទទួលខុសត្រូវក្នុងការគ្រប់គ្រងសំណល់សំណង់ ព្រមទាំងតួនាទី និងភារកិច្ចទទួលខុសត្រូវរបស់អ្នកពាក់ព័ន្ធក្នុងការគ្រប់គ្រងសំណល់ទាំងនោះ

- បង្កើតបណ្តាញសហការកាន់តែស៊ីជម្រៅនៅក្នុងចំណោមវិស័យឧស្សាហកម្ម ដោយផ្តោតទៅលើការប្រើប្រាស់ឡើងវិញ ការកាត់បន្ថយ និងការកែច្នៃ ព្រមទាំងចែករំលែកចំណេះដឹងឱ្យគ្នាទៅវិញទៅមកផងដែរ
- ជាប្រការសំខាន់ដែលបុគ្គលិករបស់ក្រុមហ៊ុនសាងសង់ អ្នកម៉ៅការបន្ត និងភាគីពាក់ព័ន្ធផ្សេងៗទៀតទទួលបានការបណ្តុះបណ្តាលពីនីតិវិធីកែច្នៃនៅទីតាំងផ្ទាល់ ដើម្បីឱ្យមានការញែកសំណល់សមស្របនៅទីតាំងប្រភព និងមានការគ្រប់គ្រងបានត្រឹមត្រូវផងដែរ។ រដ្ឋបាលរាជធានីភ្នំពេញក៏គួររៀបចំសិក្ខាសាលាអំពីការកាត់បន្ថយសំណល់ ដែលគ្រប់ភាគីពាក់ព័ន្ធទាំងអស់អាចរៀនសូត្រ និងបណ្តុះបណ្តាលខ្លួនឯង ដើម្បីដោះស្រាយនូវបញ្ហាប្រឈមក្នុងពេលបច្ចុប្បន្ន

b. ការលើកទឹកចិត្តការសាងសង់ប្រកបដោយចីរភាព

រដ្ឋបាលរាជធានីភ្នំពេញ នឹងជំរុញឱ្យមានដៃគូប្រកួតប្រជែងផ្នែកសេវាគ្រប់គ្រងសំណល់សំណង់ប្រកបដោយភាពច្នៃប្រឌិត និងការប្រើប្រាស់បច្ចេកវិទ្យាបៃតងសម្រាប់ការសាងសង់ ឧទា. ការប្រើឥដ្ឋបរិស្ថាន។ ការកែសម្រួលវិធីសាស្ត្រសាងសង់បែបប្រពៃណី គួរធ្វើឡើងដោយផ្តោតទៅលើផលប៉ះពាល់បរិស្ថាននៃសំណល់ចុងក្រោយជាជាងប្រាក់ចំណេញតែមួយមុខ។ សំណង់គួររៀបចំប្លង់រចនា និងសាងសង់ប្រកបដោយភាពច្នៃប្រឌិត និងមានលក្ខណៈបរិស្ថានសមស្របទៅតាមគោលការណ៍សេដ្ឋកិច្ចចក្រា។ ជាងនេះទៅទៀត ទីចាត់ការនៃរដ្ឋបាលរាជធានីភ្នំពេញដែលទទួលខុសត្រូវក្នុងការគ្រប់គ្រងកិច្ចការពារបរិស្ថាននៅក្នុងគម្រោងសំណង់នឹងត្រូវរៀបចំឡើង ដើម្បីផ្តល់អនុសាសន៍ក្នុងការរក្សាស្តង់ដាការងារសាងសង់។

c. កំណត់ថ្លៃចាក់ចោលសំណល់នៅទីលានចាក់សំរាម

ថ្លៃចោលសំណល់សំណង់ គួរកំណត់ឡើងដោយផ្អែកលើការប៉ាន់ប្រមាណតម្លៃលម្អិត នៃការថែទាំប្រកបដោយនិរន្តរភាពទីលានចាក់សំរាម ព្រមទាំងវដ្តនៃការប្រើប្រាស់ទីលានទាំងមូល។ គេអាចកំណត់អត្រាតម្លៃខុសគ្នា សម្រាប់ប្រភេទសំណល់សំណង់ដោយផ្អែកលើទម្ងន់ ដើម្បីលើកទឹកចិត្តអ្នកផលិតសំណល់សំណង់ និងផ្តោតការយកចិត្តទុកដាក់បន្ថែមទៅលើការកាត់បន្ថយសំណល់សំណង់។

d. ការរៀបចំបទបញ្ញត្តិអំពីសំណល់សំណង់ ដោយមានការដាក់ពិន័យឱ្យបានខ្លាំង ដើម្បីទប់ស្កាត់នូវការបោះចោលសំណល់គ្មានសណ្តាប់ធ្នាប់។

## សកម្មភាពទី៤.៣. លើកកម្ពស់ការប្រើប្រាស់ឡើងវិញ និងការកែច្នៃ

### គោលបំណង

ដើម្បីកាត់បន្ថយការបោះចោលសំរាមនៅទីលានចាក់សំណល់ និងដាក់កំហិតលើតម្រូវការផលិតពីវត្ថុធាតុដើម ដែលនឹងផ្តល់អត្ថប្រយោជន៍សុទ្ធសាធចំពោះបរិស្ថាន។

### ស្ថានភាពបច្ចុប្បន្ន

ការលូតលាស់យ៉ាងឆាប់រហ័សនៃនគរូបនីយកម្មនៅរាជធានីភ្នំពេញ បណ្តាលឱ្យមានការសាងសង់អគារ ផ្លូវថ្នល់ និងស្ពានកាន់តែច្រើន។ល។ដែលជាដើមចមធ្វើឱ្យសំណល់សំណង់កើនឡើងកាន់តែច្រើន។ ច្បាប់ដែលមានស្រាប់ពុំទាន់គ្រប់គ្រាន់ដើម្បីជួយសម្រួលដល់ការប្រើប្រាស់ឡើងវិញ និងការកែច្នៃសំណល់សំណង់ ហើយពុំមានបទបញ្ញត្តិ និងគោលការណ៍ច្បាស់លាស់សម្រាប់ប្រើប្រាស់ឡើងវិញ និងការកែច្នៃសំណល់សំណង់ឡើយ។

## សកម្មភាព

a. បង្កើនការប្រើប្រាស់ឡើងវិញនូវសំណល់សំណង់នៅក្នុងការសាងសង់ និងកាត់បន្ថយសំណល់សំណង់តាមរយៈការរៀបចំផែនការ/ ការរចនា និងតាមដានវឌ្ឍនភាពនៅគ្រប់ដំណាក់កាលនៃការសាងសង់។ សមាសធាតុសំណល់ដែលបង្កើតឡើងគួរប្រើប្រាស់ឡើងវិញនៅក្នុងទីតាំងផ្ទាល់ ឬរក្សាទុកឱ្យបានល្អដើម្បីប្រើប្រាស់ឡើងវិញឱ្យអស់លទ្ធភាព និងការចាក់ចោលនៅទីលានគួរតែចាត់ទុកជាជម្រើសចុងក្រោយ។ ការរៀបចំស្តុកទុកសមាសធាតុសំណល់សំណង់ អាចជួយសម្រួលដល់ការប្រើប្រាស់ឡើងវិញនៅក្នុងគម្រោងនាពេលអនាគត ព្រមទាំងផ្តល់ឱកាសក្នុងការលក់សំណល់សំណង់ដែលបានរក្សាទុកនោះឱ្យទៅអ្នកដទៃផ្សេងទៀតដែលត្រូវការ។

b. ធ្វើការស្រាវជ្រាវកំណត់គំនិតផ្តួចផ្តើមដែលមានលក្ខណៈច្នៃប្រឌិត ដើម្បីបញ្ចៀសការបោះចោលសំរាម និងបច្ចេកវិទ្យាកែច្នៃសមស្របសម្រាប់សំណល់សំណង់ ។

តម្រូវការទីផ្សារមួយចំនួនអាចប្រើប្រាស់សំណល់សំណង់ជាប្រយោជន៍ម្តងទៀតមានដូចជា៖ សំណល់ឈើអាចកែច្នៃធ្វើជាក្តារពុម្ព ឬរបាំងការពារសំណង់ ឬបញ្ជូនទៅធ្វើការកែច្នៃជាបន្ទះឈើកិន។ សំណល់បេតុងអាចប្រើប្រាស់ជាសម្ភារចាក់បំពេញផ្លូវ ក្រៅពីនេះថ្មក្រួសអាចញែក និងប្រើប្រាស់ឡើងវិញនៅក្នុងការងារសំណង់។ ចំណែកប៊ីទីម (bitumen) និងកៅស៊ូអាចយកទៅប្រើប្រាស់ឡើងវិញនៅក្នុងគម្រោងផ្លូវថ្នល់ផងដែរ។

## សកម្មភាពទី៤.៤. ការអនុវត្តន៍ តាមដានត្រួតពិនិត្យ និងពង្រឹងច្បាប់លើការបោះចោល

## គោលបំណង

ដើម្បីតាមដាន និងគ្រប់គ្រងការចោលសំណល់គ្មានសណ្តាប់ធ្នាប់ បង្កការបំពុលបរិស្ថាន និងគ្រប់គ្រងការបោះចោលសំណល់សំណង់ឱ្យបានត្រឹមត្រូវនៅទីលានចាក់សំរាម។

## ស្ថានភាពបច្ចុប្បន្ន

សំណល់សំណង់ពុំមានយន្តការតាមដាន រាយការណ៍ ប្រមូល និងចាក់ចុងក្រោយបានត្រឹមត្រូវនៅឡើយទេ។ អនុក្រឹត្យលេខ១១៣ (ការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន) ចែងអំពីទំនួលខុសត្រូវរបស់អ្នកបង្កើតសំណល់ និងអ្នកសាងសង់ក្នុងការស្តុកទុក ប្រមូល ដឹកជញ្ជូន និងទុកដាក់សំណល់ចុងក្រោយ ហើយអនុញ្ញាតឱ្យអ្នកបង្កើតបោះចោលសំណល់សំណង់ដែលបានបង្កើតឡើងនៅទីលានចាក់សំរាមទាំងដោយខ្លួនឯង ឬដោយប្រើប្រាស់សេវាឯកជន។ ទោះបីយ៉ាងណា នៅក្នុងការអនុវត្តន៍ជាក់ស្តែង សំណល់សំណង់មិនត្រូវបានទទួលយកដោយទីលានចាក់សំរាមឡើយ ដោយសារសាលារាជធានីភ្នំពេញព្យាយាមរក្សា/ពន្យាអាយុកាលរបស់ទីលាន លុះត្រាតែសំណល់ទាំងនោះត្រូវបានប្រមូលមកដោយអ្នកផ្តល់សេវា។ ជាលទ្ធផលសំណល់ជាច្រើនត្រូវបានបោះចោលតាមដងទន្លេ ទីសាធារណៈ និងតំបន់ជាយរាជធានី។ លើសពីនេះទៀតសំណល់សំណង់ពីលំនៅដ្ឋាន ជាញឹកញាប់មិនត្រូវបានប្រមូលដោយកម្មករក្រុមហ៊ុនស៊ីនទ្រី ដែលត្រូវគេទុកចោលតាមផ្លូវ ដោយសារកិច្ចសន្យារវាងក្រុមហ៊ុន និងរដ្ឋបាលរាជធានីភ្នំពេញនៅមានភាពមិនស៊ីចង្វាក់គ្នាលើនិយមន័យ "សំរាម" សំណល់រឹងទីប្រជុំជន។ វាក៏ជាហេតុជំរុញនាំឱ្យមានការចោលសំណល់សំណង់គ្មានសណ្តាប់ធ្នាប់ផងដែរ។

## សកម្មភាព

a. ការបង្កើត និងផ្សព្វផ្សាយគោលការណ៍ណែនាំ ស្តីពីការតាមដានត្រួតពិនិត្យ និងការទុកដាក់សំណល់នៅទីលានចាក់សំរាមឱ្យបានត្រឹមត្រូវដោយពុំមានការបំពុលដល់បរិស្ថាន។ គោលការណ៍ណែនាំដែលបានបង្កើតឡើង គួរលើកកម្ពស់វិធីសាស្ត្រ

គ្រប់ជ្រុងជ្រោយ និងបែបចម្រុះ ដោយចិត្តទុកឱ្យគ្រប់គ្រាន់លើការគ្រប់គ្រងសំណល់សំណង់ នៅក្នុងរយៈពេលគម្រោងទាំងមូល រួមទាំងការតាមដាន និងការបោះចោលគ្មានសណ្តាប់ធ្នាប់ផងដែរ។ គោលការណ៍ណែនាំនេះគួររួមបញ្ចូលផងដែរនូវផែនការគ្រប់គ្រងសំណល់មួយចំនួនដែលលើសពីកម្រិតធម្មតាផងដែរ។ ការគ្រប់គ្រងសំណល់គ្រោះថ្នាក់នៃសំណល់សំណង់ដូចជា សារធាតុអាបេស្តុសនឹងត្រូវបានគ្រប់គ្រងដោយបទបញ្ញត្តិថ្នាក់ជាតិពាក់ព័ន្ធផ្សេងទៀត ហើយត្រូវស្ថិតនៅក្រោមការណែនាំ និងការអនុម័តពីក្រសួងបរិស្ថាន។

b. វិធានការបង្ការប្រឆាំងនឹងការចោលសំរាមដោយគ្មានសណ្តាប់ធ្នាប់

- អាយុកាលទីលានចាក់សំរាមអាចនឹងត្រូវបានពន្យាតាមរយៈការពង្រីកទីលាន ក្នុងករណីមិនមានលំហរគ្រប់គ្រាន់សម្រាប់ចាក់ចោលសំណល់សំណង់។ ទោះជាយ៉ាងណាក៏ដោយ សំណល់សំណង់ ដែលនៅសេសសល់បន្ទាប់ពីបានប្រើ និងការកែច្នៃឡើងវិញ គេគួរតែបង់ថ្លៃទៅឱ្យទីលាននៅពេលគេយកវាទៅចោល។ កម្ទេចថ្ម និងខ្សាច់អាចត្រូវបានប្រើជាជំរើសសម្ភារសម្រាប់គ្របតាមស្រទាប់នៅទីលានជាប្រចាំ
- ការតាមដានត្រួតពិនិត្យគួរតែត្រូវបានពង្រឹង ដើម្បីរួមបញ្ចូលការអនុវត្តន៍ច្បាប់ទៅលើការចោលសំណល់ដោយគ្មានសណ្តាប់ធ្នាប់។ ការដាក់ពិន័យលើជនល្មើសគួរតែធ្វើបន្ត ដើម្បីបង្ការការបោះចោលសំរាមដោយគ្មានសណ្តាប់ធ្នាប់
- ការគិតគូរទៅលើក្រុមហ៊ុនសក្តានុពលលើការគ្រប់គ្រងសំណល់ថ្មី ក៏គួរធ្វើទៅតាមលទ្ធភាព និងទីកន្លែងដែលអាចធ្វើទៅបាន។

---

## សំណល់ពិសេសទី២៖ សំណល់វេជ្ជសាស្ត្រ

### សកម្មភាពទី ៤.៥. ពង្រឹងប្រព័ន្ធគ្រប់គ្រងសំណល់វេជ្ជសាស្ត្រ

### គោលបំណង

ដើម្បីលុបបំបាត់ការបោះចោលសំណល់វេជ្ជសាស្ត្រមិនត្រឹមត្រូវក្នុងចំណោមស្ថាប័ន/ អង្គភាពអ្នកផ្តល់សេវាសុខាភិបាល និងលើកកម្ពស់ប្រសិទ្ធភាពយន្តការគ្រប់គ្រងបច្ចុប្បន្ន។

### ស្ថានភាពបច្ចុប្បន្ន

បច្ចុប្បន្ន សំណល់វេជ្ជសាស្ត្រពីមណ្ឌលវេជ្ជសាស្ត្រសាធារណៈ និងឯកជននៅទីក្រុងភ្នំពេញត្រូវបានគ្រប់គ្រងជាចម្បងដោយសាខាកាកបាទក្រហមកម្ពុជារាជធានី (CRC)។ ទោះបីនៅក្នុងរបាយការណ៍បង្ហាញថា សេវាគ្រប់គ្រងសំណល់វេជ្ជសាស្ត្រត្រូវបានគ្រប់ដណ្តប់ពេញលេញក៏ដោយ ក៏នៅតែមានចំណុចខ្វះខាតនៅក្នុងដំណើរការគ្រប់គ្រងសំណល់វេជ្ជសាស្ត្រនៅឡើយ។ ដោយចាប់ផ្តើមពីគ្លីនិក និងមណ្ឌលវេជ្ជសាស្ត្រតូចៗជាច្រើននៅប្រទេសកម្ពុជាពុំបានដឹងអំពីវិធីបែងចែក និងចាត់ថ្នាក់សំណល់វេជ្ជសាស្ត្រឱ្យបានត្រឹមត្រូវឡើយ។ បញ្ហានេះកើតឡើងភាគច្រើនចំពោះគ្លីនិកមួយចំនួននៅភ្នំពេញ ដែលកំពុងប្រតិបត្តិការសេវាវេជ្ជសាស្ត្រដែលមិនគោរព និងអនុវត្តក្រមសីលធម៌វិជ្ជាជីវៈត្រឹមត្រូវ។ ក្នុងករណីនេះ ជារឿយៗសំណល់វេជ្ជសាស្ត្រត្រូវបានដាក់ចូលគ្នាជាមួយសំណល់ផ្សេងទៀត ដែលក្រុមហ៊ុនស៊ីនទ្រីបានប្រមូលយកទៅបោះចោលនៅទីលានចាក់សំរាម។ ការបោះចោលសំណល់វេជ្ជសាស្ត្រនៅទីលានចាក់សំរាមអាចបណ្តាលឱ្យមានផលវិបាកចំពោះសុខភាពផ្សេងៗ ដូចជាការឆ្លងមេរោគអេដស៍ មេរោគថ្លើមប្រភេទបេ និងប្រភេទសេ ទៅអ្នករើសអេតចាយនៅទីលានចាក់សំរាម និងប្រជាជនរស់នៅក្បែរនោះ។

## សកម្មភាព

ខណៈដែលក្រសួង និងមន្ទីរសុខាភិបាល ដែលទទួលបានការគាំទ្រពីក្រសួងពាក់ព័ន្ធ ដែលមានដែនសមត្ថកិច្ចបឋមលើការគ្រប់គ្រងសំណល់វេជ្ជសាស្ត្រនៅក្នុងរាជធានីភ្នំពេញ រដ្ឋបាលរាជធានីភ្នំពេញ ជាមួយនឹងដែនសមត្ថកិច្ចរបស់ខ្លួននឹងជួយដល់ស្ថាប័នថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ដែលទទួលខុសត្រូវនូវវិធានការដូចខាងក្រោម៖

a. ជ្រោមជ្រែងក្រសួង និងមន្ទីរសុខាភិបាលលើកកម្ពស់ការយល់ដឹង និងកម្មវិធីបណ្ដុះបណ្ដាលស្ដីពីការគ្រប់គ្រងសំណល់វេជ្ជសាស្ត្រដល់ទីតាំងសេវាថែទាំសុខភាពទាំងអស់។ កម្មវិធីនេះត្រូវបានបង្កើតឡើង ដើម្បីផ្ដល់ឱ្យអ្នកជំនាញផ្នែកវេជ្ជសាស្ត្រនូវការយល់ដឹងច្បាស់លាស់ និងសមត្ថភាពក្នុងការគ្រប់គ្រងសំណល់វេជ្ជសាស្ត្រ បច្ចេកទេសនៃការទុកដាក់សំណល់ឱ្យបានត្រឹមត្រូវ និងហានិភ័យដែលទាក់ទងនឹងការទុកដាក់សំណល់វេជ្ជសាស្ត្រមិនបានត្រឹមត្រូវ
b. ជ្រោមជ្រែងក្រសួង និងមន្ទីរសុខាភិបាលរៀបចំយុទ្ធនាការលើកកម្ពស់ការយល់ដឹងជាសាធារណៈ ដើម្បីបង្កើនការយល់ដឹងដល់ប្រជាពលរដ្ឋអំពីហានិភ័យប៉ះពាល់នៃសំណល់វេជ្ជសាស្ត្រ
c. ពិគ្រោះជាមួយ និងជ្រោមជ្រែងដល់ក្រសួង និងមន្ទីរសុខាភិបាលក្នុងការធ្វើអធិការកិច្ចតាមកាលកំណត់នៅតាមគ្រប់គ្រឹះស្ថានសុខាភិបាលទាំងអស់ ដើម្បីធានាឱ្យមានការអនុវត្តន៍ ការទុកដាក់ និងបញ្ជូនសំណល់វេជ្ជសាស្ត្រត្រឹមត្រូវទៅតាមគោលការណ៍ណែនាំរបស់ថ្នាក់ជាតិ
d. ពិគ្រោះយោបល់ជាមួយក្រសួង និងមន្ទីរសុខាភិបាលអំពីលទ្ធភាពនៃការបង្កើតយន្តការរាយការណ៍ (ដូចជា តាមប្រព័ន្ធទូរស័ព្ទ) សម្រាប់សាធារណជនទូទៅ អាចរាយការណ៍ពីការអនុវត្តន៍ ការទុកដាក់ និងបញ្ជូនសំណល់វេជ្ជសាស្ត្រមិនបានត្រឹមត្រូវនៅតាមសេវាថែទាំសុខភាពណាមួយ។
e. ពិគ្រោះ និងជ្រោមជ្រែងដល់ក្រសួង និងមន្ទីរសុខាភិបាលក្នុងការធ្វើអធិការកិច្ចជាប្រចាំលើអង្គភាពគ្រប់គ្រងសំណល់វេជ្ជសាស្ត្រនៃសាខាកាកបាទក្រហមកម្ពុជារាជធានី ដើម្បីធានាការប្រមូល ប្រព្រឹត្តកម្មបឋម (ការដុតកម្ទេចក្នុងឡ និងប្រព្រឹត្តកម្មផ្សេងទៀត) និងការចោលសំណល់វេជ្ជសាស្ត្រចុងក្រោយ ត្រូវបានអនុវត្តស្របតាមគោលការណ៍ណែនាំរបស់ថ្នាក់ជាតិ និងហានិភ័យសុខភាពសាធារណៈ និងបរិស្ថានជាលក្ខណៈអវិជ្ជមាន ត្រូវបានបន្សាបជាតិពុលជាអប្បបរមា។ ការគ្រប់គ្រងផ្សេង និងផេះពីឡដុតសំណល់ ព្រមទាំងការប្រើឧបករណ៍ការពារសុវត្ថិភាពបុគ្គលិកប្រតិបត្តិការនឹងត្រូវបានត្រួតពិនិត្យត្រឹមត្រូវ
f. ជួយជ្រោមជ្រែងដល់អង្គភាពគ្រប់គ្រងសំណល់វេជ្ជសាស្ត្រក្នុងការរៀបចំផែនការ និងអនុវត្តឱ្យមានប្រសិទ្ធភាពតាមរយៈការគ្រប់គ្រងភស្តុភារកាន់តែល្អប្រសើរ និងការរៀបចំផែនការប្រកបដោយប្រសិទ្ធភាព។
    - ការចែកចាយធុងសំរាមទ្រង់ទ្រាយធំ ដែលរចនាឡើងជាពិសេសសម្រាប់សំណល់វេជ្ជសាស្ត្រ
    - ការពង្រីកសមត្ថភាពឡដុតសំណល់វេជ្ជសាស្ត្របច្ចុប្បន្ន និងបរិក្ខារពាក់ព័ន្ធផ្សេងៗទៀត ដើម្បីឆ្លើយតបទៅនឹងកំណើនឡើងនៃសំណល់វេជ្ជសាស្ត្រ។ ប្រសិនបើអាច ត្រូវកាត់បន្ថយចម្ងាយដឹកជញ្ជូនទៅកាន់ឡដុត។ ត្រូវធានាថា ការប្រើប្រាស់ឡដុតនឹងមិនប៉ះពាល់ដល់បរិស្ថាន ហើយត្រូវតាមដានដំណើរការឡឱ្យបានជាប្រចាំ។ ត្រូវបង្កើនចំនួនរថយន្តប្រមូលសំរាម ដើម្បីបង្កើនប្រសិទ្ធភាពនៃការប្រមូល
    - ត្រូវកំណត់ពេលប្រមូលសំរាមឱ្យបានច្បាស់លាស់៖ ការប៉ះពាល់ជាមួយសំណល់វេជ្ជសាស្ត្រអាចមានផលវិបាកធ្ងន់ធ្ងរភ្លាមៗលើសពីសំណល់ធម្មតា។ ដូច្នេះ សំណល់វេជ្ជសាស្ត្រដែលបានបង្កើតគួរប្រមូលឱ្យបានឆាប់តាមដែលអាចធ្វើបានដើម្បីបញ្ចៀសហានិភ័យនៃការប៉ះពាល់ ជាពិសេសចំពោះអ្នករើសអេតចាយ។ អង្គភាពសំណល់វេជ្ជសាស្ត្រ គួររៀបចំកាលវិភាគប្រមូលប្រកបដោយប្រសិទ្ធភាព ជាមួយនឹងការរៀបចំទុកដាក់ និងបញ្ជូនសំរាមបោះចោលនៅក្នុង

តំបន់នីមួយៗនៅក្នុងរាជធានីភ្នំពេញ។ កាលវិភាគគួរផ្សព្វផ្សាយទៅដល់គ្រប់ភាគីពាក់ព័ន្ធទាំងអស់ ជាពិសេស ទីតាំងថែទាំសុខភាព

- ធានាឱ្យបាននូវទីលានសំណល់វេជ្ជសាស្ត្រប្រកបដោយសុវត្ថិភាព ជាពិសេសសម្រាប់សំណល់វេជ្ជសាស្ត្រ។

## សំណល់ពិសេសទី៣៖ សំណល់ឧស្សាហកម្ម

### សកម្មភាពទី៤.៦. ពង្រឹងយន្តការកែលម្អប្រព័ន្ធគ្រប់គ្រងសំណល់ឧស្សាហកម្ម

#### គោលបំណង

ពង្រឹងការតាមដាន និងការត្រួតពិនិត្យ ដើម្បីធានាថាអ្នកបង្កើតសំណល់ធ្វើការគ្រប់គ្រងសំណល់ឧស្សាហកម្មបានត្រឹមត្រូវ និងមានចីរភាពបរិស្ថានស្របទៅតាមគោលការណ៍ **អ្នកបំពុលត្រូវបង់ប្រាក់** (Polluter-pay-principle)។

#### ស្ថានភាពបច្ចុប្បន្ន

បច្ចុប្បន្ន ការគ្រប់គ្រងសំណល់ឧស្សាហកម្មត្រូវបានផ្តល់អាជ្ញាប័ណ្ណទៅឱ្យក្រុមហ៊ុនឯកជន សារ៉ុ ត្រេឌីង ដែលផ្តល់សេវាប្រមូល ដឹកជញ្ជូន និងទុកដាក់សំណល់ចុងក្រោយ ដោយផ្អែកលើកិច្ចសន្យាសេវារវាងក្រុមហ៊ុន និងអ្នកបង្កើតសំរាម។ ទោះជាការធ្វើប្រព្រឹត្តកម្ម និងការចាក់ចោលសំណល់ឧស្សាហកម្មត្រូវបានកំណត់នៅក្នុងក្របខណ្ឌច្បាប់ថ្នាក់ជាតិ ថាជាទំនួលខុសត្រូវរបស់អ្នកបង្កើតសំរាមក៏ដោយ ប៉ុន្តែជាក់ស្តែង ប្រព្រឹត្តកម្ម និងការបោះចោលសំណល់គ្មានសណ្តាប់ធ្នាប់/ មិនត្រឹមត្រូវនៅតែកើតមានឡើងជារឿយៗ ចំណែកការមិនទូទាត់សម្រាប់ថ្លៃសេវាទៅឱ្យក្រុមហ៊ុនគ្រប់គ្រងសំណល់ក៏នៅតែកើតឡើងជាញឹកញាប់។ (សូមមើលជំពូកទី៦)

#### សកម្មភាព

a. ការបង្កើតបទបញ្ញត្តិថ្នាក់ក្រោមជាតិ ដែលបញ្ជាក់អំពីទំនួលខុសត្រូវ និងបន្ទុកចំណាយរបស់ភាគីពាក់ព័ន្ធ ព្រមទាំងវិធានការដាក់ពិន័យទៅតាមទំនួលខុសត្រូវបន្ថែមរបស់អ្នកផលិត (EPR)

b. ការបង្កើតអង្គភាព/មុខតំណែងពិសេសសម្រាប់គ្រប់គ្រងសំណល់ឧស្សាហកម្មនៅក្នុងនាយកដ្ឋាន/មន្ទីរគ្រប់គ្រងសំណល់ទៅតាមភាពសមស្រប

c. ការបង្កើតស្តង់ដា និងគោលការណ៍ណែនាំបច្ចេកទេសសម្រាប់ការកែច្នៃ និងប្រព្រឹត្តកម្មប្រកបដោយចីរភាពបរិស្ថាន

d. បង្កើត និងធ្វើបច្ចុប្បន្នភាពមូលដ្ឋានទិន្នន័យអំពីអ្នកបង្កើតសំណល់ឧស្សាហកម្មនៅភ្នំពេញដែលរួមមាន ប្រវត្តិក្រុមហ៊ុន ប្រភេទសំណល់ បរិមាណសំណល់ដែលបានបង្កើត និងកម្រិតគ្រោះថ្នាក់ ព្រមទាំងព័ត៌មានអំពីរបៀបធ្វើប្រព្រឹត្តកម្មសំណល់ផងដែរ (ស្វ័យប្រព្រឹត្តកម្ម ឬប្រគល់ការងារទៅឱ្យក្រុមហ៊ុនពីខាងក្រៅ)

e. ការបង្កើតវេទិកាជាប្រចាំសម្រាប់កិច្ចពិភាក្សារវាងរដ្ឋបាលរាជធានីភ្នំពេញ និងភាគីពាក់ព័ន្ធ ដើម្បីផ្សព្វផ្សាយពីបទបញ្ញត្តិ ស្តង់ដា/ គោលការណ៍ណែនាំបច្ចេកទេស លើកកម្ពស់ការយល់ដឹងអំពីបញ្ហាសំណល់ឧស្សាហកម្ម និងធ្វើឱ្យមានការផ្លាស់ប្តូរឥរិយាបថ។ សហជីពឧស្សាហកម្ម ឬមកពីវិស័យផ្សេងៗ ដែលអាចដើរតួជាអន្តរការីសម្រាប់ក្រុមហ៊ុននីមួយៗនឹងត្រូវបានអញ្ជើញឱ្យដើរតួនាទីសំខាន់ៗនៅក្នុងដំណើរការនេះ

f. ពង្រឹងការអនុវត្តន៍បទបញ្ញត្តិស្តង់ដា និងគោលការណ៍ណែនាំ ដោយធ្វើការចុះត្រួតពិនិត្យជាប្រចាំលើក្រុមហ៊ុនដែលមិនបានអនុទ្បោមតាមគោលការណ៍ច្បាប់ និងមានវិធានការពិន័យសម្រាប់ការមិនគោរពគោលការណ៍ (រួមទាំងការបោះចោលសំរាមគ្មានសណ្តាប់ធ្នាប់ និងការអនុវត្តន៍មិនស្របតាមស្តង់ដា)

g. លើកកម្ពស់គោលការណ៍ **កាត់បន្ថយ - ប្រើប្រាស់ឡើងវិញ - កែច្នៃ (៣អ៊ែរ)** ចំពោះសំណល់ឧស្សាហកម្ម ដោយសហការជាមួយអ្នកពាក់ព័ន្ធក្នុងវិស័យឧស្សាហកម្មតាមរយៈការដាក់បញ្ចូលគោលការណ៍ "កាត់បន្ថយ" និង "ប្រើប្រាស់ឡើងវិញ" នៅក្នុងដំណើរការផលិតកម្មរបស់ខ្លួនទៅតាមស្តង់ដាសុវត្ថិភាព និងតាមរយៈការលើកកម្ពស់ការវិនិយោគកែច្នៃឯកជនដែលមានចាប់អារម្មណ៍។ រដ្ឋបាលរាជធានីភ្នំពេញនឹងដើរតួជាកាតាលីករនៅក្នុងការងារសម្របសម្រួល ដើម្បីផ្គូរផ្គង់រវាងអ្នកបង្កើតសំណល់ និងអ្នកកែច្នៃ។ ទិន្នន័យ ដែលបានចងក្រងអំពីអ្នកបង្កើតសំរាមនឹងត្រូវប្រើប្រាស់ពេញលេញនៅក្នុងដំណើរការនេះ។ ការអនុវត្តន៍ញែកសំណល់នៅនឹងប្រភព ដោយអ្នកបង្កើតសំណល់ក៏មានសារសំខាន់ផងដែរនៅក្នុងការលើកកម្ពស់ការកែច្នៃ

h. ការអភិវឌ្ឍសមត្ថភាព ដោយផ្តោតគោលដៅទៅលើក្រុមហ៊ុនគ្រប់គ្រងសំណល់ឧស្សាហកម្ម ឆ្ពោះទៅការធ្វើប្រព្រឹត្តកម្មសំណល់ប្រកបដោយចីរភាព និងការទុកដាក់ចុងក្រោយ

i. បន្តការកសាងសមត្ថភាពជាប្រចាំដល់មន្ត្រីរដ្ឋបាលរាជធានីភ្នំពេញ ដែលមានភារកិច្ចគ្រប់គ្រងសំណល់ឧស្សាហកម្ម ដើម្បីឆ្ពោះទៅការរៀបចំផែនការ គោលនយោបាយ ការអនុវត្តន៍ឱ្យកាន់តែប្រសើរ ការតាមដាន និងការរៀបចំគោលនយោបាយបន្ថែម។

## សំណល់ពិសេសទី៤៖ សំណល់បរិក្ខារអគ្គិសនី និងអេឡិចត្រូនិក

### សកម្មភាពទី៤.៧. ដោះស្រាយការចាក់ចោលសំណល់ដោយគ្មានសណ្តាប់ធ្នាប់ ការកំណត់បទបញ្ញត្តិលើការគ្រប់គ្រងសំណល់បរិក្ខារអគ្គិសនី និងអេឡិចត្រូនិក ដែលមានតម្លៃកែច្នៃជាវត្ថុធាតុដើមសម្រាប់ពាណិជ្ជកម្ម

### គោលបំណង

ដើម្បីបង្វែរសំណល់អេឡិចត្រូនិកពីការចូលទៅក្នុងរំហូរសំរាម សំណល់រឹងទីក្រុង តាមរយៈការបង្កើនគុណតម្លៃសំណល់អេឡិចត្រូនិកឱ្យទៅជាធនធានដែលអាចជួញដូរបាន។

ដើម្បីទប់ស្កាត់ការចោលសំរាមគ្មានសណ្តាប់ធ្នាប់ និងការអនុវត្តន៍ការគ្រប់គ្រងសំណល់អេឡិចត្រូនិកដែលមិនមាននិរន្តរភាព ដូចជា ការដុតនៅទីចំហរ និងការរំលាយសំណល់នៅតាមផ្ទះ ដែលជាមធ្យោបាយចំណាយតិច។

### ស្ថានភាពបច្ចុប្បន្ន

សព្វថ្ងៃ សំណល់អេឡិចត្រូនិកដែលបានបង្កើនឡើងនៅក្នុងរាជធានីភ្នំពេញ ត្រូវបានចាក់ចោលដូចគ្នានឹងសំណល់រឹងទីប្រជុំជន និងចុងក្រោយចាក់ចោលនៅទីលានចាក់សំរាម ឬតាមទម្រង់ស្រដៀងគ្នាបន្ទាប់ពីសម្ភារទាំងនេះត្រូវបានប្រើប្រាស់រាប់សិបឆ្នាំដោយការប្រើប្រាស់ឡើងវិញ ជួសជុល ឬដោះបំបែកយកវត្ថុធាតុដើម។ ខណៈដែលដំណើរការនៃការគ្រប់គ្រងសំណល់អេឡិចត្រូនិកភាគច្រើននៅក្នុងរាជធានីភ្នំពេញត្រូវបានកើតឡើងតាមរយៈការប្រមូល ការដោះបំបែក និងនាំចេញករណីខ្លះត្រូវបានគេរាយការណ៍ថា ធនធានមានតម្លៃត្រូវបានទាញយកតាមវិធីសាស្រ្តមិនសមស្រប ដែលបង្កផលប៉ះពាល់ដល់បរិស្ថាន និងសុខភាព។ អនុក្រឹត្យលេខ១៦ ស្តីពីការគ្រប់គ្រងសំណល់អេឡិចត្រូនិកត្រូវបានចូលជាធរមាននៅក្នុងឆ្នាំ២០១៦ ហើយការទទួលខុសត្រូវរបស់អ្នកធ្វើអាជីវកម្មសំណល់អេឡិចត្រូនិក (អ្នកប្រមូល ហាងជួសជុល អ្នកដោះបំបែកសំណល់អេឡិចត្រូនិក និងអ្នកកែច្នៃ) ត្រូវបានកំណត់យ៉ាងច្បាស់លាស់។ ទោះជាយ៉ាងណាក៏ដោយ វាត្រូវបានគេរំពឹងថានឹងមានការចំណាយពេលយូរមុននឹងមានការផ្លាស់ប្តូរ ដែលគួរឱ្យកត់សំគាល់នោះ អាចត្រូវបានគេមើលឃើញទៅនឹងការអនុវត្តន៍ជាក់ស្តែង។

### សកម្មភាព

a. រៀបចំមូលដ្ឋានទិន្នន័យ អំពីអ្នកកែច្នៃសំណល់អេឡិចត្រូនិកនៅក្នុងរាជធានីភ្នំពេញរួមមាន ប្រវត្តិក្រុមហ៊ុន ប្រភេទសំណល់អេឡិចត្រូនិក បរិមាណសំណល់អេឡិចត្រូនិកដែលបានទទួលលក់ និងសំណល់ដែលមានកម្រិតគ្រោះថ្នាក់ និងព័ត៌មានអំពីរបៀបដែលសំណល់ត្រូវគេធ្វើប្រព្រឹត្តកម្ម

b. បង្កើតសារពើភ័ណ្ឌសំណល់អេឡិចត្រូនិក ដោយសហការជាមួយមន្ទីរបរិស្ថាន និងក្រសួងបរិស្ថានតាមរយៈការស្រង់ស្ថិតិខាងលើ

c. ផ្សព្វផ្សាយគោលការណ៍ណែនាំរបស់ក្រសួងបរិស្ថាន អំពីការគ្រប់គ្រងបរិស្ថានប្រកបដោយចីរភាព ដោយផ្តោតគោលដៅទៅលើអ្នកប្រមូលសំណល់អេឡិចត្រូនិក ឈ្មួញកណ្តាល និងអ្នកដោះបំបែកសំណល់ដើម្បីកែច្នៃ

d. រៀបចំសកម្មភាពផ្សព្វផ្សាយស្តីពីផលប៉ះពាល់ទៅលើបរិស្ថាន និងសុខភាពក្នុងការធ្វើប្រព្រឹត្តកម្មសំណល់អេឡិចត្រូនិកឱ្យបានសមស្រប ជាពិសេសផ្តោតលើការរំលាយសំណល់តាមផ្ទះ

e. បង្កើតបទបញ្ញត្តិនៅថ្នាក់ក្រោមជាតិ ស្តីពីស្តង់ដាការបំភាយឧស្ម័ន ស្តង់ដាប្រតិបត្តិការកែច្នៃ ដោយមានការសហការជាមួយមន្ទីរបរិស្ថាន និងក្រសួងបរិស្ថាន

f. បង្កើតបញ្ជីឈ្មោះអ្នកកែច្នៃដែលបង្ហាញពីការគ្រប់គ្រងសំណល់អេឡិចត្រូនិក ដោយអនុលោមតាមស្តង់ដាឱ្យបានត្រឹមត្រូវ។ បោះពុម្ពផ្សាយ និងចែកចាយបញ្ជីឈ្មោះនេះទៅដល់អ្នកបង្កើតសំណល់អេឡិចត្រូនិកទាំងអស់ ដើម្បីសម្រួលដល់ការទុកដាក់សំណល់ចុងក្រោយ និងមានការប្រមូលឱ្យបានត្រឹមត្រូវ

g. រៀបចំជាយុទ្ធនាការណ៍ការប្រមូលសំណល់អេឡិចត្រូនិក ដោយផ្តោតសំខាន់លើអ្នកប្រើប្រាស់ទូទៅ (អ្នកបង្កើតសំណល់តាមផ្ទះ) ដោយមានការសហការជាមួយហាងនានា និងអ្នកជួញដូរ/អ្នកកែច្នៃសំណល់អេឡិចត្រូនិក ដើម្បីបង្កើនអត្រា និងបរិមាណប្រមូលឱ្យបានកាន់តែប្រសើរឡើង

h. ពង្រឹងការតាមដាន និងត្រួតពិនិត្យឱ្យទៀងទាត់ ដើម្បីគ្រប់គ្រងការចោលសំណល់គ្មានសណ្តាប់ធ្នាប់ និងអនុវត្តការគ្រប់គ្រងមិនបានត្រឹមត្រូវ/ក្រោមកំរិតស្តង់ដា។

## ៥. សកម្មភាពចម្បងទី ៥. ការចែករំលែកចក្ខុវិស័យ និងដៃគូជាមួយភាគីពាក់ព័ន្ធលើសកម្មភាពរួម

### សកម្មភាពទី៥.១. ជំរុញការចូលរួមរបស់ប្រជាពលរដ្ឋក្នុងការរៀបចំផែនការគ្រប់គ្រងសំណល់

### គោលបំណង

ដើម្បីសម្រេចបានការអនុវត្តន៍ប្រកបដោយប្រសិទ្ធភាព ដោយផ្អែកលើគោលការណ៍ធ្វើឱ្យប្រសើរឡើង ទំនាក់ទំនងល្អរវាងរដ្ឋបាលរាជធានីភ្នំពេញ និងប្រជាពលរដ្ឋ គឺត្រូវលើកកម្ពស់ការចូលរួមរបស់សាធារណជននៅក្នុងវដ្តគ្រប់គ្រងទាំងមូល (ការរៀបចំផែនការ ការអនុវត្តន៍ ការតាមដាន និងការកែសម្រួល) នូវយុទ្ធសាស្ត្រគ្រប់គ្រងសំណល់។

### ស្ថានភាពបច្ចុប្បន្ន

ការចូលរួមរបស់សាធារណៈមានតិចតួចនៅក្នុងវដ្តគ្រប់គ្រងសំណល់ បើទោះបីជារដ្ឋបាលរាជធានីភ្នំពេញ បានខិតខំប្រឹងប្រែងយ៉ាងខ្លាំងនៅក្នុងការផ្តល់ឱកាសសិក្សាអំពីប្រធានបទគ្រប់គ្រងសំណល់ជាច្រើនដងរួចមកហើយក៏ដោយ។ យន្តការផ្តល់មតិប្រឡប់ជាផ្លូវការនៅមិនទាន់បានធ្វើនៅតាមស្ថាប័ននៅឡើយ ហើយប្រជាពលរដ្ឋមានឱកាសតិចតួចក្នុងការផ្តល់ និង

ឆ្លុះបញ្ចាំងអំពីទស្សនៈរបស់ខ្លួន អំពីការរៀបចំផែនការ ការអនុវត្តន៍ និងការតាមដានទៅលើការគ្រប់គ្រងសំណល់ទីប្រជុំជន។

## សកម្មភាព

ក. ការលើកកម្ពស់ការបង្ហាញព័ត៌មាន

ការលើកកម្ពស់ការបង្ហាញព័ត៌មានជាសាធារណៈ គឺជាវិធីសាស្ត្រមានប្រសិទ្ធភាព ដើម្បីផ្តួចផ្តើម/ លើកកម្ពស់ការចូលរួមរបស់សាធារណជននៅក្នុងវិស័យសំណល់។ ការជំរុញឱ្យមានការលាតត្រដាងជាសាធារណៈអំពីបញ្ហាសំណល់នឹងជួយបង្កើតសន្ទុះនយោបាយ។

- ផ្សព្វផ្សាយឯកសាររដ្ឋបាលពាក់ព័ន្ធ រួមទាំងច្បាប់ស្តីពីការគ្រប់គ្រងសំណល់ ផែនការថវិកា និងរបាយការណ៍ប្រចាំឆ្នាំតាមប្រព័ន្ធអ៊ីនធឺណិត ដើម្បីផ្សព្វផ្សាយឱ្យបានកាន់តែទូលំទូលាយ អំពីយុទ្ធសាស្ត្រនៅលើវេបសាយត៍របស់រដ្ឋបាលរាជធានីភ្នំពេញ (ទិដ្ឋភាពនៃនីតិវិធី)
- ដាក់កម្មវិធីប្រមូល គោលការណ៍ញែក/ បញ្ចេញសំណល់លើប្រព័ន្ធអ៊ីនធឺណិត និងនៅកន្លែងប្រមូល ដើម្បីសម្រួលដល់ការមើលឃើញរបស់សាធារណជន (ទិដ្ឋភាពបច្ចេកទេស)។

ខ. ប្រមូល និងឆ្លុះបញ្ចាំងអំពីសំឡេងសាធារណជនទូទៅ តាមរយៈការបង្កើតយន្តការទទួលមតិត្រឡប់ស្តីពីការបង្កើតគោលនយោបាយគ្រប់គ្រងសំរាម សំណល់រឹងទីក្រុង៖

- រៀបចំវេទិការសាធារណៈ និង/ឬធ្វើការស្ទង់មតិ
- រៀបចំសន្និសីទស្តីពីការគ្រប់គ្រងសំណល់ទីប្រជុំជន
- ជ្រើសរើស (ដោយបើកចំហ) ចាត់តាំង និងអញ្ជើញតំណាងប្រជាពលរដ្ឋឱ្យចូលរួមនៅក្នុងកិច្ចប្រជុំសំខាន់ៗស្តីពីការគ្រប់គ្រងសំណល់។

## សកម្មភាពទី៥.២. ការទាក់ទាញការចូលរួមពីយុវជន តាមរយៈការអប់រំអំពីបរិស្ថាន

## គោលបំណង

ការបង្រៀន និងការទាក់ទាញយុវជនជំនាន់ក្រោយចូលរួម គឺជាយុទ្ធសាស្ត្រដ៏សំខាន់ក្នុងការពង្រីក និងនិរន្តរភាពកិច្ចខិតខំប្រឹងប្រែងឆ្ពោះទៅសង្គមបៃតងប្រកបដោយចីរភាព។ រដ្ឋបាលរាជធានីភ្នំពេញនឹងលើកកម្ពស់ការយល់ដឹងដល់យុវវ័យ ស្តីពីផលប៉ះពាល់បណ្តាលមកពីការគ្រប់គ្រងសំណល់មិនបានត្រឹមត្រូវ តាមរយៈការលើកកម្ពស់ការកសាងសមត្ថភាពមូលដ្ឋាននៅតាមសាលារៀន យុទ្ធនាការលើកកម្ពស់ការយល់ដឹង និងការអប់រំ ដើម្បីជំរុញការចូលរួមពីសំណាក់យុវជន និងលើកកម្ពស់ការយល់ដឹងអំពីបរិស្ថាន។

## ស្ថានភាពបច្ចុប្បន្ន

ក្រសួងអប់រំ យុវជន និងកីឡា និងក្រសួងបរិស្ថាន បានផ្តួចផ្តើមនូវកម្មវិធីលើកកម្ពស់ និងបញ្ជ្រាបការអប់រំបរិស្ថាន និងគ្រប់គ្រងធនធានធម្មជាតិក្នុងវិស័យអប់រំ ដោយបានចុះហត្ថលេខាលើអនុស្សារណៈនៃការយោគយល់កាលពីឆ្នាំ២០១៦។ ទោះយ៉ាងណា កម្មវិធី/មុខវិជ្ជាសិក្សាបច្ចុប្បន្ននេះ មាននូវមេរៀនតិចតួច ដែលបង្រៀនផ្តោតលើការអប់រំបរិស្ថាន ដែលទាក់ទងទៅនឹងការគ្រប់គ្រងសំរាម សំណល់រឹង/ធនធានវត្ថុធាតុដើម។

## សកម្មភាព

a. សហការរៀបចំ បញ្ជ្រាបកម្មវិធីសិក្សាតាមសាលារៀននូវការអប់រំអំពីបរិស្ថាន ជាមួយភាគីពាក់ព័ន្ធផ្សេងៗដូចជា ទីភ្នាក់ងារអប់រំ សាលារៀន និងជំនាញការផ្នែកបង្កើតកម្មវិធីសិក្សាជាដើម។ ក្នុងចំណោមបញ្ហាបរិស្ថាន កម្មវិធីសិក្សានឹងរួមបញ្ចូលបញ្ហាប្រឈមផ្នែកសំរាម សំណល់រឹង និងធនធានទាំងនៅកម្រិតតំបន់ និងសាកល។ គេអាចយករាជធានីភ្នំពេញធ្វើជាឧទាហរណ៍ ដោយមានគោលបំណងជំរុញសកម្មភាពស្ម័គ្រចិត្តរបស់សិស្ស ឬសាលារៀនលើប្រធានបទនានាដូចជា ការញែកសំណល់ និងការគ្រប់គ្រងធនធានសំណល់ជាដើម

b. បង្កើតឯកសារអប់រំ ដែលត្រូវដាក់បញ្ចូលទៅក្នុងកម្មវិធីសិក្សាដូចជា ខិត្តប័ណ្ណ ឬកូនសៀវភៅខ្លីៗជាដើម។ បង្កើតវីដេអូអប់រំរយៈពេល ៣០នាទីសម្រាប់បញ្ចាំងនៅតាមសាលារៀន ដោយបង្កើតឡើងតាមរយៈកិច្ចសហការជាមួយក្រសួងអប់រំ និងសាលារៀនតាមមូលដ្ឋាន។ វីដេអូនឹងត្រូវរៀបចំឡើងដើម្បីគូសបញ្ជាក់ជូនអ្នកទស្សនាអំពីបញ្ហាសំណល់ និងវិធានការផ្ទាល់ខ្លួន ហើយអាចមានសេចក្តីសង្ខេបអំពីបញ្ហាប្រឈមពាក់ព័ន្ធនឹងសំណល់/ធនធាននៅក្នុងរាជធានីភ្នំពេញ និងពិភពលោក ប្រវត្តិនៃសារធាតុផ្សេងៗ (ចាប់ផ្តើមពីការទាញយកវត្ថុធាតុដើម ផលិត ប្រើប្រាស់ ក្លាយទៅជាសំណល់ និងត្រូវបានគេបោះបង់ចោល) ចក្ខុវិស័យរបស់រដ្ឋបាលរាជធានីភ្នំពេញ និងកិច្ចការដែលអ្នកទស្សនាអាចអនុវត្តដើម្បីការពារបរិស្ថាន

c. បង្កើតគោលការណ៍ណែនាំអំពីវិធីសាស្ត្របង្រៀន និងបណ្តុះបណ្តាលគ្រូបង្រៀន/អ្នកគ្រប់គ្រងដើម្បីគាំទ្រដល់ការអនុវត្តន៍កម្មវិធីសិក្សាជាក់ស្តែង។

d. ពានរង្វាន់បរិស្ថានទីក្រុង៖ ប្រព័ន្ធពានរង្វាន់ប្រកួតប្រជែងតាមសាលារៀន ដែលមានបរិមាណ/ អត្រាកែច្នៃខ្ពស់ជាងគេ ឬគំនិតផ្តួចផ្តើមកែច្នៃប្រកបដោយភាពច្នៃប្រឌិត អាចរៀបចំឡើងដើម្បីជាការលើកទឹកចិត្ត។ កម្មវិធីប្រកួតគូររូបតាមសាលាបឋមសិក្សា ក៏អាចយកមកពិចារណាផងដែរ

e. ផ្តល់នូវឱកាសរៀនសូត្រ (ឧទាហរណ៍ កម្មសិក្សា ឬអ្នកស្ម័គ្រចិត្ត) ដល់សិស្សានុសិស្សនៅតាមវិទ្យាល័យតាមរយៈការជំរុញកិច្ចសហប្រតិបត្តិការរវាងវិទ្យាល័យ និងស្ថាប័នផ្សេងៗ

- ឱកាសបែបនេះអាចផ្តល់ជូននៅឆ្នាំសិក្សាចុងក្រោយ
- ស្ថាប័នអប់រំអាចសហការផងដែរជាមួយនឹងក្រសួងបរិស្ថាន
- រយៈពេលកម្មវិធីអាចប្រែប្រួលពីរយៈពេលខ្លី (១សប្តាហ៍) រហូតដល់រយៈពេលវែង (២ខែ សម្រាប់ការឈប់សំរាកប្រចាំឆមាស)
- កម្មវិធីបែបនេះក៏អាចផ្តល់ជាឱកាសដល់ស្ថាប័ន ដែលជ្រើសរើសទទួលយកការស្ម័គចិត្តនោះនូវលទ្ធភាពកំណត់អត្តសញ្ញាណអ្នកជំនាញនៅក្នុងវិស័យនេះនៅពេលអនាគតផងដែរ

f. ភ្ជាប់ស្លាកឃីហោ ផ្ទាំងបដា និងស្លាកសញ្ញានៅជុំវិញសាលារៀនដែលណែនាំការកាត់បន្ថយសំណល់ និងការកែច្នៃសំរាម ធ្វើការផ្សព្វផ្សាយតាមរយៈកូនសៀវភៅផ្សព្វផ្សាយទស្សនាវដ្តីបង្ហាញអំពីផលវិបាកនៃការបោះចោលសំរាមមិនត្រឹមត្រូវ។

## សកម្មភាពទី៥.៣. ការទាក់ទាញការចូលរួម និងអភិវឌ្ឍសមត្ថភាពរបស់សាធារណជន និងវិស័យឯកជន

### គោលបំណង

ការលើកកម្ពស់ការយល់ដឹង និងការពង្រីកកិច្ចសហការជាមួយសាធារណជន ដែលរួមមាន អ្នកពាក់ព័ន្ធផ្នែកសេដ្ឋកិច្ចផ្សេងៗ គឺជាសសរស្តម្ភដ៏សំខាន់មួយទៀត ដើម្បីជម្រុញ ៣អ៊ែរ និងសម្រេចបាននូវគោលដៅគ្រប់គ្រងសំណល់/ ធនធាន។ តាមរយៈកិច្ចសហការជាមួយស្ថាប័នផ្សេងៗ និងការប្រើប្រាស់បណ្តាញផ្សព្វផ្សាយចម្រុះសមស្រប រដ្ឋបាលរាជធានីភ្នំពេញគួរលើកទឹកចិត្តប្រជាពលរដ្ឋឱ្យមានការយល់ដឹងអំពីសារសំខាន់នៃកិច្ចការពារបរិស្ថានក្នុងមូលដ្ឋាន និងអភិវឌ្ឍន៍សមត្ថភាពដើម្បីជំរុញសកម្មភាពរបស់ប្រជាពលរដ្ឋម្នាក់ៗឆ្ពោះទៅការរស់នៅប្រកបដោយចីរភាព។

### ស្ថានភាពបច្ចុប្បន្ន

- ប្រជាពលរដ្ឋរស់នៅទីក្រុងភ្នំពេញភាគច្រើន មិនសូវមានការយល់ដឹងអំពីសារសំខាន់នៃការវេចខ្ចប់ និងញែកសំណល់របស់ខ្លួនឱ្យបានត្រឹមត្រូវឡើយ ដោយពួកគាត់ភាគច្រើនវេចខ្ចប់សំរាមបញ្ចូលគ្នា ដែលធ្វើឱ្យមានការលំបាកក្នុងការញែកសំរាមដើម្បីធ្វើការកែច្នៃ និងធ្វើជីកំប៉ុស។ ប្រជាពលរដ្ឋភាគច្រើនមានទម្លាប់មិនចោលសំរាមនៅក្នុងធុងសំរាមពោលគឺពួកគាត់ចោលសំរាមនៅតាមដងផ្លូវ ឬនៅលើទីតាំងមិនសមស្រប ឬខុសពេលវេលាដោយសារការយល់ដឹងនៅមានកម្រិត។
- ការទុកដាក់សំណល់វេជ្ជសាស្ត្រនៅរាជធានីភ្នំពេញ នៅមានកម្រិតនៅឡើយសម្រាប់សេវាថែទាំសុខភាពមួយចំនួន ធ្វើឱ្យមានសំណល់វេជ្ជសាស្ត្រមួយចំនួននៅតែមានលាយឡំជាមួយនឹង សំរាមទូទៅ ហើយវាក៏អាចបង្កហានិភ័យដល់កុមារមួយចំនួន ដែលដើររើសសំណល់អេតចាយជារៀងរាល់ថ្ងៃ។
- បច្ចុប្បន្ន នៅពុំទាន់មានកម្មវិធីលើកទឹកចិត្ត ដើម្បីជំរុញការចូលរួមពីវិស័យឯកជននៅក្នុងការកែច្នៃ និងការអនុវត្តន៍គ្រប់គ្រងសំណល់ឱ្យបានល្អប្រសើរនៅឡើយ។

### សកម្មភាព

a. រៀបចំកម្មវិធីលើកកម្ពស់ការយល់ដឹង ដោយផ្តោតគោលដៅទៅលើប្រជាពលរដ្ឋ និងវិស័យសាធារណៈក្នុងការកាត់បន្ថយសំណល់ និងប្រើប្រាស់ឡើងវិញនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។

- រៀបចំពិព័រណ៍បរិស្ថាននៅក្នុងខណ្ឌនីមួយៗនៃរាជធានីភ្នំពេញដើម្បីលើកកម្ពស់ការកែច្នៃសំណល់នៅក្នុងសហគមន៍។ ព្រឹត្តការណ៍ទាំងនេះ គួររៀបចំឡើងឱ្យបានជារៀងរាល់ឆ្នាំដោយមានកិច្ចសហការពីរដ្ឋបាលរាជធានីភ្នំពេញ បុគ្គលិកស្ម័គ្រចិត្ត និងប្រធានសហគមន៍តាមមូលដ្ឋាន
- ផ្សព្វផ្សាយព័ត៌មានបរិស្ថាន និងយុទ្ធនាការអប់រំតាមរយៈការប្រើប្រាស់នូវវិធីសាស្ត្រពីផ្ទះមួយទៅផ្ទះមួយដោយបង្រៀនប្រជាពលរដ្ឋឱ្យចេះរបៀបកែច្នៃសំណល់ និងឱ្យមានការយល់ដឹងអំពីផលប៉ះពាល់នៃការទុកដាក់សំរាមមិនបានត្រឹមត្រូវទៅលើបរិស្ថាន និងសុខភាព ព្រមទាំងតួនាទីរបស់បុគ្គលម្នាក់ៗក្នុងវិស័យសំណល់ (រួមទាំងវិស័យក្រៅផ្លូវការ) នៅក្នុងការលើកកម្ពស់អនាម័យ និងកិច្ចគាំពារបរិស្ថាននៅក្នុងទីក្រុង
- ចែកចាយឯកសារផ្សេងៗដូចជា ខិត្តប័ណ្ណ សៀវភៅណែនាំសម្រាប់គ្រួសារ និងបិទស្ទីគើរនៅលើធុងសំរាម និងនៅជុំវិញតំបន់ទីផ្សារដើម្បីជំរុញការកែច្នៃសំណល់
- ការប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយក្នុងមូលដ្ឋាន ដូចជាសារព័ត៌មាន វិទ្យុ និងទូរទស្សន៍ ដើម្បីបង្កើនការយល់ដឹង។ វីដេអូ

ខ្លីៗ នឹងត្រូវផ្តល់ជូនដោយសហការជាមួយសាកលវិទ្យាល័យ ដោយមានគោលដៅលើកកម្ពស់ការយល់ដឹងអំពីបញ្ហាប្រឈមផ្នែកបរិស្ថាន

- រៀបចំការអប់រំផ្សព្វផ្សាយ/ កម្មវិធីបណ្តុះបណ្តាល ស្តីពីការគ្រប់គ្រងសំរាមដែលផ្តោតលើមន្ត្រីជំនាញនៃរដ្ឋបាលថ្នាក់ក្រោមជាតិទាំងអស់ ដើម្បីលើកកម្ពស់ការយល់ដឹងរបស់ពួកគេ ស្តីពីខ្សែសង្វាក់គ្រប់គ្រងសំណល់ទាំងមូល ក៏ដូចជាការលើកកម្ពស់ការគ្រប់គ្រងសំណល់ឱ្យបានសមស្រប។
- ជំរុញក្រុមហ៊ុនប្រមូលសំរាមឱ្យចូលរួមក្នុងយុទ្ធនាការលើកកម្ពស់ការយល់ដឹង ដល់ប្រជាពលរដ្ឋតាមរយៈការរៀបចំសិក្ខាសាលា ដោយសហការជាមួយក្រុមហ៊ុនប្រមូលសំរាមនៅតាមសហគមន៍មូលដ្ឋាន ជូនដំណឹងដល់ខណ្ឌអំពីពេលវេលា ទីតាំងប្រមូលសំរាម ការអនុវត្តន៍កែច្នៃសំណល់ និងការគ្រប់គ្រងសំណល់ឱ្យបានល្អប្រសើរ។

b. ជំរុញឱ្យមានការចូលរួមពីសំណាក់វិស័យឯកជន តាមរយៈការវាយតម្លៃការលើកទឹកចិត្ត (លក្ខខណ្ឌសេដ្ឋកិច្ច និងមិនមែនសេដ្ឋកិច្ច) និងយុទ្ធសាស្ត្រទីផ្សារក្នុងការផ្លាស់ប្តូរមករកឥរិយាបថ ៣អ៊ែរ និងការគ្រប់គ្រងសំណល់សមស្រប។

- រដ្ឋបាលរាជធានីភ្នំពេញ អាចលើកទឹកចិត្តដល់ក្រុមហ៊ុននានាឱ្យធ្វើសមាហរណកម្ម និងជម្រុញការអនុវត្តន៍ ៣អ៊ែរ នៅក្នុងដំណើរការអាជីវកម្មរបស់ពួកគេ តាមរយៈការគូសបញ្ជាក់/ ទំនាក់ទំនងពីអត្ថប្រយោជន៍នៃការកែលម្អការគ្រប់គ្រងសំណល់ និងធនធានវត្ថុធាតុដើមទាំងក្នុងលក្ខខណ្ឌសេដ្ឋកិច្ច និងមិនមែនសេដ្ឋកិច្ច (ឧទា. ការកាត់បន្ថយចំណាយពីការប្រើវត្ថុធាតុដើមកែច្នៃឡើងវិញ ឬប្រើប្រាស់ធនធានឱ្យមានប្រសិទ្ធភាពតាមរយៈការកែលម្អដំណើរការផលិតកម្មឱ្យបានប្រសើរឡើង)

**ឧទាហរណ៍៖ ការកែច្នៃសំណល់ទៅជាថាមពលនៅក្នុងឧស្សាហកម្មស៊ីម៉ង់ត៍**

កាលពីពេលថ្មីៗនេះក្រុមហ៊ុនស៊ីម៉ងត៍ជីបម៉ុង អ៊ិនស៊ី (Chip Mong Insee) បានបង្កើតមជ្ឈមណ្ឌលផលិតកម្មថ្មីមួយនៅខេត្តកំពត ហើយកំពុងទទួលយកសំណល់ឧស្សាហកម្ម ដែលមានគុណភាពពីរោងចក្រ និងរោងម៉ាស៊ីនកិនស្រូវមកពីតាមបណ្តាខេត្ត-ក្រុងមួយចំនួន ដើម្បីជំនួសការប្រើប្រាស់ធ្យូងថ្មសម្រាប់ដុតនៅក្នុងឡ។ សំណល់ទាំងនោះមានប្រភពមកពីរាជធានីភ្នំពេញ ខេត្តតាកែវ កំពង់ស្ពឺ និងខេត្តកណ្តាល ហើយក៏កំពុងស្វែងរកអ្នកផ្គត់ផ្គង់សំណល់កាន់តែច្រើនថែមទៀតដែរ។ ប្រតិបត្តិការទាំងនេះអាចផ្តល់ប្រយោជន៍ផ្នែកហិរញ្ញវត្ថុដល់ភាគីទាំងពីរក្នុងការកាត់បន្ថយចំណាយសម្រាប់ប្រតិបត្តិការអាជីវកម្ម (ការចំណាយលើការគ្រប់គ្រងសំណល់ដោយអ្នកបង្កើតសំរាម និងថ្លៃចំណាយលើថាមពលដោយក្រុមហ៊ុនស៊ីម៉ងត៍) ខណៈពួកគេក៏អាចជួយកាត់បន្ថយផលប៉ះពាល់បរិស្ថានពីសកម្មភាពរបស់ពួកគេបានថែមទៀតផង។

- គេអាចគិតគូរផ្តល់ពានរង្វាន់អាជីវកម្មស្អាតសម្រាប់វិស័យគោលដៅផ្សេងៗ (ឧទា. សណ្ឋាគារ ផ្នែកដឹកជញ្ជូន និងផលិតកម្ម/ សិប្បកម្ម) ដើម្បីលើកទឹកចិត្តការអនុវត្តន៍ការគ្រប់គ្រងអាជីវកម្មប្រកបដោយចីរភាពសំដៅជំរុញការអនុវត្តន៍ ៣អ៊ែរ នៅក្នុងវិស័យអាជីវកម្ម
- ការបង្ហាញពីលទ្ធភាពក្នុងការទទួលបាននូវការកាត់បន្ថយពន្ធអាជីវកម្ម/ ការវិនិយោគ អាចជួយជំរុញដល់ការគិតគូរពីការគ្រប់គ្រងអាជីវកម្មប្រកបដោយចីរភាព បន្ថែមពីលើយន្តការផ្តល់ពានរង្វាន់ខាងលើ
- លើកទឹកចិត្ត/ លើកកម្ពស់/ ជួយសម្រួលដល់ក្រុមសហគមន៍ស្ថាប័ននានា ដើម្បីចាប់ផ្តើម/ បន្តការធ្វើអាជីវកម្មកែច្នៃឡើងវិញ ជាមួយក្រុមហ៊ុនកែច្នៃឯកជន តាមរយៈការអភិវឌ្ឍ និងផ្សព្វផ្សាយពីបញ្ជីឈ្មោះ/ ទំនាក់ទំនងរបស់ក្រុមហ៊ុនកែច្នៃឡើងវិញ។

## ៦. តារាងប្រតិបត្តិការ - សកម្មភាពអាទិភាព ផែនតួនាទី និងភារកិច្ច និងសូចនាករ

| សកម្មភាព | អនុសកម្មភាព | សូចនាករ | ភាគីពាក់ព័ន្ធ<br>(ភារដឹកនាំ និងគាំទ្រដល់អនុវត្តភាព) | អាទិភាព | | |
|---|---|---|---|---|---|---|
| | | | | ខ្លី | មធ្យម | វែង |
| **សកម្មភាពចម្បងទី1៖ ពង្រឹងប្រព័ន្ធបញ្ចេញចោលសំរាម ប្រព័ន្ធប្រមូលសំរាម និងបង្កើនគុណភាពសេវាកម្មប្រមូលសំរាម** | | | | | | |
| **សកម្មភាពទី1.1៖ កែលម្អឥរិយាបថបោះចោលសំរាម និងទីតាំងប្រមូលសំរាមដែលបានកំណត់** | | | | | | |
| a. សម្រេចចិត្តនូវវិធានការញែកសំណល់ | | វិធាននៃការញែកសំណល់ត្រូវច្បាស់លាស់ | PPCA, មន្ទីរពាក់ព័ន្ធ, ខណ្ឌ/សង្កាត់, ភាគីពាក់ព័ន្ធ | | | |
| b. ការអភិវឌ្ឍសៀវភៅណែនាំ | | សៀវភៅណែនាំអំពីការបញ្ចេញ-ប្រមូលសំរាម | PPCA, DoE, ខណ្ឌ/សង្កាត់, CINTRI | | | |
| c. រៀបចំទីតាំងបញ្ចេញសំរាម | កំណត់ទីតាំងចាក់សំរាមបណ្ដោះអាសន្ន | ទីតាំងចាក់សំរាមបណ្ដោះអាសន្ន | PPCA, ខណ្ឌ/សង្កាត់, CINTRI | | | |
| | កំណត់ទីតាំងចាក់សំរាមជាអចិន្ត្រៃយ៍ | ទីតាំងចាក់សំរាមជាអចិន្ត្រៃយ៍ | PPCA, ខណ្ឌ/សង្កាត់, CINTRI | | | |
| d. កម្មវិធីផ្សព្វផ្សាយសម្រាប់ការជូនដំណឹងពីបទដ្ឋានគ្រប់គ្រង និងបញ្ចេញសំរាម | កម្មវិធីបង្កើនការយល់ដឹង | ចំនួននៃព្រឹត្តិការណ៍លើកកម្ពស់ការយល់ដឹងបានរៀបចំ និងចំនួនអ្នកចូលរួមក្នុងព្រឹត្តិការណ៍ | PPCA, DoE, ខណ្ឌ/សង្កាត់ | | | |
| | យុទ្ធនាការផ្សព្វផ្សាយតាមបណ្ដាញសង្គម | "ចំនួនយុទ្ធនាការដែលបានរៀបចំ | PPCA, DoE/MoE, ខណ្ឌ/សង្កាត់ | | | |
| e. ការអនុវត្តការគ្រប់គ្រងសំណល់ និងការបញ្ចេញចោលសំណល់ | ប្រឹក្សាយោបល់/ ការអនុវត្តច្បាប់ថ្មី/ សៀវភៅណែនាំប្រចាំថ្ងៃ | ចំនួនអ្នកចូលរួមយុទ្ធនាការ | ខណ្ឌ/សង្កាត់ គាំទ្រដោយ PPCA, DoE | | | |
| f. ពង្រឹងវិធានការប្រឆាំងនឹងការបោះចោលសំណល់ខុសច្បាប់ | ដាក់ធុងសំរាម និងស្លាកសញ្ញា/ ផ្ទាំងបដា | ធុងសំរាម និងស្លាកសញ្ញាបានតំឡើង | PPCA, DoE/MoE, ខណ្ឌ/សង្កាត់ | | | |
| | កំណត់ទីតាំងចាក់សំរាមបណ្ដោះអាសន្ន | វិធាននៃការញែកសំណល់ត្រូវច្បាស់លាស់ | ខណ្ឌ/សង្កាត់ គាំទ្រដោយ PPCA, DoE | | | |
| | កំណត់ទីតាំងចាក់សំរាមជាអចិន្ត្រៃយ៍ | សៀវភៅណែនាំអំពីការបញ្ចេញ-ប្រមូលសំរាម | PPCA, DoE/MoE | | | |
| **សកម្មភាពទី1.2៖ កែលម្អសេវាប្រមូលសំរាម បោសសម្អាតផ្លូវ និងទីកន្លែងសាធារណៈ** | | | | | | |
| a. ណែនាំ ការវាយតម្លៃសមត្ថភាព/ លទ្ធផល | | ការវាយតម្លៃសមត្ថភាព/ ការអនុវត្តន៍ | PPCA, DoE | | | |
| b. បង្កើន/ អភិវឌ្ឍផែនការប្រមូលសំរាម | រៀបចំផែនការប្រមូល (តាមផ្ទះ) | ផែនការប្រមូលសំរាមត្រូវបានរៀបចំ | ខណ្ឌ DoE | | | |
| | រៀបចំការស្តុកសំណល់ (ប្រមូលសំរាមតាមផ្ទះ) | ដំឡើងទីតាំងស្តុកសំរាម | PPCA, DoE, ខណ្ឌ/សង្កាត់ | | | |
| | បង្កើតកាលវិភាគ/ ផែនការសម្របសម្រួល (ការបោសសម្អាតតាមផ្លូវ) | ការរៀបចំប្រមូលសំរាម / ផែនការបោសសម្អាត | ខណ្ឌ CINTRI, DoE | | | |

| | | | | | | |
|---|---|---|---|---|---|---|
| | ពិនិត្យវាយតម្លៃ/ វាយតម្លៃផែនការប្រមូលសំរាម (ការបោសសម្អាតតាមផ្លូវ) | ចំនួនពិនិត្យឡើងវិញបានធ្វើឡើង | ខណ្ឌ DoE, | | | |
| | រៀបចំផែនទីសេវានៃផ្លូវដែលត្រូវប្រមូលសំរាម (ការបោសសម្អាតតាមផ្លូវ) | ផែនទីសេវាកម្មបានរៀបចំ | ខណ្ឌ CINTRI | | | |
| | កំណត់ទំហំផ្ទុកសម្រាប់រទេះប្រមូលតូចៗ | ចំនួនករណីដែលបញ្ហាចន្លោះត្រូវបានដោះស្រាយ | ខណ្ឌ/សង្កាត់ គាំទ្រដោយ CINTRI | | | |
| | រៀបចំ/ ថែរក្សាទីតាំងប្រមូល | ចំនួននៃចំណុចប្រមូលដែលបានកំណត់ | PPCA, ខណ្ឌ | | | |
| | ពិនិត្យមើលការអនុវត្តសេវាកម្មរបស់ក្រុមហ៊ុនប្រមូលសំរាម | ការវាយតម្លៃសមិទ្ធផលបានធ្វើឡើង | ខណ្ឌ គាំទ្រដោយ សង្កាត់ PPCA, DoE | | | |
| c. ការណែនាំអំពីការអនុវត្តការប្រមូលសំរាមតាមសហគមន៍ | | ចំនួនសហគមន៍គ្រប់គ្រងប្រមូលសំរាម<br>ការពង្រីកសេវាកម្មតាមរយៈទម្រង់នៃការប្រមូលសំរាម | ខណ្ឌ/សង្កាត់ គាំទ្រដោយប្រជាពលរដ្ឋ អង្គការក្រៅរដ្ឋាភិបាល | | | |
| d. បង្កើនប្រសិទ្ធភាពទំនាក់ទំនង រវាង PPCA និងក្រុមហ៊ុនប្រមូលសំរាម | ស្នើសុំរបាយការណ៍វិភាគលើសេវាកម្ម | របាយការណ៍ស្តីពីសេវាដឹកជញ្ជូន | ខណ្ឌ/សង្កាត់, PPCA | | | |
| | ណែនាំយន្តការទទួលយោបល់ | យន្តការទទួលយោបល់ត្រឡប់ត្រូវបានប្រើប្រាស់ | ខណ្ឌ/សង្កាត់ គាំទ្រដោយ CINTRI | | | |
| e. ការវិភាគសេដ្ឋកិច្ចដើម្បីពិនិត្យឡើងវិញនូវថ្លៃសេវា | | ការវិភាគសេដ្ឋកិច្ចបានធ្វើឡើង<br>ពិនិត្យ និងផ្លាស់ប្តូរថ្លៃសេវា | PPCA គាំទ្រដោយក្រសួង/មន្ទីរ ពាក់ព័ន្ធ | | | |
| f. ការណែនាំទីផ្សារប្រកួតប្រជែង | ណែនាំការដេញថ្លៃដោយបើកចំហ | សេចក្តីផ្តើមនៃការដេញថ្លៃបើកចំហ | PPCA | | | |
| **សកម្មភាពទី1.3៖ គាំទ្រដល់ខណ្ឌរដ្ឋបាល/ សង្កាត់ ដើម្បីពង្រឹងការតាមដាន ត្រួតពិនិត្យ និងការអនុវត្តន៍** | | | | | | |
| a. បង្កើតគោលការណ៍ណែនាំ និងសូចនាករសម្រាប់ការអនុវត្តន៍ | | សេចក្តីណែនាំ និងសូចនាករត្រូវបានបង្កើត | PPCA, DoE, ខណ្ឌ/សង្កាត់ | | | |
| b. ការបង្កើតគណៈកម្មាធិការខណ្ឌ សម្រាប់ការសម្របសម្រួល និងការត្រួតពិនិត្យ | | ចំនួនគណៈកម្មាធិការខណ្ឌបានបង្កើតឡើង<br>ចំនួនកិច្ចប្រជុំរៀបចំដោយគណៈកម្មាធិការខណ្ឌ | PPCA, DoE, ខណ្ឌ/សង្កាត់ | | | |
| c. ការអភិវឌ្ឍសមត្ថភាពសម្រាប់ផែនការគ្រប់គ្រងរបស់ខណ្ឌ | | ចំនួនព្រឹត្តិការណ៍អភិវឌ្ឍន៍សមត្ថភាព<br>ចំនួនអ្នកចូលរួមក្នុងព្រឹត្តិការណ៍ | PPCA, DoE, ខណ្ឌ/សង្កាត់ មន្ទីរពាក់ព័ន្ធ | | | |
| d. ថៃទាំអ្នកត្រួតពិនិត្យសម្រាប់ការត្រួតពិនិត្យ/ ការណែនាំ | | ចំនួនអ្នកត្រួតពិនិត្យដែលសកម្មនៅក្នុងខណ្ឌនីមួយៗ | PPCA, DoE, ខណ្ឌ/សង្កាត់ | | | |
| e. បណ្តុះបណ្តាលអាជ្ញាធរមូលដ្ឋាន | | ចំនួននៃព្រឹត្តិការណ៍លើកកម្ពស់ការយល់ដឹង<br>ចំនួនអ្នកចូលរួមក្នុងព្រឹត្តិការណ៍ | PPCA, DoE | | | |
| **សកម្មភាពចម្បងទី២៖ ផ្សព្វផ្សាយការកែច្នៃឡើងវិញ តាមរយៈការញែកសំណល់ ការចូលរួមរបស់វិស័យឯកជន និងផ្សព្វផ្សាយការប្រើប្រាស់ផលិតផលកែច្នៃឡើងវិញ** | | | | | | |
| **សកម្មភាពទី2.1៖ បង្កើនសមត្ថភាពកែច្នៃតាមរយៈការជំរុញសកម្មភាពតាមមូលដ្ឋាន និងសម្របសម្រួលការបង្កើតឧស្សាហកម្មកែច្នៃក្នុងស្រុក** | | | | | | |

| | | | | | | |
|---|---|---|---|---|---|---|
| a. ធ្វើការវិភាគសេដ្ឋកិច្ច ដើម្បីបង្កើតឧស្សាហកម្មកែច្នៃ | ការវិភាគស៊ីជម្រៅនៃប្រព័ន្ធកែច្នៃបច្ចុប្បន្ន | របាយការណ៍សិក្សាលទ្ធភាព៖ 1. ទីផ្សារនាំចេញនូវផលិតផលកែច្នៃរួច 2. ការវិភាគចំណេញ-ខាត ក្នុងការវិនិយោគរោងចក្រកែច្នៃសំណល់ | PPCA គាំទ្រដោយ DoIH, DEF, DoC, DoE, CDC | | | |
| | ការវិភាគថ្លៃចំណាយសម្រាប់បង្កើតមធ្យោបាយកែច្នៃឡើងវិញ | | | | | |
| b. កំណត់ដំណោះស្រាយបច្ចេកវិទ្យាកែច្នៃដ៏សាកសម | | របាយការណ៍ស្ដីពីការវាយតម្លៃបច្ចេកវិទ្យាបានធ្វើឡើង | | | | |
| c. ផ្ដល់ការគាំទ្រដល់ក្រុមហ៊ុនកែច្នៃឡើងវិញ | | ចំនួនក្រុមហ៊ុនកែច្នៃថ្មីត្រូវបានបង្កើតឡើង/ ទាក់ទាញមកបាន | | | | |
| d. ទាក់ទាញការវិនិយោគក្នុងវិស័យកែច្នៃ | ការបង្កើតកិច្ចប្រជុំពិគ្រោះយោបល់ (អ្នកកែច្នៃឡើងវិញ និងអ្នកបង្កើតសំណល់) | ចំនួននៃកិច្ចប្រជុំពិគ្រោះយោបល់ត្រូវបានរៀបចំ ចំនួនអ្នកបង្កើតសំរាម សំណល់រឹង និងកែច្នៃសំណល់បានចូលរួមនៅក្នុងព្រឹត្តិការណ៍ | | | | |
| | បង្កើតមូលដ្ឋានទិន្នន័យអំពីអ្នកកែច្នៃ | បានបង្កើតមូលដ្ឋានទិន្នន័យ | | | | |
| | កំណត់ទុក ការអនុវត្តល្អបំផុត | ចំនួនការអនុវត្តល្អបំផុតដែលបានកំណត់ និងចម្លង | | | | |
| | ការគាំទ្រការលើកទឹកចិត្តអាជីវកម្មកែច្នៃឡើងវិញ | វិធានការគាំទ្រដែលបានអនុវត្ត | | | | |
| e. លើកកម្ពស់សកម្មភាពស្ម័គ្រចិត្តតាមមូលដ្ឋានសម្រាប់ការកែច្នៃឡើងវិញ | លើកកម្ពស់ប្រព័ន្ធធ្វើជីកំប៉ុសតាមបែបវិមជ្ឈការតាមគ្រួសារ/ សហគមន៍ | ចំនួននៃគំនិតផ្ដួចផ្ដើមធ្វើជីកំប៉ុសថ្មីបានចាប់ផ្ដើម ចំនួនសម្ភារផ្ដល់ព័ត៌មានដែលបានចែកចាយ | ខណ្ឌ/សង្កាត់ DoE គាំទ្រដោយ PPCA | | | |
| | លើកកម្ពស់ការប្រើប្រាស់សំណល់ម្ហូបអាហារតាមបែបវិមជ្ឈការ ដែលផ្ដោតទៅលើវិស័យឯកជន | ចំនួនយុទ្ធនាការ/ សិក្ខាសាលាបានរៀបចំ ចំនួនអ្នកចូលរួមក្នុងយុទ្ធនាការ/ សិក្ខាសាលា | | | | |
| **សកម្មភាពទី2.2៖ លើកកម្ពស់ការញែកសំណល់** | | | | | | |
| a. កែតម្រូវឧបករណ៍ស្របច្បាប់ដែលមានស្រាប់ដើម្បីមានវិធានផ្លូវការក្នុងការញែកសំណល់ | | វិសោធនកម្មបានណែនាំ យោងទៅតាមឧបករណ៍ច្បាប់ដែលមានស្រាប់ | PPCA គាំទ្រដោយ DoE, ខណ្ឌ/សង្កាត់ | | | |
| b. ការលើកកម្ពស់ការយល់ដឹងនិងយុទ្ធនាការអប់រំ | ការចែកចាយសំណល់ ដែលញែកដោយដៃ | ចំនួនសៀវភៅណែនាំដែលបានចែកចាយ | PPCA គាំទ្រដោយ DoE, ខណ្ឌ/សង្កាត់ | | | |
| | សិក្ខាសាលា និងវគ្គបណ្ដុះបណ្ដាល | ចំនួនព្រឹត្តិការណ៍រៀបចំបានរៀបចំ ចំនួនអ្នកចូលរួមក្នុងព្រឹត្តិការណ៍ | | | | |
| c. ចែកចាយធុងដាក់សំណល់តាមប្រភេទ | | ចំនួនធុងញែកសំណល់ ត្រូវបានចែកចាយ | ខណ្ឌ/សង្កាត់ គាំទ្រដោយ PPCA, DoE | | | |

| | | | | | | |
|---|---|---|---|---|---|---|
| d. លើកកម្ពស់ការសហការជាមួយផ្នែកកែច្នៃក្រៅផ្លូវការ ដើម្បីធានាការប្រមូលសំណល់ដែលអាចកែច្នៃឡើងវិញ | | សហការជាមួយក្រុមអ្នកកែច្នៃសំណល់ក្រៅប្រព័ន្ធ | ខណ្ឌ/សង្កាត់ គាំទ្រដោយ PPCA, DoE, DoIH | | | |
| **សកម្មភាពទី2.3៖ ផ្សព្វផ្សាយការប្រើផលិតផលកែច្នៃ** | | | | | | |
| a. បង្កើតគ្រោងការបិទស្លាកសញ្ញា | | គ្រោងការដាក់ស្លាកសញ្ញាដែលបានផ្តួចផ្តើម | ក្រសួងពាក់ព័ន្ធ PPCA, DoE | | | |
| b. ជំរុញការប្រើផលិតផលកែច្នៃឡើងវិញដោយអ្នកប្រើប្រាស់ | | វិធានការគោលនយោបាយត្រូវបានអនុវត្ត | PPCA គាំទ្រដោយ ខណ្ឌ/សង្កាត់ DoIH, DoE | | | |
| c. សេចក្តីណែនាំអំពីច្បាប់លទ្ធកម្មសាធារណៈបៃតង | | ច្បាប់លទ្ធកម្មសាធារណៈបៃតងបានអនុម័ត និងអនុវត្ត | PPCA, DoE | | | |
| d. វិធានការដើម្បីផ្លាស់ប្តូរអាកប្បកិរិយារបស់ភាគីពាក់ព័ន្ធ | កម្មវិធីបង្កើនការយល់ដឹង | ចំនួនព្រឹត្តិការណ៍នៃការលើកកម្ពស់ការយល់ដឹងត្រូវបានរៀបចំ និងចំនួនអ្នកចូលរួមក្នុងព្រឹត្តិការណ៍ | PPCA គាំទ្រដោយ ខណ្ឌ/សង្កាត់ DoE | | | |
| | កែលម្អលទ្ធភាពទទួលបានជម្រើសកែច្នៃ | លទ្ធភាពប្រើប្រាស់បាន មានលក្ខណៈប្រសើរឡើង | PPCA គាំទ្រដោយ ខណ្ឌ/សង្កាត់ DoE | | | |
| | ការកសាងសមត្ថភាពលើការកែច្នៃឡើងវិញ | ចំនួនព្រឹត្តិការណ៍កសាងសមត្ថភាពត្រូវបានរៀបចំ និងចំនួនអ្នកចូលរួមក្នុងព្រឹត្តិការណ៍ | PPCA គាំទ្រដោយ ខណ្ឌ/សង្កាត់ DoE | | | |
| | ណែនាំ ការវាស់ស្ទង់ ការតាមដាននិងវឌ្ឍនភាព | ប្រព័ន្ធតាមដាន និងវាយតម្លៃត្រូវបានណែនាំ | PPCA, DoE | | | |
| **សកម្មភាពចម្បងទី3៖ ជំរុញការគ្រប់គ្រងបរិមាណសំណល់ ដែលផ្តល់ផលល្អដល់បរិស្ថាន និងកាត់បន្ថយផលប៉ះពាល់ដល់បរិស្ថាន និងមនុស្ស** | | | | | | |
| **សកម្មភាពទី3.1៖ កែលម្អការគ្រប់គ្រងទីលានចាក់សំរាម** | | | | | | |
| a. ចាប់ផ្តើមប្រតិបត្តិការ/ ការថែទាំត្រឹមត្រូវឡើងវិញ | តាមដានកម្ពស់គំនរសំរាម ដើម្បីការពារការដួលរលំ | ការអនុវត្តន៍ឡើងវិញ | PPCA អង្គភាពគ្រប់គ្រងទីលានចាក់សំរាម ខណ្ឌ | | | |
| | លុបដី ប្រចាំថ្ងៃ | | | | | |
| | កែលម្អ សកម្មភាពរបស់រថយន្តប្រមូលសំណល់យកមកចាក់ | | | | | |
| | ឧបករណ៍ការពារផ្ទាល់ខ្លួន | | | | | |
| | ការសាកល្បងការប្រមូលឧស្ម័ននៅកន្លែងចាក់សំរាម | | | | | |
| | រៀបចំគ្រឿងបរិក្ខារនិងនីតិវិធីសម្រាប់ការពារនិងពន្លត់ភ្លើងនៅកន្លែងចាក់សំរាម | | | | | |
| b. ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធនៅទីលានចាក់សំរាម | ប្រព័ន្ធប្រព្រឹត្តិកម្មទឹកសំអុយ (ការធ្វើប្រព្រឹត្តកម្មដោយគីមី) | ហេដ្ឋារចនាសម្ព័ន្ធត្រូវបានរៀបចំ | PPCA អង្គភាពគ្រប់គ្រងទីលានចាក់សំរាម | | | |

| | | | | | | |
|---|---|---|---|---|---|---|
| | ពង្រីកទីតាំងសម្រាប់យកសំរាមមកចាក់ | | | | | |
| | បន្ថែមគ្រឿងចក្រថ្មីជាប្រចាំសម្រាប់ប្រតិបត្តិការ (គ្រឿងចក្រ អេស្កា អាបុល) | | | | | |
| c. រៀបចំការផ្លាស់ប្ដូរទៅជាទម្រង់នៃការញែកសំណល់ | | វេទិកាញែកសំរាមត្រូវបានបង្កើតឡើង និងបានចាប់ផ្ដើមដំណើរការ | PPCA អង្គភាពគ្រប់គ្រងទីលានចាក់សំរាម | | | |
| d. ទាក់ទាញអ្នកឯកទេស និងពង្រឹងធនធានមនុស្ស | វាយតម្លៃបច្ចេកទេស សមត្ថភាព និងកំណត់ផ្នែកត្រូវការកែលម្អ | ការវាយតម្លៃសមត្ថភាពបានធ្វើឡើង | PPCA អង្គភាពគ្រប់គ្រងទីលានចាក់សំរាម | | | |
| | ដឹកនាំបុគ្គលិកទៅទីតាំងបណ្ដុះបណ្ដាល/ ទស្សនកិច្ចនៅតាមតំបន់ | ចំនួនអ្នកចូលរួមក្នុងកម្មវិធីបណ្ដុះបណ្ដាល | | | | |
| | ស្វែងរកជំនួយបច្ចេកទេសពីម្ចាស់ជំនួយ | កម្មវិធីផ្ទេរចំណេះដឹងបានធ្វើឡើង | | | | |
| | ភ្ជាប់ជាមួយកម្មសិក្សា | កម្មសិក្សាបានធ្វើឡើង | | | | |
| e. កែលម្អឧបករណ៍/ វិធីសាស្រ្តកត់ត្រាបរិមាណសំណល់ | | បរិមាណទិន្នន័យសំណល់ដែលបានផលិត | PPCA អង្គភាពគ្រប់គ្រងទីលានចាក់សំរាម CINTRI | | | |
| f. ការត្រួតពិនិត្យសុខភាពនិងផលប៉ះពាល់ដល់បរិស្ថាន | ធ្វើការសិក្សាអំពីការបំពុលទឹកក្រោមដី | របាយការណ៍វាយតម្លៃផលប៉ះពាល់បរិស្ថាន | PPCA, DoH, DoE | | | |
| | ធ្វើការសិក្សាលើផលប៉ះពាល់លើសុខភាព | របាយការណ៍វាយតម្លៃផលប៉ះពាល់សុខភាព | | | | |
| **សកម្មភាពទី 3.2 ធានាសុវត្ថិភាពធនធានហិរញ្ញវត្ថុ សម្រាប់ការគ្រប់គ្រងទីលានចាក់សំរាមប្រកបដោយនិរន្តភាព** | | | | | | |
| a. រៀបចំប៉ាន់ប្រមាណការចំណាយ ដើម្បីឱ្យមានការគ្រប់គ្រងប្រកបដោយចីរភាព | | ការប៉ាន់ស្មានការចំណាយ ត្រូវបានបង្កើតឡើង | PPCA/ អង្គភាពគ្រប់គ្រងទីលានចាក់សំរាម | | | |
| b. បង្កើនថ្លៃចាក់សំរាមនៅទីលាន | | កំណត់ថ្លៃទីលានសម្រាប់ចាក់សំរាម | PPCA/ អង្គភាពគ្រប់គ្រងទីលានចាក់សំរាម និងភាគីពាក់ព័ន្ធ | | | |
| c. វាយតម្លៃឡើងវិញអំពីជម្រើសហិរញ្ញវត្ថុ ដើម្បីបង្កើនប្រសិទ្ធភាពទីលានចាក់សំរាម | | ជម្រើសហិរញ្ញវត្ថុត្រូវបានកំណត់ | PPCA/ អង្គភាពគ្រប់គ្រងទីលានចាក់សំរាម និងភាគីពាក់ព័ន្ធ | | | |
| d. រក្សា កត់ត្រា និងប្រើប្រាស់សំរាម ដែលចូលឱ្យបានសុក្រឹត | | MRF ត្រូវបានតម្លើង | PPCA/ អង្គភាពគ្រប់គ្រងទីលានចាក់សំរាម | | | |
| **សកម្មភាព 3.3 សហការជាមួយភាគីពាក់ព័ន្ធ** | | | | | | |
| a. រៀបចំទម្រង់នៃការញែកសំណល់សមស្រប | | ប្រហែល 20-30 ភាគរយនៃអ្នករើសសំរាមត្រូវបានជួលឱ្យធ្វើការនៅ MRF | PPCA/ អង្គភាពគ្រប់គ្រងទីលានចាក់សំរាម | | | |

| | | | | | | |
|---|---|---|---|---|---|---|
| b. ចងក្រង និងទទួលស្គាល់តួនាទីរបស់វិស័យក្រៅប្រព័ន្ធ | | អ្នករើសសំរាមនៅកន្លែងចាក់សំរាមបានរៀបចំ និងចុះបញ្ជីនៅទីលានចាក់សំរាម<br>ព្រឹត្តិការណ៍អប់រំ/ ការបណ្ដុះបណ្ដាលត្រូវបានសម្រាប់អ្នករើសសំរាម (4-5 លើក / ឆ្នាំ) ។ | PPCA/ អង្គភាពគ្រប់គ្រងគ្រប់គ្រងទីលាន | | | |
| c. យុទ្ធនាការយល់ដឹងដើម្បីផ្លាស់ប្ដូរទស្សនៈរបស់សាធារណជន | | យុទ្ធនាការទៀងទាត់មួយ ដែលរៀបចំដោយ PPCA DoE/អង្គភាពគ្រប់គ្រងទីលានចាក់សំរាម | PPCA/ អង្គភាពគ្រប់គ្រងទីលានចាក់សំរាម ខណ្ឌ សង្កាត់ DoE | | | |
| d. បង្កើតជាផ្លូវការនៃវិស័យក្រៅប្រព័ន្ធ | | បទបញ្ញា និងច្បាប់សម្រាប់ការជ្រើសរើសអ្នករើសសំរាមជាផ្លូវការ | អង្គភាពគ្រប់គ្រងទីលានចាក់សំរាម PPCA | | | |
| e. បញ្ចូលវិស័យមិនផ្លូវការទៅក្នុងប្រព័ន្ធរដ្ឋាភិបាល | | អ្នករើសសំរាម សំណល់រឹងនៅទីលានចាក់សំរាម ត្រូវបានទទួលការងារធ្វើនៅទីលានចាក់សំរាម (MRF, កន្លែងជីកំប៉ុស) | PPCA/ អង្គភាពគ្រប់គ្រងទីលានចាក់សំរាម | | | |
| សកម្មភាពចម្បងទី4៖ ការគ្រប់គ្រងរំហូរសំណល់ពិសេស (សំណល់សំណង់ សំណល់វេជ្ជសាស្ត្រ និងសំណល់ឧស្សាហកម្ម) | | | | | | |
| **សំណល់សំណង់** | | | | | | |
| **សកម្មភាពទី4.1៖ ការបង្កើតប្រព័ន្ធគ្រប់គ្រងទិន្នន័យ** | | | | | | |
| a. ការបង្កើតទិន្នន័យសំណល់តាមប្រភេទ | | រៀបចំប្រព័ន្ធកត់ត្រា និងប្រមូលទិន្នន័យ<br>ទិន្នន័យបរិមាណសំណល់បង្កើតឡើង និងការប្រមូល | PPCA/ ខណ្ឌ<br>គាំទ្រដោយ មន្ទីរសុរិយោដី មន្ទីរបរិស្ថាន ក្រុមហ៊ុនប្រមូលសំណល់ និងអង្គភាពគ្រប់គ្រងទីលានចាក់សំរាម | | | |
| b. ការប៉ាន់ស្មានលើការប្រើប្រាស់សំណល់សំណង់ | | កម្រិតទិន្នន័យដែលអាចចូលមើលបានជាសាធារណៈ | PPCA/ ខណ្ឌ<br>គាំទ្រដោយ មន្ទីរសុរិយោដី មន្ទីរបរិស្ថាន ក្រុមហ៊ុនប្រមូលសំណល់ និងអង្គភាពគ្រប់គ្រងទីលានចាក់សំរាម | | | |
| **សកម្មភាពទី4.2៖ លើកកម្ពស់ការកាត់បន្ថយសំណល់** | | | | | | |
| a. បង្កើនការយល់ដឹង | | ចំនួនក្រុមហ៊ុនដែលទទួលបានលទ្ធផលពីសកម្មភាពលើកកម្ពស់ការយល់ដឹង | PPCA/ ខណ្ឌ គាំទ្រដោយមន្ទីរសុរិយោដី និងមន្ទីរបរិស្ថាន | | | |
| b. ការជម្រុញការសាងសង់ប្រកបដោយនិរន្តរភាព | | ចំនួនអន្តរាគមន៍គោលនយោបាយត្រូវបានណែនាំ | PPCA/ ខណ្ឌគាំទ្រដោយសមាគមឧស្សាហកម្មនៃក្រុមហ៊ុនសាងសង់ | | | |
| c. សេចក្តីណែនាំអំពីថ្លៃសេវាសំរាម | | សេចក្តីណែនាំ និងការអនុវត្តន៍ថ្លៃចំណាយលើសេវាចាក់ចោលសំរាម | PPCA/ ខណ្ឌ | | | |

| | | | | | | |
|---|---|---|---|---|---|---|
| d. ការកែសម្រួល/ ធ្វើបច្ចុប្បន្នភាពនៃការអនុវត្តន៍បទបញ្ញត្តិដែលមានស្រាប់លើសំណល់សំណង់ | | បទប្បញ្ញត្តិបានធ្វើបច្ចុប្បន្នភាព និងអនុវត្ត | គាំទ្រដោយ មន្ទីរសុរិយោដី មន្ទីរបរិស្ថាន ក្រុមហ៊ុនប្រមូលសំណល់ និងអង្គភាពគ្រប់គ្រងទីលានចាក់សំរាម | | | |
| **សកម្មភាពទី4.3៖ លើកកម្ពស់ការប្រើឡើងវិញ និងការកែច្នៃឡើងវិញ** | | | | | | |
| a. ការលើកកម្ពស់ការប្រើប្រាស់ឡើងវិញ | | អន្តរាគមន៍គោលនយោបាយណែនាំសម្រាប់ការលើកកម្ពស់ការប្រើឡើងវិញនៃសំណល់សំណង់ | PPCA/ ខណ្ឌ គាំទ្រដោយសមាគមឧស្សាហកម្មនៃក្រុមហ៊ុនសាងសង់ និងភាគីពាក់ព័ន្ធ | | | |
| b. ការកំណត់បច្ចេកវិទ្យាសមស្រប | | បច្ចេកវិទ្យាការធ្វើប្រព្រឹត្តិកម្ម អាចអនុវត្តបាននៅតាមស្ថានភាពមូលដ្ឋាន | PPCA/ ខណ្ឌ គាំទ្រដោយសមាគមឧស្សាហកម្មនៃក្រុមហ៊ុនសាងសង់ | | | |
| **សកម្មភាពទី4.4៖ ការអនុវត្ត ការត្រួតពិនិត្យ និងការអនុវត្តន៍ទប់ស្កាត់ការបោះចោលសំរាមគ្មានសណ្តាប់ធ្នាប់** | | | | | | |
| a. បង្កើត និងផ្សព្វផ្សាយគោលការណ៍ណែនាំការគ្រប់គ្រងសំណល់សំណង់ | | "គោលការណ៍ណែនាំបានអភិវឌ្ឍ<br>ចំនួននៃការណែនាំ (ឯកសារថតចម្លង ឬបែបអេឡិចត្រូនិក) ចែកចាយ/ ចូលប្រើប្រាស់" | PPCA/ ខណ្ឌ<br>គាំទ្រដោយ មន្ទីរសុរិយោដី មន្ទីរបរិស្ថាន | | | |
| b. ផ្តល់ដំបូន្មានដល់អ្នកបោះចោលសំណល់ដើម្បីនាំសំណល់សំណង់មកចាក់ នៅទីលានចាក់សំរាម | | អន្តរាគមន៍គោលនយោបាយបានណែនាំ<br>ចំនួនការចោលសំរាមដោយខុសច្បាប់ត្រូវបានរាយការណ៍ | PPCA/ ខណ្ឌ គាំទ្រដោយ មន្ទីរសុរិយោដី មន្ទីរបរិស្ថាន | | | |
| c. ការត្រួតពិនិត្យ និងការអនុវត្តន៍ | | ចំនួននៃការចោលសំណល់ខុសច្បាប់ត្រូវបានរាយការណ៍ | PPCA/ ខណ្ឌ មន្ទីរបរិស្ថាន អង្គភាពគ្រប់គ្រងទីលានចាក់សំរាម | | | |
| **សំណល់វេជ្ជសាស្ត្រ** | | | | | | |
| **សកម្មភាពទី4.5៖ ការពង្រឹងប្រព័ន្ធគ្រប់គ្រងសំណល់វេជ្ជសាស្ត្រ** | | | | | | |
| a. បង្កើនការយល់ដឹង និងបណ្តុះបណ្តាលវិទ្យាស្ថានសុខាភិបាល | | ចំនួននៃព្រឹត្តិការណ៍លើកកម្ពស់ការយល់ដឹងបានរៀបចំ និងចំនួនប្រជាពលរដ្ឋដែលបានចូលរួម | MoH និង DoH គាំទ្រដោយ PPCA, MWMU, DoEYS | | | |
| b. យុទ្ធនាការបង្កើនការយល់ដឹងផ្តោតលើប្រជាពលរដ្ឋ | | ចំនួននៃព្រឹត្តិការណ៍លើកកម្ពស់ការយល់ដឹងបានរៀបចំ និងចំនួនប្រជាពលរដ្ឋដែលបានចូលរួម | MoH and DoH<br>គាំទ្រដោយ PPCA, MWMU, DoEYS | | | |
| c. អនុវត្តន៍ការត្រួតពិនិត្យបន្តបន្ទាប់ | | ចំនួន និងភាពញឹកញាប់នៃការធ្វើអធិការកិច្ច | MoH and DoH<br>គាំទ្រដោយ PPCA, MWMU | | | |
| d. បង្កើតយន្តការកត់ត្រាសម្រាប់ការចាក់ចោលសំរាមខុសច្បាប់ | | បង្កើតយន្តការរាយការណ៍ | MoH and DoH<br>គាំទ្រដោយ PPCA, MWMU | | | |

| | | | | | | |
|---|---|---|---|---|---|---|
| e. អនុវត្តន៍ការត្រួតពិនិត្យបន្តបន្ទាប់ទៅអង្គភាពគ្រប់គ្រងសំណល់វេជ្ជសាស្ត្រ | | ការត្រួតពិនិត្យបានធ្វើឡើង ហើយលទ្ធផលត្រូវបានកត់ត្រា និងបោះផ្សាយ | MoH and DoH<br>គាំទ្រដោយ PPCA, MWMU | | | |
| f. ជួយ CRC ឆ្ពោះទៅរកការអនុវត្តន៍ និងការធ្វើផែនការដែលមានប្រសិទ្ធភាព | ការចែកចាយធុងសំរាមសម្រាប់សំណល់វេជ្ជសាស្ត្រ | អត្រាផ្សព្វផ្សាយ (= ស្ថាប័នសុខាភិបាលដែលមានធុងសំរាមសមរម្យ / ស្ថាប័នវេជ្ជសាស្ត្រទាំងអស់នៅក្នុងរាជធានីភ្នំពេញ) | អង្គភាព MWMU គាំទ្រដោយ DoH, DoE, PPCA | | | |
| | ពង្រីកការប្រើប្រាស់ឡដុតសំណល់វេជ្ជសាស្ត្របច្ចុប្បន្ន | ការស្ទង់ / បរិមាណសំណល់វេជ្ជសាស្ត្រ ដែលមិនបានទុកដាក់ឱ្យបានត្រឹមត្រូវ ដោយសារកង្វះខាតសមត្ថភាពដុត | MWMU គាំទ្រដោយ DoH, DoE, PPCA | | | |
| | បង្កើនចំនួនរថយន្តប្រមូល | ចំនួនរថយន្តប្រមូលសំរាម | MWMU គាំទ្រដោយ DoH, DoE, PPCA | | | |
| | កំណត់កាលវិភាគប្រមូលសំរាមឱ្យបានច្បាស់លាស់ | កាលវិភាគប្រមូល | MWMU គាំទ្រដោយ DoH, DoE, PPCA | | | |
| **សំណល់ឧស្សាហកម្ម** | | | | | | |
| **សកម្មភាពទី4.6៖ ការពង្រឹងយន្តការត្រួតពិនិត្យ ដើម្បីធានាឱ្យមានការអនុវត្ត** | | | | | | |
| a. ការអភិវឌ្ឍច្បាប់សម្រាប់ថ្នាក់ក្រោមជាតិ | | បទបញ្ញាថ្នាក់ក្រោមជាតិត្រូវបានបង្កើតឡើង | PPCA, DoIH, DoE | | | |
| b. ការកសាងអង្គភាពពិសេស/តួនាទី សម្រាប់ការគ្រប់គ្រងសំណល់ឧស្សាហកម្ម | | ការបង្កើតអង្គភាពពិសេស/ ទីតាំង | PPCA, DoIH, DoE | | | |
| c. អភិវឌ្ឍបទដ្ឋាន/គោលការណ៍ណែនាំ សម្រាប់ប្រព្រឹត្តិកម្ម/ការកែច្នៃឡើងវិញ | | បទដ្ឋាន/ គោលការណ៍ណែនាំដែលបានបង្កើត | PPCA<br>គាំទ្រដោយ MoE, DoE | | | |
| d. អភិវឌ្ឍ និងធ្វើបច្ចុប្បន្នភាពមូលដ្ឋានទិន្នន័យស្ដីពីការផលិតសំណល់ | | មូលដ្ឋានទិន្នន័យបានបង្កើត<br>ទំហំ និងភាពញឹកញាប់នៃការធ្វើបច្ចុប្បន្នភាព | PPCA គាំទ្រដោយ ម្ចាស់សំណល់ MoE, DoE ក្រុមហ៊ុនគ្រប់គ្រងសំណល់ | | | |
| e. បង្កើតវេទិកាសម្រាប់ការសន្ទនារវាងអ្នកពាក់ព័ន្ធ និងអាជ្ញាធរ | | វេទិកាបានបង្កទំហំ និងភាពញឹកញាប់នៃការផ្លាស់ប្តូរព័ត៌មាន | PPCA គាំទ្រដោយ ម្ចាស់សំណល់ MoE, DoE ក្រុមហ៊ុនគ្រប់គ្រងសំណល់ | | | |
| f. អនុវត្តបទបញ្ញាតាមរយៈការត្រួតពិនិត្យ និងវិធានការដាក់ទោសទណ្ឌ | | ការត្រួតពិនិត្យបានធ្វើឡើង ហើយលទ្ធផលត្រូវបានកត់ត្រា និងបោះផ្សាយ<br>ចំនួនរបាយការណ៍ខុសប្រក្រតីត្រូវបានកត់ត្រាទុក | PPCA, ខណ្ឌ/ សង្កាត់ | | | |
| g. ការផ្សព្វផ្សាយនៃ 3R តាមរយៈ "ការបង្កើតភាពជាដៃគូត្រូវគ្នាក្នុងការផលិតសំណល់ និងការកែច្នៃ " | | ចំនួននៃទំនាក់ទំនងអាជីវកម្មកែច្នៃ ដែលបានបង្កើតឡើងតាមរយៈការសម្របសម្រួលរបស់រដ្ឋបាលរាជធានីភ្នំពេញ និងបរិមាណសំណល់បង្វែរចេញពីទីលានទៅធ្វើការកែច្នៃឡើងវិញ | PPCA គាំទ្រដោយ ក្រុមហ៊ុនបង្កើតសំណល់ MoE, DoE | | | |

| | | | | | | |
|---|---|---|---|---|---|---|
| h. ការអភិវឌ្ឍសមត្ថភាពក្រុមហ៊ុនគ្រប់គ្រងសំណល់ | | ចំនួនព្រឹត្តិការណ៍អភិវឌ្ឍន៍សមត្ថភាពត្រូវបានរៀបចំ<br>ចំនួនអ្នកចូលរួមក្នុងព្រឹត្តិការណ៍ | PPCA គាំទ្រដោយ ខណ្ឌ/សង្កាត់ និង ក្រុមហ៊ុនបង្កើតសំណល់ | | | |
| i. ការអភិវឌ្ឍសមត្ថភាពមន្ត្រីនៃរដ្ឋបាលរាជធានីភ្នំពេញ | | ចំនួនព្រឹត្តិការណ៍អភិវឌ្ឍន៍សមត្ថភាពត្រូវបានរៀបចំ និងចំនួនអ្នកចូលរួមក្នុងព្រឹត្តិការណ៍ | PPCA, DoIH, DoE | | | |
| **សំណល់អេឡិចត្រូនិច** | | | | | | |
| **សកម្មភាពទី4.7៖ ដោះស្រាយបញ្ហាការបោះចោលសំណល់ខុសច្បាប់ រៀបចំការអនុវត្តគ្រប់គ្រងសំណល់អេឡិចត្រូនិច នឹងបង្វែរសំណល់អេឡិចត្រូនិចទៅជាធនធានដែលអាចដោះដូរបាន** | | | | | | |
| a. អភិវឌ្ឍ និងធ្វើបច្ចុប្បន្នភាពលើមូលដ្ឋានទិន្នន័យលើអ្នកកែច្នៃសំណល់ | | មូលដ្ឋានទិន្នន័យបានបង្កើត<br>ទំហំ និងភាពញឹកញាប់នៃការធ្វើបច្ចុប្បន្នភាព | PPCA គាំទ្រដោយ DoE, ខណ្ឌ/ សង្កាត់ | | | |
| b. រៀបចំបង្កើតបញ្ជីសារពើភ័ណ្ឌសំណល់អេឡិចត្រូនិក | | មូលដ្ឋានទិន្នន័យបានបង្កើត<br>ទំហំ និងភាពញឹកញាប់នៃការធ្វើបច្ចុប្បន្នភាព | PPCA គាំទ្រដោយ DoE, ខណ្ឌ/ សង្កាត់ | | | |
| c. ចែកចាយគោលការណ៍ណែនាំរបស់ក្រសួងបរិស្ថាន ស្តីពីការគ្រប់គ្រងសំណល់បរិក្ខារអគ្គិសនី និងអេឡិចត្រូនិក | | ចំនួនគោលការណ៍ណែនាំដែលបានចែកចាយ / ទទួលបាន | PPCA គាំទ្រដោយ DoE, ខណ្ឌ/ សង្កាត់ | | | |
| d. បង្កើនការយល់ដឹង | | ចំនួននៃព្រឹត្តិការណ៍លើកកម្ពស់ការយល់ដឹងបានរៀបចំ និងចំនួនអ្នកចូលរួមក្នុងព្រឹត្តិការណ៍ | PPCA<br>គាំទ្រដោយ DoE, ខណ្ឌ/ សង្កាត់ និងDoEYS | | | |
| e. អភិវឌ្ឍច្បាប់ថ្នាក់ក្រោមជាតិ | | បទបញ្ញាថ្នាក់ក្រោមជាតិត្រូវបានអភិវឌ្ឍន៍ | PPCA គាំទ្រដោយ DoE | | | |
| f. អភិវឌ្ឍ និងចែកចាយបញ្ជីអ្នកកែច្នៃសំណល់ដែលមានការទទួលស្គាល់ | | បញ្ជីឈ្មោះអ្នកកែច្នៃដែលបានបង្កើត និងផ្សព្វផ្សាយបរិមាណសំណល់ដែលបានទទួល | PPCA គាំទ្រដោយ ខណ្ឌ/ សង្កាត់ ក្រុមហ៊ុនបង្កើតសំណល់ | | | |
| g. រៀបចំយុទ្ធនាការប្រមូលសំណល់បរិក្ខារអគ្គិសនី និងអេឡិចត្រូនិក | | ចំនួនយុទ្ធនាការដែលបានរៀបចំ<br>ចំនួនអ្នកចូលរួមក្នុងយុទ្ធនាការ | PPCA គាំទ្រដោយ ខណ្ឌ/ សង្កាត់ សហការជាមួយក្រុមហ៊ុននានា | | | |
| h. ពង្រឹងការត្រួតពិនិត្យ/អធិការកិច្ចប្រឆាំងនឹងការចាក់ចោលសំណល់ខុសច្បាប់ | | ការត្រួតពិនិត្យបានធ្វើឡើង ហើយលទ្ធផលត្រូវបានកត់ត្រា និងបោះផ្សាយ<br>ចំនួនរបាយការណ៍ខុសប្រក្រតីត្រូវបានកត់ត្រាទុក | PPCA<br>គាំទ្រដោយ DoE, ខណ្ឌ/ សង្កាត់ | | | |
| សកម្មភាពចម្បងទី5៖ ការចែករំលែកចក្ខុវិស័យ និងការចូលរួមរបស់ភាគីពាក់ព័ន្ធ ក្នុងសកម្មភាពគ្រប់គ្រងសំណល់ | | | | | | |
| **សកម្មភាពទី5.1៖ ជម្រុញការចូលរួមរបស់ប្រជាពលរដ្ឋក្នុងផែនការគ្រប់គ្រងសំណល់** | | | | | | |
| a. លើកស្ទួយការបង្ហាញព័ត៌មាន | បោះពុម្ពឯកសាររដ្ឋបាលអនឡាញ | ចំនួនឯកសារគ្រប់គ្រងសំណល់ដែលបានបោះពុម្ពផ្សាយ ឬអាចរកបាននៅលើអ៊ីនធឺណិត លទ្ធភាពទទួលបាន/ ការផ្តល់ឯកសារបែបនេះដល់សាធារណជនទូទៅ | PPCA<br>គាំទ្រដោយ DoEYS, DoE, DoT | | | |

| | | | | | | |
|---|---|---|---|---|---|---|
| | ចែករំលែកកាលវិភាគប្រមូល ការចេញបទបញ្ញត្តិផ្សេងៗតាមរយៈអនឡាញ | មានយន្តការមតិយោបល់ដែលបានរៀបចំ | | | | |
| b. កសាងយន្តការផ្តល់យោបល់ | រៀបចំវេទិកាសាធារណៈ | ចំនួនវេទិកាសាធារណៈបានរៀបចំ | | | | |
| | សន្និសីទ ស្តីពីការគ្រប់គ្រងសំរាម សំណល់រឹងទីក្រុង | ចំនួនព្រឹត្តិការណ៍ដែលបានរៀបចំ | | | | |
| | ជ្រើសរើស ចាត់តាំង និងចាត់តាំងតំណាងប្រជាពលរដ្ឋឱ្យរៀបចំផែនការ | ចំនួនតំណាងរបស់ប្រជាពលរដ្ឋដែលមាននៅក្នុងផែនការ | | | | |
| | ប្រើប្រាស់បច្ចេកវិទ្យាគមនាគមន៍ ព័ត៌មានវិទ្យា ដូចជា SNS ដើម្បីប្រមូលមតិយោបល់ | ការប្រើប្រាស់ ICTs/SNS | | | | |
| **សកម្មភាពទី5.2៖ ការចូលរួមរបស់យុវជនតាមរយៈការអប់រំបរិស្ថាន** | | | | | | |
| a. សហការអភិវឌ្ឍន៍កម្មវិធីសិក្សា សម្រាប់ការអប់រំបរិស្ថាន | | កម្មវិធីសិក្សារបស់សាលារៀន ដែលត្រូវអភិវឌ្ឍន៍ | PPCA, MoE, MoEYS, DoE, DoEYS | | | |
| b. អភិវឌ្ឍន៍សម្ភារអប់រំសម្រាប់បង្រៀន | | សម្ភារអប់រំត្រូវបានបង្កើត | | | | |
| c. អភិវឌ្ឍន៍គោលការណែនាំ ស្តីពីវិធីសាស្ត្របង្រៀន | | បង្កើតគោលការណ៍ណែនាំស្តីពីវិធីសាស្ត្របង្រៀន | | | | |
| d. ផ្តល់រង្វាន់ដល់ទីក្រុងមានបរិស្ថានស្អាត | | ចំនួនសាលារៀនបានចូលរួមក្នុងកម្មវិធីពានរង្វាន់បរិស្ថានក្រុង | | | | |
| e. ផ្តល់ឱកាសចុះសិក្សាតាមមូលដ្ឋានដល់សិស្ស | | ចំនួនកម្មវិធីរៀនសូត្រតាមទីតាំងជាក់ស្តែង ដែលបានបង្កើត និងឱកាសផ្តល់ដល់សិស្សវិទ្យាល័យ | | | | |
| f. ដាក់តាំងសញ្ញា និងបិទតាមទីតាំងនានាក្នុងសាលារៀន | | ចំនួនផ្ទាំងប៉ាណូ ផ្លាក និងសញ្ញា | | | | |
| **សកម្មភាពទី5.3៖ ចូលរួម និងអភិវឌ្ឍសមត្ថភាពសាធារណៈទូទៅ វិស័យសាធារណៈ/ ឯកជន** | | | | | | |
| a. ព្រឹត្តិការបង្កើនការយល់ដឹង ផ្តោតទៅលើប្រជាពលរដ្ឋ | ពិព័រណ៍បរិស្ថាន | ចំនួនព្រឹត្តិការណ៍ ដែលបានរៀបចំ | PPCA, ភាគីពាក់ព័ន្ធ | | | |
| | យុទ្ធនាការអប់រំ ស្តីពីការកែច្នៃ និងផលប៉ះពាល់ | ចំនួនសកម្មភាព ដែលបានរៀបចំ | PPCA, ភាគីពាក់ព័ន្ធ | | | |
| | សម្ភារអប់រំសម្រាប់បង្កើនការយល់ដឹង | ចំនួនសម្ភារផ្សព្វផ្សាយការយល់ដឹង ដែលបានផ្សព្វផ្សាយដល់សាធារណជន | PPCA | | | |
| | ការបង្កើនការយល់ដឹងតាមរយៈបណ្តាញព័ត៌មានសង្គម | ចំនួនទស្សនិកជន ដែលបានទទួលព័ត៌មានតាមរយៈប្រព័ន្ធផ្សព្វផ្សាយ | PPCA, មន្ទីរពាក់ព័ន្ធ ប្រព័ន្ធផ្សព្វផ្សាយសហការ (ទូរទស្សន៍ ស្ថានីយវិទ្យុ សារព័ត៌មាន ... ។ល។ ) | | | |

| | | | | | | |
|---|---|---|---|---|---|---|
| | បណ្តុះបណ្តាលបុគ្គលិក មន្ត្រីរាជការ | ការរួមបញ្ចូលផ្នែកបរិស្ថាន (រួមទាំងការគ្រប់គ្រងសំណល់) ទៅកម្មវិធីសិក្សា | PPCA | | | |
| | ជម្រុញការចូលរួម និងបង្កើនការយល់ដឹងរបស់ក្រុមហ៊ុនប្រមូលសំណល់ | ចំនួនសកម្មភាពដែលបានរៀបចំ | PPCA, CINTRI | | | |
| b. ចូលរួម និងអភិវឌ្ឍសមត្ថភាពសាធារណៈទូទៅ វិស័យសាធារណៈ/ ឯកជន | ធ្វើទំនាក់ទំនងផលប្រយោជន៍ដែលទទួលបានពីការកែលម្អការគ្រប់គ្រងសំណល់ និងការគ្រប់គ្រងធនធាន | ចំនួនគ្រឹះស្ថានឯកជនត្រូវបានទាក់ទង/ ទំនាក់ទំនង | PPCA, វិស័យឧស្សាហកម្មផ្សេងៗ (ឧទា. សណ្ឋាគារ រោងចក្រវាយនភ័ណ្ឌ។ល។) | | | |
| | ពានរង្វាន់អាជីវកម្មស្អាត | ចំនួនក្រុមហ៊ុនបានចូលរួមក្នុងកម្មវិធីប្រគល់ពានរង្វាន់ | PPCA, វិស័យឧស្សាហកម្មផ្សេងៗ (ឧទា. សណ្ឋាគារ រោងចក្រវាយនភ័ណ្ឌ។ល។) | | | |
| | សេចក្តីណែនាំអំពីការកាត់បន្ថយពន្ធសម្រាប់ការគ្រប់គ្រងអាជីវកម្មប្រកបដោយនិរន្តភាព | គ្រោងការណ៍កាត់បន្ថយពន្ធ ដែលបានណែនាំ | PPCA, ក្រសួងពាក់ព័ន្ធ និងមន្ទីរ | | | |
| | ជម្រុញចលនាអាជីវកម្មកែច្នៃសំណល់ | ចំនួនក្រុម ស្ថាប័ន អាជីវករចូលរួមអាជីវកម្មកែច្នៃ | PPCA, ភាគីពាក់ព័ន្ធ | | | |

# ជំពូកទី ៥

# ការគ្រប់គ្រងវដ្តនៃ
# គម្រោង ទិន្នន័យ និង
# ហិរញ្ញវត្ថុ

Chapter V

# ការគ្រប់គ្រងវដ្តនៃគម្រោង ទិន្នន័យ និងហិរញ្ញវត្ថុ

## ១. ការគ្រប់គ្រងវដ្តនៃគម្រោង ទិន្នន័យ និងហិរញ្ញវត្ថុ - ធានាការអនុវត្តន៍ និងគុណភាពសេវាកម្ម

ការធានាធនធានហិរញ្ញវត្ថុគ្រប់គ្រាន់ ការអភិវឌ្ឍ/ ការសម្របខ្លួន/ ការផ្សព្វផ្សាយបច្ចេកវិទ្យាសមស្រប ការបង្កើតភាពជាដៃគូ និងការកសាងសមត្ថភាពរបស់ភាគីពាក់ព័ន្ធ ព្រមទាំងការបង្កើតប្រព័ន្ធសមស្របសម្រាប់ការតាមដានទិន្នន័យ និងក្របខណ្ឌគណនេយ្យភាពសុទ្ធតែមានសារសំខាន់ ដើម្បីធានាការអនុវត្តន៍ និងគុណភាពសេវារបស់យុទ្ធសាស្ត្រ និងផែនការសកម្មភាព។ រដ្ឋបាលរាជធានីភ្នំពេញនឹងខិតខំឱ្យអស់លទ្ធភាពដើម្បីធានាថា មធ្យោបាយអនុវត្តទាំងអស់នេះនឹងត្រូវធានាបានសម្រាប់និរន្តរភាពនៃសេវាសាធារណៈរបស់ខ្លួន។




រូបភាពទី៣០៖ មធ្យោបាយនៃការអនុវត្តន៍

## ២. ដំណើរការគ្រប់គ្រងដោយផ្អែកលើវដ្ត PDCA

យុទ្ធសាស្ត្រគ្រប់គ្រងសំណល់ ព្រមទាំងសម្មភាពគម្រោងនឹងត្រូវអនុវត្ត តាមដាន វាយតម្លៃ ពិនិត្យឡើងវិញ និងធ្វើបច្ចុប្បន្នភាពដោយអនុវត្តទៅតាមវដ្ត PDCA (រៀបចំផែនការ អនុវត្ត ត្រួតពិនិត្យ និងធ្វើសកម្មភាព) ដូចដែលបានបង្ហាញខាងក្រោម។

* <u>**ដំណាក់កាលទី១៖ រៀបចំផែនការ – ការរៀបចំ និងការរៀបចំពង្រាងយុទ្ធសាស្ត្រ**</u>

- ធ្វើការសិក្សាព័ត៌មានមូលដ្ឋាន និងប្រើប្រាស់ចំណេះដឹងផ្នែកគ្រប់គ្រង និងបែបវិទ្យាសាស្ត្រថ្មីចុងក្រោយ ដើម្បីធ្វើជាមូលដ្ឋាននៃការពិភាក្សាសម្រាប់ការបង្កើតយុទ្ធសាស្ត្រ
- ស្វែងយល់អំពីស្ថានភាព បញ្ហាប្រឈម និងការធ្វើការវិភាគចន្លោះខ្វះខាត
- កំណត់វិសាលភាព ចក្ខុវិស័យ បេសកកម្ម និងគោលដៅនៃយុទ្ធសាស្ត្រ
- កំណត់ និងរាប់បញ្ចូលគ្រប់ភាគីពាក់ព័ន្ធ និងបញ្ហាប្រឈមផ្សេងៗក្នុងការគ្រប់គ្រងតាមរយៈការពិគ្រោះយោបល់ជា

មួយភាគីពាក់ព័ន្ធ

- ជ្រើសរើសជម្រើសគោលនយោបាយ ស្ដីពីការទប់ស្កាត់ និងការកែច្នៃសំណល់ និងរៀបចំពង្រាងផែនការសកម្មភាព
- ធានាការសម្របសម្រួលអន្តរស្ថាប័ន និងជំរុញរៀបចំកិច្ចព្រមព្រៀងនយោបាយសម្រាប់ការបង្កើតយុទ្ធសាស្ត្រ

* **ដំណាក់កាលទី ២៖ អនុវត្ត – ការអនុវត្តន៍ និងការតាមដានយុទ្ធសាស្ត្រ**

- រៀបចំជាលក្ខណៈផ្លូវការនូវយុទ្ធសាស្ត្រតាមរយៈនីតិវិធីរដ្ឋបាលសមស្រប
- ផ្សព្វផ្សាយយុទ្ធសាស្ត្រតាមរយៈសកម្មភាពសង្គមជាសាធារណៈផ្សេងៗ
- កៀរគរធនធាន (ហិរញ្ញវត្ថុ ធនធានមនុស្ស និងនយោបាយ) និងពង្រីកកិច្ចសហការជាមួយភាគីពាក់ព័ន្ធឆ្ពោះទៅការអនុវត្តន៍ផែនការសកម្មភាព
- អនុវត្តការងារតាមដានឱ្យបានទៀងទាត់ ដើម្បីទទួលស្គាល់វឌ្ឍនភាព និងរក្សាកំណត់ត្រាវឌ្ឍនភាព និង/ឬសូចនាករសមិទ្ធកម្មសំខាន់ៗសម្រាប់ធ្វើការវាយតម្លៃនាពេលអនាគត។

* **ដំណាក់កាលទី ៣៖ ត្រួតពិនិត្យ – ការវាយតម្លៃ និងត្រួតពិនិត្យយុទ្ធសាស្ត្រ**

- វិភាគ និងវាយតម្លៃវឌ្ឍនភាព/លទ្ធផលគម្រោងធៀបនឹងគោលបំណង និងគោលដៅ
- ពិនិត្យមើលវឌ្ឍនភាពជាមួយភាគីពាក់ព័ន្ធ និងដាក់ជូនគណៈកម្មាធិការវាយតម្លៃឯករាជ្យ
- កំណត់ និងវិភាគផ្នែកជោគជ័យ និងបរាជ័យ រួចកំណត់កត្តារួមចំណែក

* **ដំណាក់កាលទី ៤៖ សកម្មភាព – ធ្វើបច្ចុប្បន្នភាពយុទ្ធសាស្ត្រដោយផ្អែកលើការវាយតម្លៃ**

- ពង្រីកករណីជោគជ័យ
- វាយតម្លៃឡើងវិញនូវការវិវត្តនៃបរិស្ថានប្រតិបត្តិការ និងធ្វើការកែសម្រួល/កំណត់យុទ្ធសាស្ត្រឡើងវិញដើម្បីដោះស្រាយបញ្ហាប្រឈមដែលកើតឡើង




**រូបភាពទី៣១៖ វដ្ត PDCA**

## ៣. ដំណើរការបង្កើតទិន្នន័យ ដើម្បីសម្រួលដល់ការសម្រេចចិត្ត និងគ្រប់គ្រងគម្រោងបានល្អ

ដើម្បីលើកកម្ពស់ការសម្រេចចិត្តលើគោលនយោបាយ ដោយផ្អែកលើភស្តុតាងច្បាស់លាស់ក្នុងការគ្រប់គ្រងសំណល់ក្នុងទីប្រជុំជន និងគ្រប់គ្រងគុណភាពការផ្តល់សេវា សាលារាជធានីភ្នំពេញ ត្រូវពង្រឹងកិច្ចខិតខំប្រឹងប្រែង និងបង្កើនសមត្ថភាពរបស់ខ្លួននៅក្នុងការបង្កើត និងរក្សាសូចនាករសំខាន់ៗជាមូលដ្ឋានដែលបង្ហាញអំពីស្ថានភាពគ្រប់គ្រងសំណល់នៅក្នុងទីក្រុង។

នៅចុងបញ្ចប់ រដ្ឋបាលរាជធានីភ្នំពេញនឹង៖

- រក្សាកំណត់ត្រាត្រឹមត្រូវនៃសំរាម ដែលបានយកមកចោលនៅទីលានចាក់សំរាម ជាពិសេសបរិមាណសំរាម ប៉ុន្តែបន្តិចម្តងៗពង្រីករហូតដល់ការកត់ត្រា ជាប្រភេទសំរាម ប្រភព និង/ឬតំបន់បង្កើត/ប្រមូល
- ប្រើប្រាស់ទិន្នន័យដែលបានប្រមូល ដើម្បីរៀបចំផែនការ អនុវត្ត តាមដាន និងវាយតម្លៃលើយុទ្ធសាស្ត្រ ព្រមទាំងការធ្វើសេចក្តីសម្រេចចិត្តដែលពាក់ព័ន្ធផងដែរ
- ប្រើប្រាស់ឱកាសកសាងសមត្ថភាព ដែលទទួលបានពីខាងក្រៅដល់បុគ្គលិកទទួលខុសត្រូវលើការគ្រប់គ្រងទិន្នន័យ
- បង្កើតបណ្តាញគាំទ្រតាមរយៈភាពជាដៃគូជាមួយអង្គការមិនមែនរដ្ឋាភិបាល វិស័យឯកជន រដ្ឋបាលខណ្ឌ/ សង្កាត់ ដើម្បីស្នើឱ្យអង្គភាពទាំងនោះចូលរួមនៅក្នុងការប្រមូលទិន្នន័យ។

**<u>ប្រភពព័ត៌មានដែលមានប្រយោជន៍៖</u>**

- Data Collection Tool for Urban Solid Waste Management (World Bank) http://siteresources.worldbank.org/INTUSWM/Resources/463617-1202332338898/User-Manual-Data-Collection-Tool-for-SWM.pdf
- 3R Policy Indicators Factsheets Series (IGES) https://pub.iges.or.jp/pub/by/tags/3r-policy-indicators-factsheets-series

## ៤. ការធានាធនធានមនុស្សសម្រាប់ការផ្តល់សេវាប្រកបដោយចីរភាព

ដើម្បីបំពេញតម្រូវការសេវាសាធារណៈរបស់ប្រជាពលរដ្ឋ រដ្ឋបាលរាជធានីភ្នំពេញត្រូវខិតខំប្រឹងប្រែងឱ្យអស់ពីលទ្ធភាពដើម្បីធានាធនធានមនុស្សប្រតិបត្តិដែលត្រូវការចាំបាច់ ធានានិរន្តរភាព និងលើកកម្ពស់ការផ្តល់សេវា។

នៅចុងបញ្ចប់ រដ្ឋបាលរាជធានីភ្នំពេញនឹង៖

- ជម្រុញកិច្ចខិតខំប្រឹងប្រែងក្នុងការកំណត់ និងបង្កើតធនធានហិរញ្ញវត្ថុ ដើម្បីទ្រទ្រង់អភិបាលកិច្ចគ្រប់គ្រងសំណល់
- ស្វែងរកឱកាសសម្រាប់ភាពជាដៃគូរវាងវិស័យសាធារណៈ និងឯកជន ដើម្បីទទួលបាននូវការផ្តល់សេវាប្រកបដោយលក្ខណៈសេដ្ឋកិច្ច និងប្រសិទ្ធភាពដែលអាចធ្វើបាន
- បង្កើនកិច្ចសហការរបស់ខ្លួនជាមួយស្ថាប័នខាងក្រៅ (ស្ថាប័នជាតិ ដៃគូអភិវឌ្ឍន៍ និងវិស័យឯកជន) ដើម្បីទាក់ទាញគម្រោង និងថវិកាអភិវឌ្ឍន៍
- ជ្រើសរើសមន្ត្រីរដ្ឋបាលរាជធានីភ្នំពេញ ដែលសមស្រប ដើម្បីធានានូវសេវាសាធារណៈប្រកបដោយគុណភាព។

ធ្វើសកម្មភាពអភិវឌ្ឍន៍សមត្ថភាពដោយខ្លួនឯង និង/ឬ ប្រើប្រាស់ឱកាសពីខាងក្រៅ (នៅពេលដែលមាន) ដើម្បីពង្រឹងការរៀបចំផែនការ និងសមត្ថភាពប្រតិបត្តិការដែលចាំបាច់លើកិច្ចការរដ្ឋបាលគ្រប់គ្រងសំណល់។ ចំណុចសំខាន់ៗសម្រាប់ការអភិវឌ្ឍសមត្ថភាពអាចរួមមាន៖ ការគ្រប់គ្រងទិន្នន័យ ការគ្រប់គ្រងទំនាក់ទំនងសាធារណៈ និងព័ត៌មានវិទ្យា ការគ្រប់គ្រង និងបច្ចេកវិទ្យាកែច្នៃសំណល់ ការវិភាគសេដ្ឋកិច្ច ការរៀបចំគោលនយោបាយគ្រប់គ្រងសំណល់-កែច្នៃធនធានវត្ថុធាតុដើមឡើងវិញ និងការគ្រប់គ្រងរដ្ឋបាលសាធារណៈ។

VI

# ជំពូកទី ៦

# ឧបសម្ព័ន្ធ

Chapter VI | ឧបសម្ព័ន្ធ

## ឧបសម្ព័ន្ធទី១. ឯកសារយោង


- Choeu, C. (2016). Basic Information of Medical Waste Management Unit 24-April-2016.
- City of Kitakyushu and Phnom Penh Capital City (2017). Phnom Penh Capital City Strategic Action Plan for Climate Change.
- Department of Hospital Services. (2006). National Assessment on Health Care Waste Management in Cambodia: Current Situation.
- Ekins, P., Hughes, N., Brigenzu, S., Arden Clark, C., Fischer-Kowalski, M., Graedel, T., ... & Hertwich, E. (2016). Resource Efficiency: Potential and Economic Implications.
- Hoklis, Chhay and Alice Sharp (2014). Greenhouse gas emission from municipal solid waste in Phnom Penh, Cambodia, GMSARN International Journal, Vol. 8, No. 3, September 2014, pp. 73-78
- Hul, S., Kuok, F., Soy, T., & Khoeurn, K. (2015). Solid waste generation and life-span with credible growth forecasts waste generation, volume and composition (p. 41). Phnom Penh.
- JICA and MPP. (2005). Study on Solid Waste Management in the Municipality of Phnom Penh in the Kingdom of Cambodia; Main Report.
- Leng, V. (2013). Decentralised and deconcentralised sub-national administration management in Cambodia (p. 92).
- Min, M. (2016). Survey Report on Waste Management Practices At Municipality/District Level.
- Ministry of Environment Cambodia. Declaration on collecting and transporting industrial solid waste in Phnom Penh, Pub. L. No. 148 (2002).
- Ministry of Environment Cambodia. (2009a). Baseline: WEEE / e-waste in Phnom Penh municipality and current management system.
- Ministry of Environment Cambodia. (2014). Solid waste Management in Cambodia.Delivered at Regional Workshop on Development of National and Strategy for Radioactive Waste Management, 24-28 March 2014, IAEA, Vienna, Austria.
- 
- https://gnssn.iaea.org/RTWS/general/Shared%20Documents/Waste%20Management/March%202014%20RAS9069%20WS%20on%20policy%20and%20strategy%20development/national%20presentations/Cambodia.pdf (Accessed 9 May 2018).
- Ministry of Health. Declaration No. 19 on Waste Management from Health Care Service in the Kingdom of Cambodia (2008).
- MOE. (2014). Medical waste for dioxin.
- MOE Cambodia’s Technical Working Group. (2013). Comprehensive Assessment on E-waste Management in Cambodia.
- MPP. (2011). 3 Years Rolling Investment Programme in Phnom Penh Municipality.
- National Biodigester Programme. (2011). *Tehnical and Benefit of Biogas Plant*. Presented at Training Course and Technology Transfer on Renovation Waste and Reuse the Renewalbe Energy Resources, June 2011.
- National Council for Sustainable Development, Ministry of Environment, Global Green Growth Institute. (2017). Phnom Penh Green City Strategic Plan 2017-2026 And List of Priority Green City Investment

Projects for Phnom Penh.

- Phnom Penh Capital Hall. (n.d.). Facts of Phnom Penh Capital Hall.
- Phnom Penh Capital Hall - Urbanisation Division. (2011). Overview of Urban Development in Phnom Penh Capital City.
- Phnom Penh Department of Planning. (2015). Data Documentation on Phnom Penh Municipality Situation in 2015.
- Phnom Penh Landfill Authority. (2016). Weigh bridge data at old and new landfills.
- Project Coordination Unit. (2014). Inventory report on unintentionally produced POPs in Cambodia.
- Royal Government of Cambodia. Law on administration and management of the capital, province, municipality, district, ខណ្ឌ (2008).
- Royal Government of Cambodia. Sub-Decree on Garbage and Urban Solid Waste Management, Pub. L. No. 113 (2015).
- Sang-Arun, J., Heng, C. K., & Al., E. (2011). A guide for Technology Selection and Implementation of Urban Organic Waste Utilisation Projects in Cambodia.
- Save Cambodia's Wildlife., & Open Development Cambodia. (2014). Atlas of Cambodia – Maps on Socio-economic Development and Environment.
- Sethy, S. (2017). Country Chapter – The Kingdom of Cambodia. in The Drafting Committee of the State of the 3Rs ion Asia and the Pacific, *State of the 3Rs in Asia and the Pacific.* (Retrieved on July 26 2018 from www.uncrd.or.jp/content/documents/5686[Nov%202017]%20Cambodia.pdf)
- Seng, B. (2014). Working task in cleansing, collection and transport in Daun Penh district, Phnom Penh.
- Seng, B., Kaneko, H., Hirayama, K., & Katayama-Hirayama, K. (2011). Municipal solid waste management in Phnom Penh, capital city of Cambodia. Waste Management & Research : The Journal of the International Solid Wastes and Public Cleansing Association, ISWA, 29(5), 491–500. http://doi.org/10.1177/0734242X10380994
- Seng, K. (2015). Analysis of solid waste composition and waste forecasting in Phnom Penh with the production of methane from Dangkor landfill, Cambodia. Institute of Technology of Cambodia.
- The Asia Foundation and the Overseas Development Institute. (2016). Working Politically in Practice Series - Case Study No. 8 - Reforming Solid Waste Management in Phnom Penh. https://asiafoundation.org/publication/reforming-solid-waste-management-phnom-penh/
- The Drafting Committee of the State of the 3Rs in Asia and the Pacific. (2018). The State of the 3Rs in Asia and the Pacific.
- Theng, C.S. (2012), Administrative Law and Decentralization. In Peng, H., Phallack, K., and Menzel, J. (Eds.), Introduction to Cambodian Law (247-264). Phnom Penh: Konrad-Adenauer-Stiftung, Cambodia.
- Uch, R., Sam, P., Stäudel, J., & Hädrich, G. (2014). Report for a study research on Improving Waste Management in Phnom Penh taking into account Study & Analysis on "Institutional framework of solid waste management and the development of the current landfill operation and management in Phnom Penh ." UNEP. (2009). Developing Integrated Solid Waste Management Plan: Training Manual, 1, 1–77.

## ឧបសម្ព័ន្ធទី២. ផែនការគម្រោងសាកល្បង

### គម្រោងសាកល្បងទី១

កម្មវិធីជំរុញការចូលរួមកែច្នៃឡើងវិញនៅក្នុងសាលារៀននៅរាជធានីភ្នំពេញ (PPAP)

គឺជាគម្រោងសាកល្បង ដើម្បីលើកកម្ពស់ការផ្លាស់ប្តូរឥរិយាបថ ឆ្ពោះទៅរករបៀបរស់នៅប្រកបដោយចីរភាពបរិស្ថានតាមរយៈការណែនាំអំពីមេរៀនជាទ្រឹស្តី និងបទពិសោធន៍ផ្សារភ្ជាប់ដោយការអនុវត្តន៍ផ្ទាល់លើវិស័យអប់រំបរិស្ថាន។

### ការពិពណ៌នា

គំនិតនៃគម្រោងបង្កើនការយល់ដឹង ភាគច្រើនត្រូវបានអនុវត្តឡើងតាមការសន្មតថា សាធារណជននឹងចាប់ផ្តើមអនុវត្តការកែច្នៃឡើងវិញ ប្រសិនបើពួកគេទទួលបានព័ត៌មានគ្រប់គ្រាន់អំពីតម្លៃនៃសុខភាព/បរិស្ថាន ផលប្រយោជន៍/ ការចំណាយ និងសម្ភារអប់រំផ្សេងៗ ដូចជា សៀវភៅណែនាំអំពីគំនិតច្នៃប្រឌិតធ្វើអ្វីមួយជាដើមទៅដល់ក្រុមគោលដៅ។ ទោះជាយ៉ាងណាសកម្មភាពស្ម័គ្រចិត្ត អាចពិបាកនឹងជំរុញឱ្យកើតឡើង ប្រសិនបើពួកគាត់គ្មានឱកាស (ឧទា. ការកែច្នៃឡើងវិញ) ដើម្បីអនុវត្តចំណេះដឹងបែបនេះ ឬមិនបានទទួលផលប្រយោជន៍ជាក់ស្តែងនៃសកម្មភាពនោះ។




អាស្រ័យហេតុនេះ ទើបគម្រោងសាកល្បងនេះផ្តោតទៅលើការអប់រំបរិស្ថានដែលបច្ចុប្បន្នអនុវត្តនៅតាមសាលារៀននានានៅក្នុងរាជធានីភ្នំពេញ និងណែនាំបទពិសោធន៍អនុវត្តន៍ជាក់ស្តែង ដើម្បីចូលរួមក្នុងសកម្មភាពអនុវត្ត ៣អ៊ែរ (3R) ដែលបំពេញបន្ថែមលើការបង្រៀនក្នុងថ្នាក់។ តាមរយៈការផ្តល់នូវឱកាស ដើម្បីបង្ហាញពីអត្ថប្រយោជន៍នៃ ៣អ៊ែរ គម្រោងនេះមានគោលបំណងលើកកម្ពស់ការយល់ដឹង និងការលើកទឹកចិត្ត ដើម្បីអនុវត្ត ៣អ៊ែរ នៅក្នុងជីវិតប្រចាំថ្ងៃរបស់សិស្សានុសិស្ស ដែលជំរុញឱ្យមានការផ្លាស់ប្តូរឥរិយាបថបាន។




ជាពិសេស សិស្សានុសិស្សនឹងត្រូវបានស្នើសុំឱ្យនាំយកសម្ភារ ដែលអាចកែច្នៃឡើងវិញពីគ្រួសារនីមួយៗរបស់ពួកគេទៅសាលារៀនជាផ្នែកនៃលំហាត់អនុវត្តន៍។ សំណល់អេតចាយ ដែលប្រមូលបាននឹងត្រូវរក្សាទុកក្នុងបរិវេណសាលារហូតគេអាចលក់ឱ្យអ្នកទិញសំណល់អេតចាយ ដេប៉ូអេតចាយ ឬក្រុមហ៊ុនកែច្នៃសំណល់អេតចាយ ហើយប្រាក់ចំណូលដែលទទួលបាននឹងត្រូវបានប្រើ ដើម្បីទិញឧបករណ៍សម្ភារអប់រំសម្រាប់សាលារៀនរបស់ពួកគេ។ ការអនុវត្តន៍បែបនេះ ក៏អាចបង្កើតជាមូលដ្ឋានគ្រឹះនៃការអប់រំលើការធ្វើសេចក្តីសម្រេចរួមគ្នា និងការគ្រប់គ្រងហិរញ្ញវត្ថុដែលជាតម្រូវការចាំបាច់។ លើសពីនេះទៀត ការរៀបចំប្រកួតប្រជែងនៅទូទាំងក្រុងកិច្ចសន្ទនារបស់សិស្សតាមប្រព័ន្ធអ៊ីនធឺណិតរវាង ប្រទេសកម្ពុជា និងជប៉ុន ដែលសម្របសម្រួលដោយអង្គការ CITYNET ទីក្រុង Yokohama និងវិទ្យាស្ថាន CCET ក៏អាចចាត់ទុកថា ជាវិធានការជំរុញសិស្សឱ្យចូលរួមកម្មវិធីនេះផងដែរ។

### សហការ និងអនុវត្តគម្រោង

- រដ្ឋបាលរាជធានីភ្នំពេញ (PPCA)
- មន្ទីរអប់រំ យុវជន និងកីឡា (DoEYS)
- សាលារៀនបឋមសិក្សាដែលបានជ្រើសរើសនៅក្នុងរាជធានីភ្នំពេញ
- វិទ្យាស្ថាន IGES សហការជាមួយ UNEP ស្តីពីបច្ចេកវិទ្យាបរិស្ថាន (CCET)
- អង្គការកែច្នៃសំរាម និងការសិក្សានៅកម្ពុជា (COMPED)

## លទ្ធផលរំពឹងទុក និងការរួមចំណែកដល់យុទ្ធសាស្ត្រនេះ

នៅពេលដែលអនុវត្តគម្រោងសាកល្បងនេះ សិស្សានុសិស្សនឹងទទួលបាននូវការយល់ដឹងកាន់តែប្រសើរឡើងលើអត្ថប្រយោជន៍នៃការអនុវត្តន៍ ៣R ដោយផ្អែកលើបទពិសោធន៍ក្នុងការរស់នៅជាក់ស្តែងរបស់ពួកគេ និងអាចមានបំណងចង់អនុវត្ត ៣R ដោយផ្ទាល់នៅក្នុងជីវិតប្រចាំថ្ងៃ។ ការបង្ហាញពី "វិធី/របៀប" និង "អត្ថប្រយោជន៍ជាក់ស្តែង" នឹងជួយកាត់បន្ថយគម្លាតរវាងចំណេះដឹង និងការផ្លាស់ប្តូរឥរិយាបថរបស់បុគ្គល ដែលជាទំពាំងតំណាងឱ្យគ្រឹះស្ថលក្នុងការផ្សព្វផ្សាយជំរុញការអនុវត្តន៍ ៣R នៅក្នុងរាជធានីភ្នំពេញ ដោយសហការជាមួយប្រជាពលរដ្ឋ និងសហគមន៍។ កម្មវិធីនេះ មានការពាក់ព័ន្ធដោយផ្ទាល់ទៅនឹងសកម្មភាពចម្បងទី១, ២ និងទី៥ ជាពិសេសសកម្មភាពទី៥.២ - ការជំរុញយុវជនចូលរួមតាមរយៈការអប់រំបរិស្ថាន "។

## ថវិការំពឹកទុក

ប្រហែល ៣០.០០០ ដុល្លាអាមេរិក

## អ្នកឧបត្ថម្ភ

អង្គការ UN Environment តាមរយៈវិទ្យាស្ថាន IGES សហការលើបច្ចេកវិទ្យាបរិស្ថាន ហៅកាត់ថា CCET

## រយៈពេលរំពឹងទុក

ប្រហែល៣ខែ

## គម្រោងសាកល្បងទី២
## "សម្អាត! ការគ្រប់គ្រងសំណល់តាមបែបសហគមន៍ នៅក្នុងរាជធានីភ្នំពេញ" ឆ្នាំ២០១៧-២០១៨

## ការពិពណ៌នា៖

"សកម្មភាពនៃគម្រោង "សម្អាត! ការគ្រប់គ្រងសំណល់តាមបែបសហគមន៍ ត្រូវបានអនុវត្តនៅតំបន់បឹងទំពុន ក្នុងឃុំព្រែកតាគង់ទី១ សង្កាត់ចាក់អង្រែលើ ខណ្ឌមានជ័យ និងនៅឃុំខ្វា ខណ្ឌដង្កោ រាជធានីភ្នំពេញ។

## អ្នកអនុវត្តគម្រោង

អង្គការក្រៅរដ្ឋាភិបាលក្នុងស្រុកមួយ គឺUPWD ទទួលខុសត្រូវចំពោះការអនុវត្តន៍សកម្មភាពទាំងអស់នៅក្នុងសហគមន៍គោលដៅ ហើយគម្រោងនេះនឹងក្លាយជាផ្នែកមួយនៃសកម្មភាពអនាម័យបរិស្ថានរបស់ UPWD ដែលបានអនុវត្តនៅក្នុងតំបន់ក្នុងភាពជាដៃគូជាមួយអង្គការ People in Need (PIN)។

អង្គការអភិវឌ្ឍន៍ស្ត្រីក្រីក្រក្នុងទីក្រុង (UPWD) ត្រូវបានបង្កើតឡើងនៅឆ្នាំ១៩៩៧ នៅរាជធានីភ្នំពេញដោយក្រុមអ្នកជំនាញ ដែលបានទទួលស្គាល់ពីសារៈសំខាន់នៃការគាំទ្រដល់ស្ត្រីក្រីក្រនៅតាមទីប្រជុំជន និងសហគមន៍របស់ពួកគេ។ កន្លងមក អង្គការ UPWD បានជួយដល់សហគមន៍ក្រីក្រក្នុងទីក្រុងចំនួន ១០សហគមន៍ តាមរយៈការរៀបចំសហគមន៍ ការចុះស្វាបស្ទង់មតិ ការរៀបចំផែនទី សុខភាពនៅទីប្រជុំជន ទឹកស្អាត និងអនាម័យ ព្រមទាំងគម្រោងកាត់បន្ថយគ្រោះមហន្តរាយ។ ម្ចាស់ជំនួយរបស់អង្គការ UPWD រួមមាន PIN, Misseror, HBF, Asia Foundation និង Bread for the World។ អង្គការ UPWD មានបុគ្គលិកអចិន្ត្រៃយ៍ចំនួន ១៤នាក់ ហើយគ្រប់គ្រងថវិកាប្រចាំឆ្នាំចំនួន ២០០.០០០ ដុល្លារអាមេរិក។

## លទ្ធផលរំពឹងទុក និងការរួមចំណែកដល់យុទ្ធសាស្ត្រនេះ

គម្រោងនេះត្រូវបានជ្រើសរើសពីសំណើគម្រោងចំនួនបួន ដែលគ្របដណ្តប់លើតំបន់នានាដូចជា ការកែច្នៃសំណល់ហាងកាហ្វេគ្មានសំរាម និងការគ្រប់គ្រងសំណល់តាមបែបសហគមន៍។ គម្រោងគ្រប់គ្រងសំណល់តាមបែបសហគមន៍ត្រូវបានជ្រើសរើសជាគម្រោងសាកល្បង ដែលត្រូវបានធ្វើឡើងរវាងអង្គការ Nexus និងរដ្ឋបាលរាជធានីភ្នំពេញ នៅខែកក្កដា ឆ្នាំ២០១៧ ជាកិច្ចឆ្លើយតបចំពោះបញ្ហាប្រមូលសំរាម ដែលមានស្រាប់នៅតំបន់ដែលពិបាកទៅដល់ក្នុងរាជធានីភ្នំពេញ។ សកម្មភាពរបស់គម្រោងបានចាប់ផ្តើមនៅចុងឆ្នាំ២០១៧ ហើយបន្តរហូតដល់ចុងឆ្នាំ២០១៨។

ដោយផ្អែកលើការរៀបចំហិរញ្ញវត្ថុរវាងអង្គការ Nexus និងអង្គការ UPWD គេនឹងរាយការណ៍ទៅរដ្ឋបាលរាជធានីភ្នំពេញនូវទិន្នន័យមូលដ្ឋានរៀងរាល់ ២ឆ្នាំ ម្តងនៅឆ្នាំ២០១៨ ដើម្បីធ្វើបច្ចុប្បន្នភាពលើវឌ្ឍនភាពគម្រោង និងលទ្ធផល។

ការគ្រប់គ្រងសំណល់ គឺជាបញ្ហាធំបំផុតសម្រាប់សហគមក្រីក្រនៅតាមទីក្រុង ដែលខ្វះការប្រមូលសំរាមសាធារណៈ។ យោងទៅតាមការសិក្សារបស់សមាគម STT កាលពីឆ្នាំ២០១៤ មានសហគមន៍ចំនួន ៧២% នៅតាមតំបន់ខាងក្រៅនៃរាជធានីភ្នំពេញ ដែលខ្វះសេវាកម្មប្រមូលសំរាមជាប្រចាំ។ មូលហេតុចម្បងនៃបញ្ហានេះរួមមាន ការចូលទៅកាន់ទីលំនៅកង្វះខាតកន្លែងដាក់ធុងសំរាមនៅលើផ្លូវមេ បញ្ហាទំនួលខុសត្រូវជាមួយក្រុមហ៊ុនប្រមូលសំរាមស៊ីនទ្រី និងទម្លាប់គ្រប់គ្រងសំណល់មិនល្អរបស់សមាជិកសហគមន៍មួយចំនួន។ ជាលទ្ធផល សហគមន៍ជាច្រើនចាក់សំរាមទៅក្នុងទន្លេ និងបឹងបួរក៏ដូចជានៅក្រោមផ្ទះរបស់ពួកគេផងដែរ។ វិធីសាស្ត្រក្នុងការចោលសំណល់ផ្សេងទៀត រួមមាន ការដុតសំរាម ហើយការកែច្នៃឡើងវិញនៅមានកម្រិតនៅឡើយ។ សំណល់មិនបានគ្រប់គ្រងត្រឹមត្រូវ ធ្វើឱ្យមានហានិភ័យដល់សុខភាពដូចជា ជំងឺរាគរូស កន្ទួលស្បែក ជំងឺភ្នែក និងជំងឺឆ្លងជាច្រើនទៀត។

លើសពីនេះទៅទៀត វត្តមានរបស់សំរាមនៅតាមសហគមន៍ធ្វើឱ្យប៉ះពាល់ដល់ការរើសអើងសង្គមនៃជនក្រីក្រនៅតាមទីប្រជុំជន និងជាហានិភ័យនៃការបណ្តេញចេញផងដែរ។

គម្រោងបានអនុវត្តនូវវិធីសាស្ត្រគ្រប់គ្រងសំណល់តាមបែបសហគមន៍ ដែលបានបង្កើតឡើងដោយ អង្គការ UPWD និងបានសាកល្បងរួចហើយនៅសហគមន៍មួយចំនួននៅរាជធានីភ្នំពេញ ក្នុងសកម្មភាពផ្តោតលើសហគមន៍ចំនួនពីរនៅក្នុងតំបន់បឹងទំពុន ដែលប្រឈមនឹងបញ្ហាស្រដៀងគ្នា គឺការប្រមូលសំរាម និងកង្វះការយល់ដឹង និងសម្ភារប្រើប្រាស់ក្នុងការគ្រប់គ្រងសំណល់៖

១. សហគមន៍ព្រែកតាគង្ស ១ សង្កាត់ចាក់អង្រែលើ ខណ្ឌមានជ័យ មាន ៣៥៧ គ្រួសារ

២. សហគមន៍ខ្វា សង្កាត់ដង្កោ ខណ្ឌដង្កោ មាន ១៨៤គ្រួសារ

គំរូនេះ ត្រូវបានបង្កើតឡើងដោយផ្អែកលើសកម្មភាពសំខាន់ៗមួយចំនួនៈ

- ការសិក្សាអំពីលទ្ធភាព និងការប៉ាន់ប្រមាណតម្រូវការ
- ការបង្កើតគណៈកម្មាធិការគ្រប់គ្រងសំណល់ និងបង្កើតបណ្តាញទំនាក់ទំនងទៀងទាត់ជាមួយអាជ្ញាធរមូលដ្ឋាន
- ការរៀបចំឧបករណ៍ទំនាក់ទំនងផ្លាស់ប្តូរឥរិយាបថ
- ព្រឹត្តិការណ៍អនាម័យបរិស្ថាន និងការបង្ហាញសហគមន៍គំរូ
- សេវាប្រមូលសំរាម
- អ្នកដើររើសសំណល់អេតចាយបំពេញការងារជាអ្នកប្រមូលសំរាម និងប្រមូលដាក់ក្នុងធុងសំរាមរបស់ក្រុមហ៊ុនស៊ីនទ្រី (អ្នកប្រមូលសំរាមទាំងនេះទទួលបានកម្រៃពីសមាជិកសហគមន៍)

- យុទ្ធនាការលើកកម្ពស់ការយល់ដឹងតាមរយៈព្រឹត្តិការណ៍ផ្សេងៗ និងយុទ្ធនាការតាំងបង្ហាញ (ផ្ទាំងប៉ាណូ) ។

**ថវិការំពឹងទុក**

ថវិការួមចំណែករបស់អង្គការ Nexus ចំពោះគម្រោងសាកល្បងនេះមានចំនួន ៥000 ដុល្លារអាមេរិក ចន្លោះខែកក្កដា និងខែធ្នូ ឆ្នាំ២០១៧ ដើម្បីគាំទ្រការរៀបចំគម្រោង និងសកម្មភាពចលនាសហគមន៍។

សហហិរញ្ញប្បទានគម្រោង និងតម្លៃសរុបនៃគម្រោងគឺ

អង្គការ Nexus (៥.000) + អង្គការ UPWD/PIN (១0.000) = USD ១៥.000

**អ្នកឧបត្ថម្ភ**

អង្គការ Nexus និង អង្គការ UPWD/PIN

## ឧបសម្ព័ន្ធទី៣. ការគ្រប់គ្រងហិរញ្ញវត្ថុ

### ១. ទិន្នន័យមូលដ្ឋាន - តម្លៃសេវាប្រមូលសំរាម និងហិរញ្ញវត្ថុ

**ហិរញ្ញវត្ថុសាធារណៈ**

ច្បាប់ស្ដីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ចែងអំពីការទទួលខុសត្រូវរបស់ស្ថាប័នថ្នាក់ក្រោមជាតិ ដើម្បីធានានូវប្រភពហិរញ្ញវត្ថុចាំបាច់ក្នុងការបំពេញតួនាទី និងការទទួលខុសត្រូវរបស់រដ្ឋបាល ដើម្បីសម្រេចឱ្យបាននូវប្រសិទ្ធភាព តម្លាភាព និងគណនេយ្យភាព។ សម្រាប់រដ្ឋបាលសារពើពន្ធរបស់ពួកគេ នឹងផ្ដល់នូវប្រភេទប្រាក់ចំណូលនៅក្នុងការផ្ដល់ហិរញ្ញប្បទានថ្នាក់ក្រោមជាតិ ដូចមានរៀបរាប់ខាងក្រោម៖

១. ចំណូលថ្នាក់ក្រោមជាតិ
   - ពន្ធដារក្នុងស្រុក
   - ថ្លៃប្រើសេវា ថ្លៃឈ្នួល និងប្រាក់ចំណូលមិនមែនពន្ធ

២. ចំណូលពីរដ្ឋាភិបាលថ្នាក់ជាតិ
   - ពន្ធមូលដ្ឋានលើប្រាក់ចំណូល
   - ប្រាក់ចំណូលផ្ទេរពីថវិកាថ្នាក់ជាតិ
   - ថវិកាអនុវត្តគម្រោង/ សេវាពិសេសរបស់រដ្ឋាភិបាល ឬស្ថាប័នថ្នាក់ជាតិ

៣. ថវិកាចំណូលផ្សេងៗ

   រូបភាពទី៣២ បង្ហាញអំពីរបៀរ និងទំហំទឹកប្រាក់ជាមធ្យមនៃការផ្ទេរអន្តរស្ថាប័នពីថ្នាក់ជាតិទៅថ្នាក់ក្រោមជាតិឆ្នាំ២០១៣ (Kamiko, ២០១៦) ។ ជាការពិត រដ្ឋបាលថ្នាក់ក្រោមជាតិពឹងផ្អែកស្ទើរទាំងស្រុងលើប្រាក់ចំណូលដែលមានការកម្រិតពីថ្នាក់ជាតិសម្រាប់សេវាសាធារណៈ។ ដូច្នេះហើយហិរញ្ញប្បទានសាធារណៈសម្រាប់ការគ្រប់គ្រងសំណល់នៅរាជធានីភ្នំពេញក៏មានកម្រិតផងដែរ។




កំណត់សំគាល់

* តួលេខគិតជាមធ្យមក្នុងមួយឯកតានៅក្នុងឆ្នាំ២០១៣

** គណនាអត្រាប្តូរប្រាក់ USD ១ = KHR ៤.000

**រូបភាពទី៣២៖ រំហូរថវិការដ្ឋបាលពីថ្នាក់ជាតិទៅថ្នាក់ក្រោមជាតិគិតត្រឹមឆ្នាំ ២០១៣**

ប្រភព: Kamiko (២០១៦) សិក្ខាសាលាគ្រប់គ្រងស្តីពីវិមជ្ឈការ និងភាពជាអ្នកដឹកនាំសម្រាប់តម្រូវការមូលដ្ឋាន និងផ្លាស់ប្តូរសង្គម

នៅឆ្នាំ២០១៥ ក្រសួងបរិស្ថានរបស់ប្រទេសកម្ពុជាបានអនុម័តសារាចរ ស្តីពីការអនុវត្តន៍កម្មវិធីអនាម័យ និងបរិស្ថាន ដើម្បីលើកកម្ពស់ការគ្រប់គ្រងសំរាម សំណល់រឹង និងរាវសម្រាប់ទីក្រុងសរុបចំនួន ២៦ នៅទូទាំងប្រទេសលើកលែងតែរាជធានីភ្នំពេញ។ ក្រោមកញ្ចប់ថវិកាជាតិតាមរយៈក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ មូលនិធិសរុបនៃកម្មវិធីនេះគឺ ៥៣ាន់លានរៀល (ស្មើនឹង ១,២៥លានដុល្លារអាមេរិក) សម្រាប់ឆ្នាំ២០១៥ ដែលនឹងកើនឡើងរហូតដល់ ៩៣ាន់លានរៀល (ស្មើនឹង ២,២៥លានដុល្លារអាមេរិក) ក្នុងឆ្នាំ២០១៦។ ដោយសារមូលនិធិនេះមានបំណងគាំទ្រដល់ទីក្រុង ដែលទន់ខ្សោយផ្នែកហិរញ្ញវត្ថុ ដូចនេះ រាជធានីភ្នំពេញមិនទទួលបាននូវមូលនិធិនេះទេ ដោយគេរំពឹងថា រាជធានីភ្នំពេញអាចនឹងមានថវិកាផ្ទាល់ខ្លួនសម្រាប់សេវាកម្មគ្រប់គ្រងសំណល់របស់ខ្លួន។

លទ្ធភាពធនធានហិរញ្ញវត្ថុនៃទីលានចាក់សំរាមដង្កោ ដែលគ្រប់គ្រងដោយរដ្ឋបាលរាជធានីភ្នំពេញ គឺជាបញ្ហាមួយផ្សេងទៀត។ បច្ចុប្បន្ន កម្រៃចាក់សំរាមនៅទីលានចាក់សំរាម គឺ០,៧៥ដុល្លារ/១តោនសំរាម ដែលយកមកចាក់នៅទីលានចាក់សំរាម។ ទោះយ៉ាងណា យោងទៅតាមការវិភាគស៊ីជម្រៅអំពីទីលានចាក់សំរាមនេះ ដែលបានសិក្សាដោយអង្គការ JICA (២០០៥) ការគ្រប់គ្រងស្ថានភាពទីលានឱ្យមានកំរិតអនាម័យល្អត្រឹមត្រូវ គឺត្រូវតម្រូវឱ្យការបង់ថ្លៃទីលានចំនួន ៤,៤ដុល្លារ/១តោនសំរាមព្រមទាំងមានជំនួយឥតសំណងបន្ថែមទៀតផងដែរ ឬ ៥,៩២ដុល្លារ/១តោនសំរាម ក្នុងលក្ខខណ្ឌមិនមានជំនួយឥតសំណង (JICA និង MPP ឆ្នាំ២០០៥)។ ម្យ៉ាងវិញទៀតក្រុមហ៊ុនស៊ីនទ្រីបានពន្យារពេលមិនបានបង់ថ្លៃចាក់សំណល់នៅទីលានចាប់តាំងពីខែមករា ឆ្នាំ២០០១៨ ដោយសារតែអះអាងថាមិនមានថវិកាគ្រប់គ្រាន់។ ការមិនទូទាត់នេះនៅតែបន្តរហូតដល់ខែកក្កដា ឆ្នាំ២០១៨ បើទោះបីជាមានការស្នើសុំម្តង ហើយម្តងទៀតដោយរដ្ឋបាលរាជធានីភ្នំពេញសម្រាប់ការទូទាត់ក៏ដោយ។

## ហិរញ្ញប្បទានប្រតិបត្តិការគ្រប់គ្រងសំណល់នៅក្នុងកិច្ចសន្យាសម្បទាន

ផ្នែកមួយដ៏សំខាន់នៃសេវាគ្រប់គ្រងសំណល់របស់រាជធានីភ្នំពេញ ត្រូវបានផ្តល់បន្តទៅក្រុមហ៊ុនឯកជនស៊ីនទ្រី ហើយការគ្រប់គ្រងថវិកាមានលក្ខណៈឯករាជ្យក្នុងការផ្តល់សេវាកម្មប្រមូលនិងដឹកជញ្ជូនសំរាម សំណល់រឹងក្នុងរាជធានីភ្នំពេញ ដោយផ្អែកលើថ្លៃសេវាកម្មពី ១ដុល្លារ ដល់ ១០០ដុល្លារ។ ការប្រមូលថ្លៃសេវាកម្មអាចត្រូវបានគេចាត់ទុកថាទទួលបានជោគជ័យ ដោយសារតែថ្លៃសេវាប្រមូលសំរាមទាំងនេះត្រូវបានបញ្ចូលក្នុងវិក្កយបត្រអគ្គិសនីឯកជន បន្ទាប់ពីកិច្ចព្រមព្រៀង ដែលបានធ្វើឡើងរវាងក្រុមហ៊ុនស៊ីនទ្រី និងអគ្គិសនីកម្ពុជា (Sang-Arun et al., ២០១១)។

ទោះជាយ៉ាងណា ម៉ូដែលសេវាកម្មរបស់ក្រុមហ៊ុនស៊ីនទ្រីនៅតែបន្តប្រឈមនឹងបញ្ហានិរន្តរភាពហិរញ្ញវត្ថុទូទៅពីកម្រៃសេវាដែលប្រមូលបាន សម្រាប់ទ្រទ្រង់សេវាប្រមូល និងដឹកជញ្ជូន។ ជារឿយៗ ក្រុមហ៊ុនបានរាយការណ៍ពីការខាតបង់ក្នុងការចំណាយលើប្រតិបត្តិការសេវាកម្មជារួម ទាំងការសម្អាតតាមដងផ្លូវ និងការចាក់ចោលនៅទីលានចាក់សំរាម។

ហេតុដូច្នេះហើយ សេវាប្រមូលសំណល់ និងការសម្អាតតាមដងផ្លូវរបស់ក្រុមហ៊ុនស៊ីនទ្រីមិនបានបំពេញតាមកម្រិតរំពឹងទុកនោះទេ ដោយការគ្រប់ដណ្តប់សេវាកម្មមិនទាន់អាចពង្រីកបន្ថែមទៅតំបន់ជាយរាជធានី ដោយមិនទាន់មានលទ្ធភាពទទួលបានការទូទាត់ប្រាក់ចំណូលបន្ថែមនៅឡើយ។

ប្រតិបត្តិការប្រមូលសំណល់តាមផ្ទះរបស់ក្រុមហ៊ុនក៏ជួបប្រទះការលំបាកផងដែរ ដោយត្រូវប្រឈមនឹងតម្រូវការឱ្យមានភាពប្រសើរឡើងនៃសេវាកម្មប្រមូលសំរាម ឧទាហរណ៍ ការបង្កើនប្រាក់ខែដល់កម្មកររបស់ខ្លួន ស្របពេលដែលមានការរិះគន់ និងមិនពេញចិត្តពីសំណាក់អ្នកប្រើប្រាស់សេវារបស់ខ្លួន រួមទាំងការយល់ដឹងពីការអនុវត្តន៍ការគ្រប់គ្រងសំណល់ឱ្យបានសមរម្យ ព្រមទាំងការចូលរួមធ្វើសេចក្តីសម្រេចជាផ្លូវការរបស់អ្នកប្រើប្រាស់នៅមានកម្រិតនៅឡើយ។ ដូច្នេះ អាជ្ញាធរមូលដ្ឋានបានគិតគូរពិចារណាក្នុងការលុបចោលថ្លៃសេវាប្រមូលសំរាមរបស់ក្រុមហ៊ុន ពីវិក័យប័ត្រអគ្គិសនីរបស់អ្នកប្រើប្រាស់ ដែលវានឹងលុបបំបាត់បុព្វហេតុសាធារណៈ ក្នុងការតវ៉ាទៅអាជ្ញាធរអគ្គិសនីកម្ពុជា។ ក្នុងន័យនេះ ប្រាក់កម្រៃពីការប្រមូលសំរាមតំណាងឱ្យប្រភពចំណូលយ៉ាងសំខាន់សម្រាប់ទ្រទ្រង់សេវារបស់ក្រុមហ៊ុន ហើយនិរន្តរភាពហិរញ្ញវត្ថុនៃប្រតិបត្តិការរបស់ក្រុមហ៊ុនប្រមូលសំរាមអាចប្រឈមនឹងផលប៉ះពាល់ធំធេងក្នុងការផ្តល់គុណភាពគ្រប់គ្រងសំណល់សម្រាប់រាជធានីភ្នំពេញទាំងមូល។

**ការចំណាយលើសេវាកម្មគ្រប់គ្រងសំណល់**

យោងតាមធនាគារពិភពលោក និងទីភ្នាក់ងារ USAID វាជារឿងសាមញ្ញសម្រាប់ក្រុងក្នុងបណ្តាប្រទេសកំពុងអភិវឌ្ឍន៍ក្នុងការចំណាយថវិកាក្រុងចំនួន ២០ ទៅ ៥០ ភាគរយលើការគ្រប់គ្រងសំណល់រឹង។

- ចំណាយសរុបសម្រាប់ការប្រមូលសំណល់ និងការចាក់ចោល ជាទូទៅ គឺ៤០ ទៅ ៨០ដុល្លារ/តោន
- ៦០-៧០% នៃចំណាយគ្រប់គ្រងសំណល់សរុប ជាទូទៅ ត្រូវបានត្រៀមបម្រុងសម្រាប់ការប្រមូលសំរាម
- ៥០-៧០% ត្រូវបានប្រើសម្រាប់ចំណាយលើ កម្មករ ប្រេង និងការចំណាយផ្សេង ៗ

ចំណាយសំខាន់នៃសេវាកម្មគ្រប់គ្រងសំណល់ គួរតែត្រូវបានគ្របដណ្តប់ដោយការប្រមូលកម្រៃសេវា ដើម្បីរក្សានិរន្តភាព។ ប្រភពផ្សេងទៀត អាចរួមមានមូលនិធិរបស់រដ្ឋាភិបាល ឬហិរញ្ញវត្ថុអភិវឌ្ឍន៍ភាពជាដៃគូសាធារណៈ -ឯកជន ប្រាក់កម្ចីពីទីផ្សារទុន និងការផ្តល់ហិរញ្ញប្បទានកាបូនជាដើម។

## ការផ្តល់ហិរញ្ញប្បទានពីរដ្ឋាភិបាលជាតិ និងស្ថាប័នខាងក្រៅ

ផ្នែកនេះសង្ខេបពីនិន្នាការថ្មីៗនៃការគាំទ្រហិរញ្ញវត្ថុពីរដ្ឋាភិបាលជាតិ ដៃគូអភិវឌ្ឍន៍ និងវិស័យឯកជនសម្រាប់ការផ្តល់សេវាកម្មគ្រប់គ្រងសំណល់ប្រកបដោយប្រសិទ្ធភាព៖

- នៅក្នុងឆ្នាំ២០១៧ ក្រសួងបរិស្ថានបានរៀបចំប្រមូលនូវប្រាក់កម្រៃជាង ៣០០.០០០ដុល្លារ ផ្តល់ទៅមូលនិធិបរិស្ថានជាតិ និងប្រាក់ចំណូលប្រមាណ ៣ពាន់លានរៀល ប្រមូលបានពីសេវាកម្មផ្សេងៗ
- រាជរដ្ឋាភិបាលកម្ពុជាបានចូលរួមយ៉ាងសកម្ម ជាមួយដៃគូអភិវឌ្ឍន៍នានា រួមទាំង ADB និង JICA ដោយផ្តោតលើការគ្រប់គ្រងសំណល់ និងការបណ្តុះបណ្តាលសមត្ថភាព ទៅលើការវាយតម្លៃលើបរិស្ថាន និងការគ្រប់គ្រងការបំពុល។

នៅក្នុងឆ្នាំ២០១៦ ថវិកា ២លានដុល្លារ ត្រូវបានបែងចែកសម្រាប់តែការគ្រប់គ្រងសំណល់តែមួយគត់។ នៅឆ្នាំ២០១៧ មូលនិធិអភិវឌ្ឍន៍សម្រាប់ទប់ទល់នឹងការប្រែប្រួលអាកាសធាតុមានថវិកាចំនួន ២,៨១លានដុល្លារអាមេរិក មានប្រភពពីមូលនិធិអន្តរជាតិសម្រាប់ការអភិវឌ្ឍកសិកម្ម (IFAD) រដ្ឋបាលមូលដ្ឋាន និងការផ្តួចផ្តើមប្រែប្រួលអាកាសធាតុ (LGCC) II និងធនាគារអភិវឌ្ឍន៍អាស៊ី (ADB)

- នាពេលបច្ចុប្បន្ននេះ មានក្រុមហ៊ុនឯកជន និងមូលនិធិជាច្រើនដែលមានការចាប់អារម្មណ៍លើបញ្ហាបរិស្ថានរួមទាំងការគ្រប់គ្រងសំណល់ដូចជា ក្រុមហ៊ុន Unilever និង Chevron ជាដើម។ ចំនួនទឹកប្រាក់មិនត្រូវបានបញ្ចេញ និងអាស្រ័យលើគម្រោងសំណើដែលបានផ្ញើដោយផ្ទាល់ទៅអង្គការដែលជាប់ពាក់ព័ន្ធ។

## ២. ប្រភពមូលនិធិគ្រប់គ្រងសំណល់ប្រកបដោយសក្តានុពល

តារាងខាងក្រោមនេះ បង្ហាញនូវបញ្ជីឈ្មោះដៃគូអភិវឌ្ឍន៍ និងគ្រឹះស្ថានឯកជន ដែលផ្តល់ឱកាសក្នុងការទទួលបានហិរញ្ញប្បទានលើវិស័យគ្រប់គ្រងសំណល់។

| ឈ្មោះម្ចាស់ជំនួយ | អាទិភាព | សំគាល់ | អាសយដ្ឋានទំនាក់ទំនង | ប្រភេទម្ចាស់ជំនួយ | គោលការណ៍ផ្តល់ជំនួយ (រួមទាំងឱកាស និងហានិភ័យ) |
|---|---|---|---|---|---|
| វិស័យអភិវឌ្ឍន៍ | | | | | |
| ADB | ខ្ពស់ | ធនាគារអភិវឌ្ឍន៍អាស៊ីធ្វើការតាមរយៈរដ្ឋាភិបាលនៃបណ្តាប្រទេសកំពុងអភិវឌ្ឍន៍របស់ខ្លួន ប៉ុន្តែអាចផ្តល់កិច្ចសន្យាសម្រាប់តាមផ្នែកនៃគម្រោង និងសកម្មភាពជំនួយផ្នែកបច្ចេកទេស | Cambodia Resident Mission<br>No. 29 ផ្លូវព្រះសុរាម្រិត (268/19) សង្កាត់ចតុមុខ ខណ្ឌដូនពេញ រាជធានីភ្នំពេញ ប្រទេសកម្ពុជា<br>ម៉ោងការងារ: ថ្ងៃច័ន្ទ ដល់ថ្ងៃសុក្រ 08:00 - 12:00, 13:00 - 17:00<br>Tel:<br>+ 855 23 215 805, 215 806, 216 417<br>+ 855 23 215 807 | ពហុស្ថាប័ន | មូលនិធិរបស់ធនាគារអភិវឌ្ឍន៍អាស៊ីនៅប្រទេសកម្ពុជារួមមាន គោលដៅយុទ្ធសាស្ត្រសំខាន់ៗចំនួនបីគឺ (១) កំណើនសេដ្ឋកិច្ចសម្រាប់ទាំងអស់គ្នា (២) កំណើនប្រកបដោយនិរន្តរភាពបរិស្ថាន និង (៣) កិច្ចសហប្រតិបត្តិការ និងការធ្វើសមាហរណកម្មក្នុងតំបន់។ យុទ្ធសាស្ត្រភាពជាដៃគូរបស់ប្រទេសឆ្នាំ២០១៤-២០១៨ ចែងថា ADB នឹងសហការជាមួយរដ្ឋាភិបាល ដើម្បីបំពេញនូវយុទ្ធសាស្ត្រចតុកោណ ជម្រុញកំណើនការងារសមធម៌ និងប្រសិទ្ធភាព (RSIII) និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ (NSDP) ឆ្នាំ២០១៤-២០១៨។ |
| AFD | ខ្ពស់ | AFD សហការជាមួយរដ្ឋបាលរាជធានីភ្នំពេញ និងគាំទ្រដល់រដ្ឋាករទឹកស្វយ័តរាជធានីភ្នំពេញ និងអគ្គិសនីកម្ពុជាដោយផ្តល់នូវគន្លឹះសេវាកម្មទីក្រុង | ទីភ្នាក់ងារភ្នំពេញ៖<br>ផ្ទះលេខ៥ ផ្លូវ១០៦ BP102 សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ<br>Tel: +855 23 426 360<br>+855 23 426 036<br>Fax: +855 23 426 243<br>afdphnompenh@afd.fr | ធនាគារអភិវឌ្ឍន៍សាធារណៈ | ទីភ្នាក់ងារបារាំងដើម្បីអភិវឌ្ឍន៍ (AFD) លើកកម្ពស់គំនិតផ្តួចផ្តើមឯកជន-សាធារណៈ ដូចជាការផ្តល់ភ្លើងបំភ្លឺតាមចិញ្ចើមផ្លូវប្រកបដោយប្រសិទ្ធភាព និងគម្រោងសំណល់ជាថាមពល។ យុទ្ធសាស្ត្រចម្បងនៃ AFD គឺត្រូវប្រមូលផ្តុំការវិនិយោគឯកជនសម្រាប់ (១) ផែនការទីក្រុង (២) ថាមពលកកើតឡើងវិញ (៣) ការដឹកជញ្ជូន (ការដឹកជញ្ជូនក្នុងរាជធានីភ្នំពេញ និងគម្រោងកែលម្អផ្លូវជនបទទី២ ក្នុងខេត្តត្បូងឃ្មុំចម្ងាយ ១៩៣,៩ គីឡូម៉ែត្រ)។ |

| ឈ្មោះម្ចាស់ជំនួយ | អាទិភាព | សំគាល់ | អាសយដ្ឋានទំនាក់ទំនង | ប្រភេទម្ចាស់ជំនួយ | គោលការណ៍ផ្តល់ជំនួយ (រួមទាំងឱកាស និងហានិភ័យ) |
|---|---|---|---|---|---|
| The Asia Foundation | ទាប | | The Asia Foundation – Cambodia<br>ផ្ទះលេខ 59 ផ្លូវលេខ 242 រាជធានីភ្នំពេញ ប្រទេសកម្ពុជា<br>Tel: + 855 23 210-431 | ដៃគូអង្គការអភិវឌ្ឍអន្តរជាតិ | អង្គការមូលនិធិអាស៊ី បានដោះស្រាយការគ្រប់គ្រងធនធានធម្មជាតិនៅក្នុងទ្វីបអាស៊ី និងមានបំណងផ្តល់ថវិកានិងការគាំទ្រលើៈ<br>- ការគ្រប់គ្រងធនធានធម្មជាតិប្រកបដោយប្រសិទ្ធភាពសម្រាប់ការអភិវឌ្ឍប្រកបដោយចីរភាព<br>- កសាងសមត្ថភាពរបស់រដ្ឋាភិបាលពាណិជ្ជកម្ម និងឯកជន ដើម្បីកាត់បន្ថយផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ និងហានិភ័យដែលទាក់ទងនឹងបាតុភូតធម្មជាតិ<br>- ការពង្រឹងទិដ្ឋភាពបរិស្ថានទៅក្នុងក្របខណ្ឌ/ផែនការ ឬគោលនយោបាយនៅកម្រិតធម្មជាតិ និងកម្រិតទីក្រុង<br>នៅប្រទេសកម្ពុជា អង្គការនេះបានធ្វើការស្រាវជ្រាវ ស្តីពីការគ្រប់គ្រងសំរាម សំណល់រឹង និងបានធ្វើការជាមួយអ្នកពាក់ព័ន្ធផ្សេងៗក្នុងវិស័យនេះដើម្បីបញ្ចូលយុទ្ធសាស្ត្រគ្រប់គ្រងសំណល់ប្រកបដោយប្រសិទ្ធភាពសម្រាប់រាជធានីភ្នំពេញ ដូចជា នៅក្នុងឆ្នាំ២០១៣ បានធ្វើការយ៉ាងសកម្មជាមួយក្រុមហ៊ុនប្រមូលសំរាមស៊ីនទ្រី លើកម្មវិធីកែទម្រង់ការគ្រប់គ្រងសំរាមសំណល់រឹង និងបានចូលរួមយ៉ាងសកម្មនៅក្នុងកម្មវិធីដែលពាក់ព័ន្ធនឹងសំណល់ និងបរិស្ថានរួមទាំងកម្មវិធីសេវាទីក្រុង និងកម្មវិធីអេកូអាស៊ី។ |
| DANIDA | ធម្យម | កម្ពុជាមិនមែនជាប្រទេសអាទិភាព | Team Leader Rights and Governance<br>Thea Lund Christiansen<br>Development Policy and Global Cooperation (UGS) Tel. +45 33 92 12 24<br>thechr@um.dk | រដ្ឋាភិបាល | ការងារអាទិភាពរបស់ DANIDA គឺកំណើន និងការអភិវឌ្ឍប្រកបដោយនិរន្តរភាព ដែលក្នុងនោះមានគោលបំណងជួយ និងផ្តល់មូលនិធិដល់គម្រោងជំនាញរបស់ខ្លួនរួមមាន ថាមពល ទឹក កសិកម្ម និងស្បៀង។ ទោះបីជាយុទ្ធសាស្ត្ររបស់ DANIDA បង្ហាញថា កិច្ចគាំពារបរិស្ថាន គឺជាផ្នែកមួយរបស់ខ្លួន តែបច្ចុប្បន្នវិស័យគោលដៅសំខាន់ៗនៃការងាររបស់DANIDA នៅកម្ពុជាផ្តោតទៅលើតំបន់ជនបទរាប់បញ្ចូលទាំងកិច្ចគាំពារធនធានធម្មជាតិ ដែនជម្រក និងការកាប់បំផ្លាញព្រៃឈើ។ |
| European Union | ខ្ពស់ | | | | យុទ្ធសាស្ត្រចម្បងនៃសហភាពអឺរ៉ុប គឺគាំទ្រដល់រដ្ឋាភិបាលកម្ពុជាក្នុងវិស័យផ្សេងៗ ដូចជាវិស័យកសិកម្ម ការគ្រប់គ្រងធនធានធម្មជាតិ ការអប់រំ ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងពាណិជ្ជកម្ម។ |

| ឈ្មោះម្ចាស់ជំនួយ | អាទិភាព | សំគាល់ | អាសយដ្ឋានទំនាក់ទំនង | ប្រភេទម្ចាស់ជំនួយ | គោលការណ៍ផ្តល់ជំនួយ (រួមទាំងឱកាស និងហានិភ័យ) |
|---|---|---|---|---|---|
| GIZ | មធ្យម | | ទំនាក់ទំនងទៅការិយាល័យ GIZ ប្រចាំប្រទេសកម្ពុជា លោក Thomas Waldraff នាយកប្រចាំប្រទេសកម្ពុជា៖ giz-kambodscha@giz.de **អាសយដ្ឋានការិយាល័យ** GIZ រាជធានីភ្នំពេញ ប្រទេសកម្ពុជា Tel: +855 23 860 110 + 855 23 2127 83 giz-kambodscha@giz.de P.O. Box 81 រាជធានីភ្នំពេញ ប្រទេសកម្ពុជា | រដ្ឋាភិបាល | អង្គការ GIZ ធ្វើការងារពីរយ៉ាង៖ (១) សុខភាព និងសន្តិសុខសង្គម និង(២) ការអភិវឌ្ឍជនបទ ដោយផ្តោតលើការកសាងសមត្ថភាពរបស់រាជរដ្ឋាភិបាលកម្ពុជា និងរដ្ឋប្បវេណីសង្គម។ នៅឆ្នាំ២០១៦ GIZ បានអនុវត្តកម្មវិធីសិទ្ធិដីធ្លី ដើម្បីគាំទ្រការអភិវឌ្ឍសមត្ថភាពសម្រាប់ការរៀបចំផែនការទីក្រុងនៅក្នុងក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ (MLMUPC)។ GIZ បានធ្វើការជាមួយសហការជាមួយ MULMUPC នៅក្នុងការធ្វើផែនការលំហរទីក្រុង នៅកម្រិតផ្សេងៗគ្នាជាង ២០ឆ្នាំ ហើយថ្មីៗនេះធ្វើការនៅក្នុងខេត្តចំនួន៤ គឺ បាត់ដំបង កំពង់ឆ្នាំង កណ្តាល និងតាកែវ។ GIZ ក៏បានផ្តួចផ្តើមកម្មវិធីសម្រាប់ទីក្រុងពាក់ព័ន្ធនឹងបរិស្ថាន និងការដឹកជញ្ជូននៅក្នុងតំបន់អាស៊ានផងដែរ។ |
| Global Affairs Canada | ទាប | ព្រមទទួលសំណើដែលមិនបានស្នើសុំ និងបញ្ជូនទៅអង្គការនៅកាណាដា | www.international.gc.ca/world-monde/funding-financement/apply_fundingdemande_financement.aspx?lang=eng | រដ្ឋាភិបាល | ប្រទេសកាណាដាផ្តល់មូលនិធិគម្រោងពាក់ព័ន្ធនឹងគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពឆ្នាំ ២០៣០<br>ការអភិវឌ្ឍប្រកបដោយចីរភាព ដែលរួមបញ្ចូលទីក្រុង និងសហគមន៍ ដែលមាននិរន្តរភាពថាមពលកកើតឡើងវិញ<br>សកម្មភាពបន្សាំអាកាសធាតុ & ការទទួលខុសត្រូវលើការប្រើប្រាស់។ តែមិនមានការចង្អុលបង្ហាញទេអំពីលទ្ធភាពផ្តល់ជំនួយលើវិស័យសំណល់ទេ។ |
| International Finance Corporation (IFC) | ខ្ពស់ | | អ្នកគ្រប់គ្រងប្រចាំតំបន់៖ លោក Kyle Kelhofer E-mail: kkelhofer@ifc.org<br><br>ការិយាល័យ: Sarak Duong ជាន់ទី១១ អគារ Exchange Square, #១៩&២០ ផ្លូវ១០៦ រាជធានីភ្នំពេញ ទូរ: (+855) 23 263 200 E-mail: sduong@ifc.org | ស្ថាប័នអភិវឌ្ឍន៍សាកល | IFC ប្រកាន់ខ្ជាប់នូវវិធីសាស្ត្របីយ៉ាងនៅក្នុងការអភិវឌ្ឍអគារបៃតង រួមទាំងការប្រើប្រាស់ធនធាន និងប្រសិទ្ធភាពថាមពល៖ (១) ជួយបង្កើតបទបញ្ញាសម្រាប់អគារបៃតង និងពង្រឹងសមត្ថភាព (២) កម្មវិធីផ្តល់វិញ្ញាបនប័ត្រកាត់បន្ថយការបំភាយ ២០% ពីកម្រិតគោលផ្នែកថាមពល ទឹក និងការប្រើប្រាស់សម្ភារ (៣) ការភ្ជាប់ការអភិវឌ្ឍអគារបៃតងទៅនឹងវិស័យហិរញ្ញវត្ថុ ដើម្បីផ្តល់នូវផលិតផលបៃតង និងទទួលបាននូវប្រាក់កម្ចីល្អប្រសើរសម្រាប់លក្ខខណ្ឌឥណទាន។ លើសពីនេះទៀត IFC បានធ្វើការលើវិស័យអង្ករកម្ពុជា គាំទ្រគម្រោង ដើម្បីលើកកម្ពស់ជាប្រទេសមួយផលិតអង្ករ និងជាអ្នកនាំចេញអង្ករ ដែលមានគុណភាពខ្ពស់។<br>កម្មវិធី IFC ក៏មានបំណងអភិវឌ្ឍន៍ថាមពល និងប្រសិទ្ធភាពថាមពលប្រើប្រាស់ក្នុងវិស័យស្រូវ-អង្ករសរីរាង្គ រួមជាមួយការគ្រប់គ្រងសំណល់ និងឧបករណ៍ប្រកបដោយប្រសិទ្ធភាពខ្ពស់។ |
| JICA | ខ្ពស់ | | ការិ. JICA នៅកម្ពុជា ជាន់ទី6 ទី7 និងទី8 អគារលេខ261-64 មហាវិថី | រដ្ឋាភិបាល | JICA គឺជាដៃគូសក្តានុពលដ៏សំខាន់មួយសម្រាប់រាជធានីភ្នំពេញក្នុងការអភិវឌ្ឍគម្រោងរាជធានីបៃតងរបស់ខ្លួន។ JICA គាំទ្រ |

| ឈ្មោះម្ចាស់ជំនួយ | អាទិភាព | សំគាល់ | អាសយដ្ឋាន ទំនាក់ទំនង | ប្រភេទ ម្ចាស់ជំនួយ | គោលការណ៍ផ្តល់ជំនួយ (រួមទាំងឱកាស និងហានិភ័យ) |
|---|---|---|---|---|---|
| | | | ព្រះនរោត្តម រាជធានីភ្នំពេញ ប្រទេសកម្ពុជា (P.O.Box 613, Phnom Penh, Cambodia) Tel : +855 23 211673 Fax : +855 23 211675 | | ការងារលើវិស័យហេដ្ឋារចនាសម្ព័ន្ធ ក្នុងការអភិវឌ្ឍរាជធានីភ្នំពេញរួមមាន៖ ផែនការទីក្រុងភាពងាយរងគ្រោះនៅទីក្រុង (ការការពារទឹកជំនន់ ការកែលម្អប្រព័ន្ធលូ និងប្រឡាយ) ថាមពលស្អាត ការដឹកជញ្ជូន វិស័យស្ថាបនា បរិស្ថាន និងផលិតកម្ម (ការអភិវឌ្ឍការផ្គត់ផ្គង់ទឹកស្អាត និងគម្រោងអភិវឌ្ឍន៍សមត្ថភាព - CJCC) និងគម្រោងផ្សេងៗទៀតនៅរាជធានីភ្នំពេញលើវិស័យអប់រំ និងសុខភាព។ |
| KOICA | ខ្ពស់ | | Tel: +855 23 964 150/ 1/3 Fax: +855 23 964 152 E-mail: cambodia@koica.go.kr **អាសយដ្ឋាន:** អគារ Phnom Penh Tower ជាន់ទី១២, #445 | រដ្ឋាភិបាល | KOICA បានអនុវត្តគម្រោងសំណល់នៅកម្ពុជាចាប់តាំងពីឆ្នាំ២០១២។ គម្រោងឆ្នាំ២០១២-២០១៤ ពេលនោះមានគោលបំណង បង្កើនសមត្ថភាព និងការបង្កើតយុទ្ធសាស្ត្រគ្រប់គ្រងសំណល់ប្រកបដោយប្រសិទ្ធភាពនៅកម្ពុជា។ KOICA ក៏ផ្តោតលើគម្រោងផែនការអភិវឌ្ឍន៍ទីក្រុងរួមមាន៖ ការរៀបចំផែនទីគោលថ្នាក់ជាតិ ផែនការមេនៃទិន្នន័យហេដ្ឋារចនាសម្ព័ន្ធថ្នាក់ជាតិនៅក្នុងប្រទេសកម្ពុជា ការកសាងសមត្ថភាពសម្រាប់រាជធានីភ្នំពេញ ការអភិវឌ្ឍទីផ្សារនៅប្រទេសកម្ពុជា គម្រោងផែនការមេវិទ្យាសាស្ត្រ និងបច្ចេកវិទ្យាថ្នាក់ជាតិនៃប្រទេសកម្ពុជា (២០១៤-២០២០) ។ |
| MFAT | មធ្យម | | ក្រសួងការបរទេស និងពាណិជ្ជកម្ម 195 Lambton Quay Private Bag 18 901 Wellington 6160 New Zealand Tel: +64 4 439 8000 | រដ្ឋាភិបាល | មូលនិធិ MFAT បានណែនាំមូលនិធិអភិវឌ្ឍន៍ប្រកបដោយនិរន្តរភាពក្នុងឆ្នាំ២០១០ ហើយរហូតមកដល់ពេលនេះ មូលនិធិនេះបានផ្តល់នូវថវិកាជាង ៧៩លានដុល្លារ សម្រាប់អង្គការក្រៅរដ្ឋាភិបាលនូវែលសេឡង់នៅទូទាំងពិភពលោក។ ការអនុវត្តន៍មូលនិធិសម្រាប់អង្គការមិនមែនរដ្ឋាភិបាលដទៃទៀត គឺមិនច្បាស់លាស់។ ទោះបីជាយ៉ាងណាក៏ដោយ MFAT មានប្រវត្តិផ្តល់មូលនិធិដល់អង្គការក្រៅរដ្ឋាភិបាលជាច្រើននៅកម្ពុជាមានដូចជា WASH និង ADRA ។ |
| Netherlands Development Cooperation | ខ្ពស់ | ទាក់ទងផ្ទាល់ទៅស្ថាប័ន | www.government.nl/contact | រដ្ឋាភិបាល | វិស័យយកចិត្តទុកដាក់រួមមាន ទឹកស្អាត ការកាត់បន្ថយការបញ្ចេញកាបូន ការកាត់បន្ថយសំណល់ ការសម្អាតដីដែលរងការបំពុល និងការលើកកម្ពស់គុណភាពខ្យល់ ដើម្បីដោះស្រាយការប្រែប្រួលអាកាសធាតុ និងការថយចុះនៃធនធានធម្មជាតិ និងជីវចម្រុះ។ |
| NORAD | ខ្ពស់ | កម្ពុជាមិនមែនជាប្រទេសអាទិភាព | Bygdøy allé 2, 0257 Oslo អាសយដ្ឋានប្រៃសនីយ៍ Pb 8034 Dep. 0030 Oslo Email: postmottak@norad.no Tel: +4723980000 | រដ្ឋាភិបាល | ពង្រឹងការកសាងសមត្ថភាពនៅតាមគ្រឹះស្ថានឧត្តមសិក្សាលើ ៦វិស័យសំខាន់ៗ រួមមាន ការគ្រប់គ្រងធនធានធម្មជាតិ និងបរិស្ថាន។ NORAD បានគាំទ្រដល់គម្រោងអាកាសធាតុ និងព្រៃឈើមួយចំនួននៅក្នុងប្រទេសផ្សេងៗ ហើយបានគាំទ្រគម្រោងរបស់ INTEPOL ក្នុងការលើកទឹកចិត្តដល់ការអនុវត្តន៍ច្បាប់ ដើម្បីប្រយុទ្ធប្រឆាំងនឹងឧក្រិដ្ឋកម្មព្រៃឈើនៅតំបន់អាម៉ាហ្សូន និងតំបន់អាងទឹកទន្លេមេគង្គ ដែលរួម |

| ឈ្មោះម្ចាស់ជំនួយ | អាទិភាព | សំគាល់ | អាសយដ្ឋានទំនាក់ទំនង | ប្រភេទម្ចាស់ជំនួយ | គោលការណ៍ផ្តល់ជំនួយ (រួមទាំងឱកាស និងហានិភ័យ) |
|---|---|---|---|---|---|
| | | | | | មានប្រទេសកម្ពុជាផងដែរ។ |
| SIDA | ខ្ពស់ | | អគារ Phnom Penh Tower ជាន់ទី១០ #445, Monivong Blvd, (St. 93/232) សង្កាត់បឹងប្រលិត ខណ្ឌ៧មករា រាជធានីភ្នំពេញ<br><br>អាសយដ្ឋានប្រៃសនីយ៍<br>Embassy of Sweden<br>P.O. Box 68 រាជធានីភ្នំពេញ ប្រទេសកម្ពុជា<br>Tel: +855 23 861 700<br>Fax: +855 23 861 701<br>E-mail: ambassaden. phnom-penh@gov.se | រដ្ឋាភិបាល | នៅកម្ពុជា SIDA បានផ្តោតលើ៖<br>- លើកកម្ពស់លទ្ធិប្រជាធិបតេយ្យ និងសមភាពយេនឌ័រ<br>- លើកកម្ពស់ការអប់រំ និងការងារសម្រាប់ឱកាសសេដ្ឋកិច្ចល្អប្រសើរ ជាពិសេសសម្រាប់ជនងាយរងគ្រោះ<br>- ការជំរុញបរិស្ថាន ភាពធន់នឹងផលប៉ះពាល់បរិស្ថាន ការប្រែប្រួលអាកាសធាតុ និងគ្រោះមហន្តរាយធម្មជាតិ<br>នៅឆ្នាំ ២០១៦ SIDA បានសហការជាមួយរដ្ឋាភិបាល និងអង្គការ NGO មួយចំនួន បង្កើតគោលនយោបាយ និងគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពសាកល។ SIDA ក៏បានសហការជាមួយ Forum Syd ផងដែរ ជាកម្មវិធីជំរុញការចូលរួមជាមួយស្ថាប័នឯកជននៅប្រទេសកម្ពុជាទាក់ទងនឹងអាកាសធាតុ និងការប្រើប្រាស់ធនធានប្រកបដោយចីរភាព។ |
| UNDP | ខ្ពស់ | ទំនាក់ទំនងការិ.ក្នុងតំបន់ | #៥៣ ផ្លូវបាស្ទ័រ សង្កាត់បឹងកេងកង១<br>P.O. Box 877 រាជធានីភ្នំពេញ<br>ប្រទេសកម្ពុជា<br>Tel: +855 23 216 167/214 371<br>Fax: +855 23 216 257/721 042<br>E-mail: registry.kh@undp.org<br>(Media Related): communications.kh@ undp.org<br>Website: www.kh.undp.org | UN | អង្គការ UNDP មានគោលបំណងសម្រេចឱ្យបាននូវការអភិវឌ្ឍធនធានមនុស្សប្រកបដោយនិរន្តរភាព និងបរិយាប័ន្ន និងគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព (SDGs)។ គោលបំណងរបស់ UNDP គឺ ដើម្បីដោះស្រាយបញ្ហាគីមី និងការគ្រប់គ្រងសំណល់ ដោយគាំទ្រដល់បណ្តាប្រទេសនូវធនធានហិរញ្ញវត្ថុ និងបច្ចេកទេស ព្រមទាំងការកែលម្អការគ្រប់គ្រងសារធាតុគីមី និងសំណល់ជារួមនៅថ្នាក់ជាតិ ថ្នាក់តំបន់ និងថ្នាក់សាកល។ UNDP មានគោលបំណង "កាត់បន្ថយការប្រើប្រាស់គ្មាននិរន្តរភាព និងលំនាំផលិតកម្មដែលបណ្តាលឱ្យមានការថយចុះធនធាន ការបង្កើតសំណល់ និងការបំពុល"។ នៅប្រទេសកម្ពុជា UNDP បានចាប់ផ្តើមផ្តល់មូលនិធិ ឬបានចូលរួមយ៉ាងសកម្មនៅក្នុងគម្រោងជាច្រើនរួមទាំង "គម្រោងនៃកម្មវិធីសម្ព័ន្ធប្រែប្រួលអាកាសធាតុកម្ពុជា (CCCA) គម្រោងនៃកម្មវិធីបន្សាំដោយសហគមន៍កម្ពុជា គម្រោងជំរុញការគ្រប់គ្រងធនធានទឹកធន់នឹងអាកាសធាតុ គម្រោងអនុវត្តន៍កសិកម្មនៅតាមជនបទនៃប្រទេសកម្ពុជា គម្រោងគ្រប់គ្រងព្រៃឈើប្រកបដោយនិរន្តភាព គម្រោងនៃកម្មវិធី REDD និង REDD + Readines តាមរយៈអង្គការ សហប្រជាជាតិ"។ |
| UNIDO | ខ្ពស់ | | តំណាយ UNIDO ប្រចាំប្រទេសកម្ពុជា៖ | UN | តាំងពីឆ្នាំ១៩៩៣ អង្គការ UNIDO នៅកម្ពុជាបានផ្តោតលើ៖ កសិឧស្សាហកម្ម ការកសាង |

| ឈ្មោះម្ចាស់ជំនួយ | អាទិភាព | សំគាល់ | អាសយដ្ឋាន ទំនាក់ទំនង | ប្រភេទ ម្ចាស់ជំនួយ | គោលការណ៍ផ្តល់ជំនួយ (រួមទាំងឱកាស និងហានិភ័យ) |
|---|---|---|---|---|---|
| | | | Mr. NarinSok<br>អគារ Phnom Penh Center, Building A, Room 611, 6th Floor<br><br>Corner Sihanouk Blvd (St. 274) & Sothearos Blvd<br>Sangkat Tonle Bassac,<br>Khan Chamkarmon<br>Phnom Penh 12301<br>CAMBODIA<br>Tel: +855 23 860927 | | សមត្ថភាព ពាណិជ្ជកម្ម ការអភិវឌ្ឍជំនាញថាមពលកកើតឡើងវិញ ការអភិវឌ្ឍសហគ្រាសខ្នាតតូច និងមធ្យមប្រកបដោយប្រសិទ្ធភាព ធនធាន និងការគ្រប់គ្រងបរិស្ថាន រួមទាំងការកាត់បន្ថយការបំភាយឧស្ម័នបំពុលបរិយាកាស POPs។ នៅក្នុងឆ្នាំ ២០១៥ UNDP បានផ្តល់មូលនិធិចំនួន ៧,៥លានដុល្លារដល់ប្រទេសចំនួន៥ប្រទេស ក្នុងតំបន់អាស៊ី រួមទាំងប្រទេសកម្ពុជាផងដែរ ដើម្បីដោះស្រាយបញ្ហាគ្រប់គ្រងសំណល់តាមរយៈមូលនិធិបរិស្ថានសាកល។ |
| UNCDF | ខ្ពស់ | | លោក ធិន ហុង<br>Financial Inclusion Specialist<br>លោក ស កុសល<br>National Technical Specialist<br>អាសយដ្ឋានៈ<br>#53, ផ្លូវប៉ាស្ទ័រ សង្កាត់បឹងកេងកង១ រាជធានីភ្នំពេញ<br>PO Box 877 Cambodia<br>Tel: +855 23 216 167 | UN | ការងាររបស់ UNCDF នៅកម្ពុជាផ្តោតសំខាន់ស្តីពីការដាក់បញ្ចូលហិរញ្ញវត្ថុ និងការអភិវឌ្ឍកម្មវិធីមូលដ្ឋាន។ UNCDFបានធ្វើការក្នុងវិស័យជាច្រើន រួមមាន ការផ្តល់អំណាចដល់យុវជន ប្រសិទ្ធភាពថាមពល និងការប្រែប្រួលអាកាសធាតុ។ គម្រោងបរិស្ថានខ្លះ រួមមាន LGCC និងការរស់នៅដោយបន្សាំនឹងអាកាសធាតុមូលដ្ឋាន (LoCAL)។ ក្នុងឆ្នាំ២០១៥ ៨០% នៃមូលនិធិសរុបត្រូវបានប្រើប្រាស់ ដើម្បីគាំទ្រដល់រដ្ឋាភិបាលមូលដ្ឋាននូវគំនិតផ្តួចផ្តើមបន្សាំការប្រែប្រួលអាកាសធាតុ។ ចន្លោះឆ្នាំ២០១៥-២០១៦ អង្គការនេះបានផ្តល់ថវិកាលើគម្រោងចំនួន៦៤ នៅក្នុងភាពបន្សាំការប្រែប្រួលអាកាសធាតុ។ |
| USAID | ខ្ពស់ | ទំនាក់ទំនងផ្ទាល់ | លោក Polly Dunford, Mission Director USAID/Cambodia<br>ស្ថានទូតអាមេរិក ប្រចាំនៅរាជធានីភ្នំពេញ<br>No 1, Street 96, Wat Phnom, Daun Penh, Phnom Penh, Cambodia<br>Phone +855 (23) 728 300<br>Fax +855 (23) 430 263 | រដ្ឋាភិបាល | ទីភ្នាក់ងារ USAID បានដាក់ឱ្យដំណើរការកម្មវិធីកែច្នៃសំណល់ទីក្រុង (MWRP) នៅតំបន់អាស៊ីអាគ្នេយ៍ (បច្ចុប្បន្នមានតែប្រទេសវៀតណាម ស្រីលង្កា និងហ្វីលីពីនប៉ុណ្ណោះ)។ កម្មវិធីមានរយៈពេល ៤ឆ្នាំ មានគោលបំណង ដើម្បីដោះស្រាយបញ្ហាគ្រប់គ្រងសំណល់នៅក្នុងតំបន់ ដោយកាត់បន្ថយបរិមាណសំណល់ប្លាស្ទិក។ កម្មវិធីនេះ គឺមិនទាន់បានត្រូវបានបើកដំណើរការនៅក្នុងប្រទេសកម្ពុជាទេ។ ទោះយ៉ាងណា ទីភ្នាក់ងារ USAID បានគាំទ្រកម្មវិធីយុទ្ធសាស្ត្រអភិវឌ្ឍន៍ការបំភាយតិច (LEDS) និងគំនិតផ្តួចផ្តើមបច្ចេកវិទ្យាស្អាត ដោយ Private Finance Advisory Network ផ្តួចផ្តើមនូវគម្រោងថាមពលស្អាត។ ទន្ទឹមនឹងនេះ USAID ក៏បានផ្តល់ថវិកាដល់គម្រោងបរិស្ថានផ្សេងទៀតផងដែរ ដូចជា គម្រោងផ្តោតលើព្រៃឈើ និងគ្រប់គ្រងធនធានធម្មជាតិ។ |
| World Bank | ខ្ពស់ | ទំនាក់ទំនងដោយផ្ទាល់ | 113 Norodom Blvd.<br>Phnom Penh<br>Tel: +855 23 861 300<br>Fax: +855 23 861 | ជំនួយពហុស្ថាប័ន | ថ្វីត្បិតតែ មូលនិធិរបស់ធនាគារពិភពលោកមិនមានមិនរួមបញ្ចូលការគ្រប់គ្រងសំណល់នៅក្នុងប្រទេសកម្ពុជា ក៏ពេលបច្ចុប្បន្ន វិស័យនេះត្រូវបានគេចាត់ទុកថា ជាផ្នែកមួយអាទិភាព។ ធនាគារពិភពលោកផ្តល់ហិរញ្ញវត្ថុ និងប្រឹក្សា |

| ឈ្មោះម្ចាស់ជំនួយ | អាទិភាព | សំគាល់ | អាសយដ្ឋានទំនាក់ទំនង | ប្រភេទម្ចាស់ជំនួយ | គោលការណ៍ផ្តល់ជំនួយ (រួមទាំងឱកាស និងហានិភ័យ) |
|---|---|---|---|---|---|
| | | | 301/302 | | ស្តីពីការគ្រប់គ្រងសំណល់តាមរយៈការផ្តល់នូវមធ្យោបាយជា "ប្រាក់កម្ចីបែបប្រពៃណី ហិរញ្ញប្បទានអាស្រ័យនឹងលទ្ធផលហិរញ្ញប្បទានរៀបចំគោលនយោបាយអភិវឌ្ឍន៍ និងទីប្រឹក្សាបច្ចេកទេស "។ World Bank ផ្តោតលើវដ្តទូទៅនៃសំណល់រាប់ចាប់ពី ការបង្វែរពីការចោលសំណល់ទៅកែច្នៃ និងប្រព្រឹត្តកម្មសំណល់។ តាមរយៈយុទ្ធសាស្ត្រចូលរួមរបស់ប្រទេសសាមីខ្លួន គម្រោងរបស់ធនាគារពិភពលោកបានចូលរួមផងដែរជាមួយនឹងវិស័យដឹកជញ្ជូន ថាមពល និងភាពធន់ទ្រាំនឹងគ្រោះមហន្តរាយ។ |
| **វិស័យឯកជន** | | | | | |
| IKEA Foundation | មធ្យម | មិនទទួលយកសំណើដែលមិនបានស្នើសុំ | មិនមានព័ត៌មានទំនាក់ទំនង www.ikeafoundation.org/contact-us/ | មូលនិធិឯកជន | មូលនិធិ IKEA ផ្តោតការយកចិត្តទុកដាក់របស់ខ្លួនលើ ៤ វិស័យធំៗ ដូចជា៖ លំនៅដ្ឋាន សុខភាព ការអប់រំលើកុមារ និងប្រាក់ចំណូល។ IKEA បានជួយគាំទ្រដល់ក្រុមហ៊ុន We Mean Business ដែលមានជំនួយប្រាក់ ៤០លានអឺរ៉ូ។ គោលបំណងនៃការផ្តល់ជំនួយនេះ គឺដើម្បីផ្តល់នូវការលើកទឹកចិត្ត និងគាំទ្រដល់អាជីវកម្មនានាដើម្បីអនុវត្តដំណោះស្រាយការប្រែប្រួលអាកាសធាតុ ការរកប្រភពថាមពលកកើតឡើងវិញ ១០០% ដើម្បីជួយកាត់បន្ថយ ហានិភ័យប្រែប្រួលអាកាសធាតុ ដែលគ្រប់សហគមន៍ទាំងអស់បានជួបប្រទះ។ ទោះយ៉ាងណា រហូតមកដល់ពេលនេះ IKEA បានសហការជាមួយអង្គការ Save the Children ដើម្បីដោះស្រាយវិស័យអប់រំស្តីពីសុវត្ថិភាព។ |
| H&M | មធ្យម | | Corporate Governance Liv Asarnoj Tel: +46 8 796 55 00 | សាជីវកម្ម | ចក្ខុវិស័យរបស់ក្រុមហ៊ុន H & M គឺដើម្បីបង្កើតឧស្សាហកម្មម៉ូតនិរន្តរភាព។ នៅឆ្នាំ២០១៥ គ្រឹះស្ថាន H & M បានផ្តួចផ្តើមនូវពានរង្វាន់ Global Innovation Challenge - Global Change Award ដើម្បីស្វែងរកភាពច្នៃប្រឌិតថ្មីកែច្នៃវាយនភ័ណ្ឌ។ |
| Mitsui | High | | Mitsui & Co., Ltd. អាសយដ្ឋាន No. 29A, ផ្លូវម៉ៅសេទុង (St. 245), 12302 ភ្នំពេញ កម្ពុជា Tel: +855 23 217 548 | សាជីវកម្ម | តំបន់សំខាន់ៗចំនួន ៣ របស់ Mitsui គឺការផ្លាស់ប្តូរជាអន្តរជាតិលើវិស័យអប់រំ និងបរិស្ថាន។ នៅក្នុងវិស័យបរិស្ថាន Mitsui មានគោលបំណងដោះស្រាយបញ្ហាបរិស្ថាន និងបង្កើតបរិយាកាសប្រកបដោយនិរន្តរភាព និងសុខដុមរមនានៅក្នុងប្រទេសជប៉ុន និងនៅក្រៅប្រទេស។ ជាទូទៅ Mitsui បានផ្តល់មូលនិធិដល់គម្រោងបរិស្ថានចំនួន ៥៤៨ នៅទូទាំងពិភពលោកដែលផ្តោតលើផ្នែកសំខាន់ៗចំនួន៤ គឺ បរិស្ថានពិភពលោក ធនធានចក្រា សង្គមបែបប្រព័ន្ធអេកូ និងសង្គមរួបរួមគ្នា - ទំនាក់ទំនងសង្គម និងប្រជាពលរដ្ឋ។ |
| Unilever | ខ្ពស់ | | No. 443A ផ្លូវ 105 សង្កាត់បឹងព្រលិត ខណ្ឌ7មករា | សាជីវកម្ម | Unilever ប្តេជ្ញាបង្កើតសេដ្ឋកិច្ចចក្រា និងកាត់បន្ថយផលប៉ះពាល់បរិស្ថានតាមរយៈគម្រោងការ |

| ឈ្មោះម្ចាស់ជំនួយ | អាទិភាព | សំគាល់ | អាសយដ្ឋាន ទំនាក់ទំនង | ប្រភេទម្ចាស់ជំនួយ | គោលការណ៍ផ្តល់ជំនួយ (រួមទាំងឱកាស និងហានិភ័យ) |
|---|---|---|---|---|---|
| | | | រាជធានីភ្នំពេញ<br>Tel: +855 23 990 055<br>Email:<br>Monica.Soy@unilever.com<br>Website:<br>www.unilever.com | | រស់នៅប្រកបដោយចីរភាពរបស់ក្រុមហ៊ុន Unilever ។ ក្រុមហ៊ុន Unilever បានយកសំណល់សូន្យទៅជាយុទ្ធសាស្រ្តក្នុងការគ្រប់គ្រងសំណល់របស់ខ្លួន ដោយដោះស្រាយកែច្នៃកញ្ចប់សំណល់អាហារដែលខ្លួនបានប្រើ។ |
| Chevron | ខ្ពស់ | | ផ្លូវ ២៧៤ ជាន់ទី៤ Phnom Penh Center<br>សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន ភ្នំពេញ<br>កម្ពុជា | សាជីវកម្ម | ចាប់តាំងពីឆ្នាំ ២០១៤ មកក្រុមហ៊ុន Chevron បានរៀបចំយុទ្ធនាការជាច្រើននៅទូទាំងប្រទេសកម្ពុជា ដើម្បីដោះស្រាយបញ្ហាបរិស្ថានដូចជាយុទ្ធនាការសម្អាតតាមបណ្តោយឆ្នេរអូរឈើទាលនៅក្រុងសីហានុ និងនៅសាលាបឋមព្រែកលៀបក្នុងរាជធានីភ្នំពេញ។ |
| Coca Cola | ខ្ពស់ | ទំនាក់ទំនងផ្ទាល់ | អាសយដ្ឋាន #287, ភូមិមិត្តភាព ខណ្ឌឬស្សីកែវ រាជធានីភ្នំពេញ<br>ប្រទេសកម្ពុជា<br>Tel: +855 23 428 995<br>Website:<br>www. thecoca-colacompany. com<br>Email:<br>llina@coca-cola.com.kh | សាជីវកម្ម | កូកាកូឡា ផ្តោតលើ ៣ចំណុចសំខាន់ៗ:<br>- ស្ត្រី: ការផ្តល់អំណាចផ្នែកសេដ្ឋកិច្ច និងភាពជាសហគ្រិន<br>- ទឹក: ការទទួលបានទឹកស្អាត ការអភិរក្សទឹក និងការកែច្នៃឡើងវិញ<br>- សុខុមាលភាព: ការអប់រំ ការអភិវឌ្ឍយុវជន និងគំនិតផ្តួចផ្តើមបែបសហគមន៍ និងសង្គម<br>នៅប្រទេសកម្ពុជា អង្គការនេះបានឧបត្ថមកម្មវិធីកែច្នៃទឹកដោយសហការជាមួយ Cambodian Women for Peace and Development (CWPD) និងអង្គការ UN-HABITAT ដើម្បីធានាលទ្ធភាពទទួលបានទឹកស្អាតប្រើប្រាស់ ប្រសិទ្ធភាពប្រើប្រាស់ទឹកស្អាត និងការគ្រប់គ្រងទឹកសំអុយក្នុងប្រតិបត្តិការរបស់ខ្លួន។ ក្រុមហ៊ុនកូកាកូឡាកម្ពុជាក៏បានគាំទ្រមូលនិធិទឹកស្អាតផងដែរ ដើម្បីអនុវត្តកម្មវិធីបណ្តុះបណ្តាលអនាម័យ និងការដាក់ប្រព័ន្ធចម្រោះទឹកស្អាត និងប្រកបដោយសុវត្ថិភាពដល់សហគមន៍ជនបទនៅកម្ពុជា។ |
| C&A Foundation | ទាប | ទំនាក់ទំនងផ្ទាល់ | www.candafoundation.org/who-we-are/contact-us/ | សាជីវកម្ម | មូលនិធិ C & A បានប្រើប្រាស់យុទ្ធសាស្ត្រម៉ូដចក្រា ដែលស្វែងរកនូវគំនិតច្នៃប្រឌិតថ្មីក្នុងការផលិតសំលៀកបំពាក់តាមរយៈការប្រើប្រាស់ឡើងវិញ (សំដៅទៅលើការកែច្នៃវាយនភ័ណ្ឌ)។ នៅឆ្នាំ២០១៦ ក្រុមហ៊ុននេះបានផ្តល់មូលនិធិចំនួន ២៥០.០០០អឺរ៉ូ ដល់សេដ្ឋកិច្ចចក្រា ដែលជាសហគ្រាសសហគមន៍សំដៅលើការកែច្នៃវាយនភ័ណ្ឌ។ មូលនិធិ C & A ក៏បានគាំទ្រគំនិតផ្តួចផ្តើម "សមុទ្រគ្មានប្លាស្ទិក" ជាមួយនឹងមូលនិធិ ៥០.០០០ អឺរ៉ូ ដើម្បីដោះស្រាយបញ្ហាសំណល់ប្លាស្ទិកក្នុងមហាសមុទ្រ និងទន្លេ។ |

| ឈ្មោះម្ចាស់ជំនួយ | អាទិភាព | សំគាល់ | អាសយដ្ឋានទំនាក់ទំនង | ប្រភេទម្ចាស់ជំនួយ | គោលការណ៍ផ្តល់ជំនួយ (រួមទាំងឱកាស និងហានិភ័យ) |
|---|---|---|---|---|---|
| Citi Bank | មធ្យម | ទាក់ទងដោយផ្ទាល់ | www.citibank.com/citi/contact/form.htm?foundation | សាជីវកម្ម | Citibank មានគោលបំណងដោះស្រាយបញ្ហាទាក់ទងនឹងហេដ្ឋារចនាសម្ព័ន្ធ លំនៅដ្ឋានសមរម្យ និរន្តរភាពបរិស្ថាន ហិរញ្ញវត្ថុ និងបរិយាប័ន្នហិរញ្ញវត្ថុតាមរយៈការអនុវត្តន៍បច្ចេកវិទ្យាជឿនលឿន។<br>ក្នុងវិស័យបរិស្ថាន Citibank ប្តេជ្ញាផ្តល់ហិរញ្ញប្បទានឥតសំណងចំនួន ១០០ពាន់លានដុល្លារអាមេរិកទៅក្នុងគម្រោងថាមពលស្អាត បច្ចេកវិទ្យា និងគម្រោងហេដ្ឋារចនាសម្ព័ន្ធសម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ចប្រកបដោយនិរន្តរភាព។ |

## ៣. ហិរញ្ញប្បទានកាបូន

សំណល់ជីវៈនៅទីលានចាក់សំរាមបង្កើតជាឧស្ម័នមេតាន ដែលជាប្រភេទឧស្ម័នផ្ទះកញ្ចក់ដ៏មានឥទ្ធិពល (GHG) (សូមមើលសកម្មភាពចម្បងទី៣) ដោយសារវាមានសក្តានុពលកម្តៅផែនដីដ៏ខ្ពស់ជាង ឧស្ម័នកាបូនឌីអុកស៊ីត។ ក្នុងចំណោមឧស្ម័នផ្ទះកញ្ចក់ ឧស្ម័នមេតានមានលក្ខណៈពោរពេញទៅដោយថាមពល និងបម្លែងទៅជាឧស្ម័នកាបូនឌីអុកស៊ីតនៅក្នុងដំណើរការនៃការបង្កើតថាមពល ដែលមានន័យថាគេអាចចាប់យកឧស្ម័នមេតាន និងប្រើផលិតជាថាមពលអគ្គិសនីបាន។ លើសពីនេះទៀត នៅពេលដែលប្រទេសកម្ពុជាជាប្រទេសហត្ថលេខីលើពិធីសារក្យូតូ ដែលគេអាចធ្វើពាណិជ្ជកម្មឧស្ម័នកាបូន ជាមួយនឹងបណ្តាប្រទេសអភិវឌ្ឍន៍ និងកំពុងអភិវឌ្ឍន៍បាន។

ការកាត់បន្ថយការបំភាយឧស្ម័ន GHG ពីវិស័យសំណល់ដូចជា តាមរយៈការចាប់យកឧស្ម័នមេតាន អាចបម្លែងទៅជាអត្រាកាត់បន្ថយការបំភាយឧស្ម័ន ដែលគេជួញដូរនៅលើទីផ្សារកាបូន (CER)។ យន្តការឥណទានទ្វេភាគីមានដូចជា យន្តការឥណទានរួមគ្នានៃប្រទេសជប៉ុន (JCM) ជាការផ្តល់ហិរញ្ញប្បទានដល់ការវិនិយោគលើបច្ចេកវិទ្យាបញ្ចេញកាបូនតិចនៅក្នុងប្រទេសហត្ថលេខី (ដូចជាប្រទេសកម្ពុជា) ដើម្បីធានាការកាត់បន្ថយ GHG អាចត្រូវបានប្រើប្រាស់រួមគ្នា ដោយប្រទេសជប៉ុន និងប្រទេសហត្ថលេខី ដើម្បីសម្រេចគោលដៅកាត់បន្ថយការបំភាយ GHG រៀងៗខ្លួន។

មូលនិធិអាកាសធាតុសាកល (GCF) គឺជាមូលនិធិសាកលថ្មីមួយ (យន្តការហិរញ្ញវត្ថុ) ដែលបានបង្កើតឡើងក្រោយពីកិច្ចព្រមព្រៀងទីក្រុងប៉ារីស ស្តីពីការប្រែប្រួលអាកាសធាតុក្នុងគោលបំណងគាំទ្រដល់កិច្ចខិតខំប្រឹងប្រែងរបស់បណ្តាប្រទេសកំពុងអភិវឌ្ឍន៍ក្នុងការឆ្លើយតបទៅនឹងការប្រែប្រួលអាកាសធាតុ។ មូលនិធិត្រូវបានផ្តល់ជូនជាជំនួយឥតសំណង ប្រាក់កម្ចីដោយសមភាពដល់អង្គភាពដែលគេទទួលស្គាល់ជាផ្លូវការ (នៅក្នុងប្រទេសកម្ពុជា គឺ ក្រសួងបរិស្ថាន ឬរដ្ឋបាលរាជធានីភ្នំពេញ ឬភាពជាដៃគូគ្នា) សម្រាប់គម្រោងដោះស្រាយការកាត់បន្ថយការបំភាយឧស្ម័ន។

គម្រោងមួយចំនួន ដែលបញ្ជាក់ពីការបំភាយឧស្ម័នកាបូនពីសំណល់រឹងទីប្រជុំជន ត្រូវបានចុះបញ្ជីនៅក្នុងតំបន់ (ឧទា. ប្រទេសវៀតណាម និងឥណ្ឌូនេស៊ី)។ អ្នកអភិវឌ្ឍន៍គម្រោងនៅកម្ពុជាអាចបង្កើតគម្រោងដោយផ្អែកលើបទពិសោធន៍ និងបច្ចេកវិជ្ជាដែលបានប្រើនៅក្នុងគម្រោងកន្លងមក ដែលទាមទារឱ្យមានអភិបាលកិច្ចល្អ និងប្រព័ន្ធតាមដានដ៏រឹងមាំ ដើម្បីអនុវត្តគម្រោងហិរញ្ញប្បទានកាបូនប្រកបដោយជោគជ័យនៅក្នុងវិស័យសំណល់។

## ៤. ភាពជាដៃគូរវាងវិស័យឯកជន-សាធារណៈ

ការបង្កើនភាពជាដៃគូសាធារណៈ-ឯកជន (PPP) បានលេចឡើងជាមធ្យោបាយមួយ ដើម្បីធ្វើឱ្យប្រសើរឡើងនូវការផ្តល់សេវាសំណល់រឹងរបស់ទីក្រុងដែលពួកគេអាចចំណាយតិច។ ការចូលរួមចំណែកគ្នារវាងវិស័យឯកជនក្នុងប្រព័ន្ធគ្រប់គ្រងសំណល់នឹងធ្វើឱ្យប្រសើរឡើងនូវប្រសិទ្ធភាព និងសក្តានុពលតាមរយៈការគ្រប់គ្រងល្អ ការវិនិយោគ និងបច្ចេកវិទ្យាថ្មី។

ខាងក្រោមនេះ គឺជាការផ្តល់យោបល់មួយចំនួន អំពីរបៀបជាគំរូរបស់ PPP និង PSP ដែលអាចដាក់បញ្ចូលជាប្រព័ន្ធនៅប្រទេសកម្ពុជា។

## និន្នាការថ្មីៗ ដោយសហគ្រាសឯកជននៅក្នុងឧស្សាហកម្មកែច្នៃឡើងវិញ

### ក្រុមហ៊ុន Twinagri

- Twinagri គឺជាក្រុមហ៊ុនកសិកម្មក្នុងស្រុកមួយ ដែលមានមូលដ្ឋាននៅសិង្ហបុរី ដែលមានឯកទេសក្នុងការស្រាវជ្រាវ និងផ្តល់បច្ចេកទេសកសិកម្មថ្មីនៅតំបន់អាស៊ីអាគ្នេយ៍។ នៅក្នុងប្រទេសកម្ពុជា ក្រុមហ៊ុននេះផ្តោតសំខាន់ទៅលើការកែច្នៃសំណល់ជីវៈទៅជាជី ដែលត្រូវបានចែកចាយទៅកសិដ្ឋាននៅប្រទេសកម្ពុជា ហើយក៏ផ្តល់ផងដែរនូវការបណ្តុះបណ្តាលកសិកម្មដល់កសិករក្នុងតំបន់។ បច្ចុប្បន្ន ក្រុមហ៊ុននេះបានក្លាយទៅជាអ្នកផ្គត់ផ្គង់ជីសម្រាប់ក្រុមហ៊ុន ម៉ុង ឫទ្ធី គ្រុប ដែលជាក្រុមហ៊ុនកសិកម្មធំបំផុតរបស់ប្រទេសកម្ពុជា
- ក្រុមហ៊ុននេះបានលើកឡើងពីលទ្ធភាពកែច្នៃកញ្ចក់ទៅជាដីខ្សាច់ ដែលអាចប្រើជាសមាសធាតុសម្រាប់ការផលិតជីសរីរាង្គផងដែរ។ ដោយហេតុថាកញ្ចក់ត្រូវបានគេផលិតឡើងពីដីខ្សាច់ ម៉ាស៊ីនកម្ទេចកញ្ចក់អាចត្រូវបានប្រើ ដើម្បីបំបែកវាទៅសមាសធាតុដើមរបស់វា ដែលអាចរួមមាន ផេះសូដា ដីខ្សាច់ និងថ្មកំបោរ ដែលបន្ទាប់មកគេអាចញែកវា ហើយប្រើប្រាស់ឡើងវិញ។

### ក្រុមហ៊ុនកែច្នៃ Gomi Recycle 101

- ក្រុមហ៊ុន Gomi Recycle ១០១ ជាក្រុមហ៊ុនជប៉ុនមួយ ដែលមានឯកទេសក្នុងការកែច្នៃសំណល់ប្លាស្ទិក និងសំណល់កៅស៊ូ ទៅជាគ្រឿងបន្លាស់សង្ហារឹម។ សម្រាប់ឆ្នាំ២០១៦ ក្រុមហ៊ុនមានផែនការរបស់ខ្លួនក្នុងការវិនិយោគលើរោងចក្រកែច្នៃឡើងវិញ នៅខេត្តស្វាយរៀង ដើម្បីផលិតផលិតផលកែច្នៃចុងក្រោយសម្រាប់ទីផ្សារក្នុងស្រុក។

### ក្រុមហ៊ុន Chipmong និង តំបន់សេដ្ឋកិច្ចពិសេស

- ក្រុមហ៊ុន Chipmong ជាសាជីវកម្មធំបំផុតមួយរបស់ប្រទេសកម្ពុជា កំពុងសម្លឹងមើលការវិនិយោគលើឡស៊ីម៉ងត៍។ ក្រុមហ៊ុននេះកំពុងស្វែងរកការទិញសំណល់ឧស្សាហកម្ម ដែលមានអនុភាពកម្តៅខ្ពស់ ដែលអាចប្រើជាមួយ ឬជំនួសធ្យូងថ្ម។ បច្ចុប្បន្ននេះ សំណល់ឧស្សាហកម្មនៅក្នុងតំបន់សេដ្ឋកិច្ចពិសេសភ្នំពេញ ត្រូវបានប្រមូលដោយក្រុមហ៊ុន SAROM Trading ។ ទោះជាយ៉ាងណាក៏ដោយ PPSEZ កំពុងសហការជាដៃគូជាមួយ UNDP ដើម្បីស្វែងរកវិធីដែលអាចធ្វើទៅបានក្នុងការកែលម្អការគ្រប់គ្រងសំណល់នៅតំបន់របស់ខ្លួន ដោយមានការបណ្តាក់ទុនរួមជាមួយក្រុមហ៊ុន Twinagri និងក្រុមហ៊ុន Gomi Recycle ដើម្បីដោះស្រាយបញ្ហាប្រឈមនៃការគ្រប់គ្រងសំណល់ជាម៉ូដែលគំរូអាជីវកម្មមួយ។

**តួនាទីរាជរដ្ឋាភិបាលក្នុងការសម្របសម្រួលការអភិវឌ្ឍឧស្សាហកម្មកែច្នៃ**
**(សកម្មភាពចម្បងទី២)**

សម្រាប់ទាក់ទាញអ្នកចូលរួមថ្មីទៅក្នុងវិស័យនេះឱ្យមាននិរន្តរភាព គេទាមទារឱ្យមានការគាំទ្រយ៉ាងធំធេង និងការចូលរួមយ៉ាងសកម្មពីស្ថាប័នរដ្ឋាភិបាល និងទីភ្នាក់ងារអភិវឌ្ឍន៍ផ្សេងៗ។ ដើម្បីជាជំនួយនៅក្នុងយុទ្ធសាស្ត្រនេះ វេទិកាមួយដែលមានលក្ខណៈងាយស្រួលអាចចូលរួមដំណើរការ និងទទួលបាននូវព័ត៌មានលម្អិតអំពីម្ចាស់ជំនួយ និងវិនិយោគិនសំខាន់ៗ នឹងផ្តល់នូវអត្ថប្រយោជន៍ខ្ពស់សម្រាប់ក្រុមហ៊ុនបែបនេះ។ វេទិកានេះក៏អាចដើរតួជាមធ្យោបាយទំនាក់ទំនងរវាងក្រុមហ៊ុន និងអ្នកទិញ។ ក្នុងករណីនេះ រដ្ឋាភិបាលអាចដើរតួយ៉ាងសំខាន់ក្នុងការត្រួសត្រាយផ្លូវសម្រាប់ទីផ្សារកែច្នៃឡើងវិញ ដោយការលើកទឹកចិត្តការវិនិយោគ (ឧ. តាមរយៈការកាត់បន្ថយពន្ធ) ការជំរុញតម្រូវការ និងការជួញដូរផលិតផលកែច្នៃឡើងវិញ ក៏ដូចជាការបង្កើតប្រព័ន្ធអេកូឡូស៊ីចង្វាក់ផ្គត់ផ្គង់ផលិតផលកែច្នៃ ដែលដាក់បញ្ចូល និងតភ្ជាប់គ្រប់ភាគីពាក់ព័ន្ធទាំងអស់។

## ឧបសម្ព័ន្ធទី៤. គំរូគណនាការចំណាយលើការអនុវត្តន៍

តារាងខាងក្រោមផ្តល់នូវការប៉ាន់ស្មានតម្លៃគំរូ សម្រាប់ការអនុវត្តន៍សកម្មភាពនៃយុទ្ធសាស្ត្រនេះ។ ការប៉ាន់ប្រមាណនេះត្រូវបានគណនាឡើងដោយសិក្ខាកាមនៃអង្គសិក្ខាសាលារៀបចំយុទ្ធសាស្ត្រលើកចុងក្រោយ និងក្រុមការងារពង្រាងយុទ្ធសាស្ត្រជាតួលេខបឋមសម្រាប់ការពិភាក្សានាពេលអនាគត។ គំរូការចំណាយសម្រាប់ការអនុវត្តន៍ជាក់ស្តែង នៃសកម្មភាពនីមួយៗរបស់យុទ្ធសាស្ត្រនេះមានដូចតទៅ៖

**<u>សកម្មភាពចម្បងទី១៖ គំរូការចំណាយលើការផ្សព្វផ្សាយព័ត៌មានដល់ប្រជាពលរដ្ឋ ស្តីពីការគ្រប់គ្រងសំណល់</u>**

- កន្លះថ្ងៃ x ១០០ នាក់ x ១០ ដងក្នុងមួយឆ្នាំ
- អ្នកចូលរួមរំពឹងទុក៖ រដ្ឋបាលខណ្ឌ សង្កាត់ ប្រជាពលរដ្ឋ និងភាគីអ្នកបង្កើតសំណល់ផ្សេងៗទៀត

| | **ខ្ទង់ថវិកា** | **ចំណាយប៉ាន់ស្មាន** (USD) |
|---|---|---|
| ១ | ទីកន្លែងប្រជុំ និងឧបករណ៍ | ៥០០ |
| ២ | ការផ្តល់អាហារ | ៥០០ |
| ៣ | ចំណាយដឹកជញ្ជូនសម្រាប់អ្នកចូលរួម | ២៥០ |
| ៤ | សម្ភារប្រជុំសម្រាប់អ្នកចូលរួម | ២០០ |
| ៥ | ផ្ទាំងបដា និងផ្ទាំងខាងក្រោយ | ២០០ |
| ៦ | បម្រុងចំណាយផ្សេងៗ | ៣៥០ |
| | សរុបបឋម | ២,០០០ |
| | **សរុបសម្រាប់ព្រឹត្តិការណ៍ចំនួន ១០** | **២០,០០០** |

## សកម្មភាពចម្បងទី ២: ការប៉ាន់ប្រមាណតម្លៃសម្រាប់សិក្ខាសាលា ដើម្បីជំរុញសកម្មភាពស្ម័គ្រចិត្តថ្នាក់មូលដ្ឋាន

- ពេញមួយថ្ងៃ x ១០ ថ្ងៃ x ១០០ នាក់ x ៤ ដង / ឆ្នាំ
- អ្នកចូលរួមរំពឹងទុក: ប្រជាពលរដ្ឋមូលដ្ឋាន ម្ចាស់អាជីវកម្ម

| | **ខ្ទង់ថវិកា** | **ចំណាយប៉ាន់ស្មាន** (USD) |
|---|---|---|
| ១ | បន្ទប់ប្រជុំនិងប្រព័ន្ធផ្សព្វផ្សាយ | ៥០០ |
| ២ | សម្រាកអាហារសំរ៉ន់ & អាហារថ្ងៃត្រង់ | ៣.០០០ |
| ៣ | សម្ភារសម្រាប់សិក្ខាសាលា | ១.០០០ |
| ៤ | ផ្ទាំងខាងក្រោយ | ២៥០ |
| ៥ | បំរុងចំណាយផ្សេងៗ | ៥០០ |
| | សរុបបឋម | ៥.២៥០ |
| | **សរុបសម្រាប់ ១០ ព្រឹត្តិការណ៍** | **៥២.៥០០** |

## សកម្មភាពចម្បងទី៣៖ គំរូការចំណាយលើការធ្វើឱ្យទីលានចាក់សំរាមប្រសើរឡើងវិញ

- ផ្អែកលើការគណនា សិក្ខាកាមនៃអង្គសិក្ខាសាលាបានសន្និដ្ឋានថា ថ្លៃចាក់សំរាមចោល / ថ្លៃទីលាន ដែលត្រូវបានគិតសម្រាប់រថយន្តដឹកសំរាមចូលចាក់នៅទីលាន ត្រូវបង្កើនដល់ ៣,៥០ ដុល្លារ/តោន ជាអប្បបរមា ដើម្បីគ្របដណ្តប់លើថ្លៃប្រតិបត្តិការនៅក្នុងតារាងដូចខាងក្រោម៖

| | **ខ្ទង់ថវិកា** | **ចំណាយប៉ាន់ស្មាន** (USD) |
|---|---|---|
| ១ | ឧបករណ៍/គ្រឿងចក្រកុញសំរាម Bulldozers = USD ២០០.០០០ × ៧ គ្រឿង = | ១.៤០០.០០០ |
| ២ | គ្រឿងចក្រកិនបង្ហាប់ = ២០០.០០០ ដុល្លារអាមេរិក = ៣ គ្រឿង = | ៦០០.០០០ |
| ៣ | កម្មករ/បុគ្គលិក = USD ១៧០ × ៥០ នាក់ = | ៨.៥០០ |
| ៤ | ការចំណាយលើការជួសជុល និងថែទាំសម្ភារ (ម៉ាស៊ីនរុញ និងកិនបង្ហាប់) | ១០០.០០០ |
| ៥ | វេទិកាចាក់សំរាម (ដែកថែបសម្រាប់គ្របផ្លូវសម្រាប់រថយន្តដឹកទៅចូលកន្លែងចាក់សំរាម) = USD ១០០ × ១.២០០ = | ១២០.០០០ |
| ៦ | បាញ់ប្រឆាំងក្លិនស្អុយ = ៦០០ ដុល្លារ រៀល | ៧.២០០ |
| ៧ | ចំណាយឧបករណ៍ប្រើប្រាស់ / ប្រេងម៉ាស៊ីន / ប្រេងឥន្ធនៈ = ២០.០០០ × ១២ ខែ | ២៤០.០០០ |

| | ខ្ទង់ថវិកា | ចំណាយប៉ាន់ស្មាន (USD) |
|---|---|---|
| ៨ | គម្របដី = ៣៥០.០០០USD | ៥០០.០០០ |
| ៩ | ប្រព័ន្ធទឹកសំអុយទីលាន / ប្រព្រឹត្តកម្ម = USD ៥០.០០០ | ១០០.០០០ |
| ១០ | ជញ្ជីង = USD ៥០.០០០ / ឆ្នាំ | ៥០.០០០ |
| ១១ | ផ្លូវឡាន = ៧ ម៉ែត្រ × ២.០០០ × USD 30 = | ៤២.០០០ |
| ១២ | ការដាំដើមឈើ (កម្លាំងពលកម្ម: ៥ ដុល្លារអាមេរិក x ២០០ កម្មករ) / ឆ្នាំ = | ១.០០០ |
| ១៣ | របងសម្រាប់ទីលានចាក់សំរាម (២ × ២០ × ៤.៤០០ ម) | ១៧៦.០០០ |
| ១៤ | អគារថ្មី / ការិយាល័យ | ៤០.០០០ |
| ១៥ | ការចំណាយផ្សេងទៀត | ២០.០០០ |
| ១៦ | មណ្ឌលកែច្នៃ (MRF) | ៥០០.០០០ |
| | **សរុបក្នុងមួយឆ្នាំ** | **៣.៩០៤.៧០០** |

**សកម្មភាពចម្បងទី ៥: គំរូគណនាការចំណាយលើការផ្សព្វផ្សាយអប់រំបរិស្ថាន**

- ការដាក់ធុងសំរាមនៅទីសាធារណៈ ដើម្បីលើកកម្ពស់ការញែកសំណល់នៅប្រភព
- ការផ្សព្វផ្សាយជាសាធារណៈតាមប្រព័ន្ធផ្សព្វផ្សាយចម្រុះ

| | ខ្ទង់ថវិកា | ចំណាយប៉ាន់ស្មាន (USD) |
|---|---|---|
| ១ | ធុងសំរាមញែកនៅប្រភព x ១០០ គ្រឿង | ១៩.០០០ |
| ២ | អាវយឺតមានការយល់ដឹង x ១០០០ គ្រឿង | ១០.០០០ |
| ៣ | ក្រដាសពណ៌ x ១០០០ ច្បាប់ចម្លង | ៣០០ |
| ៤ | ផ្ទាំងបដានៅទូទាំងផ្លូវ x ៥០ គ្រឿង | ២.៥០០ |
| ៥ | ផលិតកម្ម និងផ្សាយកម្មវិធីអប់រំតាមរយៈទូរទស្សន៍និង SNS: ១ នាទី x ២ វីដេអូខ្លី | ១០.០០០ |
| ៦ | ជួលម៉ូតូកង់បីចំនួន ១០ គ្រឿង x ២ ខែសម្រាប់ការផ្សាយប្រចាំថ្ងៃ លើកកម្ពស់ការយល់ដឹង | ១២.០០០ |
| ៧ | ការចំណាយផ្សេងទៀត | ៥០០ |
| | **សរុបក្នុងមួយឆ្នាំ** | **៥៤.៣០០** |

## ឧបសម្ព័ន្ធទី៥. ការបែងចែកតួនាទី និងភារកិច្ច

យោងតាមខ្លឹមសារពង្រាងសេចក្តីណែនាំ ស្តីពីការអនុវត្តន៍ភារកិច្ចកែលម្អការងារគ្រប់គ្រងការសម្អាតសំរាម សំណល់រឹង នៅរាជធានីភ្នំពេញ ដែលបច្ចុប្បន្នកំពុងត្រូវបានធ្វើសេចក្តីព្រាង ដើម្បីផ្តល់ភាពច្បាស់លាស់លើតួនាទីរបស់អ្នកពាក់ព័ន្ធផ្សេងៗ ក្នុងអភិបាលកិច្ចគ្រប់គ្រងសំណល់ និងការកែលម្អសេវាគ្រប់គ្រងសំណល់នៅរាជធានីភ្នំពេញ។

ពង្រាងសេចក្តីណែនាំនេះមានគោលបំណងចំនួន ១០ គឺ:

១. ជំរុញឱ្យមានការចូលរួមពីប្រជាពលរដ្ឋ និងអ្នកពាក់ព័ន្ធ ដើម្បីរួមសហការកែលម្អសោភ័ណភាព និងបរិស្ថានទីក្រុងឱ្យបានស្អាត

២. ពង្រឹងការងារផ្តល់សេវាកម្មរបស់ក្រុមហ៊ុន ដែលធ្វើសេវាសម្អាត ប្រមូល និងដឹកជញ្ជូនសំរាម សំណល់រឹងក្នុងរាជធានីភ្នំពេញឱ្យមានភាពប្រសើរឡើង

៣. ដាក់ចេញនូវកម្មវិធីការងារសម្អាត ប្រមូល និងដឹកជញ្ជូនសំរាម សំណល់រឹងនៅក្នុងរាជធានីភ្នំពេញឱ្យបានច្បាស់លាស់ ដើម្បីឱ្យការបោសសម្អាត ការប្រមូល និងដឹកជញ្ជូន ប្រព្រឹត្តទៅបានស៊ីសង្វាក់គ្នា

៤. ផ្លាស់ប្តូរឥរិយាបថប្រជាពលរដ្ឋឱ្យបញ្ឈប់ការចោលសំរាម សំណល់រឹងគ្មានសណ្តាប់ធ្នាប់តាមទីសាធារណៈ ងាកមកទុកដាក់សំរាមឱ្យបានត្រឹមត្រូវ តាមទីកន្លែង និងពេលវេលាដែលបានកំណត់

៥. អប់រំ ណែនាំប្រជាពលរដ្ឋឱ្យចេះទុកដាក់សំរាម សំណល់រឹងទៅតាមប្រភេទផ្សេងៗគ្នា ដើម្បីយកសំរាមមួយចំនួនទៅធ្វើការកែច្នៃ និងប្រើប្រាស់ឡើងវិញ ជាប្រយោជន៍កាត់បន្ថយនូវបរិមាណសំណល់ ដែលត្រូវយកទៅចាក់នៅទីលានចាក់សំរាមឱ្យនៅសល់តិចបំផុត

៦. កាត់បន្ថយនូវការប្រើប្រាស់ថង់ប្លាស្ទិក ដែលជាសំណល់មិនងាយរលាយ មកប្រើប្រាស់ជាថង់បរិស្ថានវិញ

៧. ជំរុញការពង្រីកសេវាសម្អាត ប្រមូល និងដឹកជញ្ជូនសំរាម សំណល់រឹង ឱ្យទៅដល់តំបន់ដែលពុំទាន់មានសេវាទៅដល់ ជាពិសេសតំបន់សង្កាត់ថ្មីទាំង២០ ដែលកាត់ចេញពីខេត្តកណ្តាល ចូលមកដែនដីរាជធានីភ្នំពេញ

៨. ស្វែងរកដៃគូវិនិយោគ ដើម្បីកែច្នៃសំណល់នៅទីលានចាក់សំរាម សម្រាប់ទាញយកប្រយោជន៍ផ្សេងៗដូចជា ថាមពលអគ្គិសនី ជីវឧស្ម័ន ជីវថាមពល និងជីកំប៉ុសជាដើម

៩. ពង្រឹងការអនុវត្តន៍ច្បាប់ឱ្យមានប្រសិទ្ធភាព លើការងារគ្រប់គ្រងសំរាម សំណល់រឹងនៅរាជធានីភ្នំពេញ

១០. រួមគិត រួមធ្វើ និងរួមទទួលខុសត្រូវ ដើម្បីធ្វើឱ្យរាជធានីភ្នំពេញ ជាទីក្រុងស្អាត គ្មានសំរាមចាប់ពីដំណាច់ឆ្នាំ២០១៤ តទៅ។

**១. ទីចាត់ការគ្រប់គ្រងសំណល់ និងបរិស្ថាននៃសាលារាជធានីភ្នំពេញ**

ក. ជំរុញឱ្យក្រុមហ៊ុនផ្តល់សេវាសម្អាត ប្រមូល និងដឹកជញ្ជូនសំរាមសំណល់រឹង ធ្វើការរៀបចំកម្មវិធីការងារសម្អាត ប្រមូល និងដឹកជញ្ជូនសំរាមតាមដងផ្លូវនីមួយៗ នៅក្នុងរាជធានីភ្នំពេញឱ្យបានច្បាស់លាស់

ខ. ត្រួតពិនិត្យ ចាត់វិធានការព្រមាន និងផាកពិន័យចំពោះក្រុមហ៊ុនធ្វើសេវាកម្មសម្អាត ប្រមូល និងដឹកជញ្ជូនសំរាម សំណល់រឹងក្នុងរាជធានីភ្នំពេញ ដែលអនុវត្តការងារបោសសម្អាត ការងារ ប្រមូលសំរាមតាមដងផ្លូវមិនបានស្អាត និងទាន់ពេលវេលាកំណត់ នៃកម្មវិធីដឹកជញ្ជូនសំរាម ព្រមទាំងការដឹកជញ្ជូនធ្វើឱ្យជ្រុះសំរាមរាយប៉ាយ និងហូរស្រក់ទឹកសំរាមនៅលើដងផ្លូវសាធារណៈ

គ. ជំរុញក្រុមហ៊ុនស៊ីនទ្រី ឱ្យពង្រីកសេវាសម្អាត ប្រមូល និងដឹកជញ្ជូនសំរាម សំណល់រឹងទៅតំបន់ដែលមិនទាន់មានសេវាទៅដល់ (ក្រៅពីតំបន់សង្កាត់ថ្មីទាំង២០)

ឃ. ធ្វើការកំណត់តារាងតម្លៃ និងកែប្រែតម្លៃសេវាសម្អាត ប្រមូល និងដឹកជញ្ជូនសំរាម សម្រាប់គ្រប់ទីតាំងលំនៅដ្ឋាន ទីតាំងអាជីវកម្ម សេវាកម្ម ក្រុមហ៊ុន រោងចក្រ សហគ្រាស អង្គភាព គ្រឹះស្ថានសាធារណៈ និងឯកជន នៅក្នុងរាជធានីភ្នំពេញ

ង. សម្របសម្រួលថ្លៃសេវាសម្អាត ប្រមូល និងដឹកជញ្ជូនសំរាមនៅពេលមានវិវាទតវ៉ា រវាងអ្នកបង់ថ្លៃសេវា និងក្រុមហ៊ុនផ្តល់សេវាសម្អាត ប្រមូល និងដឹកជញ្ជូនសំរាម

ច. ជំរុញអាជ្ញាធរមូលដ្ឋានឱ្យធ្វើការតាមដានត្រួតពិនិត្យ សម្របសម្រួល និងកែសម្រួលប្រតិបត្តិការការងាររបស់ក្រុមហ៊ុនផ្តល់សេវាសំរាមឱ្យដំណើរការផ្តល់សេវាប្រកបដោយប្រសិទ្ធភាព

ឆ. ចាត់វិធានការចំពោះម្ចាស់ការដ្ឋានសំណង់ឱ្យទុកដាក់សំណល់សំណង់ និងសំភារៈសំណង់ឱ្យបានត្រឹមត្រូវ និងចាត់វិធានការចំពោះរាល់សកម្មភាពការដឹកជញ្ជូនខ្សាច់ ថ្ម ដី ដែលហូរជ្រុះធ្លាក់លើផ្លូវ ដែលធ្វើឱ្យប៉ះពាល់ដល់សណ្តាប់ធ្នាប់ អនាម័យ និងបរិស្ថានសាធារណៈ

ជ. ធ្វើការណែនាំដល់គ្រប់ទីតាំងលំនៅដ្ឋាន ទីតាំងអាជីវកម្ម សេវាកម្ម ក្រុមហ៊ុន រោងចក្រ សហគ្រាស អង្គភាព គ្រឹះស្ថានសាធារណៈ និងឯកជននានានៅរាជធានីភ្នំពេញឱ្យមានធុងសំរាមរៀងៗខ្លួន

ឈ. ធ្វើការអប់រំ ណែនាំ និងជំរុញដល់ប្រជាពលរដ្ឋ និងអាជីវករទាំងអស់ត្រូវតែយកសំរាមទៅដាក់ក្នុងធុងសំរាមឱ្យបានត្រឹមត្រូវតាមកម្មវិធីប្រមូល និងទីតាំងដែលបានកំណត់

ញ. ដឹកនាំ និងសហការក្នុងការផលិតស្ពត (Spot) អប់រំ ដើម្បីចាក់ផ្សាយជាសាធារណៈឱ្យបានជ្រួតជ្រាបដល់ប្រជាពលរដ្ឋ អំពីការញែក ការទុកដាក់ ការវេចខ្ចប់ ការបញ្ចេញសំណល់ និងពេលវេលានៃការប្រមូលសំរាម សំណល់រឹងជាមួយស្ថានីយ៍វិទ្យុ ទូរទស្សន៍រាជធានីភ្នំពេញ និងទូរទស្សន៍នានា

ដ. ណែនាំដល់គ្រប់ផ្សារទាំងអស់ រៀបចំឱ្យមានបរិស្ថានល្អ ដោយធ្វើការសម្អាតជាប្រចាំ និងរកទីតាំងសមស្រប ដែលអាចដាក់ធុងសំរាមបាន ដើម្បីបង្កភាពងាយស្រួលដល់ការទុកដាក់ និងការដឹកជញ្ជូនចេញ

ឋ. ធ្វើការកំណត់ បែងចែកភារកិច្ច រវាងអ្នកម៉ៅការភាស៊ីផ្សារ អ្នកម៉ៅការចំណតរថយន្តជុំវិញផ្សារ និងក្រុមហ៊ុនផ្តល់សេវាសម្អាត ប្រមូល និងដឹកជញ្ជូនសំរាម អំពីភារកិច្ចទទួលខុសត្រូវបោសសម្អាត និងប្រមូលសំរាមក្នុងផ្សារ ជុំវិញផ្សារ និងតាមចំណតរថយន្តឱ្យច្បាស់លាស់

ឌ. រៀបចំទីលានចាក់សំរាម ឱ្យមានផ្លូវដែលអាចឱ្យរថយន្តចូលចាក់សំរាមបានងាយស្រួល ដែលមិនបង្កឱ្យ

មានការកកស្ទះរថយន្តដឹកសំរាម

ឍ. ធ្វើការណែនាំដល់ក្រុមហ៊ុនសារ៉ុត្រេឌីង ដែលគ្រប់គ្រងទីលានចាក់សំណល់ឧស្សាហកម្ម ឱ្យរៀបចំទីលានឱ្យបានត្រឹមត្រូវតាមបទដ្ឋានបច្ចេកទេស មានបរិស្ថានល្អ និងមិនមានផលប៉ះពាល់ដល់ប្រជាពលរដ្ឋនៅក្នុងតំបន់នោះ

ណ. ពិនិត្យលទ្ធភាពរកដៃគូវិនិយោគក្នុងការប្រមូល ការគ្រប់គ្រង និងការកែច្នៃសំណល់រឹង

ត. តម្រង់ទិស និងត្រួតពិនិត្យគម្រោង ផែនការ វិធានការ និងទិសដៅការងារ ដើម្បីពង្រឹង និងពង្រីកវិសាលភាពការងារគ្រប់គ្រងសំណល់ ការញែកសំរាម និងផាកពិន័យឱ្យបានទូលំទូលាយដល់គ្រប់ខណ្ឌ សង្កាត់ទាំងអស់ នៅទូទាំងរាជធានីភ្នំពេញ

ថ. សហការរៀបចំ និងដាក់ចេញនូវលិខិតបទដ្ឋាន សេចក្តីសម្រេច ដីកា និងវិធានការនានា ដើម្បីជំរុញឱ្យដំណើរការគ្រប់គ្រង សេវាកម្មសម្អាត ប្រមូល និងដឹកជញ្ជូនសំរាម សំណល់រឹងអាចប្រព្រឹត្តទៅបានដោយរលូន និងទាន់ពេលវេលាកំណត់

ទ. បន្តជំរុញឱ្យអនុវត្តផែនការញែកសំរាម សំណល់រឹង នៅទូទាំងរាជធានីភ្នំពេញ

ធ. ប្រើប្រាស់យន្តការផាកពិន័យដែលមានស្រាប់ និងរៀបចំបង្កើតក្រុមការងារ ដែលមានសមាសភាពមកពីរដ្ឋបាលរាជធានីភ្នំពេញ មន្ទីរជំនាញ និងអង្គភាពពាក់ព័ន្ធ ដើម្បីចុះត្រួតពិនិត្យ ណែនាំ អនុវត្តឱ្យមានប្រសិទ្ធភាព និងធ្វើការផាកពិន័យចំពោះអ្នកប្រព្រឹត្តល្មើសតាមដីកា ស្តីពីវិធានការ និងយន្តការផាកពិន័យចំពោះការបោះចោលសំរាម ការសម្អាត ការប្រមូល និងការដឹកជញ្ជូនសំរាមមិនត្រឹមត្រូវ នៅក្នុងរាជធានីភ្នំពេញរបស់ក្រុមប្រឹក្សារាជធានីភ្នំពេញ ព្រមទាំងលិខិតបទដ្ឋានពាក់ព័ន្ធផ្សេងទៀត

ន. ពង្រឹងការផាកពិន័យឱ្យបានម៉ឺងម៉ាត់គ្រប់ទីកន្លែងចំពោះអ្នកបោះចោលសំរាមគ្មានសណ្តាប់ធ្នាប់ ព្រមទាំងក្រុមហ៊ុនផ្តល់សេវាសម្អាត ប្រមូល និងដឹកជញ្ជូនសំរាម ដែលអនុវត្តមិនបានត្រឹមត្រូវទៅតាមភារកិច្ច ដែលបានកំណត់នៅក្នុងសេចក្តីណែនាំនេះ

ប. តាមដាន ត្រួតពិនិត្យ និងជំរុញឱ្យអាជ្ញាធរខណ្ឌ សង្កាត់ មន្ទីរជំនាញ និងអង្គភាពពាក់ព័ន្ធអនុវត្តភារកិច្ចដែលបានកំណត់ក្នុងសេចក្តីណែនាំនេះឱ្យមានប្រសិទ្ធភាព ងធ្វើការវាយតម្លៃការអនុវត្តន៍ការងារ និងស្វែងរកចំណុចខ្វះខាត ដើម្បីធ្វើការកែលម្អ

ផ. ប្រជុំតាមដាន ត្រួតពិនិត្យ និងវាយតម្លៃលើការងារដែលក្រុមហ៊ុនផ្តល់សេវាកម្ម និងអង្គភាពពាក់ព័ន្ធដែលបានអនុវត្តកន្លងមក និងដាក់ទិសដៅអនុវត្តបន្តឱ្យមានប្រសិទ្ធភាព ព្រមទាំងបូកសរុបលទ្ធផលការងារដើម្បីរាយការណ៍ជូនអភិបាល នៃគណៈអភិបាលរាជធានីភ្នំពេញ

ព. ត្រូវរៀបចំកែលម្អហេដ្ឋារចនាសម្ព័ន្ធទីលានចាក់សំរាមនិងកិច្ចប្រតិបត្តិនៅទីនោះឱ្យបានល្អប្រសើរកុំឱ្យមានការកកស្ទះមធ្យោបាយដឹកជញ្ជូនសំរាម ដែលចូលចាក់សំរាមនៅក្នុងទីលាន ហើយត្រូវមានកំណត់ហេតុកត់ត្រាហេតុការណ៍កើតឡើងនៅទីលានឱ្យបានត្រឹមត្រូវ ដើម្បីងាយស្រួលតាមដាន និងដោះស្រាយបញ្ហាផ្សេងៗបានទាន់ពេលវេលា

ភ. ត្រូវរៀបចំដាំដើមឈើព័ទ្ធជុំវិញទីលានចាក់សំរាម ដើម្បីកាត់បន្ថយក្លិនស្អុយជះចេញពីទីលានដែលធ្វើឱ្យប៉ះពាល់ដល់បរិស្ថាន និងការរស់នៅរបស់ប្រជាពលរដ្ឋនៅជុំវិញតំបន់នោះ

ម. រៀបចំកែលម្អប្រព័ន្ធបង្ហូរទឹកកខ្វក់ចេញពីសំរាម និងធ្វើប្រព្រឹត្តកម្មទឹកស្អុយឱ្យបានត្រឹមត្រូវ មុននឹងបង្ហូរចូលប្រឡាយសាធារណៈ។

## ២. ក្រុមហ៊ុនប្រមូលសំរាម

### ១). ការរៀបចំផែនការ និងការទទួលខុសត្រូវលើអាជីវកម្ម

ក. ត្រូវគោរព និងអនុវត្តឱ្យបានម៉ឺងម៉ាត់ នូវរាល់លិខិតបទដ្ឋានគតិយុត្តិ ច្បាប់ កិច្ចសន្យា និងបទបញ្ញត្តិនានាពាក់ព័ន្ធនឹងអាជីវកម្ម សេវាកម្មសម្អាត ប្រមូល និងដឹកជញ្ជូនសំរាម សំណល់រឹង

ខ. ទទួលខុសត្រូវលើការសម្អាត ប្រមូល និងដឹកជញ្ជូនសំរាម សំណល់រឹង ពីលំនៅដ្ឋាន ទីតាំងអាជីវកម្ម សេវាកម្ម ក្រុមហ៊ុន រោងចក្រ សហគ្រាស អង្គភាព គ្រឹះស្ថានសាធារណៈ និងឯកជននានានៅរាជធានីភ្នំពេញ ឱ្យបានស្អាតជាប្រចាំតាមកម្មវិធីសម្អាត ប្រមូល និងដឹកជញ្ជូនសំរាម

គ. ត្រូវរៀបចំផែនការអាជីវកម្ម ការងារគ្រប់គ្រងសេវាកម្មសម្រាប់រយៈពេលខ្លី-វែង ផែនការ សកម្មភាពប្រតិបត្តិលើការងារសម្អាត ប្រមូល និងដឹកជញ្ជូនសំរាម សំណល់រឹង នៅក្នុងតំបន់ផ្តល់សេវាកម្មរបស់ខ្លួន បញ្ជូនមកសាលារាជធានីភ្នំពេញ ដើម្បីពិនិត្យ និងសំរេច

ឃ. រៀបចំផែនការសកម្មភាពការងារលម្អិតឱ្យបានច្បាស់លាស់ ពីការផ្តល់សេវាកម្មសម្អាត ប្រមូល និងដឹកជញ្ជូនសំរាម សំណល់រឹង ទៅតាមស្ថានភាពជាក់ស្តែងរបស់ខណ្ឌ និងសង្កាត់នីមួយៗ ដោយមានកំណត់អំពីចំនួនមធ្យោបាយដឹកជញ្ជូន សម្ភារប្រមូលសំរាម និងកម្លាំងពលកម្មឱ្យបានគ្រប់គ្រាន់ ដើម្បីធានាឱ្យការសម្អាត ប្រមូល និងដឹកជញ្ជូនសំរាមបានស្អាត

ង. ធានាមិនឱ្យមានសំរាមកកស្ទះតាមដងផ្លូវ ក្នុងកាលៈទេសៈដែលមានហានិភ័យកើតឡើង ដូចជា ការធ្វើបាតុកម្ម កូដកម្មរបស់កម្មករក្រុមហ៊ុនស៊ីនទ្រីមិនព្រមធ្វើការដឹកជញ្ជូនសំរាមជាដើម

ច. បំពាក់រថយន្ត គ្រឿងចក្រ និងឧបករណ៍សម្ភារ ដែលបំរើឱ្យការងារសម្អាត ប្រមូល និងដឹកជញ្ជូនសំរាមឱ្យបានគ្រប់គ្រាន់ ដើម្បីធានាឱ្យទទួលបានប្រសិទ្ធភាពនៃការធ្វើសេវាកម្មនេះ

### ២). ការរៀបចំកម្មវិធីសម្អាត ប្រមូល និងដឹកជញ្ជូនសំរាមសំណល់រឹង

ក. ត្រូវរៀបចំ និងកំណត់កម្មវិធីសម្អាត ប្រមូល និងដឹកជញ្ជូនសំរាមសំណល់រឹងឱ្យបានច្បាស់លាស់ និងសមស្រប ដោយមានការឯកភាពពីអាជ្ញាធរមូលដ្ឋាន និងរដ្ឋបាលរាជធានីភ្នំពេញ

ខ. ត្រូវធ្វើការផ្សព្វផ្សាយ និងផ្តល់កម្មវិធីដឹកជញ្ជូនសំរាម សំណល់រឹងដល់អាជ្ញាធរខណ្ឌ សង្កាត់ ភូមិ ប្រជាពលរដ្ឋគ្រប់លំនៅដ្ឋាន និងគ្រប់ម្ចាស់ទីតាំងអាជីវកម្ម សេវាកម្ម ក្រុមហ៊ុន រោងចក្រ សហគ្រាស អង្គភាព គ្រឹះស្ថានសាធារណៈ និងឯកជននានា នៅក្នុងរាជធានីភ្នំពេញឱ្យបានដឹង ងាយស្រួលក្នុងការបញ្ចេញសំណល់ឱ្យបានស្របគ្នានឹងម៉ោងដឹកជញ្ជូន

### ៣). ការរៀបចំដាក់ធុងសំរាមតាមទីផ្សារ សួនច្បារ និងទីសាធារណៈ

ក. ត្រូវរៀបចំដាក់ធុងសំរាមសាធារណៈឱ្យបានគ្រប់គ្រាន់នៅតាមសួនច្បារ ទីសាធារណៈ ទីកន្លែងកំសាន្ត ទីផ្សារ មហាវិថី និងវិថីសំខាន់ៗនានា និងនៅត្រង់ចំណុចណាមួយក្បែរគ្រឹះស្ថានសាធារណៈ។ល។ ទៅតាមតម្រូវការជាក់ស្តែង ដោយសហការជាមួយអាជ្ញាធរខណ្ឌ សង្កាត់ ដើម្បីបង្កភាពងាយស្រួលក្នុងការទុកដាក់សំរាម

ខ. ត្រូវបំពាក់ធុងសំរាមខ្នាតធំញែកសំរាមសើម និងស្ងួត (ធុងដាមស្ទ័រ) នៅតាមទីផ្សារមួយចំនួនបន្ថែមទៀត ដើម្បីបំរើឱ្យការញែកសំរាមឱ្យបានត្រឹមត្រូវ

គ. ត្រូវលុបបំបាត់កុំឱ្យមានធុងសំរាមកុងតេន័រដាក់នៅជិតមាត់ប្រឡាយ និងលូទឹកសំអុយ

### ៤). ការអប់រំផ្សព្វផ្សាយ

ក. ត្រូវសហការជាមួយទីចាត់ការគ្រប់គ្រងសំណល់ និងបរិស្ថាន រៀបចំកម្មវិធី និងស្ពតវីដេអូអប់រំខ្លីៗតាម

ប្រព័ន្ធផ្សព្វផ្សាយនានា ដើម្បីអប់រំប្រជាពលរដ្ឋឱ្យយល់ដឹងពីប្រព័ន្ធដឹកជញ្ជូន និងពេលវេលាប្រមូលសំរាម ងាយស្រួលក្នុងការបញ្ចេញសំរាមឱ្យបានស៊ីសង្វាក់ជាមួយនឹងកម្មវិធីប្រមូលសំរាម

ខ. ត្រូវសហការជាមួយ អាជ្ញាធរមូលដ្ឋាន មន្ទីរជំនាញ និងអង្គភាពពាក់ព័ន្ធ ក្នុងការចុះអប់រំ ណែនាំជាប្រចាំដល់ប្រជាពលរដ្ឋនៅក្នុងរាជធានីភ្នំពេញ ស្តីពីការសម្អាត ការញែក ការវេចខ្ចប់ ការទុកដាក់ ការបញ្ចេញ និងការចាក់សំរាម សំណល់រឹងឱ្យបានត្រឹមត្រូវ និងប្រកបដោយអនាម័យបរិស្ថាន តាមគ្រប់មធ្យោបាយ។

**៥). ការបោសសម្អាត កៀរដី ប្រមូល និងដឹកជញ្ជូនសំរាម ទៅកាន់ទីលានចាក់សំរាម**

ក. ត្រូវធានាការបោសសម្អាត កៀរដីតាមចិញ្ចើមផ្លូវ ទ្រូងផ្លូវ និងស្ពានឱ្យបានស្អាតជាប្រចាំតាមកម្មវិធីសម្អាត ប្រមូល និងដឹកជញ្ជូនសំរាម នៅតាមផ្លូវ ស្ពានមួយចំនួន ដែលបានកំណត់។ កំណកដីដែលបានបោសសម្អាត និងកៀរ ត្រូវប្រមូលទុកដាក់ក្នុងធុងសំរាម ឬរទេះ ដើម្បីដឹកជញ្ជូនចេញភ្លាមៗ ដោយមិនត្រូវទុកចោលលើចិញ្ចើមផ្លូវ ទ្រូងផ្លូវ ឬស្ពាន ឡើយ

ខ. ត្រូវធានាការប្រមូលសំរាមដាក់រថយន្ត កុំឱ្យជ្រុះរាយប៉ាយលើផ្លូវ និងត្រូវបោសសម្អាត កន្លែងដែលប្រមូលនោះឱ្យបានស្អាត

គ. ត្រូវធានាការដឹកជញ្ជូនសំរាមទៅកាន់ទីលាន កុំឱ្យជ្រុះ កុំឱ្យហូរស្រក់ទឹកសំណល់ធ្លាក់មកលើទ្រូងផ្លូវ និងកុំឱ្យសំរាមប៉ើងតាមខ្យល់

ឃ. ត្រូវធានាការបោស ការប្រមូល និងការដឹកជញ្ជូនសំរាមនៅតាមដងផ្លូវនីមួយៗឱ្យបានស្អាត និងគោរពទៅតាមម៉ោងពេលនៃកម្មវិធីដែលបានកំណត់។ ក្នុងករណីយឺតយ៉ាវមិនបានអនុវត្តតាមម៉ោងពេលកំណត់ នឹងត្រូវទទួលការព្រមាន និងផាកពិន័យ

ង. ត្រូវបង្កើនការប្រមូលសំរាមតាមរទេះរុញ នៅតាមច្រកផ្លូវតូចៗដែលរថយន្តដឹកសំរាម មិនអាចចូលដល់។

ច. ត្រូវសហការកាត់បន្ថយ និងលុបបំបាត់ជាបណ្តើរៗនូវដេប៉ូសំរាម កន្លែងចាក់សំរាមអនាធិបតេយ្យ និងកន្លែងដាក់ធុងសំរាមខ្នាតធំ (ដាមស្ទ័រ) នានា ដែលធ្វើឱ្យប៉ះពាល់ដល់សោភ័ណភាព និងបរិស្ថានទីក្រុង តាមរយៈការបង្កើនសេវាតាមរទេះរុញសំរាមឱ្យបានច្រើន និងផ្ទេរចេញដោយផ្ទាល់បញ្ចូលទៅក្នុងរថយន្តដឹកសំរាមតែម្តង

ឆ. ប្រសិនបើសេវាដឹកជញ្ជូនសំរាមមានការយឺតយ៉ាវចាប់ពី២ថ្ងៃឡើងទៅ ក្រុមហ៊ុនត្រូវផ្តល់ព័ត៌មានជាលាយលក្ខណ៍អក្សរមករដ្ឋបាលរាជធានីភ្នំពេញ ដោយបញ្ជាក់ពីមូលហេតុសមស្របឱ្យបានច្បាស់លាស់

ជ. មិនត្រូវផ្អាកការធ្វើសេវាសម្អាត ប្រមូល និងដឹកជញ្ជូនសំរាម នៅតាមលំនៅដ្ឋាន ទីតាំង អាជីវកម្ម សេវាកម្ម ក្រុមហ៊ុន រោងចក្រ សហគ្រាស អង្គភាព គ្រឹះស្ថានសាធារណៈ និងឯកជននានានៅរាជធានីភ្នំពេញ ឬទីតាំងតំបន់ណាមួយ ដោយពុំមានការឯកភាពពីសាលារាជធានីភ្នំពេញនោះឡើយ

ឈ. ត្រូវអនុវត្តការសម្អាត ការប្រមូល និងការដឹកជញ្ជូនសំរាមឱ្យបានគ្រប់តំបន់ធ្វើសេវាកម្មរបស់ខ្លួន ទោះបីជាតំបន់នោះពុំទាន់មានលក្ខណៈសេដ្ឋកិច្ចគ្រប់គ្រាន់ក៏ដោយ

ញ. ក្នុងពេលទៅទទួលយកសំរាមតាមផ្ទះនីមួយៗ រថយន្តដឹកសំរាមត្រូវបើកយឺតៗ និងរកទីតាំងសមស្របសម្រាប់ឈប់សំចតឱ្យបានត្រឹមត្រូវតាមច្បាប់ចរាចរណ៍ ព្រមទាំងត្រូវបន្លឺសំលេងសមរម្យជាសញ្ញា ឬប្រើភ្លើងសញ្ញាទៅដល់ប្រជាពលរដ្ឋឱ្យបានដឹង

ដ. ត្រូវឱ្យភ្នាក់ងារ បុគ្គលិក និងកម្មកររបស់ក្រុមហ៊ុនពាក់ឯកសណ្ឋាន ដែលមានស្លាកសញ្ញាសំគាល់របស់ក្រុមហ៊ុនឱ្យបានត្រឹមត្រូវ និងមានសុវត្ថិភាពនៅពេលបំពេញភារកិច្ច

ឋ. ក្រុមហ៊ុនត្រូវផ្តល់ប្រាក់ឧបត្ថម្ភបន្ថែម ដល់កម្មករនៅថ្ងៃបុណ្យចូលឆ្នាំថ្មីប្រពៃណីជាតិ បុណ្យភ្ជុំបិណ្ឌ និងបុណ្យអុំទូក បណ្តែតប្រទីប សំពះព្រះខែ និងអកអំបុក ដើម្បីឱ្យពួកគាត់បន្តធ្វើការងារបោសសម្អាត ប្រមូល និងដឹកជញ្ជូនសំរាម នៅក្នុងរាជធានីភ្នំពេញនៅក្នុងថ្ងៃឈប់សំរាក

ឌ. ត្រូវបង្កើត កំណត់ និងរៀបចំទីតាំងស្តុកសំរាម សំណល់រឹងបណ្តោះអាសន្ន (ជួល ឬទិញ) សម្រាប់ផ្ទេរសំរាមឱ្យបានត្រឹមត្រូវ ដោយធានាមិនធ្វើឱ្យប៉ះពាល់ដល់ការធ្វើចរាចរណ៍ សុខុមាលភាព សាធារណៈ និងសោភ័ណភាព

ណ. បង្កើតកន្លែងប្រមូលផ្តុំទុកដាក់ទេះអូសសំរាម និងសំភារៈផ្សេងៗ សម្រាប់បំរើឱ្យការផ្តល់សេវាកម្មឱ្យបានល្អ មិនត្រូវទុកចោលគ្មានសណ្តាប់ធ្នាប់នៅតាមទីសាធារណៈឡើយ

**៦). មធ្យោបាយដឹកជញ្ជូនសំរាម សំណល់រឹង និងសម្អាតផ្លូវ**

ក. ត្រូវប្រើប្រាស់រថយន្តដឹកសំរាម ដែលមានគុណភាព និងបទដ្ឋានបច្ចេកទេសត្រឹមត្រូវ មានស្លាកលេខ និងការត្រួតពិនិត្យលក្ខណៈបច្ចេកទេសរថយន្តស្របតាមច្បាប់ចរាចរណ៍ផ្លូវគោក ដើម្បីធានានូវសុវត្ថិភាព និងប្រសិទ្ធភាពក្នុងការផ្តល់សេវាកម្ម

ខ. ត្រូវបន្ថែមមធ្យោបាយដឹកជញ្ជូនសំរាម ឱ្យបានគ្រប់គ្រាន់ទៅតាមតម្រូវការជាក់ស្តែងរបស់មូលដ្ឋានខណ្ឌ សង្កាត់នាពេលបច្ចុប្បន្ន និងអនាគត ដើម្បីឱ្យស្របទៅនឹងកំណើននៃបរិមាណសំរាម

គ. ត្រូវប្រើប្រាស់រថយន្តដឹកសំរាម ដែលសមស្របនឹងទំហំផ្លូវ និងស្ថានភាពចរាចរណ៍ក្នុងរាជធានីភ្នំពេញ

ឃ. ត្រូវបំពាក់បន្ថែមជាបន្តបន្ទាប់នូវយានយន្តបោសសម្អាតផ្លូវសម្រាប់បំរើឱ្យការបោសសម្អាតធូលីដីក្នុងរាជធានីភ្នំពេញឱ្យបានស្អាត ហើយដែលយានយន្ត និងឧបករណ៍ទាំងនោះត្រូវធានាឱ្យបានតាមបទដ្ឋានគុណភាព និងបច្ចេកទេសត្រឹមត្រូវ

**៧). ការប្រមូលថ្លៃសេវាសម្អាត ប្រមូល និងដឹកជញ្ជូនសំរាម**

ក. ត្រូវគោរពអនុវត្តឱ្យបានត្រឹមត្រូវទៅតាមតារាងតម្លៃ ជាមូលដ្ឋានថ្លៃសេវាដឹកជញ្ជូនសំរាម និងសម្អាតទីក្រុង ដែលកំណត់ដោយរដ្ឋបាលរាជធានីភ្នំពេញ

ខ. ត្រូវបង់ថ្លៃប្រើប្រាស់ទីលានចាក់សំរាម ជូនសាលារាជធានីភ្នំពេញ ដោយគោរព និងអនុវត្តតាមខ្លឹមសារណែនាំ ដែលមានចែងក្នុងលិខិតលេខ៣២២ សជណ របស់ទីស្តីការគណៈរដ្ឋមន្ត្រី ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ២០០៧

គ. ត្រូវអនុវត្តការសម្របសម្រួលថ្លៃសេវាដឹកជញ្ជូនសំរាម ជាមួយប្រជាពលរដ្ឋ ម្ចាស់អាជីវកម្មសេវាកម្មដែលបានប្តឹងតវ៉ា និងការផ្លាស់ប្តូរកែប្រែតម្លៃនៃប្រភេទទីតាំងនីមួយៗឱ្យបានសមស្រប មិនឱ្យលើសពីតម្លៃនៅក្នុងតារាងកំណត់តម្លៃជាមូលដ្ឋានថ្លៃសេវាដឹកជញ្ជូនសំរាម និងសម្អាតទីក្រុង ដែលតម្លៃសម្របសម្រួល និងតម្លៃកែប្រែនៃប្រភេទទីតាំងទាំងនោះត្រូវមានការឯកភាពពីរដ្ឋបាលរាជធានីភ្នំពេញជាមុនសិន មុននឹងកែសម្រួលផ្លាស់ប្តូរតម្លៃ និងចុះកិច្ចសន្យាជាមួយអតិថិជន

ឃ. ត្រូវផ្សព្វផ្សាយឱ្យបានទូលំទូលាយ នូវតារាងតម្លៃជាមូលដ្ឋានថ្លៃសេវាប្រមូលដឹកជញ្ជូនសំរាម និងសម្អាតទីក្រុងជូនដល់អតិថិជន និងសាធារណជនឱ្យបានជ្រាប

**៨). ការធ្វើរបាយការណ៍ និងការចូលរួមកិច្ចប្រជុំ**

ក. ត្រូវធ្វើរបាយការណ៍ប្រចាំខែ ប្រចាំត្រីមាស ឆមាស និងប្រចាំឆ្នាំ ពីលទ្ធផលការងារដែលបានអនុវត្ត និងទិសដៅការងារអនុវត្តបន្តមករដ្ឋបាលរាជធានីភ្នំពេញឱ្យបានទៀងទាត់ ព្រមទាំងចម្លងជូនមន្ទីរជំនាញ និងអង្គភាពពាក់ព័ន្ធ

ខ. ត្រូវចូលរួមប្រជុំឱ្យបានទៀងទាត់តាមការអញ្ជើញរបស់រដ្ឋបាលរាជធានីភ្នំពេញ និងអាជ្ញាធរមូលដ្ឋាន។ នៅរាល់កិច្ចប្រជុំនីមួយៗ ប្រសិនបើប្រធានក្រុមហ៊ុនមិនបានចូលរួម តំណាងក្រុមហ៊ុនដែលត្រូវចូលរួមប្រជុំជំនួសប្រធាន គឺត្រូវតែជាអ្នកមានសិទ្ធិសម្រេចឆ្លើយតបក្នុងកិច្ចប្រជុំបាន

**៩). ការគ្រប់គ្រង ត្រួតពិនិត្យ និងសហការ**

ក. ក្រុមហ៊ុនត្រូវសហការឱ្យបានជិតស្និទ្ធជាមួយ អាជ្ញាធរខណ្ឌ សង្កាត់ លើការងារសម្អាត ប្រមូល និងដឹកជញ្ជូនសំរាម សំណល់រឹងឱ្យមានប្រសិទ្ធភាព

ខ. ត្រូវចាត់តំណាងក្រុមហ៊ុន១នាក់ សម្រាប់ប្រចាំការនៅតាមសង្កាត់នីមួយៗ ដើម្បីងាយស្រួលទំនាក់ទំនងដោះស្រាយការងារបានទាន់ពេល។

## ៣. សាលាខណ្ឌ និងសង្កាត់

ក. អប់រំផ្សព្វផ្សាយ និងណែនាំដល់ប្រជាពលរដ្ឋ ឱ្យយកចិត្តទុកដាក់ក្នុងការវេចខ្ចប់ ការទុកដាក់ និងការបោះចោលសំរាមឱ្យបានត្រឹមត្រូវនៅតាមទីកន្លែង និងពេលវេលាដែលបានកំណត់តាមកម្មវិធីប្រមូល និងដឹកជញ្ជូនសំរាម

ខ. ត្រួតពិនិត្យ តាមដានការអនុវត្តន៍ការសម្អាត ការប្រមូល និងដឹកជញ្ជូនសំរាម ព្រមទាំងទាក់ទងទៅក្រុមហ៊ុនផ្តល់សេវាសម្អាត ប្រមូល និងដឹកជញ្ជូនសំរាមឱ្យមកប្រមូលសំរាមចេញឱ្យអស់ និងស្អាតជាប្រចាំនៅក្នុងមូលដ្ឋានរបស់ខ្លួន

គ. ជំរុញ និងលើកទឹកចិត្តដល់សកម្មភាពប្រើប្រាស់ឡើងវិញ ឬកែច្នៃសំណល់រឹងនៅក្នុងមូលដ្ឋានរបស់ខ្លួន

ឃ. គ្រប់គ្រងឱ្យបានហ្មត់ចត់នូវទីតាំងប្រមូលទិញអេតចាយ និងទីតាំងកែច្នៃសំណល់រឹងគ្រប់ប្រភេទព្រមទាំងណែនាំឱ្យម្ចាស់ទីតាំងទាំងនោះមកសុំច្បាប់ពីសាលារាជធានីភ្នំពេញ

ង. ធ្វើការស្រង់ស្ថិតិទីតាំងកែច្នៃសំណល់រឹងទាំងអស់ និងបរិមាណប្រភេទសំរាមដែលបានកែច្នៃក្នុងមូលដ្ឋានរបស់ខ្លួន រួចធ្វើរបាយការណ៍មកសាលារាជធានីភ្នំពេញ

ច. ដឹកនាំកងកំលាំងនគរបាលខណ្ឌ សង្កាត់ និងមន្ត្រីបរិស្ថាន ចុះទប់ស្កាត់ ណែនាំ និងពិន័យចំពោះជនទាំងឡាយណា ដែលបានបោះចោលសំរាម សំណល់រឹងគ្មានសណ្តាប់ធ្នាប់តាមទីសាធារណៈ

ឆ. រៀបចំ ឬស្នើទៅមន្ទីរបរិស្ថាន ឱ្យជួយដាក់ស្លាកសញ្ញាហាមឃាត់ការទុកដាក់ និងការបោះចោលសំរាមគ្មានសណ្តាប់ធ្នាប់នៅតាមទីតាំងសំខាន់ៗមួយចំនួន

ជ. ត្រូវសម្របសម្រួលក្នុងការកំណត់ទីតាំងទុកដាក់សំរាមបណ្តោះអាសន្ន រួមទាំងធុងសំរាមសាធារណៈឱ្យបានសមស្រប ដោយមិនបង្កបញ្ហានាំឱ្យប៉ះពាល់ដល់ការធ្វើចរាចរណ៍របស់ប្រជាពលរដ្ឋ សុខុមាលភាពសាធារណៈ សោភ័ណភាព និងសណ្តាប់ធ្នាប់សង្គម

ឈ. ត្រូវធ្វើការតាមដានលើការសម្អាត ការប្រមូល ការស្តុក និងការដឹកជញ្ជូនសំរាម សំណល់រឹងរបស់ក្រុមហ៊ុនក្នុងសេវាកម្មសម្អាត ប្រមូល និងដឹកជញ្ជូនសំរាមឱ្យបានទៀងទាត់ជាប្រចាំ ឱ្យយកទៅចាក់នៅទីតាំងចាក់សំរាមដែលបានកំណត់ ដោយស្ថាប័នមានសមត្ថកិច្ច ឬសាលារាជធានីភ្នំពេញ

ញ. ត្រូវជំរុញឱ្យគណៈកម្មការផ្សារទាំងអស់ក្នុងមូលដ្ឋានរបស់ខ្លួន ធ្វើការផ្សព្វផ្សាយនូវកម្មវិធីដឹកជញ្ជូនសំរាម និងភារកិច្ចដែលបានកំណត់ ដល់អាជីវករក្នុងផ្សារ ជុំវិញផ្សារឱ្យបានជ្រួតជ្រាប និងចូលរួមអនុវត្តទាំងអស់គ្នាឱ្យមានប្រសិទ្ធភាព

ដ. ធ្វើការត្រួតពិនិត្យ តាមដានការបញ្ចេញសំណល់ និងការសម្អាត ប្រមូល និងដឹកជញ្ជូន សំរាមដែលអនុវត្ត មិនបានត្រឹមត្រូវតាមពេលវេលាកំណត់ ដើម្បីចាត់វិធានការព្រមាន និងផាកពិន័យ

ឋ. ត្រូវចាត់ឱ្យភ្នាក់ងារពិន័យប្រចាំមូលដ្ឋានរបស់ខ្លួន ចុះធ្វើការពិន័យអ្នកដែលចោលសំរាមគ្មានសណ្តាប់ធ្នាប់ និងអ្នកដែលបញ្ចេញសំរាមមកដាក់ក្រៅផ្ទះខុសទីតាំង និងម៉ោងពេលកំណត់នៃកម្មវិធីដឹកជញ្ជូនសំរាម

ឌ. ត្រូវធានាកុំឱ្យមានសំរាមកកស្ទះក្នុងមូលដ្ឋានរបស់ខ្លួន ដោយសហការជាមួយក្រុមហ៊ុនសម្អាត ប្រមូល និងដឹកជញ្ជូនសំរាម

ឍ. ត្រួតពិនិត្យនិងជំរុញការងារដឹកជញ្ជូនសំរាមរបស់ក្រុមហ៊ុនឱ្យបានទៀងទាត់តាមកម្មវិធីដែលបានកំណត់។ ក្នុងករណីដែលក្រុមហ៊ុនផ្តល់សេវាមិនបានគោរពតាមកម្មវិធីដឹកជញ្ជូនរបស់ខ្លួន រាប់ទាំងការដឹកជញ្ជូនធ្វើឱ្យជ្រុះសំរាម ហូរទឹកសំអុយលើទ្រូងផ្លូវ និងមានសំរាមសល់គរចោលច្រើន ត្រូវធ្វើសេចក្តីរាយការណ៍ជាបន្ទាន់មកសាលារាជធានីភ្នំពេញ អំពីទីតាំងដែលក្រុមហ៊ុនមិនបានអនុវត្ត ដើម្បីធ្វើការណែនាំ និងផាកពិន័យក្រុមហ៊ុន

ណ. រៀបចំសណ្តាប់ធ្នាប់តាមដងផ្លូវសាធារណៈ ចំពោះការលក់ដូរ ការចតយានជំនិះ។ល។ ដើម្បីបង្កលក្ខណៈងាយស្រួលដល់ក្រុមហ៊ុនក្នុងការសម្អាត ប្រមូល និងដឹកជញ្ជូនសំរាម

ត. ណែនាំប្រជាពលរដ្ឋឱ្យម្ចាស់ការថែរក្សាអនាម័យ និងសម្អាតចិញ្ចើមផ្លូវមុខផ្ទះ ឬទីតាំងរបស់ខ្លួនឱ្យបានស្អាត។ ក្នុងករណីមិនគោរពតាមការណែនាំ នឹងទទួលការព្រមាន ឬផាកពិន័យ

ថ. ណែនាំប្រជាពលរដ្ឋឱ្យចូលរួមលុបបំបាត់នូវដេប៉ូសំរាម ដែលចាក់គរចោលលើចិញ្ចើមផ្លូវ ទ្រូងផ្លូវ តាមទីសាធារណៈ និងតាមប្រឡាយ លូ។ ល។

ទ. ដឹកនាំសមត្ថកិច្ចពាក់ព័ន្ធនានា ចុះដោះស្រាយតាមនីតិវិធីនូវរាល់បញ្ហាផ្សេងៗ ដែលកើតមានទាក់ទងនឹងការងារគ្រប់គ្រង និងការផ្តល់សេវាកម្មសំរាម សំណល់រឹងនៅក្នុងមូលដ្ឋានរបស់ខ្លួន

ធ. ត្រូវម្ចាស់ការបន្តធ្វើយុទ្ធនាការយល់ដឹងជាសាធារណៈ នៅក្នុងមូលដ្ឋានរបស់ខ្លួនរៀងរាល់ ៣ខែម្តង ដើម្បីរំលឹកដល់ប្រជាពលរដ្ឋអំពីការថែរក្សាអនាម័យបរិស្ថាន ឬក៏រៀបចំកម្មវិធីសម្អាតតាមទីសាធារណៈ ដោយសហការជាមួយក្រុមហ៊ុនផ្តល់សេវាកម្មសំរាម ប្រជាពលរដ្ឋស្ម័គ្រចិត្ត សិស្សានុសិស្សនៅតាមសាលារៀន និងអង្គការក្រៅរដ្ឋាភិបាលនានា

ន. សហការដើម្បីកាត់បន្ថយអ្នករើសអេតចាយ តាមរយៈការត្រួតពិនិត្យ ការតាមដានការបញ្ចេញ និងការប្រមូលសំរាមឱ្យទាន់ពេលវេលា និងត្រូវពេលគ្នា

ប. ត្រូវសហការជាមួយក្រុមហ៊ុនឱ្យបានឯកភាពគ្នាអំពីកម្មវិធីនៃការបញ្ចេញ និងការប្រមូលសំរាមតាមផ្ទះ និងបញ្ជាក់ពីទីតាំងច្បាស់លាស់សម្រាប់ការទុកដាក់សំរាម

ផ. ត្រូវណែនាំដល់ម្ចាស់ការដ្ឋានសំណង់ឱ្យទុកដាក់សំណល់សំណង់ឱ្យបានត្រឹមត្រូវដោយមិនត្រូវទុកដាក់សំណល់ទាំងនោះ លាយឡំគ្នាជាមួយនឹងសំណល់សំរាមឡើយ

ព. រាល់ពិធីបុណ្យទាន ឬពិធីផ្សេងៗត្រូវណែនាំម្ចាស់ពិធីនោះឱ្យធ្វើកិច្ចសន្យាសម្អាតទីតាំងឱ្យបានស្អាតនៅពេលចប់កម្មវិធីដូចជា ពិធីអាពាហ៍ពិពាហ៍ ការប្រគុំតន្ត្រី។ល។

ភ. កំណត់មុខសញ្ញាជនប្រព្រឹត្តខុសដែលបានបោះចោល ឬដឹកជញ្ជូនសំរាមទៅចោលខុសទីតាំងកំណត់ ដោយត្រូវហៅជននោះមកធ្វើការអប់រំ និងផាកពិន័យ

ម. អនុគណៈកម្មការតាមខណ្ឌ សង្កាត់ ត្រូវធ្វើរបាយការណ៍ពីស្ថានភាពសំរាម ការផាកពិន័យ លទ្ធផលការងារ បញ្ហាប្រឈម ដំណោះស្រាយ និងសំណូមពរ រួចរាយការណ៍មកសាលារាជធានីភ្នំពេញឱ្យបានទៀងទាត់នៅរៀងរាល់ខែ និងចម្លងជូនមន្ទីរជំនាញពាក់ព័ន្ធ។

**៤. ភារកិច្ច និងកាតព្វកិច្ច របស់ប្រជាពលរដ្ឋនៅក្នុងរាជធានីភ្នំពេញ**

ក. ត្រូវចូលរួមក្នុងការសម្អាត ថែទាំអនាម័យលំនៅដ្ឋាន ជុំវិញលំនៅដ្ឋាន ទីតាំងអាជីវកម្ម សេវាកម្មគ្រប់ប្រភេទ និងទីសាធារណៈ ព្រមទាំងត្រូវថែរក្សាការពារធុងសំរាមរបស់ខ្លួន និងធុងសំរាមសាធារណៈឱ្យបានស្អាត និងម៉ត់ចត់

ខ. ត្រូវញែក និងវេចខ្ចប់សំរាមរបស់ខ្លួន ហើយយកទៅដាក់ក្នុងធុង កញ្ជេរ ឬថង់ប្លាស្ទិកនៅមុខផ្ទះ ឬទីកន្លែងដែលបានកំណត់ឱ្យបានត្រឹមត្រូវ រួចបញ្ចេញសំរាមឱ្យបានទៀងទាត់តាមពេលវេលាកំណត់

គ. ត្រូវបញ្ចេញសំរាមមកទុកដាក់តាមកន្លែងកំណត់ស្របតាមកម្មវិធីប្រមូល និងដឹកជញ្ជូនសំរាមក្នុងអំឡុងពេល១ម៉ោង មុនពេលម៉ោងកំណត់ដែលមធ្យោបាយដឹកជញ្ជូនសំរាមមកដល់។ ក្នុងករណីមកមិនទាន់រថយន្តមិនត្រូវទុកសំរាមចោលលើចិញ្ចើមផ្លូវ ឬទ្រូងផ្លូវឡើយ

ឃ. ចំពោះសំណល់មែកឈើតូចៗ និងស្លឹក ត្រូវកាត់សម្រួលឱ្យតូច ខ្លី កុំឱ្យសំពីងសំពាង និងចងឱ្យបានត្រឹមត្រូវ ងាយស្រួលដាក់បញ្ចូលក្នុងមធ្យោបាយដឹកជញ្ជូនសំរាម

ង. ម្ចាស់ការដឹកជញ្ជូនសំណល់សំណង់របស់ខ្លួនចេញ ដោយមិនត្រូវទុកចោលលើចិញ្ចើមផ្លូវ ឬទ្រូងផ្លូវឡើយ

ច. ចំពោះម្ចាស់ដីឡូត៍ទំនេរត្រូវធ្វើរបងឱ្យជិត ចៀសវាង និងទប់ស្កាត់កុំឱ្យមានការយកសំរាមទៅចាក់ចោលនៅទីនោះ បង្កើតបានជាដេប៉ូសំរាមអនាធិបតេយ្យ ធ្វើឱ្យប៉ះពាល់ដល់ប្រជាពលរដ្ឋដែលរស់នៅក្បែរខាង។

ឆ. មិនត្រូវបោះសំរាមចោលតាមចិញ្ចើមផ្លូវ ទ្រូងផ្លូវ ប្រឡាយ លូ ទីផ្សារ និងតាមទីសាធារណៈក្នុងរាជធានីភ្នំពេញឡើយ

ជ. មិនត្រូវទុកដាក់សំរាមឱ្យរាយប៉ាយ ឬហូរទឹកស្អុយកខ្វក់ នៅមុខផ្ទះ មុខដីឡូត៍ ជុំវិញភូមិដ្ឋានរបស់ខ្លួន និងមិនត្រូវយកទៅបោះចោលនៅទីតាំង ឬតំបន់អ្នកដទៃឡើយ

ឈ. មិនត្រូវព្រលែង ឬយកសត្វចិញ្ចឹមឱ្យមកបន្ទោរបង់ពាសវាលពាសកាល និងដើរកកាយហែកសំរាម ដែលដាក់នៅមុខផ្ទះ និងតាមទីសាធារណៈនានា

ញ. រាល់ពិធីអាពាហ៍ពិពាហ៍ បុណ្យទាន និងពិធីផ្សេងៗ ដែលរៀបចំធ្វើមុខផ្ទះ មុខទីតាំងអាជីវកម្ម និងតាមដងផ្លូវនានា ម្ចាស់កម្មវិធីត្រូវទទួលខុសត្រូវបោសសម្អាត និងប្រមូលសំរាម វេចខ្ចប់ និងទុកដាក់ឱ្យបានត្រឹមត្រូវក្រោយបញ្ចប់ពិធី

ដ. ក្នុងករណីមានវិវាទអំពីតម្លៃសេវាប្រមូល និងដឹកជញ្ជូនសំរាម សំណល់រឹង ត្រូវពិភាក្សាជាមួយអាជ្ញាធរមូលដ្ឋាន និងក្រុមហ៊ុនផ្តល់សេវា ដើម្បីរកដំណោះស្រាយឱ្យមានការព្រមព្រៀងគ្នាក្នុងការបង់ថ្លៃសេវា ព្រមទាំងត្រូវបង់ឱ្យបានទៀងទាត់។

**៥. ផ្សាររដ្ឋ**

ក. គណៈកម្មការផ្សារនីមួយៗ ត្រូវសហការជាមួយក្រុមហ៊ុនផ្តល់សេវាប្រមូល និងដឹកជញ្ជូនសំរាម កំណត់ឱ្យមានកន្លែងស្តុកសំណល់សំរាមឱ្យបានត្រឹមត្រូវ ដើម្បីឱ្យក្រុមហ៊ុនផ្តល់សេវាមកប្រមូល និងដឹកជញ្ជូនសំរាមចេញតាមពេលវេលាកំណត់

ខ. ត្រូវរៀបចំទីតាំងសម្រាប់ដាក់ធុងសំរាមធំៗឱ្យបានយ៉ាងតិចចំនួន០២ ដែលមានចំណុះសមស្របសម្រាប់ទុកដាក់សំណល់សើម និងសំណល់ផ្សេងៗឱ្យបានគ្រប់គ្រាន់ទៅតាមលទ្ធភាព និងស្ថានភាពជាក់ស្តែង ដោយមិនបង្កការប៉ះពាល់ដល់សុខុមាលភាព និងការកកស្ទះចរាចរណ៍

គ. ត្រូវបន្តណែនាំឱ្យអាជីវករទាំងអស់ធ្វើការញែកសំណល់ជាពីរប្រភេទគឺ សំណល់សើម និងសំណល់ស្ងួត ព្រមទាំងវេចខ្ចប់ទុកដាក់ក្នុងធុងសំរាមរបស់ខ្លួនឱ្យបានត្រឹមត្រូវ

ឃ. ត្រួតពិនិត្យការអនុវត្តន៍ភារកិច្ចលើការងារបោសសម្អាត និងប្រមូលសំរាមរបស់អ្នកម៉ៅការប្រមូលចំណូលភាសីផ្សារ និងអ្នកម៉ៅការប្រមូលចំណូលពីការផ្ញើយានជំនិះជុំវិញផ្សារឱ្យបានហ្មត់ចត់

ង. សហការរៀបចំដាក់ធុងសំរាមឱ្យបានគ្រប់គ្រាន់ ដើម្បីបំពីឱ្យការចោលសំរាមរបស់ប្រជាពលរដ្ឋ ដែលចូលទៅទិញទំនិញនៅក្នុងផ្សារ

ច. ធ្វើការអប់រំ និងផាកពិន័យឱ្យបានម៉ឺងម៉ាត់ចំពោះអ្នកដែលចោលសំរាមគ្មានសណ្តាប់ធ្នាប់នៅក្នុងទីផ្សារ។

**៦. អ្នកវិនិយោគផ្សារ អ្នកម៉ៅការចំណតយានជំនិះជុំវិញផ្សារ និងអ្នកម៉ៅការភាសីផ្សារ**

ក. អ្នកវិនិយោគផ្សារ ត្រូវធានាឱ្យបរិស្ថានក្នុងផ្សារ និងជុំវិញផ្សារឱ្យបានស្អាតជាប្រចាំ និងទទួលខុសត្រូវក្នុងការរៀបចំឱ្យមានកន្លែងស្តុកសំរាមបណ្តោះអាសន្នឱ្យបានសមស្រប

ខ. ចំពោះអ្នកម៉ៅការប្រមូលចំណូលភាសីផ្សារ ត្រូវទទួលខុសត្រូវបោសសម្អាត និងប្រមូលសំរាមពីក្នុងផ្សារ និងជុំវិញបរិវេណផ្សារឱ្យបានស្អាតជាប្រចាំ រួចប្រមូលយកទៅដាក់ក្នុងធុងសំរាមនៅដេប៉ូស្តុកសំរាមផ្សារ ឬកន្លែងកំណត់ណាមួយ

គ. ចំពោះអ្នកម៉ៅការប្រមូលចំណូលពីចំណតយានជំនិះ ត្រូវទទួលខុសត្រូវបោសសម្អាត និង ប្រមូលសំរាមពីទីតាំងចំណត និងចំណតជុំវិញផ្សារ ទាំងខាងជាប់ផ្សារ ទាំងខាងមុខផ្ទះរបស់ប្រជាពលរដ្ឋ ឱ្យបានស្អាតជាប្រចាំ រួចយកទៅដាក់ក្នុងធុងសំរាមនៅដេប៉ូស្តុកសំរាមផ្សារ ឬកន្លែងកំណត់ណាមួយ។

**៧. មន្ទីរបរិស្ថានរាជធានីភ្នំពេញ**

ធ្វើជាសេនាធិការឱ្យសាលារាជធានីភ្នំពេញ ដោយសហការជាមួយទីចាត់ការគ្រប់គ្រងសំណល់ និងបរិស្ថានលើការងារដូចខាងក្រោម៖

ក. រៀបចំផែនការគ្រប់គ្រងយុទ្ធសាស្ត្រ និងផែនការសកម្មភាពនានាលើការប្រមូល ការដឹកជញ្ជូនសំរាម ការស្តុកទុកបណ្តោះអាសន្ន និងការចាក់ចោលសំរាម សំណល់រឹងក្នុងរាជធានីភ្នំពេញឱ្យមានប្រសិទ្ធភាពខ្ពស់

ខ. អប់រំផ្សព្វផ្សាយពីច្បាប់ និងលិខិតបទដ្ឋាននានា ដែលពាក់ព័ន្ធនឹងការងារគ្រប់គ្រងសំរាម សំណល់រឹង នៅរាជធានីភ្នំពេញ

គ. រៀបចំគ្រប់គ្រងទិន្នន័យតាមប្រព័ន្ធព័ត៌មានវិទ្យាអំពីប្រភព និងប្រភេទសំរាម សំណល់រឹង និងស្ថិតិអាជីវកម្មកែច្នៃសំណល់ នៅក្នុងរាជធានីភ្នំពេញ

ឃ. ចូលរួមត្រួតពិនិត្យផែនការមេ និងផែនការលម្អិត ស្តីពីកម្មវិធីនៃការប្រមូលសំរាម សំណល់រឹង ដែលធ្វើឡើងដោយក្រុមហ៊ុនស៊ីនទ្រី និងក្រុមហ៊ុនផ្តល់សេវាកម្មគ្រប់គ្រងសំណល់នានាផ្សេងទៀត

ង. ណែនាំមន្ត្រីទទួលបន្ទុកការងារបរិស្ថានប្រចាំតាមខណ្ឌនីមួយៗ ឱ្យសហការជាមួយអាជ្ញាធរខណ្ឌ សង្កាត់ ភូមិ ចុះពិនិត្យស្ថានភាពសំណល់ និងការផ្តល់សេវាសម្អាត ប្រមូល និងដឹកជញ្ជូនសំណល់រឹងក្នុងខណ្ឌនីមួយៗឱ្យបានជាប្រចាំ និងរាយការណ៍មកសាលាខណ្ឌ ដើម្បីរកវិធីដោះស្រាយ

ច. ត្រួតពិនិត្យ ណែនាំ ព្រមាន និងពិន័យចំពោះក្រុមហ៊ុនធ្វើសេវាកម្មសម្អាត ប្រមូល និងដឹកជញ្ជូនសំរាម ក្រុមហ៊ុនផ្តល់សេវាកម្មសំណល់នានា មន្ទីរ អង្គភាព និងអ្នកពាក់ព័ន្ធទាំងឡាយណាដែលប្រព្រឹត្តល្មើស នឹងសេចក្តីណែនាំនេះ ដោយអនុវត្តតាមច្បាប់ និងលិខិតបទដ្ឋាន ដែលសាលារាជធានីភ្នំពេញកំណត់

ឆ. ផ្តល់កិច្ចសហការឱ្យបានជិតស្និទ្ធិជាមួយអាជ្ញាធរមូលដ្ឋានខណ្ឌ សង្កាត់ក្នុងការរៀបចំភ្នាក់ងារពិន័យ ព្រមទាំងធ្វើការអប់រំបំពាក់បំប៉នដល់ភ្នាក់ងារពិន័យ អំពីយន្តការ និងនីតិវិធីនៃការចុះអនុវត្តឱ្យមានប្រសិទ្ធភាព

ជ. បន្តរៀបចំដាក់ផ្ទាំងស្លាកសញ្ញាហាមចាក់សំរាម ដែលបង្ហាញពីការពិន័យចំពោះអ្នកចោលសំរាមគ្មានសណ្តាប់ធ្នាប់ តាមប្រកាសអន្តរក្រសួងមហាផ្ទៃ-បរិស្ថាន លេខ៨០ ចុះថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០០៣ នៅតាមទីតាំងសាធារណៈមួយចំនួនដែលប្រជាពលរដ្ឋតែងតែយកសំរាមមកចាក់គរចោលគ្មានសណ្តាប់ធ្នាប់

ឈ. ចុះត្រួតពិនិត្យ និងវាយតម្លៃនូវលទ្ធផលអនុវត្តការញែកសំរាម និងការកាត់បន្ថយការប្រើប្រាស់ថង់ប្លាស្ទីកនៅតាមទីផ្សារនានា និងធ្វើរបាយការណ៍លទ្ធផលមកសាលារាជធានីភ្នំពេញ

ញ. ធ្វើការបូកសរុប និងវាយតម្លៃលទ្ធផលអនុវត្ត ដើម្បីដាក់ពិន្ទុប្រឡងប្រណាំងដល់បណ្តាមូលដ្ឋានខណ្ឌ សង្កាត់ ផ្សារ អង្គភាព និងមន្ទីរពាក់ព័ន្ធ ដែលមានស្នាដៃល្អ។

**៨. មន្ទីរសាធារណការ និងដឹកជញ្ជូនរាជធានីភ្នំពេញ**

ក. ត្រូវបោសសម្អាត និងប្រមូលសំរាមនៅតាមសួនច្បារ រមណីយដ្ឋាន និងតាមទីកន្លែងកំសាន្តសាធារណៈនានា ដែលស្ថិតក្រោមសមត្ថកិច្ចទទួលខុសត្រូវរបស់ខ្លួន និងត្រូវវេចខ្ចប់ឱ្យបានត្រឹមត្រូវ ប្រមូលយកទៅទុកកន្លែងកំណត់ណាមួយឱ្យបានទាន់ពេល ដែលក្រុមហ៊ុនប្រមូលសំរាមមកប្រមូលដឹកជញ្ជូនចេញ និងមិនត្រូវយកសំរាមទាំងនោះទៅដាក់នៅក្នុងធុងសំរាមសាធារណៈដែលស្ថិតនៅតាមទីតាំងទាំងនោះឡើយ

ខ. រៀបចំទីតាំងសម្រាប់ដាក់ធុងសំរាមតាមសួនច្បារ និងពិនិត្យមើលចំនួនធុងសំរាមឱ្យបានគ្រប់គ្រាន់

គ. ត្រូវពង្រឹងភ្នាក់ងារសន្តិសុខសួនច្បារឱ្យបង្កើនសកម្មភាពត្រួតពិនិត្យ និងពិន័យអ្នកដែលចោលសំរាមគ្មានសណ្តាប់ធ្នាប់នៅលើសួនច្បារ និងតាមគោលដៅដែលមន្ទីរគ្រប់គ្រងឱ្យបានសកម្ម និងម៉ឺងម៉ាត់

ឃ. ត្រូវកាយយកសំរាម និងសំណល់ដី ដែលមាននៅតាមលូ ប្រឡាយទឹកឱ្យបានជាប្រចាំ និងធ្វើការដឹកជញ្ជូនចេញទៅចោលនៅទីលានចាក់សំរាម

ង. ត្រូវសហការជាមួយកំលាំងសមត្ថកិច្ចនគរបាលរាជធានីភ្នំពេញ និងអាជ្ញាធរមូលដ្ឋាន ដើម្បីអន្តរាគមន៍រាល់អំពើល្មើសផ្សេងៗ ដែលជាឧបសគ្គដល់កិច្ចដំណើរការធ្វើសេវាកម្មសម្អាត និងការពិន័យដល់អ្នកចោលសំរាមគ្មានសណ្តាប់ធ្នាប់តាមទីសាធារណៈនានា

ច. សហការជាមួយទីចាត់ការគ្រប់គ្រងសំណល់ មន្ទីរបរិស្ថាន និងក្រុមហ៊ុនធ្វើសេវាកម្មសម្អាត ប្រមូល និងដឹកជញ្ជូនសំរាម ដើម្បីរៀបចំផែនការសកម្មភាពការងារបោសសម្អាត និងប្រមូលសំរាមនៅតាមទីតាំងគ្រប់គ្រងរបស់មន្ទីរឱ្យបានច្បាស់លាស់

ឆ. ត្រូវធ្វើរបាយការណ៍ពីលទ្ធផលការងារដែលបានអនុវត្ត និងទិសដៅការងារប្រចាំខែ ជូនមកសាលារាជធានីភ្នំពេញឱ្យបានទៀងទាត់។

**៩. មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី**

ក. ត្រូវណែនាំដល់ម្ចាស់ការដ្ឋានសំណង់ទាំងអស់ ឱ្យរៀបចំទុកដាក់សំណល់សំណង់នៅក្នុងបរិវេណរបងហ៊ុំព័ទ្ធការដ្ឋានរបស់ខ្លួនឱ្យបានត្រឹមត្រូវ និងហាមដាច់ខាតការយកសំរាមដាក់លាយឡំជាមួយនឹងសំណល់

សំណង់

ខ. ចំពោះសំណង់ថ្មីៗដូចជា៖ អាគារធំៗ បុរី ផ្សារទំនើបឯកជន ផ្សាររដ្ឋ សណ្ឋាគារ គ្រឹះស្ថានសាធារណៈ និងឯកជន មន្ទីរពេទ្យរដ្ឋ និងឯកជន រោងចក្រ សហគ្រាស ភោជនីយដ្ឋាន រមណីយដ្ឋាន ទីវត្តអារាម។ល។ នៅក្នុងគម្រោងសាងសង់ (ប្លង់) ត្រូវរៀបចំ និងសាងសង់ទីធ្លាសម្រាប់ស្តុកសំណល់រឹង សំរាម និងរៀបចំដាក់ធុងសំរាមធំៗដែលមានចំណុះសមស្រប។

**១០. មន្ទីរសុខាភិបាលរាជធានីភ្នំពេញ**

ត្រូវណែនាំដល់គ្រប់មន្ទីរពេទ្យ មន្ទីរពហុព្យាបាល និងគ្លីនិកតូច-ធំទាំងអស់ក្នុងរាជធានីភ្នំពេញឱ្យចូលរួមអនុវត្តនូវសេចក្តីណែនាំ ស្តីពីការអនុវត្តន៍ភារកិច្ចកែលម្អការងារគ្រប់គ្រងការសម្អាតសំរាម សំណល់រឹង នៅរាជធានីភ្នំពេញឱ្យបានល្អប្រសើរ ជាពិសេសត្រូវជំរុញឱ្យមានការវេចខ្ចប់សំណល់វេជ្ជសាស្ត្រ និងសំណល់ធម្មតាឱ្យបានត្រឹមត្រូវ និងដាច់ដោយឡែកពីគ្នា ព្រមទាំងបញ្ចេញចោលឱ្យត្រឹមត្រូវតាមកម្មវិធីប្រមូល និងដឹកជញ្ជូនសំណល់ទាំងពីរប្រភេទ។

**១១. មន្ទីរព័ត៌មាន និងទូរទស្សន៍រាជធានីភ្នំពេញ ប៉ុស្តិ៍លេខ ៣**

ក. មន្ទីរព័ត៌មានត្រូវណែនាំដល់គ្រប់ពិធីករតាមបណ្តាស្ថានីយទូរទស្សន៍ និងវិទ្យុទាំងអស់ឱ្យជួយផ្សព្វផ្សាយពីខ្លឹមសារនៃសេចក្តីណែនាំ ស្តីពីការអនុវត្តន៍ភារកិច្ចកែលម្អការងារគ្រប់គ្រង ការសម្អាតសំរាម សំណល់រឹង នៅរាជធានីភ្នំពេញឱ្យមានប្រសិទ្ធភាព

ខ. ទូរទស្សន៍រាជធានីភ្នំពេញ ប៉ុស្តិ៍លេខ៣ មានភារកិច្ចដូចខាងក្រោម៖

ខ១. រៀបចំបទយកការណ៍ បទសម្ភាសន៍ និងការផ្សព្វផ្សាយនានាសំដៅឱ្យមានការចូលរួមការអនុវត្តន៍ច្បាប់ទាក់ទងនឹងការងារគ្រប់គ្រងសំណល់រឹង នៅរាជធានីភ្នំពេញឱ្យបានល្អប្រសើរ

ខ២. ត្រូវបន្តផ្សព្វផ្សាយស្ពត ស្តីពីការអប់រំ និងការពិន័យអ្នកចោលសំរាមគ្មានសណ្តាប់ធ្នាប់ និងការអប់រំណែនាំពីការញែកសំរាមតាមទូរទស្សន៍ឱ្យបានញឹកញាប់

ខ៣. ត្រូវរៀបចំផលិតស្ពតថ្មី ដែលអប់រំ និងណែនាំឱ្យមានការចូលរួមធ្វើអនាម័យមុខផ្ទះ ចិញ្ចើមផ្លូវ និងសម្អាតមាត់លូ និងអណ្តូងលូជាប្រចាំ ពីការវេចខ្ចប់ ទុកដាក់ ការបោះចោល និងការបញ្ចេញសំរាមឱ្យបានត្រឹមត្រូវទៅតាមកម្មវិធីដឹកជញ្ជូនសំរាម ដែលបានកំណត់ដោយសហការជាមួយទីចាត់ការគ្រប់គ្រងសំណល់ និងមន្ទីរជំនាញពាក់ព័ន្ធ

ខ៤. ធ្វើការផ្សព្វផ្សាយកម្មវិធីប្រមូល និងដឹកជញ្ជូនសំរាម សំណល់រឹងនៅតាមខណ្ឌ សង្កាត់ និងសេចក្តីណែនាំស្តីពីការអនុវត្តន៍ភារកិច្ចកែលម្អការងារគ្រប់គ្រងការសម្អាតសំរាម សំណល់រឹង នៅរាជធានីភ្នំពេញ ដើម្បីឱ្យប្រជាពលរដ្ឋបានដឹងគ្រប់គ្នា និងចូលរួមអនុវត្ត។

**១២.មន្ទីរទេសចរណ៍រាជធានីភ្នំពេញ**

ក. ត្រូវចុះអប់រំ ផ្សព្វផ្សាយ និងណែនាំនៅតាមបណ្តាគ្រប់រមណីយដ្ឋាន និងតំបន់ទេសចរណ៍ ព្រមទាំងម្ចាស់អាជីវកម្មក្នុងវិស័យទេសចរណ៍ ឱ្យចូលរួមញែកសំរាម ទុកដាក់ វេចខ្ចប់ និងបញ្ចេញសំរាមឱ្យបានត្រឹមត្រូវតាមពេលម៉ោងដែលបានកំណត់

ខ. កំណត់ការវាយតម្លៃរមណីយដ្ឋានស្អាតគ្មានសល់សំរាមរាយប៉ាយ តាមគោលការណ៍ទីក្រុងស្អាត។

**១៣. មន្ទីរអប់រំ យុវជន និងកីឡារាជធានីភ្នំពេញ**

ក. ត្រូវផ្សព្វផ្សាយនូវផែនការញែកសំរាម និងកម្មវិធីប្រមូលសំរាមទៅដល់គ្រឹះស្ថានសិក្សារបស់រដ្ឋ និងឯកជនទាំងអស់នៅក្នុងរាជធានីភ្នំពេញឱ្យជួយធ្វើការផ្សព្វផ្សាយបន្តដល់សិស្សានុសិស្សបានយល់ដឹង និងចូលរួមអនុវត្តទាំងអស់គ្នា ដើម្បីឱ្យទីក្រុងស្អាត

ខ. ណែនាំដល់សាលារៀនទាំងអស់ឱ្យរៀបចំដាក់ធុងសំរាម និងធ្វើការអប់រំតាមរយៈការបង្កើតកម្មវិធីប្រឡងប្រណាំងអំពីការយល់ដឹងជាសាធារណៈពីការទុកដាក់ និងការបញ្ចេញសំរាមក្នុងរាជធានីភ្នំពេញឱ្យបានទូលំទូលាយបន្ថែមទៀត ។

**១៤. មន្ទីរពាណិជ្ជកម្មរាជធានីភ្នំពេញ**

ត្រូវណែនាំដល់ម្ចាស់ទីតាំងប្រកបអាជីវកម្ម និងសេវាកម្មទាំងអស់ ដែលបានចុះបញ្ជីនៅមន្ទីរពាណិជ្ជកម្មឱ្យចូលរួមអនុវត្តខ្លឹមសារនៃសេចក្តីណែនាំ ស្តីពីការអនុវត្តន៍ភារកិច្ចកែលម្អការងារគ្រប់គ្រង ការសម្អាតសំរាមនៅរាជធានីភ្នំពេញឱ្យល្អប្រសើរ និងតម្រូវឱ្យទីតាំងទាំងនោះ ត្រូវតែមានធុងសម្រាប់ដាក់សំរាមព្រមទាំងចូលរួមទុកដាក់ វេចខ្ចប់ ញែកសំរាម និងបញ្ចេញសំរាមឱ្យបានត្រឹមត្រូវតាមម៉ោងពេលនៃកម្មវិធីដឹកជញ្ជូនសំរាមដែលបានកំណត់។

**១៥. មន្ទីរឧស្សាហកម្មរាជធានីភ្នំពេញ**

ក. ត្រូវណែនាំដល់បណ្តាម្ចាស់រោងចក្រ សិប្បកម្ម និងទីតាំងអាជីវកម្មនានា ដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់មន្ទីរ ឱ្យចូលរួមអនុវត្តនូវសេចក្តីណែនាំ ស្តីពីការអនុវត្តន៍ភារកិច្ចកែលម្អការងារគ្រប់គ្រង ការសម្អាតសំរាម សំណល់រឹង នៅរាជធានីភ្នំពេញឱ្យល្អប្រសើរ និងចូលរួមទុកដាក់ វេចខ្ចប់ ញែកសំរាម និងបញ្ចេញសំរាមឱ្យបានត្រឹមត្រូវតាមម៉ោងពេលនៃកម្មវិធីដឹកជញ្ជូនសំរាមដែលបានកំណត់

ខ. ស្រង់ស្ថិតិទីតាំងរោងចក្រ និងសិប្បកម្មកែច្នៃសំណល់រឹង នៅក្នុងរាជធានីភ្នំពេញ។

**១៦. មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈរាជធានីភ្នំពេញ**

ក. ត្រូវផ្សព្វផ្សាយ និងណែនាំដល់ម្ចាស់រោងចក្រ សហគ្រាស សហជីព បុគ្គលិក កម្មករ និយោជិក ឱ្យបានជ្រួតជ្រាប និងចូលរួមចំណែកអនុវត្តតាមសេចក្តីណែនាំ ស្តីពីការអនុវត្តន៍ភារកិច្ចកែលម្អការងារគ្រប់គ្រងការសម្អាតសំរាម សំណល់រឹង នៅរាជធានីភ្នំពេញដែលបានដាក់ចេញ សំដៅឱ្យការទុកដាក់ ការវេចខ្ចប់ការបញ្ចេញសំណល់ឱ្យត្រូវតាមម៉ោងពេលដែលបានកំណត់

ខ. ត្រូវជំរុញឱ្យមានការញែកសំណល់ធម្មតា និងសំណល់ឧស្សាហ៍កម្មឱ្យដាច់ដោយឡែកពីគ្នា ព្រមទាំងណែនាំឱ្យមានធុងសម្រាប់ដាក់ និងមានកន្លែងសម្រាប់ស្តុកសំណល់ទាំងពីរប្រភេទឱ្យបានត្រឹមត្រូវ។

**១៧. មន្ទីរធម្មការ និងសាសនារាជធានីភ្នំពេញ**

ត្រូវណែនាំ និងផ្សព្វផ្សាយដល់គ្រប់វត្តអារាមទាំងអស់ឱ្យចូលរួមចំណែកអនុវត្តនូវខ្លឹមសារនៃសេចក្តីណែនាំស្តីពីការអនុវត្តន៍ភារកិច្ចកែលម្អការងារគ្រប់គ្រង ការសម្អាតសំរាម សំណល់រឹងនៅរាជធានីភ្នំពេញ និងកម្មវិធីប្រមូលសំរាមឱ្យបានសកម្ម ជាពិសេសក្នុងឱកាសបុណ្យធំៗ ដែលមានវត្តមានពុទ្ធបរិស័ទច្រើនដើម្បីឱ្យបានយល់ ចូលរួមអនុវត្ត និងត្រូវមានធុងសំរាមឱ្យបានត្រឹមត្រូវ និងគ្រប់គ្រាន់។

**១៨. មន្ទីរវប្បធម៌ និងវចិត្រសិល្បៈរាជធានីភ្នំពេញ**

ក. ត្រូវគ្រប់គ្រង និងទទួលខុសត្រូវការបោសសម្អាត ប្រមូល និងវេចខ្ចប់សំរាមនៅរមណីយដ្ឋានវត្តភ្នំឱ្យបានស្អាតល្អ និងប្រមូលយកទៅដាក់ក្នុងធុងសំរាម ឬទីកន្លែងកំណត់ណាមួយឱ្យបានត្រឹមត្រូវ

ខ. ត្រូវផ្សព្វផ្សាយសេចក្តីណែនាំ ស្តីពីការអនុវត្តន៍ភារកិច្ចកែលម្អការងារគ្រប់គ្រង ការសម្អាតសំរាម សំណល់រឹងនៅរាជធានីភ្នំពេញ ទៅដល់ពិធីករ សិល្បករ និងអ្នកកំប្លែង។ល។ ដើម្បីជួយផ្សព្វផ្សាយ តាមរយៈវេទិកាសំដែង និងតាមទូរទស្សន៍នានា សំដៅរួមចំណែកធ្វើឱ្យរាជធានីភ្នំពេញស្អាត។

**១៩. ស្នងការដ្ឋាននគរបាល និងបញ្ជាការដ្ឋានកងរាជអាវុធហត្ថ រាជធានីភ្នំពេញ**

ត្រូវសហការជាមួយអាជ្ញាធរមូលដ្ឋាន មន្ទីរជំនាញ និងអង្គភាពពាក់ព័ន្ធ ចុះអន្តរាគមន៍រាល់អំពើល្មើសផ្សេងៗ ដែលជាឧបសគ្គដល់កិច្ចដំណើរការផ្តល់សេវាកម្មសំរាម សំណល់រឹង និងការផាកពិន័យចំពោះអ្នកចោលសំរាមគ្មានសណ្តាប់ធ្នាប់តាមទីសាធារណៈនានា។

**២០. មន្ទីរ និងអង្គភាពផ្សេងៗទៀត**

ត្រូវធ្វើការផ្សព្វផ្សាយនូវខ្លឹមសារនៃសេចក្តីណែនាំនេះ និងកម្មវិធីដឹកជញ្ជូនសំរាម សំណល់រឹង ជូនដល់មន្ត្រី និងបុគ្គលិករបស់ខ្លួនឱ្យចូលរួមចំណែកអនុវត្តឱ្យបានគ្រប់ៗគ្នា ដើម្បីធ្វើជាគំរូមុនគេ។

**២១. អង្គការមិនមែនរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍នានា**

ក. ជួយកៀរគរការផ្តល់ហិរញ្ញវត្ថុ និងបច្ចេកទេសសម្រាប់ជួយដល់ការងារគ្រប់គ្រងសំរាម សំណល់រឹង នៅក្នុងរាជធានីភ្នំពេញឱ្យបានល្អប្រសើរ

ខ. គាំទ្រទស្សនកិច្ចសិក្សានិងវគ្គបណ្តុះបណ្តាលពាក់ព័ន្ធនឹងការគ្រប់គ្រងសំរាម សំណល់រឹង ទាំងនៅក្នុង និងក្រៅប្រទេស

គ. ជួយរៀបចំឯកសារ ដើម្បីទាក់ទាញអ្នកផ្តល់ជំនួយ និងអ្នកវិនិយោគគិននានា ដែលមានចំណាប់អារម្មណ៍លើការងារវិនិយោគប្រកបអាជីវកម្មក្នុងការគ្រប់គ្រង និងកែច្នៃសំណល់រឹង

ឃ. ជួយផ្សព្វផ្សាយព័ត៌មាន អំពីសារៈសំខាន់នៃការអនុវត្តន៍ល្អក្នុងការគ្រប់គ្រងសំរាម សំណល់រឹង ផ្អែកតាមគោលការណ៍ ៣Rs (ការកាត់បន្ថយ ការប្រើប្រាស់ឡើងវិញ និងការកែច្នៃសំណល់) ទៅដល់អ្នកពាក់ព័ន្ធ

ង. ជួយរៀបចំផលិតស្ពតអប់រំអំពីផលប៉ះពាល់ពីការទុកដាក់សំរាមមិនបានត្រឹមត្រូវទៅដល់ប្រជាពលរដ្ឋតាមរយៈប្រព័ន្ធផ្សព្វផ្សាយនានា។

## ឧបសម្ព័ន្ធទី៦. រូបភាពអនុវត្តន៍ការគ្រប់គ្រងសំណល់



ការគ្រប់គ្រងទឹកសំអុយនៅទីលានដង្កោ



គំនរសំរាមនៅទីលានដង្កោ



គ្រឿងចក្រប្រើប្រាស់នៅទីលានដង្កោ



រថយន្តប្រើប្រាស់នៅទីលានដង្កោ



អ្នករើសសំណល់អេតចាយនៅទីលានដង្កោ



សំណល់អេតចាយប្រមូលបាន ត្រូវបានថ្លឹងលក់



ភ្លើងឆេះ និងភ្នាក់ងារពន្លត់អគ្គីភ័យនៅទីលានដង្កោ



ភ្លើងឆេះ និងផ្សែងហុយនៅទីលានដង្កោ



ទីលានដង្កោបន្ទាប់ពីភ្លើងឆេះ



គំនរសំរាមគ្មានសណ្តាប់ធ្នាប់នៅទីដីទំនេរ





គំនរសំណល់អេឡិចត្រូនិកនៅតាមផ្លូវ



គំនរសំណល់សំណង់នៅលើចិញ្ចើមផ្លូវ



សំណល់គ្រោះថ្នាក់ និងសំរាមសំពីងសំពោង



សំរាមជំនឿសាសនានៅតាមដងផ្លូវ



សំណល់ឧស្សាហកម្មពីរោងចក្រកាត់ដេរទី១



សំណល់ឧស្សាហកម្មពីរោងចក្រកាត់ដេរទី២

## ឧបសម្ព័ន្ធទី៧. ផែនទីតំបន់នៃទីលានចាក់សំរាមដង្កោ



## ១. ប្រព័ន្ធកែច្នៃជីកំប៉ុសនៅតាមលំនៅដ្ឋានតាមបែបវិមជ្ឈការ

ការធ្វើជីកំប៉ុស មានបច្ចេកទេសកែច្នៃជាច្រើន ក្នុងការធ្វើឱ្យពុកផុយសំណល់ជីវៈ ដោយវត្តមានឧស្ម័នអុកស៊ីសែន ព្រមទាំងអាចបំភាយនូវឧស្ម័នកាបូនិច និងសំណល់រំពុកចុងក្រោយហៅថាជីកំប៉ុស។ បច្ចេកទេសកែច្នៃជីកំប៉ុសមានច្រើន តែគេឃើញប្រព័ន្ធកែច្នៃជីកំប៉ុសខ្នាតតូច ត្រូវបានអនុវត្តយ៉ាងទូលំទូលាយនៅតាមបណ្តាប្រទេសជាច្រើន ដើម្បីជំរុញការកែច្នៃសំណល់ជីវៈ។

បច្ចេកវិទ្យា Bacteria de Kiero ជាប្រព័ន្ធកែច្នៃមួយប្រភេទ ដែលកម្របានឃើញ។ គេប្រើប្រាស់នូវបន្ទះឈើ ដី និងមានគំរបជ័រប្លាស្ទិកក្រាស ដែលជាឧទាហរណ៍នៃការធ្វើជីកំប៉ុសតាមផ្ទះ។ វាមិនដូចប្រព័ន្ធជីកំប៉ុសតាមផ្ទះដទៃទៀត បច្ចេកវិទ្យា Kiero មានតែដីធម្មជាតិជាវត្ថុធាតុដើម មិនតម្រូវឱ្យមានការងារលាយផ្សំ និងថែទាំច្រើននោះទេ។ វាមានសមត្ថភាពកែច្នៃស្ទើរតែគ្រប់ប្រភេទសំណល់អាហារ ទីកន្លែងស្អាតសមរម្យ កាត់បន្ថយសំណល់ជីវៈបានច្រើន និងអាចការពារពីពពួកសត្វល្អិត បើសិនជារៀបចំវាបានត្រឹមត្រូវ។

វានៅតែត្រូវការការងារថែទាំមួយចំនួនផងដែរ ដូចជា ការរៀបចំសម្ភារ (ឈើ និងដីពណ៌ក្រហម៉ៅ) ហើយគេអាចប្រើប្រាស់ជីកំប៉ុស សម្រាប់ដាក់សួនច្បារ និងដាំដើមឈើជាដើម។ ការកែច្នៃតាមបច្ចេកវិទ្យានេះមានលក្ខណៈសាមញ្ញ ងាយអនុវត្តនៅតាមទីតាំងតូចល្មម ងាយស្រួលថែទាំ និងសមស្របសម្រាប់នៅក្នុងទីក្រុងសម្រាប់ការប្រើប្រាស់ប្រកបដោយចីរភាព។

បច្ចេកវិទ្យា Bacteria de Kiero ( バクテリア de キエーロ )

ជំនាន់ទី១ ដែលបានរចនាឡើងសម្រាប់ដាក់ផ្ទាល់នៅលើដី។




បច្ចេកវិទ្យា "Veranda de Kiero"

ជំនាន់ទី២៖ មានបាតបិទជិត (ចន្លោះខាងលើខ្លះសម្រាប់ខ្យល់) រចនាឡើងសម្រាប់ដាក់នៅតាមរានហាល។







## របៀបធ្វើ *Kiero* ក្នុងរណ្ដៅតែមួយ

1. ជីករណ្ដៅមួយមានជម្រៅប្រហាក់ប្រហែល ២០ស.ម ហើយដាក់សំណល់ផ្ទះបាយនៅក្នុងរន្ធ។ ប្រសិនបើរន្ធមានជម្រៅរាក់ពេក នោះវាអាចបង្កើតឱ្យមានក្លិនមិនល្អ និង/ ឬទាក់ទាញសត្វល្អិតផងដែរ។
2. លាយសំណល់ផ្ទះបាយជាមួយនឹងដី។ នេះគឺជាជំហានសំខាន់បំផុត។ សំណល់នឹងធ្វើការពុកផុយបានល្អ ប្រសិនបើវាត្រូវបានលាយយ៉ាងសព្វល្អជាមួយនឹងដីរហូតទាល់តែវាស្ងួត។ ការកាប់ចិញ្ច្រាំសំណល់ជីវៈឱ្យតូចៗ ក៏នឹងជួយបង្កើនដំណើរការនៃការពុកផុយជាជីកំប៉ុស្តផង ដែរ។
3. បន្ទាប់មកគ្របរណ្ដៅវិញដោយដីស្ងួត។ ស្រទាប់ដីស្ងួតអាចជួយការពារមិនឱ្យមានក្លិនអាក្រក់ និងសត្វល្អិត។







**គន្លឹះ:**

ការលាយសំណល់ជាមួយនឹងដីកំប៉ុសកែច្នៃរួចពីមុនខ្លះ និងដាក់ល្បាយនោះឱ្យត្រូវនឹងខ្យល់ នឹងជួយបង្កើនល្បឿននៃការពុកផុយផងដែរ។




### ដំណើរការរំពុក

ត្រូវការប្រមាណជា ៥ ថ្ងៃ (សីតុ. ៣០-៤០ °C )

### កម្រិតរំពុក

*Bateria de Kiero* - ប្រហែល ៨០០ ក្រាម/ ថ្ងៃ

*Veranda de Kiero* - ប្រហែល ៥០០ ក្រាម/ ថ្ងៃ




### សំណល់ដែលអាចកែច្នៃបាន

រាល់សំណល់ផ្ទះបាយក្រៅតែពី ឆ្អឹងធំៗ សំបកងៀវ គ្រំ គ្រាប់ដំណាំធំៗ ឬប្រភេទដែលសម្បូរទៅដោយសរសៃ (សំបកដូង អំពៅ) គឺអាចកែច្នៃបាន ប៉ុន្តែមានល្បឿនខុសៗគ្នា។ សំណល់អាហារ ត្រី សាច់ មានការពុកផុយយ៉ាងឆាប់រហ័ស ខណៈពេលដែលពពួកមើម ពោត និងសំបកសណ្ដែកត្រូវការពេលវេលាច្រើនជាង។

* ខ្លឹមសារនៅក្នុងផ្នែកនេះ ត្រូវបានដកស្រង់ឡើង ក្រោមការអនុញ្ញាតពី Kiero។

# ២. ប្រព័ន្ធឡជីវឧស្ម័ន

ប្រព័ន្ធឡជីវឧស្ម័ន កែច្នៃសំណល់ជីវៈ ដោយគ្មានវត្តមានឧស្ម័នអុកស៊ីសែន និងអាចផលិតជីវឧស្ម័ន ដែលមានកម្រិតមេតានដល់ ៥០-៦០%។ ជីវឧស្ម័នអាចត្រូវបានប្រើប្រាស់ជាប្រភពថាមពល និងអាចជំនួសឥន្ធនៈហ្វូស៊ីលបាន គេអាចប្រើប្រាស់សម្រាប់ដុតចម្អិន ឬផលិតអគ្គិសនីក៏បាន។ សំណល់ដែលត្រូវបានច្រាលចេញមកពីឡ គេអាចប្រើវាសម្រាប់ដាក់សួនច្បារ ឬដំណាំកសិកម្មផងដែរ។ ឧទាហរណ៍ បច្ចេកវិទ្យានេះត្រូវបានណែនាំ និងអនុវត្តនៅក្នុងគម្រោងបណ្ដុះបណ្ដាលប្រព័ន្ធថាមពលកកើតឡើងវិញ និងសាងសង់គំរូឡជីវឧស្ម័ន ដោយមន្ត្រីនៃកម្មវិធីឡជីវឧស្ម័នជាតិ (NBP)




**<u>សំណល់អាចដាក់ចូលឡ</u>**

ប្រព័ន្ធឡជីវឧស្ម័នអាចកែច្នៃសំណល់ម្ហូបអាហារ/ផ្ទះបាយភាគច្រើន ដូចជា ផ្លែឈើ បន្លែ ត្រី និងសាច់លើកលែងតែពពួកដែលសម្បូរទៅដោយសរសៃ ដូចជា អំពៅ ដូង ត្នោត។

**<u>ផលិតផលជីវឧស្ម័ន</u>**

១ ម៣ ជីវឧស្ម័នអាចប្រើសម្រាប់៖

- ជំនួសអុស ៤-៥គ.ក្រ
- ជំនួសប្រេងកាត ០,៦-០,៧ លីត្រ
- ប្រហែលរបៀង ១,៦គ.ក្រ
- ជំនួសហ្គាសLPG ០,៤៥គ.ក្រ
- អាចចំអិនរយៈពេល ២,៥ម៉
- អាចបំភ្លឺរយៈពេល ៥-៦ម៉
- អាចផលិតអគ្គិសនី ១,៦-១,៧kWh
- អាចដំណើរការម៉ាស៊ីន ១hp រយៈពេល ២ម៉






ព័ត៌មានបន្ថែមអំពីបច្ចេកវិទ្យាប្រព្រឹត្តកម្មសំណល់ជីវៈ ទាំងប្រព័ន្ធកែច្នៃជីកំប៉ុស និងប្រព័ន្ធឡជីវឧស្ម័នអាចស្វែងរក៖ *Sang-Arun, J., Kim Heng, C., Rithy, U., Phalla, S. (2011). A Guide for Technology Selection and Implementation of Urban Organic Waste Utilisation Projects in Cambodia. Institute for Global Environmental Strategies, Japan.*

ជាភាសាខ្មែរ:
http://www.comped-cam.org/Documents/developmentguideline/ IGES2011-Promoting-OWU-Cambodia-Printed_Khmer.pdf

ជាភាសាអង់គ្លេស:
https://pub.iges.or.jp/pub/guide-technology-selection-and- implementation

## ៣. ប្រព័ន្ធទាញយកថាមពលពីសំណល់ ( WtE )

### ទិដ្ឋភាពទូទៅ

- ទំហំ: ១០០០ម²
- សមត្ថភាពផលិតកម្ម: ២១០០ត/ថ្ងៃ
- សមត្ថភាពប្រចាំឆ្នាំ: ៧៦០.០០០ត
- បច្ចេកវិទ្យាប្រព្រឹត្តកម្ម: Mechanical Grate Incinerator
- សមត្ថភាពឡ: ៣ x ៧០០ត /ថ្ងៃ
- ឈុតម៉ូទ័រដើរដោយចំហាយទឹក: ២ x ២៤MW
- ទុនវិនិយោគសរុប: ១៨៦លានដុល្លាអាមេរិក
- សមត្ថភាពអគ្គិសនីប្រចាំឆ្នាំ: ១៥០ លាន kWh
- តម្លៃអគ្គិសនីសមស្របលក់ជូនEDC: USD 0,១២/kWh

ប្រព័ន្ធទាញយកថាមពលពីសំណល់ ឬប្រព័ន្ធឡដុតសំណល់ អាចផលិតនូវថាមពល និងត្រូវបានប្រើនៅក្នុងប្រទេសអភិវឌ្ឍន៍មួយចំនួន ដែលជាបច្ចេកវិទ្យាប្រព្រឹត្តកម្មសំណល់ទ្រង់ទ្រាយធំ។
ខាងក្រោមនេះ គឺជាការដកស្រង់ចេញពីគម្រោងសំណើបច្ចេកវិទ្យាកែច្នៃសំណល់ ដែលបានដាក់ជូន PPCA ដោយដៃគូអភិវឌ្ឍន៍ក្នុងការផលិតថាមពលពីសំណល់ ដែលមានសក្តានុពលនៅក្នុងរាជធានីភ្នំពេញ។



### គំនូសតាងខ្សែចង្វាក់ផលិតកម្ម





បច្ចេកទេសឡដុតនេះ (Mechanical Grate Incinerator) មានលក្ខណៈដូចខាងក្រោម:



- បច្ចេកវិទ្យាមានភាពចាស់ទុំ ភាពស្វ័យប្រវត្តិខ្ពស់លក្ខខណ្ឌប្រតិបត្តិការល្អ ហើយស្ទើរតែគ្រប់រោងចក្រផលិតថាមពលធំៗទាំងអស់ប្រើប្រភេទឡ Furnace
- វាអាចសម្របខ្លួនទៅនឹងលក្ខណៈធម្មជាតិនៃសំណល់ដែលមានបរិមាណទឹកខ្ពស់ និងកម្រិតអានុភាពកម្តៅទាប ដើម្បីធានាការដុតសំណល់ឆេះសព្វល្អ
- សំណល់អាចបញ្ចូលដោយផ្ទាល់ទៅក្នុងឡចំហាយសម្រាប់ការដុត ដោយមិនចាំបាច់ធ្វើប្រព្រឹត្តកម្មពីខាងដើមជាមុននោះទេ ការងារ និងចំណាយប្រតិបត្តិការក៏មានតម្លៃទាបផងដែរ
- អាយុកាលបំពេីសេវាកម្ម គឺមានរយៈពេលយូរ វាមានស្ថេរភាព និងអាចជឿទុកចិត្តបាន ឯការថែទាំ និងប្រតិបត្តិការមានភាពងាយស្រួល ហើយបច្ចេកវិទ្យា និងឧបករណ៍បរិក្ខារត្រូវបានផលិតឡើងនៅក្នុងប្រទេសចិន។

ដំណើរការនៃបច្ចេកវិទ្យាប្រព័ន្ធប្រព្រឹត្តកម្ម Percolate គឺជាប្រព្រឹត្តកម្មបឋម Deslagging + UBF Anaerobism + MBR ប្រភេទខាងក្រៅ + Nanofiltration មានដូចខាងក្រោម៖




*ប្រភព: រដ្ឋបាលរាជធានីភ្នំពេញ ឆ្នាំ២០១៨

## ៤. ការគ្រប់គ្រងទីលានអនាម័យនៅតំបន់អាកាសធាតុត្រូពិក

ការរៀបចំទុកដាក់សំណល់ចុងក្រោយ គឺជាកិច្ចការពារហេតុប៉ះពាល់បរិស្ថានពីទីលានចាក់សំរាមប្រកបដោយចីរភាពបរិស្ថាន។ ទោះជាយ៉ាងណា រាជធានីភ្នំពេញដែលមានអាកាសធាតុតំបន់ត្រូពិក អាចមានបញ្ហាប្រឈមមួយចំនួនក្នុងការគ្រប់គ្រងសំណល់បែបទីលានអនាម័យ ដែលអាចការពារផលប៉ះពាល់អវិជ្ជមានលើសុខភាពមនុស្ស និងបរិស្ថានជុំវិញ។ សមាគមសំណល់រឹងអន្តរជាតិ (ISWA) បានរៀបចំនូវគោលការណ៍ណែនាំ/ វិធីសាស្ត្រសម្រាប់ការសាងសង់ និងដំណើរការទីលានចាក់សំរាមបែបអនាម័យទៅតាមលក្ខខណ្ឌធម្មជាតិ ដូចជា "បច្ចេកវិជ្ជាដែលមាន/ ការអនុវត្តន៍ល្អប្រសើរបំផុត"។

ខាងក្រោមនេះ គឺជាធាតុផ្សំសំខាន់ៗ៖

**ការជ្រើសរើសទីតាំង**

- ផលប៉ះពាល់អាចជះឥទ្ធិពលដល់សហគមន៍ និងបរិស្ថានជិតខាង រួមមាន ចម្ងាយពីទីប្រជុំជន/ លំនៅដ្ឋាន ប្រភពទឹក និងព្រលានយន្តហោះ
- លក្ខខណ្ឌភូមិសាស្ត្រ និងជលសាស្ត្រ
- សណ្ឋានដី និងស្ថានភាពរញ្ជួយដីនៅក្នុងតំបន់
- ហានិភ័យនៃការជន់លិច និងការរអិលបាក់ដី
- ចំងាយយានយន្តដឹកជញ្ជូន
- លទ្ធភាពទទួលបានដីគ្របដណ្តប់សម្រាប់ប្រតិបត្តិការប្រចាំថ្ងៃ និងពេលបិទបញ្ចប់ទីលានចាក់សំរាម

**ការរៀបចំសាងសង់**

- ការប្រើស្រទាប់ដីឥដ្ឋ ជាទ្រនាប់បាតទីលានចាក់សំរាម ជំនួសឱ្យការប្រើប្រាស់ទ្រនាប់កៅស៊ូខ្មៅក្រាស់ (HDPE) ដែលមានតម្លៃថ្លៃ
- សាងសង់ជំរាលនៃផ្ទៃបាតទីលាន ដោយកម្រិតជំរាលអប្បបរមា ២%
- ធានានូវសមត្ថភាពប្រព័ន្ធលូបង្ហូរទឹកគ្រប់គ្រាន់ ដើម្បីចៀសវាងការរអិលបាក់គំនរសំរាមដែលច្រើនលើសលប់ តាមរយៈការតម្លើងប្រព័ន្ធប្រមូលទឹកសំអុយទីលានចាក់សំរាម និងស្រទាប់ការពារ (សមាសភាពក្រួស ផ្ទាំងក្រាលបាតនៃស្រទាប់ដី (Geotextile) ស្រទាប់ដីការពារ)
- ធានានូវស្ថេរភាពមេកានិក ដោយរក្សាជំរាលសំរាមក្នុងកម្រិត ២៥% និងធានានូវកម្រិតទំទីលាន សម្រាប់កន្លែងចាក់សំរាមធំៗ ដែលមានកម្ពស់ខ្ពស់ជាង ៣០ម៉

**ប្រតិបត្តិការទីលាន**

- ការរក្សាកំណត់ត្រាប្រចាំថ្ងៃ អំពីបរិមាណសំណល់សម្រាប់ការធ្វើផែនការ និងហិរញ្ញវត្ថុបានល្អប្រសើរ (ការកំណត់តម្លៃចាក់សំរាមនៅទីលានចាក់សំរាមឱ្យបានសមស្រប សម្រាប់ប្រតិបត្តិការទីលានប្រកបដោយចីរភាព)
- ធានាឱ្យមាននូវផ្ទៃលំហាទំនេរគ្រប់គ្រាន់ សម្រាប់ធានាប្រតិបត្តិការចាក់សំរាម កុំឱ្យមានការកកស្ទះ ដើម្បីឱ្យប្រតិបត្តិការដឹកសំរាមចាក់ចោលនៅទីលានដំណើរការទៅដោយរលូន និងប្រកបដោយប្រសិទ្ធភាពនៃរថយន្តដឹកសំរាម
- ការកិនបង្ហាប់សំរាមនៅទីលាន ដើម្បីសន្សំសំចៃប្រសិទ្ធភាពផ្ទៃដី ស្ថេរភាពមេកានិចល្អប្រសើរជាងមុន និងកាត់បន្ថយក្លិនស្អុយ ហានិភ័យភ្លើងឆេះទីលាន និងវត្តមានទឹកសំអុយទីលាន
- សក្តានុពលនៃការប្រើប្រាស់សមាសធាតុស្រដៀងនឹងដីកំប៉ុស ឬសំណល់សំណង់ ធ្វើជាគម្របដីសម្រាប់ទីលានចាក់សំរាម ដែលនេះជា "ការអនុវត្តន៍ល្អបំផុត"។
- ប្រព្រឹត្តកម្មទឹកសំអុយទីលានជាពហុដំណាក់កាល រួមមានប្រព្រឹត្តកម្មដោយគ្មាន និងមានវត្តមានឧស្ម័នអុកស៊ីសែន ហើយបង្ហូរចូលអាង/ស្រះចំហរចុងក្រោយ/ ស្រះធម្មជាតិ ដីសើម។ នេះជាដំណោះស្រាយ ដែលមានតម្លៃទាបសមរម្យ។ ចំណែកការរៀបចំដំណាក់កាលប្រព្រឹត្តកម្មទឹកសំអុយ ទៅតាមដំណាក់កាលទាំងនេះ ត្រូវបង្ហូរវាទៅតាមលំហូរធម្មជាតិ ដើម្បីចៀសវាងការចំណាយលើការបូមទឹកសំអុយពីដំណាក់កាលមួយទៅមួយទៀត
- ការគ្រប់គ្រងឧស្ម័នទីលានចាក់សំរាមតាមរយៈការអនុវត្តន៍៖ ១) ប្រព័ន្ធចាប់យកឧស្ម័នមេតាន សម្រាប់បង្កើតថាមពល ២) ការដុតកម្ទេចចោលនូវឧស្ម័នដែលប្រមូលបាន ឬ ៣) រៀបចំស្រទាប់អុកស៊ីតកម្មមេតាន អាស្រ័យលើលទ្ធភាពធនធាន ដែលមាន។




គំនូសបំព្រួញកាត់ទទឹងនៃទីលានចាក់សំរាមបែបអនាម័យ ជាមួយនឹងប្រព័ន្ធប្រមូលទឹកសំអុយទីលាន (កែសម្រួលពីប្រភព Qian et al, 2002)

**សំយោគពីឯកសារ (គោលការណ៍ណែនាំ របស់ ISWA):**


- Munawar, E., & Fellner, J. (2013). Guidelines for design and operation of municipal solid waste landfills in tropical climates. ISWA– the International Solid Waste Association.
- Greedy, D, et.al. (2010). Landfill Operational Guidelines 2nd Edition.

## ឧបសម្ព័ន្ធទី៩. រចនាសម្ព័ន្ធទូទៅនៃយុទ្ធសាស្ត្រ និងផែនការសកម្មភាព

**ចក្ខុវិស័យ៖**
**រាជធានីភ្នំពេញ ជាទីក្រុងដែលមានការអភិវឌ្ឍប្រកបដោយនិរន្តរភាព មានពណ៌បៃតង និងមានបរិស្ថានល្អ ជាទីក្រុងមានការប្រើប្រាស់ធនធានប្រកបដោយចីរភាព។**

**បេសកកម្ម៖**
1. ការពារបរិស្ថាន និងលើកកម្ពស់សុខមាលភាពប្រជាពលរដ្ឋ
2. ការបង្កើតសង្គមមួយដែលសំណល់ត្រូវបានកាត់បន្ថយ ប្រើប្រាស់ឡើងវិញ និងកែច្នៃឡើងវិញ ដូច្នេះសំណល់ត្រូវបានទប់ស្កាត់ដល់កម្រិតអប្បបរមា
3. ការចូលរួមកែលម្អសង្គមឱ្យមានការបំភាយកាបូនតិច តាមរយៈការគ្រប់គ្រងសំណល់
4. លើកកម្ពស់ការចូលរួមកិច្ចសហការរវាងរាជរដ្ឋាភិបាល ប្រជាពលរដ្ឋ និងអាជីវកម្ម សម្រាប់ការគ្រប់គ្រងសំណល់ឱ្យមានប្រសិទ្ធភាព

**គោលដៅ៖** បង្កើតប្រព័ន្ធគ្រប់គ្រងសំណល់ប្រកបដោយលក្ខណៈបរិស្ថាន

**ទិសដៅសកម្មភាពចម្បង៖** សូមមើលជំពូកទី៣ ៦.២.

**សកម្មភាពចម្បងទី១**
ពង្រឹងប្រព័ន្ធសេវាប្រមូល និងការបញ្ចេញសំណល់
- 1.1 បង្កើនប្រសិទ្ធភាពប្រមូល និងសម្អាត
- 1.2 កែលំអរតេរិយាបទបញ្ចេញសំណល់ និងកន្លែងទុកដាក់
- 1.3 គាំទ្រខណ្ឌ ឬសង្កាត់

**សកម្មភាពចម្បងទី២**
ជម្រុញការកែច្នៃសំណល់តាមរយៈការញែកសំណល់នៅប្រភព
- 2.1 បង្កើនសមត្ថភាពកែច្នៃ
- 2.2 ផ្សព្វផ្សាយការញែកសំណល់
- 2.3 ផ្សព្វផ្សាយការប្រើផលិតផលកែច្នៃ

**សកម្មភាពចម្បងទី៣**
ជម្រុញការគ្រប់គ្រងទីលានប្រកបដោយលក្ខណៈបរិស្ថាន
- 3.1 កែលម្អការគ្រប់គ្រងទីលានដង្កោ
- 3.2 ធានាធនធានហិរញ្ញវត្ថុ
- 3.3 សហការជាមួយផ្នែកកែច្នៃក្រៅផ្លូវការ

**សកម្មភាពចម្បងទី៤**
ការគ្រប់គ្រងសំណល់ពិសេស

**សំណល់សំណង់**
- 4.1 បង្កើតប្រព័ន្ធគ្រប់គ្រងទិន្នន័យ
- 4.2 ផ្សព្វផ្សាយការកាត់បន្ថយសំណល់
- 4.3 ផ្សព្វផ្សាយការប្រើប្រាស់ និងការកែច្នៃ
- 4.4 អនុវត្ត ត្រួតពិនិត្យ ពង្រឹងច្បាប់

**សំណល់វេជ្ជសាស្ត្រ**
- 4.5 ពង្រឹងការគ្រប់គ្រងសំណល់វេជ្ជសាស្ត្រ

**សំណល់ឧស្សាហកម្ម**
- 4.6 ពង្រឹងការគ្រប់គ្រង

**សំណល់អេឡិចត្រូនិក**
- 4.7 បង្កើតប្រព័ន្ធគ្រប់គ្រង

**សកម្មភាពចម្បងទី៥**
ការចែករំលែកចក្ខុវិស័យ និងការចូលរួមរបស់ភាគីពាក់ព័ន្ធ
- 5.1 បង្កើនការចូលរួមរបស់ប្រជាពលរដ្ឋ
- 5.2 បង្កើនការចូលរួមរបស់យុវជន
- 5.2 បង្កើនការចូលរួមរបស់សាធារណៈ

**រដ្ឋបាលរាជធានីភ្នំពេញ**

អាសយដ្ឋានៈ # ៦៩ មហាវិថីព្រះមុនីវង្ស សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ

គេហទំព័រ: www.phnompenh.gov.kh/

**United Nations Environment Programme**

**International Environmental Technology Centre**

អាសយដ្ឋានៈ 2-110 Ryokuchi koen, Tsurumi-ku, Osaka 538-0036, Japan

គេហទំព័រ: www.unep.org

**Cambodia Climate Change Alliance**

អាសយដ្ឋាន: Ministry of Environment, No. 503 Road along Bassac River,

Sangkat Tonle Bassac, Chamkamon, Phnom Penh

គេហទំព័រ: www.camclimate.org.kh/en/activities/cambodian-climate-change-alliance.html

**IGES Centre Collaborating with UNEP on Environmental Technologies,**

**Institute for Global Environmental Strategies**

អាសយដ្ឋានៈ: 2108-11 Kamiyamaguchi, Hayama, Kanagawa, 240-0115 Japan

គេហទំព័រ: www.ccet.jp

**Nexus Carbon for Development**

អាសយដ្ឋានៈ: #33 E3 Sothearos Blvd Sangkat Chey Chumneas, Daun Penh 12206, Phnom Penh

គេហទំព័រ: www.nexusfordevelopment.org/

